# ព្រះអភិធម្មត្ថសង្គហ

## បរិច្ឆេទទី ១

## ចិត្តសង្គហវិភាគ

ប្រែ និងរៀបរៀងដោយ

ភិក្ខុ ញ្ញាតិធម្មោ ពុយ សុចត្ថិឌី

សម្រាប់ជាធម្មទាន

ពុទ្ធសករាជ ២៥៦៥



# ព្រះអភិធម្មត្ថសង្គហៈ

## បរិច្ឆេទទី ១

## ចិត្តសង្គហវិភាគ

ប្រែ និងរៀបរៀងដោយ

**ភិក្ខុ ញាតិធម្មោ ពុយ សុវត្ថិឌី**

ធ្វើនៅវត្តសីតវ័ន (មហាវិហារ) ខេត្តបាត់ដំបង

( សម្រាប់ជាធម្មទាន )

ពុទ្ធសករាជ ២៥៦៥

# នាមអ្នកជួយពិនិត្យអក្ខរាវិរុទ្ធនិងវាយអត្ថបទ

១- លោកម្ចាស់គ្រូ **ចូឡវរធម្មោ ហ៊ី ជីតៅ** ជួយសម្រួលសេចក្ដី

២- លោកម្ចាស់គ្រូ **កល្យាណធម្មោ យឿន កល្យាណ** ជួយសម្រួលសេចក្ដី

៣- លោកម្ចាស់ **ញាណសារោ យ៉ាវ សំអឿន** ជួយសម្រួលសេចក្ដី

៤- លោកម្ចាស់ **សន្តចិត្តោ វេន រដ្ឋា** ជួយពិនិត្យអក្ខរាវិរុទ្ធ

៥- លោកម្ចាស់ **ញាណានន្ទោ ងួន ភារុណ** ជួយពិនិត្យអក្ខរាវិរុទ្ធ

៦- លោកម្ចាស់ **មេត្តាធនោ មឿន សឺន** ជួយពិនិត្យអក្ខរាវិរុទ្ធ

៧- លោកម្ចាស់គ្រូ **យសបាលោ ជ័យ សុហុន** ជួយពិនិត្យអក្ខរាវិរុទ្ធ

៨- សាមណេរ **ឆាយ សីលា** ជួយពិនិត្យអក្ខរាវិរុទ្ធ

៩- សាមណេរ **អឿន អេង** ជួយពិនិត្យអក្ខរាវិរុទ្ធ

១០- ភិក្ខុ **កោវិទោ ឡោះ សូវៀត** ជួយវាយអត្ថបទ

១១- ភិក្ខុ **ញាតិធម្មោ ពុយ សុវត្ថិឌី** (វី ភឿត ) បកប្រែអត្ថបទ

# អារម្ភកថា

បរិយត្តិសាសនា រមែងជាចំណែកដែលសំខាន់ក្រៃលែង ប្រការមួយដែលនឹងគាំទ្រព្រះពុទ្ធសាសនាឲ្យស្ថិតស្ថេរ និងចម្រើនរុងរឿងក្រៃលែងឡើងទៅ ក្នុងអនាគតកាល រាប់តាំងពីព្រះសម្មាសម្ពុទ្ធ ទ្រង់រំលត់ខន្ធបរិនិព្វានមក បើព្រះថេរានុថេរៈទាំងឡាយមិនចាប់ចិត្ត ក្នុងការសិក្សាព្រះពុទ្ធវចនៈ និងអដ្ឋកថាជាប់តគ្នាមកហើយ ព្រះពុទ្ធ-សាសនាក៏មិនអាចជាប់តរហូតដល់សព្វថ្ងៃនេះទេ បើដូច្នោះ មនុស្សទាំងឡាយដែលកើតមក ក្នុងសម័យក្រោយតាំងពីព្រះសម្មាសម្ពុទ្ធបរិនិព្វានមក ក៏មិនអាចដឹងព្រះពុទ្ធសាសនា មិនមានឱកាសបានសិក្សាធម៌ក្នុងព្រះពុទ្ធសាសនា កាលមិនបានសិក្សាធម៌ក្នុងព្រះពុទ្ធ-សាសនាហើយ ក៏រមែងបែរទៅនិយមរាប់អានលទ្ធិដទៃៗ ដែលមិនមែនព្រះពុទ្ធសាសនា ធ្វើឲ្យវដ្តៈរបស់បុគ្គលទាំងឡាយនោះមិនមានទីបំផុត គួរឲ្យស្តាយយ៉ាងក្រៃលែង ដូច្នោះការសិក្សាព្រះបរិយត្តិទើបជាការសំខាន់ក្រៃលែង ។

**យេ ធម្មា ហេតុប្បភវា**
**តេសំ ហេតុំ តថាគតោ (អាហ)**
**តេសញ្ច យោ និរោធោ (ច)**
**ឯវំវាទី មហាសមណោតិ ។**

ធម៌ទាំងឡាយណា គឺ ខន្ធ ៥ តែងកើតអំពីហេតុ ព្រះតថាគតពោលនូវហេតុនៃធម៌ទាំងឡាយនោះ ម្យ៉ាងទៀតសេចក្តីរលត់និងឧបាយជាគ្រឿងរលត់នូវធម៌ទាំងឡាយណា ព្រះតថាគតពោលនូវសេចក្តី

រលត់និងឧបាយជាគ្រឿងរលត់នៃធម៌ទាំងឡាយនោះ ព្រះមហាសមណៈ មានប្រក្រតីពោលយ៉ាងនេះ ។

ក្នុងសៀវភៅព្រះអភិធម្មត្ថសង្គហបរិច្ឆេទទី ១ ដល់បរិច្ឆេទទី ៩ ខ្ញុំមានសេចក្ដីជ្រះថ្លាបានរៀបចំជាសៀវភៅនេះឡើង ក៏អាស្រ័យការបានសិក្សាព្រះអភិធម្មក្នុងច្បាប់ដើម (មូលនិធិនៃបមហានីរានន្ទ) ឃើញថាមានការអធិប្បាយពិស្ដារជំនួយដល់ការយល់បានល្អ ខ្ញុំក៏ព្យាយាមប្រែជាខេមរភាសា ដើម្បីជាធម្មទាន និងដើម្បីជាប្រយោជន៍ដល់ការសិក្សារបស់ពុទ្ធបរិស័ទ ។

ក្នុងសៀវភៅនេះ ខ្ញុំពុំបានលើកយកគំនិតផ្ទាល់ខ្លួននោះទេ គឺស្រង់យកសេចក្ដីក្នុងច្បាប់ដើមទាំងស្រុង និងតាមព្រះត្រៃបិដក អដ្ឋកថាខ្លះ ប៉ុន្តែសេចក្ដីដែលបានលើកមកនេះខ្ញុំជឿជាក់ថា ការរៀបរៀងសៀវភៅនេះ ពិតជាមានកំហុសខុសឆ្គងខ្លះជាពុំខាន ពីព្រោះជាស្នាដៃលើកដំបូងបង្អស់របស់ខ្ញុំ ខ្ញុំសូមទទួលរាល់កំហុសខុសឆ្គងទាំងអម្បាលម៉ាន អំពីសម្នាក់លោកអ្នកសប្បុរសទាំងឡាយដែលមានបំណងក្នុងការកែលំអ និងស្ថាបនាក្នុងពេលជាខាងក្រោយៗ ទៀត ។

ជាទីបញ្ចប់ ដោយផលនៃការខំប្រឹងប្រែងរបស់ខ្ញុំ សូមលើកឡើងនូវមហាកុសលថ្នាក់ធម្មទាននេះ និងបុណ្យកុសលគ្រប់បែបយ៉ាងដែលបានសន្សំហើយក្នុងព្រះពុទ្ធសាសនានេះ ជាពិសេសបុណ្យកុសលដែលសម្រេចនៅលើទឹកដីពុទ្ធភូមិ មានប្រទេសឥណ្ឌា នេប៉ាល ស្រីលង្កា និងប្រទេសភូមា ដែលបានទៅហើយថ្មីៗ នេះ

សូមលើកប្រគេនចំពោះ

-ព្រះអង្គគ្រូឧបជ្ឈាយ៍ **បញ្ញាវុឌ្ឍិ គ្រួច ឆាង** វត្តព្រះនារាយណ៍ ជាព្រះគ្រូអនុគណស្រុក សង្កែ និងឧទ្ទិសប្រគេនចំពោះ

-ព្រះអង្គគ្រូឧបជ្ឈាយ៍ ព្រះនាម **ឃូ អ៊ី** វត្តតាហែន

-ព្រះអង្គគ្រូឧបជ្ឈាយ៍ **វជិរប្បញ្ញោ ហម ឈឿន** វត្តភ្នំតាមាយ អតីតជាព្រះគ្រូអនុគណស្រុករតនមណ្ឌល

-ឧទ្ទិសជូនលោកគ្រូវិនយាចារ្យ **គាំ អ៊ីវ** ជាគ្រូព្រះវិន័យ ជូនចំពោះលោកអ្នកដ៏មានគុណទាំងអស់ក្នុងសង្សារវដ្ត និងសព្វសត្វទាំងអស់ក្នុងត្រៃភព សូមបានចំណែកបុណ្យស្មើៗ គ្នា ។

មួយចំណែកសូមជូនចំពោះញោមប្រុស **ពុយ វី** ញោមស្រី **រស់ ស៊ីហៀង** ដែលមានជីវិតរស់នៅសព្វថ្ងៃនេះ និងសូមជូនចំពោះលោកគ្រូ អគ្គបណ្ឌិតធម្មាចារ្យ **ប៊ុត សាវង្ស** លោកគ្រូ ធម្មបណ្ឌិត **រស់ សុជាត** ព្រមទាំងពុទ្ធបរិស័ទទាំងអស់ សូមបានចំណែកបុណ្យធម្មទាននេះគ្រប់ព្រះអង្គគ្រប់គ្នាកុំបីអាក់ខានឡើយ ។

សូមអនុមោទនា..................!!!

បាត់ដំបង វត្តសីតវ័ន ថ្ងៃ ១៥ កើត ខែបឋមាសាឍ ព.ស. ២៥៦៥

គ.ស. 2021

**ភិក្ខុ ញាណធម្មោ ពុយ សុវត្ថិឌី**

(វត្តសីតវ័ន (មហាវិហារ) ស្ថិតនៅភូមិក្រឡាញ់ ឃុំកំពុងព្រះ ស្រុកសង្កែ)

# មាតិកា

**លរ.** **ទំព័រ**

ពាក្យផ្ដើម ....................................................................................១
ការចូលដល់ព្រះពុទ្ធសាសនាមាន ៣ ប្រការ ....................................................៦
ព្រះសម្មាសម្ពុទ្ធទ្រង់ប្រៀនប្រដៅអំពីអ្វី?........................................................៧
ព្រះវិន័យបិដកសម្ដែងអំពីអ្វី? ....................................................................៧
ព្រះសុត្តន្តបិដកសម្ដែងអំពីអ្វី?...................................................................៨
ព្រះអភិធម្មបិដកសម្ដែងអំពីអ្វី?..................................................................៨
ព្រះអភិធម្មត្ថសង្គហៈគឺអ្វី?.......................................................................៩
ព្រះអភិធម្ម សម្ដែងអំពីអ្វី?....................................................................១១
បរមត្ថធម៌មានលក្ខណៈដូចម្ដេច? ............................................................១២
បរមត្ថធម៌ដោយសង្ខេបនោះមាន ៤ ប្រការ ................................................ ១៣
ប្លង់បរមត្ថធម៌ ៤ ប្រការ ........................................................................១៥
អភិធម្មត្ថសង្គហបាលី បរិច្ឆេទទី ១ ...........................................................១៦
បរិច្ឆេទទី ១ ចិត្តសង្គហវិភាគ...................................................................២០
(គាថាផ្ដើមបករណ៍) ..............................................................................២០
ចិត្តបរមត្ថ ...........................................................................................២៣
ចិត្ត គឺ អ្វី? .........................................................................................២៣
ការដឹងអារម្មណ៍មាន ៣ យ៉ាង ..................................................................២៤
សាមញ្ញលក្ខណៈរបស់ចិត្ត.......................................................................២៥
អំណាចរបស់ចិត្ត ...................................................................................២៩
ចំនួនចិត្ត............................................................................................ ៣៣
ចែកប្រភេទចិត្តដោយន័យផ្សេងៗ ............................................................. ៣៤

អធិប្បាយចិត្ត..................................................................... ៣៥
កាមាវចរចិត្ត ៥៤ ដួង ............................................................ ៣៦
អកុសលចិត្ត ១២ ................................................................. ៣៨
គាថាសង្គហទី ៣ .................................................................. ៣៨
អធិប្បាយអកុសលចិត្ត ........................................................... ៣៩
លោភមូលចិត្ត ៨ ................................................................. ៤១
ការតាក់តែងឬដឹកនាំមាន ៣ យ៉ាង ............................................ ៤៥
ហេតុនាំឲ្យកើតលោភមូលចិត្ត ៨ ដួង មាន ៤ ប្រការ ......................... ៤៦
ហេតុនាំឲ្យកើតលោភសោមនស្ស មាន ៤ ប្រការ .............................. ៤៧
សេចក្ដីវិនាស ៥ ប្រការ ........................................................... ៤៧
ហេតុនាំឲ្យកើតលោភឧបេក្ខា មាន ៥ ប្រការ ................................... ៤៧
ហេតុនាំឲ្យកើតទិដ្ឋិគតសម្បយុត្ត មាន ៥ ប្រការ .............................. ៤៨
ហេតុនាំឲ្យកើតទិដ្ឋិគតវិប្បយុត្ត មាន ៥ ប្រការ ............................... ៤៨
ហេតុនាំឲ្យកើតអកុសលអសង្ខារិក មាន ៦ ប្រការ ............................ ៤៩
ហេតុនាំឲ្យកើតអកុសលសសង្ខារិក មាន ៦ ប្រការ ............................ ៤៩
ផលដែលកើតអំពីលោភមូលចិត្ត .................................................. ៥០
ទោសមូលចិត្ត ២ ដួង ............................................................ ៥១
អាឃាតវត្ថុ ១០ ប្រការ ........................................................... ៥៤
ផលដែលកើតពីទោសមូលចិត្ត ................................................... ៥៦
មោហមូលចិត្ត ២ ដួង ............................................................ ៥៧
ហេតុនាំឲ្យកើតមោហៈ មាន ២ ប្រការ ......................................... ៦៤
ផលដែលកើតពីមោហមូលចិត្ត ................................................... ៦៥
សម្ដែងសម្បយុត្តក្នុងអកុសលចិត្ត .............................................. ៦៥
ហេតុនាំឲ្យកើតអកុសលចិត្ត....................................................... ៧០
អកុសលចិត្តជាធម៌ដែលគួរលះ ................................................... ៧១

ហេតុដែលប្រហារវិចិកិច្ឆា ៦ ប្រការ ..... ៧៤
ហេតុដែលត្រូវលះឧទ្ធច្ចៈ ៦ ប្រការ ..... ៧៥
អហេតុកចិត្ត ១៨ ..... ៧៦
គាថាសង្គហទី ៤ ..... ៧៧
អកុសលវិបាកចិត្ត ៧ ..... ៨០
អហេតុកកុសលវិបាកចិត្ត ៨ ដួង ..... ៨៥
អហេតុកកិរិយាចិត្ត ..... ៨៩
ការញញឹមនិងការសើច ..... ៩១
សង្ខារភេទនៃអហេតុកចិត្ត ..... ៩៣
ឧប្បត្តិហេតុនៃអហេតុកចិត្ត ១៨ ដួង ..... ៩៥
កិច្ចរបស់អហេតុកចិត្ត ១៨ ដួង ..... ៩៩
ទ្វាររបស់អហេតុកចិត្ត ១៨ ដួង ..... ១០០
វត្ថុរបស់អហេតុកចិត្ត ១៨ ដួង ..... ១០១
អារម្មណ៍របស់អហេតុកចិត្ត ១៨ ..... ១០២
សម្ដែងការកើតរបស់អហេតុកចិត្ត ១៨ ដោយវីថិ ..... ១០៣
អហេតុកចិត្ត ១៨ ជាវិញ្ញាណធាតុ ៧ ..... ១០៥
អកុសលចិត្ត និង អហេតុកចិត្ត ..... ១០៦
អសោភណចិត្ត និង សោភណចិត្ត ..... ១០៨
គាថាសង្គហទី ៥ ..... ១១១
កាមាវចរសោភណចិត្ត ២៤ ..... ១១២
គាថាសង្គហទី ៦ ..... ១១២
អត្ថរបស់កុសល ..... ១១៤
អត្ថរបស់បុណ្យ ..... ១១៤
មហាកុសលចិត្ត ៨ ..... ១១៥
ការកើតឡើងរបស់បញ្ញា ៣ ប្រការ ..... ១២០

ទសវត្ថុកសម្មាទិដ្ឋិ ១០ ប្រការ ........................................ ១២២
សម្តែងការចែកកាមាវចរកុសលដោយហេតុ ........................................ ១២៤
សម្តែងការចែកកាមាវចរកុសលដោយចេតនា ........................................ ១២៥
ចែកតិហេតុកកុសល និង ទ្វិហេតុកកុសលដោយឧក្កដ្ឋ និង ឱមក ........................................ ១២៧
កាមាវចរកុសលកម្ម ១០ ........................................ ១៣១
អង្គធម៌របស់កុសលកម្មបថ ១០ ........................................ ១៣២
កាមាវចរកុសលកម្មជាបុញ្ញកិរិយាវត្ថុមាន ១០ ប្រការ ........................................ ១៣៣
ហេតុឲ្យកើតមហាកុសល ........................................ ១៣៥
ផលរបស់មហាកុសលចិត្ត ........................................ ១៣៦
ហេតុនាំឲ្យកើតសោមនស្សកុសលចិត្ត ៦ ប្រការ ........................................ ១៣៨
ហេតុនាំឲ្យកើតឧបេក្ខាកុសលចិត្ត ៦ ប្រការ ........................................ ១៣៨
ហេតុនាំឲ្យកើតញាណសម្បយុត្តធម៌មាន ៤ ប្រការ (ន័យទី ១) ........................................ ១៤០
ហេតុនាំឲ្យកើតញាណវិប្បយុត្តធម៌ ៤ ប្រការ (ន័យទី ១) ........................................ ១៤១
ហេតុនាំឲ្យកើតកុសលអសង្ខារិក ៦ ប្រការ ........................................ ១៤២
ហេតុនាំឲ្យកើតកុសលសសង្ខារិក ៦ ប្រការ ........................................ ១៤៣
អត្ថនៃវិបាក ........................................ ១៤៣
មហាវិបាកចិត្ត ៨ ដួង ........................................ ១៤៥
មហាវិបាកផ្សេងពីមហាកុសល ........................................ ១៤៩
ឋានៈដែលឲ្យផលរបស់មហាវិបាក ........................................ ១៥០
មហាកិរិយាចិត្ត ៨ ដួង ........................................ ១៥៦
គាថាសង្គហទី ៧ ........................................ ១៦១
រូបាវចរចិត្ត ១៥ ........................................ ១៦៣
គាថាសង្គហទី ៨ ........................................ ១៦៣
អធិប្បាយរូបាវចរចិត្ត ........................................ ១៦៤
អត្ថរបស់ឈាន ........................................ ១៦៤

# ឈ

ឈានមាន ២ យ៉ាង ..................................................................................... ១៦៥
អង្គនៃឈាន ................................................................................................ ១៦៨
ឈានលះបង់នីវរណៈ..................................................................................... ១៦៩
អធិប្បាយអង្គឈាន ...................................................................................... ១៧០
បីតិ នេះមាន ៥ យ៉ាង ................................................................................... ១៧១
សមាធិមាន ៣ យ៉ាង...................................................................................... ១៧៣
ប្រភេទនៃឈាន............................................................................................. ១៧៤
អានិសង្សរបស់សោមនស្សវេទនា និង ឧបេក្ខាវេទនា.......................................... ១៧៨
សេចក្ដីផ្សេងគ្នាដោយប្រភេទនៃឈាន ............................................................. ១៧៨
ឈានចតុក្កន័យ និង បញ្ចកន័យ ...................................................................... ១៧៩
រូបាវចរកុសលចិត្ត.......................................................................................... ១៨១
រូបាវចរវិបាកចិត្ត មាន ៥ ដួង ......................................................................... ១៨២
រូបាវចរកិរិយាចិត្ត មាន ៥ ដួង......................................................................... ១៨៤
ភូមិដែលជាទីកើតរបស់រូបាវចរចិត្ត ១៥ ........................................................... ១៨៥
អរូបាវចរចិត្ត មាន ១២ ដួង............................................................................ ១៨៧
គាថាសង្គហទី ៩ ........................................................................................... ១៨៧
អធិប្បាយអរូបាវចរចិត្ត.................................................................................... ១៨៨
អារម្មណ៍របស់អរូបាវចរចិត្ត............................................................................. ១៨៩
ចែកអរូបាវចរចិត្តដោយប្រភេទនៃជាតិ ............................................................. ១៩១
អត្ថរបស់អរូបជ្ឈាន ៤ .................................................................................... ១៩៤
ភូមិដែលជាទីកើតរបស់អរូបាវចរកុសលចិត្ត...................................................... ១៩៧
លោកុត្តរចិត្ត ៨ ............................................................................................. ១៩៩
គាថាសង្គហទី ១០........................................................................................... ២០០
ចែកលោកុត្តរចិត្ត ៨ ដោយប្រភេទនៃជាតិ ........................................................ ២០១
លក្ខណៈនៃការប្រហារកិលេស.......................................................................... ២០៥

ការប្រហារកិលេសប្រភេទសមុច្ឆេទប្បហាន ............................................................ ២០៦
មគ្គចិត្តប្រហារអកុសល ................................................................................. ២១១
អត្ថនៃលោកុត្តរចិត្ត ៨ .................................................................................. ២១៤
ប្រភេទរបស់ព្រះសោតាបន្ន .............................................................................. ២១៧
ហេតុដែលធ្វើឲ្យព្រះសោតាបន្នសម្រេចអរហត្តផលផ្សេងគ្នា ...................................... ២១៨
ប្រភេទរបស់ព្រះសកទាគាមី ............................................................................. ២២៣
ប្រភេទរបស់ព្រះអនាគាមី ................................................................................ ២២៥
ប្រភេទរបស់ព្រះអរហន្ត ................................................................................. ២៣០
ព្រះអរហន្តចែកជា ២ ប្រភេទ ន័យម្យ៉ាងទៀត ........................................................ ២៣២
បដិសម្ភិទាញាណ មាន ៤ ប្រការ ....................................................................... ២៣៣
ព្រះអរហន្តដែលចែកចេញជា ៣ ប្រភេទ ............................................................... ២៣៤
ព្រះអរហន្តសាវ័កមាន ៣ ប្រភេទ ........................................................................ ២៣៥
លោកុត្តរចិត្តពិស្ដារ ៤០ ដួង ........................................................................... ២៣៦
ចិត្តភេទ ....................................................................................................... ២៣៨
គាថាសង្គហទី ១១ .......................................................................................... ២៤០
ចែកចិត្ត ៨៩ ដោយភូមិភេទន័យ ....................................................................... ២៤១
គាថាសង្គហទី ១២ .......................................................................................... ២៤២
ចែកប្រភេទការរាប់ចំនួនចិត្ត ............................................................................. ២៤៣
គាថាសង្គហទី ១៣ .......................................................................................... ២៤៣
ចែកចិត្ត ៨៩ ដោយសោភណភេទន័យ ................................................................. ២៤៤
ចែកចិត្ត ៨៩ ដោយលោកភេទន័យ .................................................................... ២៤៤
ចែកចិត្ត ៨៩ ដោយហេតុភេទន័យ ..................................................................... ២៤៥
ចែកចិត្ត ៨៩ ដោយឈានភេទន័យ ..................................................................... ២៤៧
ចែកលោកុត្តរចិត្តដោយអង្គឈាន ....................................................................... ២៤៨
អាវសានគាថា ............................................................................................... ២៤៨

សង្គ្រោះលោកុត្តរចិត្តជាមួយឈាន ........................................................................២៤៩
គាថាសង្គហទី ១៥..........................................................................................................២៤៩
ចែកចិត្ត ៨៩ ដោយវេទនាភេទន័យ ..................................................................................២៥០
ចែកចិត្ត ៨៩ ដោយសម្បយោគភេទន័យ...........................................................................២៥២
ឈានចិត្ត ៦៧ .................................................................................................................២៥៥
គាថាសង្គហទី ១៦..........................................................................................................២៥៥
ចែកកុសលចិត្ត និង វិបាកចិត្តដោយពិស្តារ ......................................................................២៥៦
គាថាសង្គហទី ១៧ .........................................................................................................២៥៦
ចែកចិត្ត ១២១ ដោយជាតិភេទន័យ................................................................................ ២៥៧
ចែកចិត្ត ១២១ ដោយភូមិភេទន័យ ................................................................................ ២៥៧
ចែកចិត្ត ១២១ ដោយសោភណភេទន័យ..........................................................................២៥៨
ចែកចិត្ត ១២១ ដោយលោកភេទន័យ ..............................................................................២៥៨
ចែកចិត្ត ១២១ ដោយហេតុភេទន័យ ...............................................................................២៥៨
ចែកចិត្ត ១២១ ដោយឈានភេទន័យ ..............................................................................២៥៨
ចែកចិត្ត ១២១ ដោយវេទនាភេទន័យ ..............................................................................២៥៨
ចែកចិត្ត ១២១ ដោយសម្បយោគភេទន័យ........................................................................២៥៩
ចែកចិត្ត ១២១ ដោយសង្ខារភេទន័យ ..............................................................................២៥៩
ចំណុចសម្គាល់ពិសេស ....................................................................................................២៥៩
អវសានគាថា..................................................................................................................២៦០

# ពាក្យផ្ដើម

កាលសម្ដេចព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ទ្រង់បានប្រៀនប្រដៅមនុស្ស ទេវតា និងព្រហ្ម អស់វេលា ៦ ព្រះវស្សាហើយ ក៏ទ្រង់សម្ដែងយមកប្បាដិហារិយ៍ក្រោមដើមស្វាយឈ្មោះថា គណ្ឌាម្ពព្រឹក្ស ជិតនគរសាវត្ថី ដើម្បីនឹងទូន្មាន ពួកតិរ្ថិយទាំងឡាយ កាលទ្រង់សម្ដែងយមកប្បាដិហារិយ៍ហើយ ទ្រង់ពិចារណាថា ព្រះពុទ្ធទាំងឡាយក្នុងអតីតកាល បន្ទាប់ពីសម្ដែងយមកប្បាដិហារិយ៍ហើយទ្រង់យាងទៅទីណា ក៏ឃើញថាទ្រង់យាងទៅតាវត្តិង្សពិភព ទើបឈានជាន់ប្រឹថពីដោយព្រះបាទម្ខាង ដាក់ព្រះបាទទីពីរលើកំពូលភ្នំយុគន្ធរ ហើយលើកព្រះបាទដំបូងឈានទៅជាន់កំពូលភ្នំសិនេរុ ទ្រង់ប្រថាប់គង់លើផែនថ្មបណ្ឌុកម្ពល ហើយទ្រង់សម្ដែងអភិធម្មកថាតាំងពីដើមវស្សាដល់ទេវតាក្នុងម៉ឺនចក្រវាល ដែលមកប្រជុំគ្នា ។

ហើយក្នុងវេលាភិក្ខាចារទ្រង់និម្មិតព្រះពុទ្ធនិម្មិតឡើង ដើម្បីសម្ដែងធម៌ជំនួស ទ្រង់ជម្រះព្រះទន្ត និងជម្រះព្រះឱស្ឋនៅត្រង់អនោតត្តស្រះ យាងទៅបិណ្ឌបាតក្នុងឧត្តរកុរុទ្វីប ហើយត្រឡប់មកសោយនៅក្បែរមាត់អនោតត្តស្រះ ព្រះសារីបុត្តត្ថេរ និមន្តទៅគាល់រាល់ថ្ងៃ ព្រះអង្គទ្រង់ប្រោសប្រទានអភិធម្មកថា ដោយសង្ខេបន័យ ។

តែទ្រង់សម្ដែងដល់ទេវតានិងព្រហ្មដោយវិត្ថារន័យ អស់រយៈពេលបីខែ ធម្មាភិសម័យ បានមានដល់ទេវតា ៨០ កោដិ ដោយប្រការដូច្នេះ ។

# អភិធម្មកថាមានការសម្តែង ៣ ន័យ គឺ

១. ព្រះពុទ្ធអង្គសម្តែងដល់ទេវតានិងព្រហ្មក្នុងតាវត្តិង្សដោយវិត្ថារន័យ គឺ ន័យពិស្តារ ។

២. ព្រះពុទ្ធអង្គសម្តែងដល់ព្រះសារីបុត្តនៅមាត់អនោតត្តស្រះដោយសង្ខេបន័យ គឺន័យសង្ខេប ។

៣. ព្រះសារីបុត្តសម្តែងដល់សិស្ស ៥០០ ដែលធ្លាប់កើតជាសត្វប្រចៀវដោយនាតិវិត្ថារនាតិសង្ខេបន័យ (ដោយពាក់កណ្តាលសង្ខេបពាក់កណ្តាលពិស្តារ) ។

ព្រះអានន្ទទ្រទ្រង់ចាំយកមកសម្តែង ប្រាកដនៅក្នុងព្រះអភិធម្ម ៧ គម្ពីរ ជានាតិវិត្ថារនាតិសង្ខេបន័យ ដែលរួបរួមទុកក្នុងព្រះអភិធម្មបិដកនោះឯង ។

តមកពុទ្ធសករាជប្រមាណ ៩០០ ឆ្នាំ មានព្រះថេរៈអ្នកឆ្លាតឈ្លាសក្នុងព្រះត្រៃបិដកមួយរូបមាននាមថា ព្រះអនុរុទ្ធត្ថេរ ជាអ្នកស្រុកកាវិលកញ្ចិនគរមទ្ទរាជ ទិសខាងត្បូងនៃប្រទេសឥណ្ឌា លោកបានមកសិក្សាព្រះអភិធម្មនៅនគរអនុរាធបុរី ស្នាក់នៅវត្តតុម្ពូលសោមារាមប្រទេសស្រីលង្កា មានភាពឆ្លាតឈ្លាសណាស់ នាមរបស់លោកប្រាកដដោយទូទៅ លោកបានអាស្រ័យព្រះបាលី អដ្ឋកថា ដីកា និង អនុដីកា ដែលជាគោលសំខាន់ ហើយរួបរួមចងក្រងសង្ខេបសេចក្តីពីព្រះអភិធម្មបិដកដែលជាគម្ពីរសំខាន់បំផុតរបស់ព្រះពុទ្ធសាសនា មានអត្ថ ដែលពោលអំពីសភាវធម៌ដែលល្អិតជ្រាលជ្រៅ ពិស្តារយ៉ាងក្រៃលែង ទាំងលំបាក

ដល់ការសិក្សា និងលំបាកដល់ការអធិប្បាយឲ្យយល់សេចក្តី លោកបានព្យាយាមសង្ខេបគម្ពីរ ដ៏សែនជ្រាលជ្រៅនេះ ដោយញែកលំដាប់រឿងអត្ថចេញមក ឲ្យងាយស្រួលដល់ការសិក្សានិងចងចាំ ឈ្មោះថា អភិធម្មត្ថសង្គហៈ ដើម្បីប្រយោជន៍យូរអង្វែងដល់អ្នកសិក្សាកើតបញ្ញាជ្រះថ្លា ក្នុងព្រះពុទ្ធសាសនាដោយចិត្តពេញទៅដោយសេចក្តីករុណា ។

ជាការលំបាកក្រៃលែង ដល់អ្នកសិក្សាដោយត្រង់ក្នុងគម្ពីរព្រះអភិធម្មទាំង ៧ គម្ពីរ ឲ្យយល់ចូលចិត្តដោយមិនបាច់អាស្រ័យព្រះអភិធម្មត្ថសង្គហៈ ដែលរចនាឡើងដោយព្រះអនុរុទ្ធាចារ្យ ឲ្យជាមូលដ្ឋានជាមុនសិនទេនោះ ។ ផ្តើមតាំងពីបរិច្ឆេទទី ១ ដល់ បរិច្ឆេទទី ៩ ដោយហេតុនេះ លោកទើបបានទទួលនូវការរាប់អានក្នុងឋានៈជាព្រះគន្ថរចនាចារ្យ អ្នកតែងគម្ពីរព្រះអភិធម្មត្ថសង្គហៈ ដែលលោកអ្នកសិក្សាមានសេចក្តីយល់ហេតុផលបាន វៀរការក្រាបថ្វាយបង្គំដល់គុណរបស់លោកមិនបាន ។

លោកបានរចនាព្រះអភិធម្មត្ថសង្គហៈ ពីគម្ពីរព្រះអភិធម្មបិដកទាំង ៧ គម្ពីរ ចេញមកជាគម្ពីរមួយនេះទៀត ដើម្បីឲ្យអ្នកសិក្សាងាយយល់មិនច្របូកច្របល់ដោយរៀងលំដាប់ពីងាយៗ ទៅនេះឯង ជាហេតុឲ្យអ្នកខ្លះដែលមិនធ្លាប់បានសិក្សា ព្រះអភិធម្មមកពីមុន ទាំងការអានអភិធម្មត្ថសង្គហៈដោយខ្លួនឯង ក៏នៅតែមិនអាចយល់បាន ទើបបានពោលថា អភិធម្មត្ថសង្គហៈនោះមិនមែនជាពុទ្ធវចនៈ ព្រោះជាការតែងឡើងដោយព្រះអនុរុទ្ធាចារ្យ ក្នុងកាលខាងក្រោយប៉ុន្មានឆ្នាំមកនេះឯង ។

មែនពិត អ្នកបរិយាយអភិធម្មដោយច្រើននិងអ្នកសិក្សាអភិធម្ម ដែលមានការយល់ចូលចិត្តសមគួរល្អ រមែងប្រចក្សដល់ចិត្តខ្លួនឯង ថាព្រះអភិធម្មទាំង ៧ គម្ពីរ និងព្រះអភិធម្មត្ថសង្គហៈ ដែលព្រះអនុរុទ្ធាចារ្យរចនាឡើងនោះ មិនមានសេចក្តីផ្សេងគ្នាបន្តិចបន្តួចឡើយ មិនថា ជាអង្គធម៌ ឬតួលេខដែលឃុំគ្រងរក្សាទុកមិនឲ្យខ្វាត់ខ្វាយនោះទាំងកាល ដែលលោកតែងគម្ពីរនេះ លោកក៏បានសរសើរគុណព្រះសម្មាសម្ពុទ្ធ ជាម្ចាស់មុន ព្រមទាំងសម្តែងការគោរពតាំងពីផ្តើមបរិច្ឆេទទី ១ ។

យ៉ាងណាក្តី លោកអ្នកសិក្សាក៏រមែងជាអ្នកមានការគិតពិចារណា ជាអ្នកមានហេតុផលរបស់ខ្លួនឯង កាលលោកបានសិក្សាមិនទាន់ចប់ បរិច្ឆេទទី ១ លោកក៏ជ្រាបបានដោយខ្លួនឯងថា ព្រះអភិធម្មទាំង ៧ គម្ពីរនោះ មិនមានអ្នកណាក្នុងលោកនឹងតែងឡើងមកបាន វៀរលែងតែ ព្រះសព្វញ្ញុតញ្ញាណរបស់ព្រះសម្មាសម្ពុទ្ធប៉ុណ្ណោះ ហើយលោកក៏នឹង ជ្រាបបានដោយខ្លួនឯងទៀតថា អ្នកពោលថាព្រះអភិធម្មមិនមែន ពុទ្ធវចនៈនោះ ព្រោះមិនធ្លាប់បានសិក្សាទើបមិនមានការយល់ ក្នុង ព្រះអភិធម្មឡើយ ។

ព្រះអភិធម្មនឹងកើតឡើងក្នុងលោកបាននោះ គឺត្រូវអាស្រ័យ ព្រះសព្វញ្ញុតញ្ញាណរបស់ព្រះសម្មាសម្ពុទ្ធប៉ុណ្ណោះ ដូចមានសាធក បាលីដែលបានសម្តែងទុកក្នុងបិដកបរិវារព្រះបាលីថា

**ពុទ្ធចន្ទេ អនុប្បន្នេ ពុទ្ធាទិច្ចេ អនុគ្គតេ**
**តេសំ សភាវធម្មានំ នាមមត្តំ ន ញាយតិ ។**

ប្រែថា កាលព្រះពុទ្ធដូចជាព្រះចន្ទមិនទាន់កើតឡើង កាលព្រះពុទ្ធដូចជាព្រះអាទិត្យមិនទាន់បានត្រាស់នៅឡើយ នាមបញ្ញត្តិរបស់សភាវធម៌ទាំងឡាយនោះ ក៏មិនមានអ្នកណាអាចដឹងបាន ។ (បិ.១២ ទ.៣៨៨)

## ព្រះអដ្ឋកថាចារ្យសម្ដែងទុកក្នុងអដ្ឋសាលិនីអដ្ឋកថា ថា

**អភិធម្មោ នាម ន អញ្ញេសំ វិសយោ សព្វញ្ញុពុទ្ធានំយេវ វិសយោ តេសំ វសេន ទេសេតព្វទេសនា ។**

ប្រែថា ដែលឈ្មោះថាព្រះអភិធម្ម ព្រោះមិនមែនជាវិស័យរបស់បុគ្គលដទៃ ជាវិស័យនៃព្រះសព្វញ្ញូរបស់ព្រះសម្មាសម្ពុទ្ធប៉ុណ្ណោះ នឹងការសម្ដែងព្រះអភិធម្មដែលប្រាកដឡើងបាន ក៏ដោយអំណាចនៃព្រះសព្វញ្ញូរបស់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះឯង ។

ព្រះអនុរុទ្ធាចារ្យ រចនាព្រះអភិធម្មត្ថសង្គហៈនោះ លោកបានចែកចេញជា ៩ បរិច្ឆេទ គឺ

**បរិច្ឆេទទី ១** សម្ដែងអំពីចិត្តបរមត្ថ ឈ្មោះថា **ចិត្តសង្គហវិភាគ** ។

**បរិច្ឆេទទី ២** សម្ដែងអំពីចេតសិកបរមត្ថ ឈ្មោះថា **ចេតសិកសង្គហវិភាគ** ។

**បរិច្ឆេទទី ៣** សម្ដែងអំពីការរួបរួមធម៌ផ្សេងៗ ដែលទាក់ទងជាមួយ **ចិត្ត ចេតសិក** គឺ **វេទនា ហេតុ កិច្ច ទ្វារ អារម្មណ៍** និង **វត្ថុ** ឈ្មោះថា **បកិណ្ណកសង្គហវិភាគ** ។

**បរិច្ឆេទទី ៤** សម្តែងអំពីការងាររបស់ចិត្ត គឺ វីថិចិត្ត ឈ្មោះថា **វីថិសង្គហវិភាគ ។**

**បរិច្ឆេទទី ៥** សម្តែងអំពីចិត្តដែលផុតវីថិរហូតដល់ធម៌ដែលជាប់ទាក់ទងគ្នា ឈ្មោះថា **វីថិមុត្តសង្គហវិភាគ ។**

**បរិច្ឆេទទី ៦** សម្តែងអំពីរូបបរមត្ថ និងនិព្វាន ឈ្មោះថា **រូបសង្គ-ហវិភាគ ។**

**បរិច្ឆេទទី ៧** សម្តែងអំពីធម៌ដែលសង្គ្រោះចូលជាពួកក្រុមរួមគ្នាបាន ឈ្មោះថា **សមុច្ចយសង្គហវិភាគ ។**

**បរិច្ឆេទទី ៨** សម្តែងអំពីបរមត្ថធម៌ដែលជាបច្ច័យដល់គ្នារហូតដល់ បញ្ញត្តិធម៌ ឈ្មោះថា **បច្ចយសង្គហវិភាគ** ។

**បរិច្ឆេទទី ៩** សម្តែងអំពីការបដិបត្តិសមថៈនិងវិបស្សនា ឈ្មោះថា **កម្មដ្ឋានសង្គហវិភាគ ។**

## ការចូលដល់ព្រះពុទ្ធសាសនាមាន ៣ ប្រការ

១. **បរិយត្តិសាសនា** បានដល់ ការសិក្សាពាក្យប្រៀនប្រដៅឲ្យយល់ ដើម្បីប្រយោជន៍ដល់ការបដិបត្តិ ដោយសង្ខេប បរិយត្តិសាសនាបានដល់ ការសិក្សាព្រះធម៌វិន័យក្នុងព្រះត្រៃបិដកឲ្យយល់នោះឯង ។

២. **បដិបត្តិសាសនា** បានដល់ ការបដិបត្តិធម៌តាមដែលបានសិក្សាមកពីបរិយត្តិមាន ៣ យ៉ាង គឺ បដិបត្តិដោយ **សីល សមាធិ បញ្ញា ។**

៣. **បដិវេធសាសនា** បានដល់ ផលដែលកើតឡើងពីបរិយត្តិ

និងបដិបត្តិដែលត្រឹមត្រូវ គឺ **នវលោកុត្តរធម៌ ៩** បានដល់ **មគ្គ ៤ ផល ៤ និងនិព្វាន ១ ។**

## ព្រះសម្មាសម្ពុទ្ធទ្រង់ប្រៀនប្រដៅអំពីអ្វី?

ក្នុងរវាង ៤៥ ព្រះវស្សារាប់តាំងពីព្រះសម្មាសម្ពុទ្ធបានត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ ក៏បានសម្តែងធម៌ប្រោសដល់វេនេយ្យសត្វដើម្បីឲ្យរួចផុតចាកទុក្ខផង អស់កិលេសផង កាលបើរួមពាក្យប្រៀនប្រដៅទាំងអស់ មានចំនួន ៨៤.០០០ ព្រះធម្មក្ខន្ធ សង្គ្រោះទុកជាបិដក ចែកចេញជា ៣ បិដក ឈ្មោះថា ព្រះត្រៃបិដក បានដល់

១. **ព្រះវិន័យបិដក** មាន ២១០០០ ព្រះធម្មក្ខន្ធ ។

២. **ព្រះសុត្តន្តបិដក** មាន ២១០០០ ព្រះធម្មក្ខន្ធ ។

៣. **ព្រះអភិធម្មបិដក** មាន ៤២០០០ ព្រះធម្មក្ខន្ធ ។

## ១. ព្រះវិន័យបិដកសម្តែងអំពីអ្វី?

**ព្រះវិន័យបិដក** ជាធម៌ដែលសម្តែងអំពីរបៀប ឬអាជ្ញាជាគោលឲ្យប្រព្រឹត្តបដិបត្តិដើម្បីជារបៀបរៀបរយស្អាតល្អ ដូចផ្កាឈើដែលគេនាំយកមកក្រងទុក មិនឲ្យខ្ចាត់ខ្ចាយ អ្នកដែលមិនបានប្រព្រឹត្តតាមអាជ្ញា ឬប្រព្រឹត្តល្មើស ក៏រមែងត្រូវទោសតាមសមគួរ ព្រះវិន័យបិដកនេះមាន ២១.០០០ ព្រះធម្មក្ខន្ធ ចែកចេញជា ៥ គម្ពីរ គឺ

**១. គម្ពីរអាទិកម្មិក, ២. គម្ពីរបាចិត្តិយ, ៣. គម្ពីរមហាវគ្គ, ៤. គម្ពីរចុល្លវគ្គ**

**៥. គម្ពីរបរិវារ ។**

គម្ពីរទាំង ៥ នេះ មានឈ្មោះសង្ខេបដើម្បីឲ្យងាយចាំ ដោយយកព្យាង្គខាងមុខមកតាំងឈ្មោះថា **អា. បា. ម. ចុ. ប. ។**

## ២. ព្រះសុត្តន្តបិដកសម្តែងអំពីអ្វី?

**ព្រះសុត្តន្តបិដក** ជាធម៌ដែលសម្តែងអំពីរឿងដែលជាប់ទាក់ទងជាមួយនឹងសម្មតិសច្ចៈ ដែលជាសេចក្តីពិតចំណែកមួយសម្រាប់សត្វលោក ជាធម៌ដែលលើកសត្វបុគ្គលឡើងមកសម្តែង ដើម្បីឲ្យកើតការប្រព្រឹត្តល្អ នៅរួមគ្នាក្នុងសង្គមដោយភាពរៀបរយ មាន ២១.០០០ ព្រះធម្មក្ខន្ធ ។

ព្រះសុត្តន្តបិដកនេះ ពេលខ្លះក៏ហៅយ៉ាងខ្លីថាព្រះសូត្រ ដែលចែកចេញជា ៥ និកាយគឺ

**១. ទីឃនិកាយ, ២. មជ្ឈិមនិកាយ, ៣. សំយុត្តនិកាយ, ៤.អង្គុត្តរនិកាយ, ៥. ខុទ្ទកនិកាយ ។**

និកាយទាំង ៥ នេះ មានឈ្មោះសង្ខេបដើម្បីឲ្យងាយចាំដោយយកព្យាង្គមុខមកតាំងឈ្មោះថា **ទី. ម. សំ. អំ. ខុ. ។**

## ៣. ព្រះអភិធម្មបិដកសម្តែងអំពីអ្វី?

**ព្រះអភិធម្មបិដក** ជាធម៌ដែលសម្តែងអំពីបរមត្ថសច្ចៈ បដិសេធសត្វ បុគ្គល តួខ្លួនយើងគេ ជាសេចក្តីពិតប្រាកដមិនមានការប្រែប្រួល

មិនថាវេលាណា ឬក្នុងទីណា ស្រដៀងវិជ្ជា វិទ្យាសាស្ត្រ ដែលយើងសិក្សាអំពីកម្តៅ ពន្លឺ សំឡេង មេដែក អគ្គិសនី ជាដើម ។

**ព្រះអភិធម្មបិដក** ពោលអំពីសភាវធម៌ដែលជាសេចក្តីពិត កាលដឹងហើយធ្វើឲ្យកើតបញ្ញា អាចលះកិលេសនាំខ្លួនឲ្យផុតទុក្ខបានមាន ៤២.០០០ ព្រះធម្មក្ខន្ធ ស្មើគ្នាជាមួយនឹងព្រះវិន័យ និងព្រះសូត្ររួមគ្នា ។

ព្រះអភិធម្មបិដកក្នុងចំនួន ៤២.០០០ ព្រះធម្មក្ខន្ធ ចែកចេញជា ៧ គម្ពីរគឺ

**១. ធម្មសង្គណី** ពោលអំពីពួកក្រុមនៃបរមត្ថធម៌ ។

**២. វិភង្គ** ពោលអំពីការចែកបរមត្ថធម៌ចេញជាចំណែកៗ ។

**៣ ធាតុកថា** ពោលអំពីធាតុនៃបរមត្ថធម៌ ។

**៤. បុគ្គលប្បញ្ញត្តិ** ពោលអំពីបញ្ញត្តិបុគ្គលនិងបរមត្ថ ។

**៥. កថាវត្ថុ** ពោលអំពីពាក្យសួរ ពាក្យឆ្លើយក្នុងបរមត្ថ ។

**៦. យមក** ពោលអំពីការសម្តែងបរមត្ថជាគូៗ ។

**៧. មហាបដ្ឋាន** ពោលអំពីហេតុបច្ច័យរបស់បរមត្ថ ។

គម្ពីរទាំង ៧ នេះមានឈ្មោះ ឲ្យហៅដើម្បីងាយចាំថា **សំ. វិ. ធា. បុ. ក. យ. ប.** ។

## ព្រះអភិធម្មត្ថសង្គហៈគឺអ្វី?

**អភិធម្មត្ថសង្គហ** ចែកចេញជា **អភិ+ធម្ម+អត្ថ+សំ+គហ** ។

**អភិ** = ដ៏ប្រសើរក្រៃលែង ។

**ធម្ម** = ធម្មជាតិដែលមិនមែនសត្វ មិនមែនជីវៈ ឬធម្មជាតិទ្រទ្រង់សភាវៈទុកមិនឲ្យមានការប្រែប្រួល ។

**អត្ថ** = សេចក្តី ។

**សំ** = ដោយសង្ខេប ។

**គហ** = រួបរួម ។

**អភិធម្មត្ថសង្គហ** ជាឈ្មោះគម្ពីរអដ្ឋកថា ដែលបានប្រមូលសេចក្តីពីព្រះអភិធម្ម ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់សម្តែងទាំង ៧ គម្ពីរ ទុកដោយសង្ខេប កាលសង្ខេបគម្ពីរព្រះអភិធម្មទាំង ៧ គម្ពីរឲ្យខ្លីបំផុតហើយ ក៏បានដល់ **ចិត្ត ចេតសិក រូប និព្វាន បញ្ញត្តិ** ។

## ព្រះបាលី បានដល់ អ្វី?

**បាលី** បានដល់ ពាក្យដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ត្រាស់ទេសនាប្រោសដល់វេនេយ្យសត្វ បានដល់ព្រះពុទ្ធវចនៈដោយត្រង់ ។

## អដ្ឋកថា បានដល់ អ្វី?

**អត្ថ** = សេចក្តី, **កថា** = ពោល ឬពាក្យ រួមចូលគ្នាហើយ ប្រែថាពោលសេចក្តីនោះ គឺពោលសេចក្តីតាមបាលីនោះម្តងទៀត អ្នកអធិប្បាយសេចក្តីតាមបាលីនោះ ហៅថា អដ្ឋកថាចារ្យ លោកបានអធិប្បាយសេចក្តីពីបាលីចេញមក ដើម្បីឲ្យងាយយល់ ឲ្យជាក់ច្បាស់ឡើង ដើម្បីងាយស្រួលដល់ការសិក្សារៀនសូត្រ អដ្ឋកថាចារ្យ បានទទួលការលើក

តម្កើងពីបណ្ដាអ្នកសិក្សាទាំងឡាយ ព្រោះជាអ្នកមានការឆ្លាតឈ្លាស ភាគច្រើនជាព្រះអរិយបុគ្គល និងអ្នកទ្រទ្រង់ព្រះត្រៃបិដក ។

## ដីកាចារ្យ បានដល់ អ្វី?

កាលអដ្ឋកថា អធិប្បាយបរិយាយសេចក្ដីចេញមកហើយ អ្នកសិក្សាក៏មិនទាន់យល់បានទៀត ដីកាចារ្យទើបជាអ្នកអធិប្បាយសេចក្ដីនៃអដ្ឋកថានោះម្ដងទៀត ។

តពីនេះ ក៏មានអនុដីកាចារ្យ និងកេចិអាចារ្យជាអ្នកអធិប្បាយក្នុងគោលធម៌ទាំងឡាយ ដែលដីកាចារ្យបានធ្វើទុកដើម្បីឲ្យជាក់ច្បាស់ឡើងទៅទៀត ។

## ព្រះអភិធម្ម សំដែងអំពីអ្វី?

**ព្រះអភិធម្មនោះ** ជាធម៌ដែលសម្ដែងអំពីសេចក្ដីពិតពីរប្រភេទគឺ បរមត្ថធម៌និងបញ្ញត្តិធម៌ ។

**១. បរមត្ថធម៌** ឬ **បរមត្ថសច្ច** គឺធម្មជាតិដ៏ប្រសើរ ដែលជាសេចក្ដីពិត មានការបដិសេធសត្វនិងជីវៈ បានដល់ ធម្មជាតិដែលជាសេចក្ដីពិតមិនមានការប្រែប្រួល ឬមិនមានសេចក្ដីវិបរិតដោយប្រការណាៗ មាន ៤ ប្រការ បានដល់ **ចិត្ត ចេតសិក រូប និព្វាន** ។ ដឹងបរមត្ថធម៌មានប្រយោជន៍យ៉ាងក្រៃលែង គឺ ធ្វើឲ្យផុតទុក្ខបានដោយពិត ។

**២. បញ្ញត្តិធម៌ ឬ សម្មតិសច្ច** ជាវត្ថុដែលបញ្ញត្តតែងតាំងឡើង ហើយជាទីព្រមទទួលរបស់ពួកជន ទើបបានជាវត្ថុសន្មតឡើងមកថា ជាការពិតដើម្បីនឹងហៅឈ្មោះបានត្រឹមត្រូវ តាមការនិយមរបស់មនុស្សមួយពួក ឬមួយប្រទេស ។

## បរមត្ថធម៌មានលក្ខណៈដូចម្ដេច?

បរមត្ថធម៌មានលក្ខណៈបដិសេធសត្វ និងជីវៈ (និស្សត្ត និជ្ជីវ ធម្ម) ជាសភាវធម៌ដែលមានពិត មានលក្ខណៈជាប្រចាំ ២ លក្ខណៈ គឺ

**១. សាមញ្ញលក្ខណ** ជាធម្មជាតិដែលមានលក្ខណៈសាមញ្ញទូទៅ ឬមានលក្ខណៈប្រក្រតីធម្មតា ដែលជារូបធម៌ និងនាមធម៌ ។

ក្នុង**សាមញ្ញលក្ខណ** ដែលពោលថាមានតាមធម្មតា ឬប្រព្រឹត្តទៅតាមធម្មជាតិនោះ ប្រព្រឹត្តទៅក្នុងលក្ខណៈទាំង ៣ នេះ គឺ

**ក. អនិច្ចលក្ខណ** ជាលក្ខណៈដែលមានការមិនទៀង មិនឋិតថេរ មានការមិនគង់វង្ស ត្រូវប្រែប្រួលទៅ ។

**ខ. ទុក្ខលក្ខណ** ជាលក្ខណៈទ្រាំនៅមិនបាន ឬនៅក្នុងសភាពដើមមិនបាន ត្រូវសាបសូន្យទៅ ។

**គ. អនត្តលក្ខណ** ជាលក្ខណៈដែលសូន្យចាកតួខ្លួន គឺមិនមែនមនុស្ស មិនមែនសត្វ មិនមែនវត្ថុរបស់ ទាំងមិននៅក្នុងអំណាចបង្គាប់បញ្ជារបស់អ្នកណាឡើយ ។

## បរមត្ថធម៌ដោយសង្ខេបនោះមាន ៤ ប្រការ គឺ

**ចិត្ត ចេតសិក រូប និងព្រះនិព្វាន ។ ចិត្ត ចេតសិក រូប ទាំង ៣** នេះ មានសាមញ្ញលក្ខណៈ ព្រោះប្រកបទៅដោយ **អនិច្ចលក្ខណ ទុក្ខលក្ខណ អនត្តលក្ខណ** ដែលហៅថា **ត្រៃលក្ខណ៍ ។**

**ព្រះនិព្វាននោះ** មិនបាននៅក្នុងលក្ខណៈគ្រប់ទាំង ៣ ប្រការទេ មានសាមញ្ញលក្ខណៈ ត្រឹមតែមួយគឺ **អនត្តលក្ខណ** ប៉ុណ្ណោះ ។

សម្រាប់បញ្ញត្តិធម៌ មិនប្រកបដោយត្រៃលក្ខណ៍ ឬសាមញ្ញ-លក្ខណៈទាំង ៣ ឡើយ ព្រោះត្រឹមតែជាបញ្ញត្តិ ឬសន្មតឡើងដើម្បីឲ្យយល់គ្នាបានប៉ុណ្ណោះ មិនមានពិតទេ ។

**២. វិសេសលក្ខណ** ជាធម្មជាតិពិសេសដែលមានប្រចាំក្នុងបរមត្ថធម៌នីមួយៗ មានលក្ខណៈពិសេសចំពោះខ្លួនដែលមិនដូចគ្នាឡើយ វិសេសលក្ខណៈមាន ៤ ប្រការគឺ **លក្ខណ រស បច្ចុប្បដ្ឋាន** និង **បទដ្ឋាន** ។

**ក. លក្ខណ** បានដល់ គ្រឿងសម្គាល់ ឬគុណសម្បត្តិដែលមានប្រចាំដោយចំពោះ ។

**ខ. រស** បានដល់ កិច្ចដែលធ្វើ ឬការសម្រេចដែលមាននៅក្នុងតួរបស់បរមត្ថធម៌ទាំងឡាយ រសនេះទើបចែកចេញជា ២ ប្រការ គឺ

**(១). កិច្ចរស** បានដល់ តួនាទីរបស់បរមត្ថធម៌ទាំងឡាយ ដូចជាចិត្តមាននាទីដែលជាកិច្ចរស គឺជាប្រធានក្នុងសម្បយុត្តធម៌ទាំងឡាយ ឬ**កិច្ចរស** របស់តេជោធាតុ គឺ ធាតុភ្លើងរមែងមាននាទីក្នុងការដុតនិងធ្វើ

វត្ថុផ្សេងៗ ឲ្យឆ្អិនបានជានាទីរបស់ភ្លើង ។

**(២). សម្បត្តិរស** បានដល់ គុណសម្បត្តិដែលមាននៅប្រចាំរបស់បរមត្ថធម៌ទាំងឡាយ ដូចជាចិត្តមានគុណសម្បត្តិនៅប្រចាំដែលជា **សម្បត្តិរស** គឺ មានចេតសិកប្រកបជាសម្បយុត្តធម៌ផង **សម្បត្តិរស** របស់ព្រះនិព្វាន គឺ មានសភាពមិនប្រែប្រួលជា **និច្ចំ** ឬ **សម្បត្តិរស** របស់តេជោធាតុ គឺ ភាពក្តៅរមែងញ៉ាំងពន្លឺឲ្យសម្រេចជាគុណសម្បត្តិជាដើម ។

**គ. បច្ចុប្បដ្ឋាន** បានដល់ ផលដែលកើតឡើងអំពីកិច្ចនោះឯង ឬជាការប្រាកដឡើងពីកិច្ចនោះៗ ។

**ឃ. បទដ្ឋាន** បានដល់ ហេតុជិតដែលជាហេតុឲ្យធម៌នោះៗ ប្រាកដឡើង ។

**វិសេសលក្ខណ ៤** ប្រការ ដូចពោលមកនេះ ឈ្មោះលក្ខណាទិចតុក្កៈ មានសេចក្តីថា ធម៌ដែលមានអង្គ ៤ ប្រការ មានលក្ខណៈ ជាដើម ។

**ចិត្ត ចេតសិក រូប** មានវិសេសលក្ខណៈ ៤ ប្រការ គ្រប់បរិបូណ៌ ។

**និព្វាន** មានវិសេសលក្ខណៈ ៣ ប្រការប៉ុណ្ណោះ គឺមាន **លក្ខណ រស បច្ចុប្បដ្ឋាន** តែមិនមានបទដ្ឋាន គឺ ហេតុជិតឲ្យកើត ដោយហេតុថា ព្រះនិព្វាននោះ ជាធម៌ដែលផុតចាកហេតុបច្ច័យតាក់តែង ។

សម្រាប់បញ្ញត្តិធម៌នោះមិនមានវិសេសលក្ខណៈឡើយ។

# ប្លង់បរមត្ថធម៌ ៤ ប្រការ

- បរមត្ថធម៌
  - សង្ខត
    - នាម
      - ចិត្ត ៨៩
        - លោកិយ ៨១
          - កាមាវចរចិត្ត ៥៤
            - អសោភណ ៣០
            - សោភណ ២៤
          - មហគ្គតចិត្ត ២៧
            - រូបាវចរ .......១៥
            - អរូបាវចរ.....១២
        - លោកុត្តរ ៨
          - មគ្គចិត្ត............................៤
          - ផលចិត្ត............................៤
      - ចេតសិក ៥២
        - អញ្ញសមា ១៣
          - សព្វចិត្តសាធារណ..៧
          - បកិណ្ណក ...............៦
        - អកុសល ១៤
          - មោចតុក្ក..............៤
          - លោតិក................៣
          - ទោចតុក្ក..............៤
          - ថីទុក....................២
          - វិចិកិច្ឆា.................១
        - សោភណ ២៥
          - សោភណសាធារណ.១៩
          - វិរតិ.............................៣
          - អប្បមញ្ញា....................២
          - បញ្ញា...........................១
    - រូប ២៨
      - មហាភូតរូប.........................................................៤
      - ឧបាទាយរូប ២៤
        - បសាទរូប............................៥
        - គោចររូប.............................៤
        - ភាវរូប.................................២
        - ហទយរូប............................១
        - ជីវិតរូប.................................១
        - អាហាររូប............................១
        - បរិច្ឆេទរូប............................១
        - វិញ្ញត្តិរូប..............................២
        - វិការរូប................................៣
        - លក្ខណរូប...........................៤
  - អសង្ខតធម៌.................................................................... និព្វាន ១

# អភិធម្មត្ថសង្គហបាលី បរិច្ឆេទទី ១

# ចិត្តសង្គហវិភាគ

## គាថាផ្ដើមបករណ៍

១. សម្មាសម្ពុទ្ធមតុលំ សសទ្ធម្មគណុត្តមំ
អភិវាទិយ ភាសិស្សំ អភិធម្មត្ថសង្គហំ ។
២. តត្ថ វុត្តាភិធម្មត្ថា ចតុធា បរមត្ថតោ
ចិត្តំ ចេតសិកំ រូបំ និព្វានមិតិ សព្វថា ។

## គាថាសង្គហ

៣. អដ្ឋធា លោភមូលានិ ទោសមូលានិ ច ទ្វិធា
មោហមូលានិ ច ទ្វេតិ ទ្វាទសាកុសលា សិយុំ ។
៤. សត្តាកុសលបាកានិ បុញ្ញបាកានិ អដ្ឋធា
ក្រិយចិត្តានិ តីណីតិ អដ្ឋារស អហេតុកា ។
៥. បាបាហេតុកមុត្តានិ សោភនានីតិ វុច្ចរេ
ឯកូនសដ្ឋិ ចិត្តានិ អថេកនវុតីបិ វា ។
៦. វេទនាញាណសង្ខារ- ភេទេន ចតុវីសតិ
សហេតុកាមាវចរ- បុញ្ញបាកក្រិយា មតា ។
៧. កាមេ តេវីស បាកានិ បុញ្ញាបុញ្ញានិ វីសតិ

ឯកាទស ក្រិយា ចេតិ ចតុបញ្ញាស សព្វថា ។

៨. បញ្ចធា ឈានភេទេន រូបាវចរមានសំ
បុញ្ញបាកក្រិយាភេទា តំ បញ្ចទសធា ភវេ ។

៩. អាលម្ពនប្បភេទេន ចតុធារុប្បមានសំ
បុញ្ញបាកក្រិយាភេទា បុន ទ្វាទសធា ឋិតំ ។

១០. ចតុមគ្គប្បភេទេន ចតុធា កុសលំ តថា
បាកំ តស្ស ផលត្តាតិ អដ្ឋធានុត្តរំ មតំ ។

១១. ទ្វាទសាកុសលានេវំ កុសលានេកវីសតិ
ឆត្តឹសេវ វិបាកានិ ក្រិយចិត្តានិ វីសតិ ។

១២. ចតុបញ្ញាសធា កាមេ រូបេ បន្នរសីរយេ
ចិត្តានិ ទ្វាទសារុប្បេ អដ្ឋធានុត្តរេ តថា ។

១៣. ឥត្ថមេកូននវុតិ- បភេទំ បន មានសំ
ឯកវីសសតំ វាថ វិភជន្តិ វិចក្ខណា ។

១៤. ឈានង្គយោគភេទេន កត្វេកេកន្តុ បញ្ចធា
វុច្ចតានុត្តរំ ចិត្តំ ចត្តាលីសវិធន្តិ ច ។

១៥. យថា ច រូបាវចរំ គយ្ហតានុត្តរំ តថា
បឋមាទិឈានភេទេ អារុប្បញ្ចាបិ បញ្ចមេ ។

១៦. ឯកាទសវិធំ តស្មា បឋមាទិកមីរិតំ
ឈានមេកេកមន្តេ តុ តេវីសតិវិធំ ភវេ ។

១៧. សត្តតឹសវិធំ បុញ្ញំ ទ្វិបញ្ញាសវិធំ តថា

**បាកមិច្ឆាហុ ចិត្តានិ ឯកវីសសតំ ពុធា ។**

**ឥតិ អភិធម្មត្ថសង្គហេ ចិត្តសង្គហវិភាគោ នាម**
**បឋមោ បរិច្ឆេទោ ។**

ចប់អភិធម្មត្ថសង្គហៈបាលី បរិច្ឆេទទី ១ ពោលអំពី
**ចិត្តសង្គហវិភាគ ៕**

# ចិត្ត ៨៩ ឬ ១២១ ដួង



# បរិច្ឆេទទី ១ ចិត្តសង្គហវិភាគ

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

## បណាមនិងប្តេជ្ញារបស់ព្រះអនុរុទ្ធាចារ្យ

(**គាថាផ្តើមបករណ៍**)

**១. សម្មាសម្ពុទ្ធមតុលំ សសទ្ធម្មគណុត្តមំ**
**អភិវាទិយ ភាសិស្សំ អភិធម្មត្ថសង្គហំ ។**

ខ្ញុំព្រះអង្គ (អនុរុទ្ធាចារ្យ) សូមនមស្ការថ្វាយបង្គំចំពោះព្រះសម្មាសម្ពុទ្ធជាម្ចាស់ដែលមិនមានបុគ្គលណាមួយស្មើបាន ព្រមទាំងព្រះសទ្ធម្ម និងគណៈនៃព្រះអរិយសង្ឃដ៏ឧត្តម ហើយនឹងសូមពោលនូវគម្ពីរ **អភិធម្មត្ថសង្គហ** ។

**២. តត្ថ វុត្តាភិធម្មត្ថា ចតុធា បរមត្ថតោ**
**ចិត្តំ ចេតសិកំ រូបំ និព្វានមិតិ សព្វថា ។**

ប្រែថា អត្ថនៃព្រះអភិធម្ម ក្នុងអភិធម្មបិដកនោះ ពោលដោយបរមត្ថធម៌ហើយ មានត្រឹម ៤ ប្រការ គឺ **ចិត្ត ចេតសិក រូប និព្វាន** ដោយប្រការទាំងពួង ។

# អធិប្បាយ

**បរមត្ថ** ចែកចេញជា ២ បទគឺ **បរម+អត្ថ ។**

**បរម** ប្រែថា ដ៏ប្រសើរ ។

**អត្ថ** ប្រែថា សេចក្តី ។

ដូច្នេះ **បរមត្ថ** ទើបប្រែថា សេចក្តីដ៏ប្រសើរ ឬសេចក្តីដែលល្អក្រៃលែង ។

ពាក្យថា **បរមត្ថធម៌** ទើបជាធម៌ដែលមានសេចក្តីដ៏ប្រសើរ ។

**បរម** ឬប្រសើរ នេះកាលពោលដោយអត្ថហើយ មិនបានសំដៅដល់ ប្រណីតស្អាត តែសំដៅយក ភាវៈ ៣ ប្រការ គឺ ១ ប្រសើរ ព្រោះមិនមានការវិបរិតប្រែប្រួល ។

**បរមោ ឧត្តមោ អវិបរិតោ អត្ថោតិ = បរមត្ថោ** ប្រែថា សភាវធម៌ដ៏ប្រសើរ គឺ មិនប្រែប្រួល ទើបឈ្មោះថា **បរមត្ថ** ។

ការមិនវិបរិតប្រែប្រួលនោះ សំដៅដល់ សភាវៈរបស់ខ្លួនយ៉ាងណា ក៏ជាយ៉ាងនោះរហូតទៅ មិនខុសប្រក្រតីជាយ៉ាងដទៃ ជារបស់មានពិត ។

២. ប្រសើរ ព្រោះជាទីគោចរនៃញាណដ៏ប្រសើរ ។

**បរមស្ស ឧត្តមស្ស ញាណស្ស អត្ថោ គោចរោតិ = បរមត្ថោ** ប្រែថា សភាវធម៌ណាដែលជាទីគោចរនៃញាណដ៏ប្រសើរ គឺ ខ្ពង់ខ្ពស់បំផុត សភាវធម៌នោះ ឈ្មោះថា **បរមត្ថ** ។ ពោលគឺ បរមត្ថធម៌នោះ ជាធម៌ដែលមានសេចក្តីល្អិតសុខុមក្រៃលែង អ្នកមានបញ្ញាទន់ខ្សោយ រមែងយល់

ក្នុងសភាវៈរបស់បរមត្ថធម៌នេះមិនបានឡើយ អ្នកដែលយល់បាន ត្រូវជាអ្នកមានញាណខ្លាំងក្លា ជាតិហេតុកបុគ្គលជាដើម រហូតដល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ជាទីបំផុតប៉ុណ្ណោះ ដឹងបរមត្ថធម៌ធ្វើឲ្យបានបរមត្ថប្រយោជន៍ ។

៣. ប្រសើរ ព្រោះជាធម៌ដែលជាប្រធាននៃបញ្ញត្តិធម៌ទាំងឡាយ ។

**បរមោ បធានោ អត្ថោតិ = បរមត្ថោ** ប្រែថា សេចក្តីដែលជាប្រធាន ឈ្មោះថា **បរមត្ថ** ។ ពោលគឺ បណ្តាសត្វនិងវត្ថុទាំងឡាយក្នុងលោកនេះ មានច្រើនយ៉ាងច្រើនប្រភេទ រហូតដល់ប្រមាណមិនបាន តែបើកំណត់យកសេចក្តីពិតហើយ ក៏មានតែអត្ថៈ (សេចក្តី) គឺសភាវៈរបស់នាមរូប ដែលឈ្មោះថាជាអង្គធម៌ប៉ុណ្ណោះ ទើបពោលបានថាក្រៅពី **ចិត្ត ចេតសិក រូប** ហើយ មិនមានអ្វីទៀតឡើយ ក្នុងវត្ថុដែលមានជីវិតនិងមិនមានជីវិតទាំងឡាយ ។

**បរមត្ថធម៌** មាន ២ យ៉ាងគឺ **សង្ខតធម៌** ម្យ៉ាង និង **អសង្ខតធម៌** ម្យ៉ាង ។

**សង្ខតធម៌** បានសេចក្តីថា ធម៌ទាំងឡាយដែលមានការតាក់តែងដោយបច្ច័យ ៤ គឺ **កម្ម ចិត្ត ឧតុ** និង**អាហារ** បានដល់ **ចិត្ត ចេតសិក** និង**រូប** ។

**អសង្ខតធម៌** បានសេចក្តីថា ធម៌ទាំងឡាយដែលមិនមានការតាក់តែងដោយបច្ច័យណាៗ បានដល់ **ព្រះនិព្វាន** ។

តទៅនេះនឹងសិក្សាសង្ខេតធម៌ ពោលអំពី "**ចិត្ត**" ជាលំដាប់ដំបូងតទៅ

## ចិត្តបរមត្ថ

## ចិត្ត គឺ អ្វី?

ចិត្តជាធម្មជាតិដឹងអារម្មណ៍ គឺបានទទួលអារម្មណ៍ជានិច្ចទើបហៅថា ដឹងអារម្មណ៍ ដូចព្រះបាលីថា **អារម្មណំ ចិន្តេតីតិ = ចិត្តំ** ធម្មជាតិណា រមែងគិត គឺដឹងអារម្មណ៍ ធម្មជាតិនោះ ឈ្មោះថា "**ចិត្ត**" ។

## អារម្មណ៍ជាធម្មជាតិដែលចិត្តត្រូវដឹងមាន ៦ យ៉ាង គឺ

**១.រូបារម្មណ៍** បានដល់ **វណ្ណរូប** ចិត្តអាចដឹងបានដោយការឃើញ ។

**២. សទ្ទារម្មណ៍** បានដល់ **សំឡេង** ចិត្តអាចដឹងបានដោយការឮ ។

**៣. គន្ធារម្មណ៍** បានដល់ **ក្លិន** ចិត្តអាចដឹងបានដោយការធុំក្លិន ។

**៤.រសារម្មណ៍** បានដល់ **រស** ចិត្តអាចដឹងបានដោយការទទួលរស ។

**៥. ផោដ្ឋព្វារម្មណ៍** បានដល់ រឹង ទន់ ក្ដៅ ត្រជាក់ តឹង ញ័រ ចិត្តអាចដឹងបានដោយការពាល់ត្រូវសម្ផស្ស ។

**៦. ធម្មារម្មណ៍** បានដល់ **ចិត្ត ចេតសិក បសាទរូប សុខុមរូប និព្វាន បញ្ញត្តិ** ចិត្តអាចដឹងបានដោយការនឹកគិត ។

# ការដឹងអារម្មណ៍មាន ៣ យ៉ាង គឺ

**១. ការដឹងដោយសញ្ញា** គឺ ដឹងព្រោះអាស្រ័យការកំណត់ ចំណាំ-ទុក ដូចជាចាំបានថា ពណ៌ស ពណ៌ខ្មៅ បុរស ស្ត្រីជាដើម ហៅថា ដឹងដោយសញ្ញា ។

**២. ការដឹងដោយបញ្ញា** គឺ ដឹងហេតុផលតាមសេចក្តីពិត ដូចជាដឹងបាប បុណ្យ គុណ ទោស ប្រយោជន៍ មិនមែនប្រយោជន៍ ឬដឹងនាមរូបតាមសេចក្តីពិត ជាការដឹងដើម្បីលះបង់កិលេស មានការយល់ឃើញខុសជាដើម ហៅថា ដឹងដោយ **បញ្ញា ។**

**៣. ការដឹងដោយវិញ្ញាណ** គឺ ដឹងថាមានការទទួលអារម្មណ៍តាមទ្វារផ្សេងៗ បានដល់ ការឃើញ ការឮ ដឹងក្លិន ដឹងរស ដឹងផោដ្ឋព្វៈ និងការនឹកគិត ហៅថា ដឹងដោយវិញ្ញាណ ។

ការដឹងអារម្មណ៍របស់ចិត្តទើបជាការដឹងដោយវិញ្ញាណនោះឯង ព្រោះពាក្យថា "**ចិត្ត ឬ វិញ្ញាណ**" មានសេចក្តីដូចគ្នា ក្នុងបដិសម្ភិទាព្រះបាលីមហាវគ្គបានសម្តែងទុកថា ចិត្តមានឈ្មោះផ្សេងៗ ដែលហៅផ្សេងគ្នាមាន ១០ ឈ្មោះ ដូចសម្តែងថា

**យំ ចិត្តំ មនោ មានសំ ហទយំ បណ្ឌរំ មនាយតនំ មនិន្ទ្រិយំ វិញ្ញាណំ វិញ្ញាណក្ខន្ធោ តជ្ជា មនោវិញ្ញាណធាតុ ឥទំ ចិត្តំ** ។

(បិដកភាគ ៧០ ទំព័រ ១៦២)

អដ្ឋសាលិនីអដ្ឋកថា អធិប្បាយទុកថា

ធម្មជាតិណា រមែងគិត ធម្មជាតិនោះ ឈ្មោះថា **ចិត្ត** ។

ធម្មជាតិណា រមែងបង្អោនទៅរកអារម្មណ៍ ធម្មជាតិនោះ ឈ្មោះថា **មនោ ។**

ចិត្តដែលរួបរួមទុកខាងក្នុងនោះឯង ឈ្មោះថា **ហទយ ។**

ធម្មជាតិឆន្ទៈ គឺ សេចក្តីពេញចិត្តដែលមាននៅក្នុងចិត្តនោះ ឈ្មោះថា **មានស** ។

**ចិត្ត** ជាធម្មជាតិដែលថ្លាផូរផង់ទើប ឈ្មោះថា **បណ្ឌរ ។**

**មន** ជាអាយតនៈ គឺ គ្រឿងតទើប ឈ្មោះថា **មនាយតន** ។

**មន** ជាឥន្ទ្រិយ គឺ គ្របគ្រងជាធំ ទើបឈ្មោះថា **មនិន្ទ្រិយ** ។

**ធម្មជាតិណា** ដែលដឹងអារម្មណ៍ ធម្មជាតិនោះ ឈ្មោះថា **វិញ្ញាណ ។**

**វិញ្ញាណ** ជាខន្ធ ឈ្មោះថា **វិញ្ញាណក្ខន្ធ** ។

**មន** ជាធាតុមួយប្រភេទ ដែលដឹងអារម្មណ៍ ទើបឈ្មោះថា **មនោវិញ្ញាណធាតុ** ។

## សាមញ្ញលក្ខណៈរបស់ចិត្ត

ចិត្តជាសង្ខតធម៌ គឺ ជាធម្មជាតិដែលត្រូវតាក់តែងដោយអំណាចនៃបច្ច័យ មានអារម្មណប្បច្ច័យ អនន្តរប្បច្ច័យជាដើម ដូច្នេះចិត្តទើបមានសភាវៈដែលជាសាមញ្ញលក្ខណៈ ឬត្រៃលក្ខណៈ គឺ

**១. អនិច្ចលក្ខណ** គឺ សភាពមិនទៀងប្រែប្រួល ។

**២. ទុក្ខលក្ខណ** គឺ សភាពទ្រាំនៅមិនបាន ព្រោះត្រូវបៀតបៀន ។

**៣. អនត្តលក្ខណា** គឺ សភាពមិនមែនតួខ្លួន មិនស្ថិតនៅក្នុងអំណាចការបង្គាប់បញ្ជា ឲ្យប្រព្រឹត្តទៅយ៉ាងណាៗ បានឡើយ ។

ព្រោះចិត្តមានសភាពជាត្រៃលក្ខណៈ ដូចពោលមកនេះ ចិត្តទើបមានអាការកើតរលត់ជាប់តគ្នា ទៅមិនដាច់ក្រសែ ហើយការកើតរលត់បន្តគ្នានេះលឿនរហ័ស មានឧបមាថា មួយផ្ទាត់ម្រាមដៃ ចិត្តកើតរលត់ដល់ទៅសែនកោដិខណៈ ។

សង្ខតធម៌ដទៃ គឺ ចេតសិក និងរូប ក៏មានសាមញ្ញលក្ខណៈដូចគ្នា ព្រោះដូច្នោះ ការដែលនឹងយល់សភាវលក្ខណៈពិតរបស់ចិត្តនោះបាន ត្រូវពិចារណាវិសេសលក្ខណៈ គឺ លក្ខណៈពិសេសប្រចាំខ្លួន របស់ចិត្ត ៤ ប្រការ ដែលហៅថា លក្ខណាទិចតុក្កៈរបស់ចិត្តគឺ

**១. វិជាននលក្ខណំ** មានការដឹងនូវអារម្មណ៍ជាលក្ខណៈ

**២. បុព្វង្គមរសំ** មានភាពជាប្រធានក្នុងធម៌ទាំងពួងជាកិច្ច

**៣. សន្ធានបច្ចុប្បដ្ឋានំ** មានការកើតជាប់តគ្នាមិនដាច់ក្រសែជាអាការប្រាកដ

**៤. នាមរូបបទដ្ឋានំ** មាននាមរូបជាហេតុជិត ។

ក្នុងគាថាធម្មបទបានសម្ដែងដល់សភាពរបស់ចិត្តទុកដូច្នេះ គឺ

**ទូរង្គមំ ឯកចរំ អសរីរំ គុហាសយំ**
**យេ ចិត្តំ សញ្ញមេស្សន្តិ មោក្ខន្តិ មារពន្ធនា ។**

ប្រែថា អ្នកទាំងឡាយណា នឹងសង្រួមចិត្តដែលទៅឆ្ងាយ ជាចិត្តត្រាច់ទៅតែឯង មិនមានសរីរៈ មានគុហាគឺមហាភូតរូប ៤ ជាទីអាស្រ័យនៅ

អ្នកទាំងនោះឯង រមែងរួចចាកចំណងនៃមារ (បិដកភាគ ៥២ ទំព័រ ២៨) ។

ក្នុងគាថាធម្មបទនេះ សម្តែងសភាពរបស់ចិត្តឲ្យបានជ្រាបទុកច្រើនន័យ គឺ

**ចិត្ត** ធម្មជាតិដឹងអារម្មណ៍ ត្រាច់ទៅបានឆ្ងាយ (**ទូរង្គមំ**) បានដល់ចិត្តអាចនាំយកអារម្មណ៍ដែលនៅឆ្ងាយដ៏សែនឆ្ងាយ ដែលធ្លាប់ជួបធ្លាប់ឃើញមកហើយ យកមកនឹកគិតបាន មិនមែនចិត្តចេញពីរូបកាយត្រាច់ទៅនោះទេ ។

**ចិត្ត** ជាធម្មជាតិត្រាច់ទៅតែឯង ឬទៅតែមួយដួង (**ឯកចរំ**) បានដល់ចិត្តដឹងអារម្មណ៍បានម្តងមួយៗ ចិត្តមួយខណៈនឹងដឹងអារម្មណ៍ច្រើនយ៉ាងព្រមគ្នាមិនបាន ចិត្តមួយខណៈដឹងអារម្មណ៍បានមួយយ៉ាងប៉ុណ្ណោះ តែដោយសារចិត្តកើតរលត់លឿនរហ័ស ទើបហាក់ដូចជាអាចដឹងអារម្មណ៍បានច្រើនយ៉ាង ក្នុងគ្រាតែមួយបាន ចិត្តខណៈមួយៗរមែងដឹងអារម្មណ៍បានតែមួយយ៉ាងប៉ុណ្ណោះ ។

**ចិត្ត** ជានាមធម៌មិនមានរូបរាងសណ្ឋានឲ្យដឹងបានដោយភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយទេ អាចដឹងបានដោយចិត្តប៉ុណ្ណោះ មានសភាវៈជាអរូបធម៌ ទើបមិនអាចសម្តែងរូបរាងសណ្ឋានឲ្យប្រាកដបាន (**អសរីរំ**) ។

**ចិត្ត** ជាធម្មជាតិដែលមានវត្ថុជាទីកើត និងទីអាស្រ័យ (**គុហាសយំ**) សម្រាប់សត្វដែលកើតក្នុងបញ្ចវោការភូមិ គឺភូមិដែលមានខន្ធ ៥ វត្ថុដែលជាទីអាស្រ័យរបស់ចិត្តមាន ៦ បានដល់ **១.ចក្ខុវត្ថុ ២.សោតវត្ថុ**

**៣.ឃានវត្ថុ ៤.ជិវ្ហាវត្ថុ ៥.កាយវត្ថុ ៦.ហទយវត្ថុ** ។ ដោយសភាវបរមត្ថធម៌បានដល់ **បសាទរូប ៥** និង**ហទយវត្ថុរូប ១** ចិត្តនឹងត្រាច់ទៅក្រៅវត្ថុដែលជាទីអាស្រ័យមិនបាន ។ សូម្បីវេលាស្លាប់ ចិត្តក៏រលត់ព្រមគ្នាជាមួយការរលត់របស់ហទយវត្ថុរូបនោះឯង ។

ចិត្តរបស់សត្វទាំងឡាយ ក្រៅអំពីចិត្តរបស់ព្រះអរហន្ត រមែងត្រូវអាសវក្កិលេសរួបរឹតជាប្រចាំ ដេកត្រាំជានិច្ច ធ្វើមិនឲ្យដឹងការពិតរបស់នាមរូប គឺ ទុក្ខសច្ចៈ ទើបកើតការសម្គាល់ខុសថា នាមរូបឬខន្ធ ៥ ជាអត្តាតួខ្លួន ប្រាថ្នាភាពស្អាតសេចក្តីសុខ សេចក្តីទៀង វិបល្លាសចាកសេចក្តីពិតជានិច្ច ព្រោះហេតុនោះ ព្រះពុទ្ធអង្គឲ្យសង្រួមរក្សាចិត្តឲ្យផុតចាកគ្រឿងចងរបស់មារ (កិលេស) ដោយត្រូវចម្រើនសតិប្បដ្ឋានដែលជាផ្លូវមូលតែមួយ នឹងធ្វើឲ្យផុតកិលេស ជាក់ច្បាស់នូវព្រះនិព្វាន និងផុតចាកសង្សារទុក្ខបាន ។

ដូច្នោះ ទើបមិនមានចិត្តរបស់អ្នកណាដែលកើតមកព្រមដោយការបរិសុទ្ធបាន ត្រូវកិលេសមាររួបរឹតទុកនៅក្នុងអំណាច គ្រប់គ្នាត្រូវតែស្តាប់ធម៌ និងបដិបត្តិតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធអង្គប៉ុណ្ណោះ ទើបអាចរួចផុតចាកកិលេសជាគ្រឿងចងរបស់មារបាន ។

# អំណាចរបស់ចិត្ត

**ចិត្ត** ក្រៅពីដឹងអារម្មណ៍ជាលក្ខណៈហើយ នៅមានកិច្ច ឬតួនាទីដែលជាប្រធានក្នុងធម៌ទាំងពួង គឺធ្វើឲ្យសម្រេចការងារទាំងឡាយតាមផ្លូវកាយវាចាចិត្ត ដូចក្នុងគាថាធម្មបទពោលថា

**មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា**
**មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា**
**តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ ។**

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត (មានចិត្តជាធំ) សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តត្រូវទោសប្រទូស្តហើយពោលក្តី ធ្វើក្តី (នូវទុច្ចរិត) ព្រោះទុច្ចរិតទាំងនោះ ទុក្ខ រមែងជាប់តាមបុគ្គលនោះទៅ ដូចកង់រទេះវិលទៅតាមដានជើងគោដែលកំពុងអូសទៅ ។

**មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា**
**មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា**
**តតោ នំ សុខមន្វេតិ ឆាយាវ អនុបាយិនី ។**

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តជ្រះថ្លាហើយ ពោលក្តី ធ្វើក្តី (នូវសុចរិត) ព្រោះសុចរិតទាំងនោះ សុខរមែងជាប់តាមបុគ្គលនោះទៅ ដូចស្រមោលអន្ទោលតាមប្រាណ ។ (បិដកភាគ ៥២ ទំព័រ ២១)

មានសេចក្តីថា ការងារផ្សេងៗ របស់សត្វទាំងឡាយ មិនថាការធ្វើបាប ធ្វើបុណ្យយ៉ាងណាក៏ដោយ សុទ្ធតែសម្រេចបានដោយចិត្តទាំងអស់ បើមិនមានចិត្តហើយក៏មិនអាចធ្វើកម្មអ្វីបានឡើយ ចិត្តទើបមានអំណាចឲ្យសម្រេចការងាររបស់សត្វទាំងឡាយ ឲ្យវិចិត្តផ្សេងៗ ដូចវចនត្ថៈថា

**ចិត្តីករោតីតិ = ចិត្តំ** ប្រែថា ធម្មជាតិណាធ្វើការប្រព្រឹត្តទៅរបស់សត្វទាំងឡាយឲ្យវិចិត្រ ធម្មជាតិនោះ ឈ្មោះថា **ចិត្ត** ។

ដូច្នោះ ចិត្តទើបមានអំណាចធ្វើឲ្យធម្មជាតិទាំងឡាយ ប្រព្រឹត្តទៅដោយវិចិត្រ ការវិចិត្ររបស់ចិត្តមាន ៦ ប្រការគឺ

**១. វិចិត្តករណា ចិត្តំ** វិចិត្រដោយការធ្វើ បានសេចក្តីថា វត្ថុទាំងឡាយ ដែលប្រាកដនៅក្នុងលោក និងការប្រព្រឹត្តទៅរបស់សព្វសត្វទាំងឡាយនោះ រមែងមានទាំងស្អាត ប្លែក ចម្លែកគួរខ្លាច និងគួរតក់ស្លុតនោះសម្រេចបានដោយចិត្ត ។

**២. អត្តនោ ចិត្តតាយ** វិចិត្រដោយខ្លួនឯង បានដល់ សភាពរបស់ចិត្តនោះឯង មានការប្រព្រឹត្តទៅគួរឲ្យអស្ចារ្យដោយប្រការផ្សេងៗ មានទាំងចិត្តដែលជា **កុសល អកុសល វិបាក អភិញ្ញា** និង**កិរិយា** ដូចជាចិត្តដែលមានរាគៈ ចិត្តដែលមានទោសៈ និងចិត្តដែលមាន **សទ្ធា អភិញ្ញា បញ្ញា** ហើយនិងចិត្តស្ងប់ជាដើម ។

**៣. ចិត្តំ កម្មកិលេសេហិ** វិចិត្រដោយការសន្សំកម្មនិងកិលេស បានដល់ កម្ម គឺ ការធ្វើ និងកិលេសជាគ្រឿងធ្វើឲ្យចិត្តសៅហ្មង ដែល

ប្រាកដឡើងដល់សត្វទាំងឡាយ នៅជាប្រចាំនោះ ព្រោះមានការសន្សំទុកក្នុងចិត្តមកហើយពីអតីត កាលបានមកទទួលអារម្មណ៍ថ្មីក្នុងបច្ចុប្បន្ន ក៏សន្សំកម្ម និងកិលេសឲ្យប្រាកដឡើងមកជាថ្មី និងសន្សំទុកតទៅទៀត ។

**៤. ចិត្តំ តាយតិ** វិចិត្រក្នុងការរក្សាវិបាកដែលកម្ម និងកិលេសបានសន្សំទុក បានដល់ កម្មទាំងឡាយដែលជាកុសលកម្មនិងអកុសលកម្ម ដែលចិត្តធ្វើឲ្យកើតឡើង ផលរបស់កម្ម គឺ វិបាក រមែងមិនសាបសូន្យបាត់ទៅណា សូម្បីកម្មនោះតិចតួច ឬបានធ្វើមកហើយយូរប៉ុនណាក្តី ផលនៃកម្ម គឺ វិបាកនោះនឹងត្រូវជាប់តាមទៅរហូតបានទទួលផល ដល់ពេលមានឱកាស ។

**៥. ចិនោតិ អត្តសន្តានំ** វិចិត្រក្នុងការសន្សំសន្តានខ្លួនឯង បានដល់ចិត្តដែលធ្វើឲ្យកើតការធ្វើយ៉ាងណាមួយក្តី កាលបានធ្វើរឿយៗហើយ រមែងជាប់ជានិស្ស័យក្នុងសន្តាន ធ្វើឲ្យកើតភាពជំនាញក្នុងការធ្វើយ៉ាងនោះរឿយៗ ទៅ ទាំងនេះព្រោះកាលចិត្តមួយដួងកើតឡើងហើយ រមែងរលត់ទៅ និងធ្វើឲ្យចិត្តដួងថ្មីកើតជាប់បន្តគ្នារឿយៗ ទៅ ចិត្តដួងមុនដែលរលត់ទៅនោះ រមែងប្រគល់កិច្ចការងារឲ្យចិត្តដួងថ្មី ដោយមិនដាច់ក្រសៃ ក្នុងលក្ខណៈដែលជាអនន្តរប្បច្ច័យ និងអាសេវនប្បច្ច័យជាដើម ។

**៦. វិចិត្តារម្មណំ** វិចិត្រដោយអារម្មណ៍ផ្សេងៗ បានដល់ ចិត្តរមែងទទួលអារម្មណ៍ផ្សេងៗ ជានិច្ច គឺម្តងឃើញ ម្តងឮ ដឹងក្លិន ដឹងរស

ជាដើម ផ្លាស់ប្តូរវិលវល់នៅក្នុងអារម្មណ៍ទាំង ៦ មានរូបារម្មណ៍ខ្លះ សទ្ទារម្មណ៍ខ្លះ គន្ធារម្មណ៍ខ្លះជាដើម ។

ដូច្នោះ ទើបឃើញបានថា វត្ថុដែលមានជីវិតនិងមិនមានជីវិត ទាំងអស់ដែលវិចិត្រពិស្តារនោះ ព្រោះអំណាចនៃចិត្ត គឺ មានចិត្តជាអ្នកធ្វើឲ្យវិចិត្រ ក្នុងវត្ថុដែលមិនមានជីវិត បានដល់វត្ថុទាំងឡាយ ដែលប្រាកដនៅក្នុងលោក និងក្នុងវត្ថុដែលមានជីវិត បានដល់សត្វទាំងឡាយ ។

សត្វទាំងឡាយដែលវិចិត្រនោះ ព្រោះកំណើតវិចិត្រ កំណើតវិចិត្រ ព្រោះការធ្វើ (កុសល អកុសល) វិចិត្រ ការធ្វើវិចិត្រព្រោះតណ្ហា គឺសេចក្តីត្រេកអរជាប់ចិត្តវិចិត្រ តណ្ហាវិចិត្រព្រោះសញ្ញាវិចិត្រ សញ្ញាវិចិត្រព្រោះចិត្តសន្សំវិចិត្រ ដូចបាលីក្នុងបរមត្ថទីបនីដីកាសម្តែងថា

**ចិត្តវិចិត្តតាយ សញ្ញាវិចិត្តតា សញ្ញាវិចិត្តតាយ តណ្ហាវិចិត្តតា តណ្ហាវិចិត្តតាយ កម្មានិ វិចិត្តានិ កម្មវិចិត្តតា យោនិយោ វិចិត្តតា យោនិវិចិត្តតាយ តេសំ តិរច្ឆានគតានំ វិចិត្តតា វេទិតព្វា ។**

សញ្ញាវិចិត្រព្រោះការវិចិត្រនៃចិត្ត តណ្ហាវិចិត្រព្រោះការវិចិត្រនៃសញ្ញា កម្មវិចិត្រព្រោះការវិចិត្រនៃតណ្ហា កំណើតវិចិត្រព្រោះការវិចិត្រនៃកម្ម គប្បីជ្រាបការវិចិត្រនៃសត្វតិរច្ឆានទាំងនោះ ព្រោះការវិចិត្រនៃកំណើត ។

រួមសេចក្តីហើយ ចិត្តធ្វើឲ្យវិចិត្រទាំងខាងក្នុង និងខាងក្រៅសន្តានរបស់ខ្លួន គឺ ធ្វើឲ្យសត្វទាំងឡាយវិចិត្រ និងធ្វើឲ្យវត្ថុខាងក្រៅវិចិត្រ ។

# ចំនួនចិត្ត

កាលពោលតាមសភាវលក្ខណៈរបស់ចិត្តហើយ ចិត្តមានចំនួនត្រឹមតែមួយប៉ុណ្ណោះ ព្រោះចិត្តជាធម្មជាតិដែលដឹងអារម្មណ៍ ខណៈណាចិត្តកើតឡើង ខណៈនោះការដឹងអារម្មណ៍ក៏កើតឡើង នឹងហាមការដឹងអារម្មណ៍មិនឲ្យកើតឡើងមិនបាន ។ សភាវលក្ខណៈរបស់ចិត្តកាលពោលដោយទូទៅ មានការដឹងអារម្មណ៍តែម្យ៉ាង កាលរាប់ចំនួនដោយសភាវលក្ខណៈហើយ ទើបមានត្រឹមតែមួយ តែនឹងពោលដល់លក្ខណៈដឹងអារម្មណ៍ពិសេសរបស់ចិត្តហើយ ចិត្តមានអំណាចក្នុងការដឹងអារម្មណ៍មិនដូចគ្នា ដោយអំណាចការតាក់តែងរបស់ចេតសិកដែលកើតឡើងព្រមជាមួយចិត្ត រលត់ព្រមជាមួយចិត្ត មានទីអាស្រ័យនិងមានអារម្មណ៍តែមួយជាមួយគ្នានឹងចិត្ត ទើបអាចធ្វើឲ្យចិត្តមានអំណាចក្នុងការដឹងអារម្មណ៍ពិសេសផ្សេងគ្នា ដូចជាដឹងថាអ្វីជាបុណ្យ ជាបាប ដឹងក្នុងការស្ងប់រម្ងាប់ចាកកាម គឺ ដឹងក្នុងរូបជ្ឈានអរូបជ្ឈាន និងដឹងនិព្វាន ព្រោះដូច្នោះ កាលបើសិក្សាដល់សេចក្តីពិស្តាររបស់ចិត្តហើយ ត្រូវសិក្សាប្រភេទផ្សេងៗ របស់ចិត្តដែលទទួលអារម្មណ៍ផ្សេងៗ ទាំងនេះតទៅ ដែលចែកចិត្តទាំងអស់បានដោយសង្ខេបមាន ៨៩ ដួង និងដោយពិស្តារ ១២១ ដួង ។

# ចែកប្រភេទចិត្តដោយន័យផ្សេងៗ

ចិត្តចំនួន ៨៩ ដួង ឬ ១២១ ដួងនោះ ចែកដោយន័យផ្សេងៗ បាន ៩ ន័យ គឺ

**១. ជាតិភេទន័យ** គឺ ការចែកប្រភេទរបស់ចិត្តដោយជាតិ មាន ៤ ជាតិ បានដល់ **អកុសលជាតិ កុសលជាតិ វិបាកជាតិ និងកិរិយាជាតិ ។**

**២. ភូមិភេទន័យ** គឺ ការចែកប្រភេទរបស់ចិត្តដោយភូមិ មាន ៤ ភូមិ បានដល់ **កាមភូមិ រូបភូមិ អរូបភូមិ** និង**លោកុត្តរភូមិ** ។

**៣. សោភណភេទន័យ** គឺ ការចែកប្រភេទរបស់ចិត្តដែលស្អាតល្អមួយប្រភេទ ហៅថា **សោភណចិត្ត** និងប្រភេទចិត្តដ៏សេសក្រៅពីនោះហៅថា **អសោភណចិត្ត ។**

**៤. លោកភេទន័យ** គឺ ការចែកប្រភេទរបស់ចិត្តដែលនៅក្នុងលោកទាំង ៣ មាន **កាមលោក រូបលោក** និង**អរូបលោក** ហៅថា **លោកិយចិត្ត** ចិត្តដែលផុតពីការប្រព្រឹត្តទៅក្នុងលោកទាំង ៣ ហៅថា **លោកុត្តរចិត្ត** ។

**៥. ហេតុភេទន័យ** គឺ ការចែកប្រភេទរបស់ចិត្តដែលប្រកបដោយ **ហេតុ** ហៅថា **សហេតុកចិត្ត** និងមិនប្រកបដោយ **ហេតុ** ហៅថា **អហេតុកចិត្ត** ។

**៦. ឈានភេទន័យ** គឺ ការចែកប្រភេទរបស់ចិត្តដែលអាចធ្វើឈាន ហៅថា **ឈានចិត្ត** និងមិនអាចធ្វើឈាន ហៅថា **អឈានចិត្ត ។**

**៧. វេទនាភេទន័យ** គឺ ការចែកប្រភេទរបស់ចិត្តដោយការសោយអារម្មណ៍ បានដល់ ចិត្តដែលកើតព្រមដោយ **សុខវេទនា ទុក្ខវេទនា សោមនស្សវេទនា ទោមនស្សវេទនា** និង**ឧបេក្ខាវេទនា** ។

**៨. សម្បយោគភេទន័យ** គឺ ការចែកប្រភេទរបស់ចិត្តដោយ **សម្បយុត្ត** និង **វិប្បយុត្ត** ។

**៩. សង្ខារភេទន័យ** គឺ ការចែកប្រភេទរបស់ចិត្តដោយសភាពមានកម្លាំងខ្លាំងក្លា ហៅថា **អសង្ខារិក** និងសភាពដែលមានកម្លាំងខ្សោយ ហៅថា **សសង្ខារិក** ។

## អធិប្បាយចិត្ត

ព្រះអនុរុទ្ធាចារ្យ បានសម្តែងចិត្តដោយភូមិភេទន័យមុន ព្រោះសម្តែងអំពីការប្រព្រឹត្តទៅរបស់ចិត្តដែលត្រាច់ទៅក្នុងភូមិផ្សេងៗ មានកាមភូមិជាដើម ដែលយើងទាំងឡាយកំពុងប្រសព្វនេះ រមែងងាយយល់ជាងការសម្តែងចិត្តក្នុងប្រភេទដទៃទៀត ។

## ចែកចិត្តដោយភូមិ

**តត្ថ ចិត្តំ តាវ ចតុព្វិធំ ហោតិ កាមាវចរំ រូបាវចរំ អរូបាវចរំ លោកុត្តរញ្ចេតិ ។**

ចិត្តបរមត្ថដែលសម្តែងដោយភូមិទុកជាលំដាប់ដំបូងនេះមាន ៤ ប្រភេទ គឺ

**កាមាវចរចិត្ត រូបាវចរចិត្ត អរូបាវចរចិត្ត** និង**លោកុត្តរចិត្ត ។**

ក្នុងចំនួនចិត្ត ៨៩ ដួង ឬ ១២១ ដួងនោះ កាលចែកដោយភូមិហើយបាន ៤ ប្រភេទគឺ

**ចិត្ត ៨៩ ដួង ឬ ១២១ ដួង ចែកដោយភូមិ គឺ**

**១. កាមាវចរភូមិមានចិត្ត ៥៤ ដួង**

**២. រូបាវចរភូមិមានចិត្ត ១៥ ដួង**

**៣. អរូបាវចរភូមិមានចិត្ត ១២ ដួង**

**៤. លោកុត្តរភូមិមានចិត្ត ៨ ដួង ឬ ៤០ ដួង ។**

## កាមាវចរចិត្ត ៥៤ ដួង

ពាក្យថា **កាមាវចរចិត្ត** កាលកាត់បទហើយបាន ៣ បទ គឺ **កាម+អវចរ+ចិត្ត = កាមាវចរចិត្ត ។**

**កាម** បានដល់ សេចក្តីត្រេកអរជាប់ចិត្តក្នុងអារម្មណ៍ ៦ មាន រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងរឿងរ៉ាវដែលនឹកគិត ឬបានដល់ វត្ថុណាដែលជាទីពេញចិត្ត វត្ថុនោះក៏បានឈ្មោះថា **កាម** ដូចមាន វចនត្ថៈថា **កាមេតីតិ = កាមោ (វា) កាមីយតីតិ = កាមោ** ប្រែថា ធម្មជាតិណា រមែងមានសេចក្តីត្រូវការកាមារម្មណ៍ ធម្មជាតិនោះ ឈ្មោះថា **កាម** បានដល់ **កិលេសកាម** គឺ **កាមតណ្ហា** ឬធម្មជាតិណា ជាទីប្រាថ្នារបស់ **កាមតណ្ហា** ធម្មជាតិនោះក៏ ឈ្មោះថា **កាម** បានដល់ **វត្ថុកាម** គឺ **កាមចិត្ត ចេតសិក រូប** ដែលជាអារម្មណ៍របស់ **កាមតណ្ហា** ។

**កិលេសកាម** បានដល់ សភាវៈដែលជាអ្នកប្រាថ្នា អ្នកត្រេកអរ ភ្លើតភ្លើនក្នុងលាភ យស សរសើរ សុខ ដែលជាកាមធម៌ ។

**វត្ថុកាម** បានដល់ សភាវធម៌ដែលជាអារម្មណ៍ឲ្យកាមតណ្ហា ចូលទៅចាប់យក បានដល់ កាមារម្មណ៍ គឺ កាមចិត្តជាមួយនឹងចេតសិក ដែលប្រកប និងរូបធម៌ ។

**អវចរ** ប្រែថា ត្រាច់ទៅ ឬដែលអាស្រ័យ ដូច្នោះ កាមាវចរចិត្ត ទើបសំដៅដល់ ចិត្តដែលត្រាច់ទៅ ឬអាស្រ័យនៅក្នុងភូមិដែលជាទី កើតរបស់កិលេសកាម និងវត្ថុកាម ។

រួមសេចក្តីថា **កាមាវចរចិត្ត** ឬហៅសង្ខេបថាកាមចិត្តនោះ មាន ៣ ន័យ គឺ

១. ជាចិត្តដែលទទួលកាមារម្មណ៍ដោយច្រើន ។

២. ជាចិត្តដែលកើតក្នុងកាមភូមិ ១១ ដោយច្រើន ។

៣. ជាចិត្តដែលជាប់នៅក្នុងកាមារម្មណ៍ ។

មានវចនត្ថៈថា **កាមេ អវចរតីតិ = កាមាវចរំ** ប្រែថា ចិត្តទាំងឡាយ ណា ដែលត្រាច់ទៅក្នុងកាមារម្មណ៍ ឬកាមភូមិដោយច្រើន ចិត្តទាំង-ឡាយនោះ ឈ្មោះថា **កាមាវចរ ។**

**កាមាវចរចិត្ត** ឬ **កាមចិត្ត** ដែលមានចំនួន ៥៤ ដួងនោះ ចែក បាន ៣ ប្រភេទគឺ

កាមាវចរចិត្ត ៥៤ { អកុសលចិត្ត ១២ ដួង
អហេតុកចិត្ត ១៨ ដួង
កាមាវចរសោភណចិត្ត ២៤ ដួង }

ក្នុងកាមាវចរចិត្ត ៥៤ ដួងនេះ ព្រះអនុរុទ្ធាចារ្យ បានសម្ដែងអកុសលចិត្តមុន ព្រោះអកុសលចិត្តនេះ កាលកើតឡើងដល់បុគ្គលណា ក៏រមែងឲ្យទោសដល់បុគ្គលនោះ ទើបសមគួរនឹងបានដឹងសភាពរបស់ចិត្ត ដែលនឹងធ្វើឲ្យកើតទោសភ័យដល់ជីវិតជាដើម ។

## អកុសលចិត្ត ១២

**អកុសលចិត្ត** ជាចិត្តដែលមិនល្អមិនស្អាត ជាចិត្តដែលគ្រោតគ្រាត ឬជាចិត្តដែលប្រកបដោយអកុសលចេតសិក ដែលជាទោស មានទោសនិងឲ្យផលជាទុក្ខ ។

## គាថាសង្គហទី ៣

**៣. អដ្ឋធា លោភមូលានិ ទោសមូលានិ ច ទ្វិធា**
**មោហមូលានិ ច ទ្វេតិ ទ្វាទសាកុសលា សិយុំ ។**

ប្រែថា លោភមូលចិត្ត ៨ ដួង ទោសមូលចិត្ត ២ ដួង មោហមូលចិត្ត ២ ដួង សរុប ១២ ដួងនេះជាអកុសលចិត្ត ។

# អធិប្បាយអកុសលចិត្ត

**អកុសលចិត្ត ១២** នេះ ចែកចេញជា ៣ ប្រភេទ គឺ លោភមូលចិត្ត ៨ ដួង ទោសមូលចិត្ត ២ ដួង និងមោហមូលចិត្ត ២ ដួង ។

**លោភមូលចិត្ត** បានសេចក្តីថា ចិត្តដែលកើតឡើងដោយមានអកុសលចេតសិកប្រកប និងមានលោភចេតសិកជាប្រធាន ។

**ទោសមូលចិត្ត** បានសេចក្តីថា ចិត្តដែលកើតឡើងដោយមានអកុសលចេតសិកប្រកប និងមានទោសចេតសិកជាប្រធាន ។

**មោហមូលចិត្ត** បានសេចក្តីថា ចិត្តដែលកើតឡើងដោយមានអកុសលចេតសិកប្រកប និងមានមោហចេតសិកជាប្រធាន ។

## សម្តែងការចែកអកុសលចិត្តជា ៣ ប្រភេទ

អកុសលចិត្ត ១២
- លោភមូលចិត្ត ៨ ដួង
- ទោសមូលចិត្ត ២ ដួង
- មោហមូលចិត្ត ២ ដួង

# អកុសលចិត្ត ៣ ប្រភេទដោយពិស្តារ

- អកុសលចិត្ត (១២)
  - លោភមូល (៨)
    - សោមនស្ស
      - ទិដ្ឋិគតសម្បយុត្ត
        - អសង្ខារិក...១
        - សសង្ខារិក..១
      - ទិដ្ឋិគតវិប្បយុត្ត
        - អសង្ខារិក.....១
        - សសង្ខារិក....១
    - ឧបេក្ខា
      - ទិដ្ឋិគតសម្បយុត្ត
        - អសង្ខារិក......១
        - សសង្ខារិក.....១
      - ទិដ្ឋិគតវិប្បយុត្ត
        - អសង្ខារិក.......១
        - សសង្ខារិក.....១
  - ទោសមូល ទោមនស្ស បដិឃសម្បយុត្ត (២)
    - អសង្ខារិក......១
    - សសង្ខារិក.....១
  - មោហមូលឧបេក្ខា (២)
    - វិចិកិច្ឆាសម្បយុត្ត............................១
    - ឧទ្ធច្ចសម្បយុត្ត...............................១

# លោភមូលចិត្ត ៨

**លោភមូលចិត្ត ៨** ដួងនេះ ជាចិត្តដែលកើតឡើងដោយអាស្រ័យលោភជាហេតុ ពោលគឺ ការត្រេកអរចង់បាន និងជាប់ចិត្តក្នុងអារម្មណ៍ផ្សេងៗ ចិត្តប្រភេទនេះទើបប្រាកដឡើង ។

**លោភមូលចិត្ត**នេះ ជាចិត្តដែលប្រកបជាមួយលោភចេតសិកជាប្រធាន សភាវធម៌ដែលកើតព្រមជាមួយលោភចេតសិកនោះ ទើបត្រូវបណ្ដោយតាមអំណាចរបស់លោភចេតសិក ដែលមានលក្ខណៈពិសេសចំពោះខ្លួនដូច្នេះគឺ (ក្នុងអដ្ឋសាលិនី)

**១. អារម្មណគ្គហណលក្ខណោ** មានការចាប់ប្រកាន់ក្នុងអារម្មណ៍ជាលក្ខណៈ

**២. អភិសង្គរសោ** មានការជាប់ជំពាក់ក្នុងអារម្មណ៍ ជាកិច្ច

**៣. អបរិច្ចាគបច្ចុប្បដ្ឋានោ** មានការមិនលះបង់អារម្មណ៍ ជាផល

**៤. សំយោជនិយធម្មេសុ អស្សាទទស្សនបទដ្ឋានោ** មានការឃើញដោយសេចក្ដីត្រេកអរ ពេញចិត្តក្នុងធម៌ដែលជាអារម្មណ៍របស់សំយោជនៈ ជាហេតុជិត ។

**លោភមូលចិត្ត** មានចំនួន ៨ ដួង ការដែលចែកចិត្តប្រភេទនេះជា ៨ ដួងនោះ ព្រោះលោភចិត្តមួយដួងៗ រមែងប្រកបដោយធម៌ ៣ ប្រការ គឺ ប្រកបដោយវេទនា (ការសោយអារម្មណ៍) ទិដ្ឋិ (សេចក្ដីឃើញខុស)

និងសង្ខារ (មានការបបួលដឹកនាំ ឬមិនមានការបបួលដឹកនាំ) ។

**លោភចិត្ត** មានចំនួន ៨ ដួងនេះ មានឈ្មោះនិងសេចក្តីដូច្នេះ គឺ

**១. សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ ។**

ចិត្តដែលកើតឡើងព្រមដោយសោមនស្ស ប្រកបដោយសេចក្តីឃើញខុស មិនមានការបបួលដឹកនាំ ។

**២. សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារិកំ ។**

ចិត្តដែលកើតឡើងព្រមដោយសោមនស្ស ប្រកបដោយសេចក្តីឃើញខុស មានការបបួលដឹកនាំ ។

**៣. សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកំ ។**

ចិត្តដែលកើតឡើងព្រមដោយសោមនស្ស មិនប្រកបដោយសេចក្តីឃើញខុស មិនមានការបបួលដឹកនាំ ។

**៤. សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ សសង្ខារិកំ ។**

ចិត្តដែលកើតឡើងព្រមដោយសោមនស្ស មិនប្រកបដោយសេចក្តីឃើញខុស មានការបបួលដឹកនាំ ។

**៥. ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ ។**

ចិត្តដែលកើតឡើងព្រមដោយឧបេក្ខា ប្រកបដោយសេចក្តីឃើញខុស មិនមានការបបួលដឹកនាំ ។

**៦. ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារិកំ ។**

ចិត្តដែលកើតឡើងព្រមដោយឧបេក្ខា ប្រកបដោយសេចក្តីឃើញខុស មានការបបួលដឹកនាំ ។

**៧. ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកំ ។**

ចិត្តដែលកើតឡើងព្រមដោយឧបេក្ខា មិនប្រកបដោយសេចក្តីឃើញខុស មិនមានការបបួលដឹកនាំ ។

**៨. ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំ សសង្ខារិកំ ។**

ចិត្តដែលកើតឡើងព្រមដោយឧបេក្ខា មិនប្រកបដោយសេចក្តីឃើញខុស មានការបបួលដឹកនាំ ។

## សម្តែងការចែកលោភមូលចិត្ត ៨ ដួង

- លោភមូល
  - សោមនស្សវេទនា
    - ទិដ្ឋិគតសម្បយុត្ត
      - អសង្ខារិក....១
      - សសង្ខារិក...១
    - ទិដ្ឋិគតវិប្បយុត្ត
      - អសង្ខារិក....១
      - សសង្ខារិក...១
  - ឧបេក្ខាវេទនា
    - ទិដ្ឋិគតសម្បយុត្ត
      - អសង្ខារិក.....១
      - សសង្ខារិក....១
    - ទិដ្ឋិគតវិប្បយុត្ត
      - អសង្ខារិក.....១
      - សសង្ខារិក....១

៨ ដួង

**ចំណុចសម្គាល់** ក្នុងលោភមូលចិត្ត ៨ ដួងនេះ សម្តែងសភាវធម៌ដែលប្រាកដ ៣ ប្រការគឺ

១. **សភាវ** ដែលដឹងក្នុងការសោយអារម្មណ៍ គឺ

**សោមនស្សសហគតំ** និង **ឧបេក្ខាសហគតំ ។**

**សោមនស្សសហគតំ** ប្រែថា កើតព្រមដោយការត្រេកអរខ្លាំង មានបីតិ ឆ្អែតចិត្ត ។

**ឧបេក្ខាសហគតំ** ប្រែថា កើតព្រមដោយសេចក្តីត្រេកអរត្រឹមតែបន្តិចបន្តួច ។

២. **សម្តែងសភាវៈរបស់ចិត្តខណៈខ្លះ** ប្រកបដោយសេចក្តីឃើញខុស ឬខណៈខ្លះក៏មិនបានប្រកបដោយសេចក្តីឃើញខុស គឺ

**ទិដ្ឋិគតសម្បយុត្តំ** និង **ទិដ្ឋិគតវិប្បយុត្តំ** ។

**ទិដ្ឋិ** តាមព្យញ្ជនៈ ប្រែថា ការយល់ឃើញ តែបើប្រែដោយអត្ថ គឺសេចក្តីនៃធម៌ហើយ **ទិដ្ឋិ** ក្នុងទីនេះ សំដៅដល់ ទិដ្ឋិចេតសិកដែលប្រកបនៅក្នុងលោភមូលចិត្ត ដែលជាអកុសលចិត្ត ដូច្នោះទិដ្ឋិទើបមានការប្រព្រឹត្តទៅក្នុងផ្លូវមិនល្អ គឺ សំដៅយក **មិច្ឆាទិដ្ឋិ** ដែលនាំឲ្យមាន **មិច្ឆាទិដ្ឋិ** ក្នុងមនោទុច្ចរិត **(និយតមិច្ឆាទិដ្ឋិ) ។**

**ទិដ្ឋិគតសម្បយុត្តំ** មានសេចក្តីថា ប្រកបដោយសេចក្តីឃើញខុស ។

**ទិដ្ឋិគតវិប្បយុត្តំ** មានសេចក្តីថា មិនប្រកបដោយសេចក្តីឃើញខុស ។ ចិត្តដែលមិនប្រកបដោយសេចក្តីឃើញខុសនេះ មិនមែនបានន័យថា ជាចិត្តដែលមានសេចក្តីឃើញត្រូវទេ ត្រឹមតែសំដៅដល់ចិត្តដែលកើតឡើង ដោយមិនទាក់ទងជាមួយការយល់ឃើញខុសប៉ុណ្ណោះ ។

**៣. សម្ដែងសភាវៈរបស់ចិត្តដែលកើតឡើង** ដោយកម្លាំងខ្លាំងក្លា និងកម្លាំងខ្សោយត្រូវមានការបបួលដឹកនាំគឺ

**អសង្ខារិកំ** និង **សសង្ខារិកំ** ។

**អសង្ខារិកំ** ប្រែថា ចិត្តកើតឡើងដោយមិនបាច់អាស្រ័យការដឹកនាំអំពីអ្នកណាមួយជាបុព្វបយោគ គឺប្រារព្ធឡើងមុន ។

**សសង្ខារិកំ** ប្រែថា ចិត្តកើតឡើងដោយអាស្រ័យមានការដឹកនាំឬប្រារព្ធតាមអ្នកដទៃ ។

ការដឹកនាំដែលហៅថា **សសង្ខារិកំ** នោះ គឺសង្ខារដែលប្រែថាតាក់តែងនោះឯង ។

## ការតាក់តែងឬដឹកនាំមាន ៣ យ៉ាង គឺ

**១. កាយបយោគ** គឺ ការបបួលដឹកនាំដោយអាស្រ័យកិរិយាអាការតាមផ្លូវកាយ ដូចជាដឹកដៃ មិចភ្នែក ងក់ក្បាល ជាដើម ។

**២. វចីបយោគ** គឺ ការបបួលដឹកនាំដោយវាចា ដូចជានិយាយបបួល និយាយមួលបង្កាច់ មើលងាយ ញុះញង់ សរសើរ ស៊កសៀតឲ្យកើតឧស្សាហៈ ជាដើម ។

**៣. មនោបយោគ** គឺ ការបបួលខ្លួនឯង ដោយអាស្រ័យជំរុញចិត្តឲ្យគិតដល់រឿងរ៉ាវដែលនឹងធ្វើឲ្យកើតសេចក្ដីត្រេកអរពេញចិត្តជាដើមដែលប្រាកដច្បាស់ក្នុងការចម្រើន **សមថភាវនា** ឬ **វិបស្សនាភាវនា** ត្រូវអាស្រ័យមនោបយោគយ៉ាងពិតប្រាកដ ។

ការដឹកនាំដូចពោលហើយ បើជាការដឹកនាំរបស់អ្នកដទៃក៏មានត្រឹមតែពីរយ៉ាង គឺ **កាយបយោគ** និង **វចីបយោគ** តែបើជាខ្លួនឯងដឹកនាំខ្លួនឯងហើយ ក៏រមែងធ្វើបានទាំង ៣ យ៉ាង គឺ **កាយបយោគ វចីបយោគ** និង **មនោបយោគ** ។

## ការចែកលោភមូលចិត្ត ៨ ដួង ដែលកើតព្រមជាមួយនឹង សភាវធម៌ ៣ ប្រការ

**១. លោភមូលចិត្ត ៨ ដួង** ដោយការកើតព្រមជាមួយនឹង **វេទនា** គឺ **សោមនស្សសហគត ៤ ដួង ឧបេក្ខាសហគត ៤ ដួង ។**

**២. លោភមូលចិត្ត ៨ ដួង** ដោយការប្រកប និងមិនប្រកបជាមួយការយល់ឃើញខុស គឺ **ទិដ្ឋិគតសម្បយុត្ត ៤ ដួង ទិដ្ឋិគតវិប្បយុត្ត ៤ ដួង ។**

**៣. លោភមូលចិត្ត ៨** ដោយការតាក់តែង គឺ **អសង្ខារិក ៤ ដួង សសង្ខារិក ៤ ដួង ។**

## ហេតុនាំឲ្យកើតលោភមូលចិត្ត ៨ ដួង មាន ៤ ប្រការ

**១. លោភបរិវារកម្មបដិសន្ធិកតា** ភាពជាអ្នកបដិសន្ធិដោយកម្មដែលមានលោភជាបរិវារ ។

**២. លោភឧស្សន្នភវតោចវនតា** ភាពជាអ្នកចុតិចាកភពដែលមានលោភច្រើន ។

**៣. ឥដ្ឋារម្មណសមាយោគោ** បានប្រសព្វជាមួយនឹងអារម្មណ៍ដែល

ល្អ ។

**៤. អសុប្បាទទស្សនំ** បានឃើញវត្ថុដែលជាទីពេញចិត្ត ។

## ហេតុនាំឲ្យកើតលោភសោមនស្ស មាន ៤ ប្រការ

**១. សោមនស្សបដិសន្ធិកតា** ភាពជាអ្នកបដិសន្ធិដោយសោមនស្សវេទនា ។

**២. អគម្ភីរបកតិតា** ភាពជាអ្នកមានប្រក្រតីមិនសុខុមគម្ភីរភាព ។

**៣. ឥដ្ឋារម្មណសមាយោគោ** បានប្រសព្វនឹងអារម្មណ៍ដែលល្អ ។

**៤. ព្យសនមុត្តិ** ផុតចាកសេចក្ដីវិនាស ៥ ប្រការ ។

## សេចក្ដីវិនាស ៥ ប្រការ គឺ

**១. ញាតិព្យសន** សេចក្ដីវិនាសនៃញាតិ ។

**២. ភោគព្យសន** សេចក្ដីវិនាសនៃទ្រព្យសម្បត្តិ ។

**៣. រោគព្យសន** សេចក្ដីវិនាសនៃរោគបៀតបៀន ។

**៤. ទិដ្ឋិព្យសន** សេចក្ដីវិនាសព្រោះការយល់ឃើញខុស ។

**៥. សីលព្យសន** សេចក្ដីវិនាសព្រោះប្រព្រឹត្តខុសសីល ។

## ហេតុនាំឲ្យកើតលោភឧបេក្ខា មាន ៥ ប្រការ

**១. ឧបេក្ខាបដិសន្ធិកតា** ភាពជាអ្នកបដិសន្ធិដោយឧបេក្ខាវេទនា ។

**២. គម្ភីរបកតិតា** ភាពជាអ្នកមានប្រក្រតីសុខុមគម្ភីរភាព ។

**៣. មជ្ឈត្តារម្មណសមាយោគោ** បានប្រសព្វនឹងអារម្មណ៍ជាកណ្ដាល ។

**៤. ព្យសនមុត្តិ** ផុតចាកសេចក្ដីវិនាស ៥ ប្រការ ។

**៥. មូគធាតុកតា** ភាពជាអ្នកមានសន្ដានជាមនុស្សមិនសូវនិយាយ ។

## ហេតុនាំឲ្យកើតទិដ្ឋិគតសម្បយុត្ត មាន ៥ ប្រការ

**១. ទិដ្ឋិជ្ឈាសយតា** មានការយល់ឃើញខុសជាអធ្យាស្រ័យ ។

**២. ទិដ្ឋិវិប្បន្នបុគ្គលសេវនតា** សេពគប់ជាមួយនឹងបុគ្គលដែលយល់ឃើញខុស ។

**៣. សទ្ធម្មវិមុខតា** បែរមុខចេញពីព្រះសទ្ធម្ម ។

**៤. មិច្ឆាវិតក្កពហុលតា** ច្រើនទៅដោយមិច្ឆាវិតក្កៈ ។

**៥. អយោនិសោ ឧម្មុជ្ជនំ** មិនពិចារណាដោយឧបាយត្រូវទំនង ។

## ហេតុនាំឲ្យកើតទិដ្ឋិគតវិប្បយុត្ត មាន ៥ ប្រការ

**១. សស្សតឧច្ឆេទទិដ្ឋិអនជ្ឈាសយតា** មិនមានសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិជាអធ្យាស្រ័យមកពីអតីតជាតិ ។

**២. ទិដ្ឋិវិប្បន្នបុគ្គលអសេវនតា** មិនសេពគប់ជាមួយនឹងបុគ្គលដែលឃើញខុស ។

**៣. សទ្ធម្មសម្មុខតា** បែរមុខរកព្រះសទ្ធម្ម ។

**៤. សម្មាវិតក្កពហុលតា** ច្រើនដោយសម្មាវិតក្កៈ ។

**៥. អយោនិសោ ន ឧម្មុជ្ជនំ** មិនលិចចុះក្នុងការពិចារណាដោយឧបាយមិនត្រូវទំនង ។

## ហេតុនាំឲ្យកើតអកុសលអសង្ខារិក មាន ៦ ប្រការ

**១. អសង្ខារិកកម្មជនិតបដិសន្ធិកតា** ភាពជាអ្នកមានបដិសន្ធិដោយកម្មដែលជាអសង្ខារិក ។

**២. កល្លកាយចិត្តតា** មានកាយនិងចិត្តមាំមួន ។

**៣. សីតុណ្ហាទីនំ ខមនពហុលតា** មានសេចក្តីអត់ធន់ចំពោះត្រជាក់និងក្តៅជាដើម ។

**៤. កត្តព្វកម្មេសុ ទិដ្ឋានិសំសតា** មានការឃើញអានិសង្សក្នុងការងារដែលគប្បីធ្វើ ។

**៥. កម្មេសុ ចិណ្ណវសិតា** មានភាពជំនាញក្នុងការងារទាំងឡាយ ។

**៦. ឧតុភោជនាទិសប្បាយលាភោ** បានទទួលឧតុនិងភោជនជាទីសប្បាយជាដើម ។

## ហេតុនាំឲ្យកើតអកុសលសសង្ខារិក មាន ៦ ប្រការ

**១. សសង្ខារិកកម្មជនិតបដិសន្ធិកតា** ភាពជាអ្នកបដិសន្ធិដោយកម្មដែលជាសសង្ខារិក ។

**២. អកល្លកាយចិត្តតា** មានកាយនិងចិត្តមិនមាំមួន ។

**៣. សីតុណ្ហាទីនំ អខមនពហុលតា** មិនមានសេចក្ដីអត់ធន់ ចំពោះក្ដៅនិងត្រជាក់ជាដើម ។

**៤. អកត្តព្វកម្មេសុ ទិដ្ឋានិសំសតា** មិនមានការឃើញអានិសង្ស ក្នុងការងារដែលធ្វើ ។

**៥. កម្មេសុ អចិណ្ណវសិតា** មិនមានជំនាញក្នុងការងារទាំងឡាយ ។

**៦. ឧតុភោជនាទិអសប្បាយលាភោ** មិនបានទទួលឧតុនិងភោជនជាទីសប្បាយជាដើម ។

## ផលដែលកើតអំពីលោភមូលចិត្ត

**លោភមូលចិត្ត** ជាចិត្តដែលសាងហេតុលោភ គឺសេចក្ដីចង់បាន ឬសេចក្ដីប្រាថ្នាក្នុងអារម្មណ៍ ដែលគួរត្រេកអរពេញចិត្ត កាលសាងហេតុឡើងហើយ ផលក៏រមែងប្រាកដឡើងព្រោះអាស្រ័យហេតុនោះ ជាធម្មតា ផលដែលកើតឡើងព្រោះអាស្រ័យលោភហេតុ ឬផលដែលកើតពីលោភមូលចិត្តនោះ លោកសម្ដែងថា

សម័យណាមនុស្សមានសន្ដានច្រើនទៅដោយសេចក្ដីលោភ សម័យនោះរមែងកើតទុព្ភិក្ខន្តរាយ គឺអន្តរាយកើតអំពីការខ្វះខាត បាយរកបានដោយលំបាក ជាហេតុឲ្យកើតការស្រេកឃ្លានចូលមកគ្របសង្កត់ រហូតដល់ស្លាប់យ៉ាងច្រើន សេចក្ដីទុក្ខផ្សេងៗ នឹងប្រាកដដល់មហាជនយ៉ាងច្រើនប្រមាណមិនបាន នេះជាផលបច្ចុប្បន្ន ដែលកើតពីអំណាចរបស់លោភមូលចិត្ត តែសម្រាប់ផលដែលកើតពីលោភក្នុងអនាគតនោះ មាន

សម្ដែងក្នុងអដ្ឋសាលិនីអដ្ឋកថា ថា

**យេភុយ្យេន ហិ សត្តា តណ្ហាយ បេត្តិវិសយំ ឧបបជ្ជន្តិ ។**

សត្វទាំងឡាយដោយច្រើន រមែងទៅកើតជាប្រេតខ្លះ ជាអសុរកាយខ្លះ តាមអំណាចនៃលោភៈ ដែលមានសេចក្ដីចង់បានជាមូល ។

ម្យ៉ាងទៀត លោភមូលចិត្តនេះ ជាហេតុឲ្យកើតទុក្ខ សំដៅដល់ទុក្ខសច្ចៈកើតឡើងបានព្រោះអាស្រ័យសមុទយសច្ចៈជាហេតុ គឺ

**លោភ** ក្នុងអតីតជាតិបានធ្វើកម្មក្នុងអតីត ជាហេតុ ។

**ជាតិទុក្ខ ជរាទុក្ខ មរណទុក្ខ** ទើបកើតឡើងជាផល ។

**លោភៈក្នុងបច្ចុប្បន្ន** គឺ សេចក្ដីប្រាថ្នា សេចក្ដីត្រូវការ សេចក្ដីចង់បាន កាមគុណារម្មណ៍ជាហេតុ ។

**សោក បរិទេវ ទុក្ខ ទោមនស្ស ឧបាយាស** ទើបប្រាកដឡើងជាផល។

## ទោសមូលចិត្ត ២ ដួង

**ទោសមូលចិត្ត** ជាចិត្តដែលកើតឡើងព្រោះមានទោសៈជាហេតុការមិនប្រាថ្នាអារម្មណ៍នោះៗ រមែងមានទោសៈជាអ្នកនាំ ឬជាហេតុ

**ទោស** ជាចេតសិកធម៌ដែលតាក់តែងចិត្ត ឲ្យកើតសេចក្ដីក្រោធ សេចក្ដីស្អប់ ខ្ញូចចិត្ត សេចក្ដីទុក្ខព្រួយ និងសេចក្ដីភ័យខ្លាច ។

ចិត្តដែលត្រូវទោសចេតសិកគ្របសង្កត់នោះ រមែងជាចិត្តប្រទូសរ៉ាយអារម្មណ៍ ព្រោះធម្មជាតិរបស់ទោសចេតសិកមានលក្ខណៈ ៤ ប្រការ គឺ (ក្នុងអដ្ឋសាលិនី)

**១. ចណ្ឌិក្កលក្ខណោ** មានការកាចសាហាវ ជាលក្ខណៈ។

**២. អត្តនោ និស្សយទហនរសោ** មានការដុតទីអាស្រ័យរបស់ខ្លួន ជាកិច្ច ។

**៣. ទុស្សនបច្ចុប្បដ្ឋានោ** មានការប្រទូសរ៉ាយអារម្មណ៍ជា អាការប្រាកដ ។

**៤. អាឃាតវត្ថុបទដ្ឋានោ** មានអាឃាតវត្ថុជាហេតុជិត ។

ដូច្នោះ ទោសមូលចិត្ត ទើបមានសេចក្តីថា ចិត្តដែលកើតឡើង ដោយមានទោសចេតសិកជាមូល ជាប្រធាន ។

## ទោសមូលចិត្តមាន ២ ដួង

**១. ទោមនស្សសហគតំ បដិឃសម្បយុត្តំ អសង្ខារិកំ ។**

ទោសមូលចិត្តកើតឡើងព្រមដោយទោមនស្សវេទនា ប្រកប ដោយបដិឃៈ គឺ ការថ្នាំថ្នាក់មិនមានការបបួលដឹកនាំ ។

**២. ទោមនស្សសហគតំ បដិឃសម្បយុត្តំ សសង្ខារិកំ ។**

ទោសមូលចិត្តកើតឡើងព្រមដោយទោមនស្សវេទនា ប្រកប ដោយបដិឃៈ គឺ ការថ្នាំថ្នាក់មានការបបួលដឹកនាំ ។

**ទោមនស្សសហគតំ បដិឃសម្បយុត្តំ អសង្ខារិកំ ១ សសង្ខារិកំ ១ ។**

**ទោសមូលចិត្ត ២** ដួងនេះ មានសភាវធម៌ ៣ ប្រការ គឺ

**១. ទោមនស្សសហគតំ** កើតព្រមដោយសេចក្តីខូចចិត្ត **ទុមន** ប្រែតាមសព្ទថា ចិត្តអាក្រក់ ប្រែតាមអត្ថថា មានចិត្តអាក្រក់ គឺ សភាវៈ

នៃចិត្តអាក្រក់ ក្តៅក្រហាយ សៅហ្មង បុគ្គលដែលមានចិត្តអាក្រក់នោះ ឈ្មោះថា **ទោមនស្ស** ដែលមានអង្គធម៌ បានដល់ **វេទនាចេតសិក** (ធម្មជាតិដែលសោយអារម្មណ៍) ។ ជាវេទនាមួយប្រភេទក្នុងវេទនា ៥ យ៉ាង គឺ **ទុក្ខវេទនា សុខវេទនា សោមនស្សវេទនា ទោមនស្សវេទនា** និង **ឧបេក្ខាវេទនា** ។

**ទោមនស្សវេទនា** នេះកើតព្រមជាមួយទោសមូលចិត្ត ២ ដួង ប៉ុណ្ណោះ នឹងកើតព្រមជាមួយចិត្តដទៃមិនបាន ព្រោះដូច្នោះ កាលទោស-មូលចិត្តកើតឡើងខណៈណា ខណៈនោះទោមនស្សវេទនា ក៏កើតជានិច្ច ទើបហៅថា **ទោមនស្សសហគតំ ។**

**២. បដិឃសម្បយុត្តំ** ប្រកបដោយសេចក្តីក្រោធ **បដិឃ** ប្រែថា សេចក្តីក្រោធ សេចក្តីចង្អៀតចង្អល់ ឬការប៉ះទង្គិចជាដើម ។ កាលប្រែដោយអត្ថហើយ បានដល់ ការប៉ះទង្គិចក្នុងអារម្មណ៍ គឺ មានសភាពប្រទូសរ៉ាយ ទម្លាយអារម្មណ៍ដែលប៉ះខ្ទប់ឲ្យវិនាសទៅ អង្គធម៌បានដល់ **ទោសចេតសិក** (ធម្មជាតិដែលប្រទូសរ៉ាយអារម្មណ៍) **បដិឃ** ឬ **ទោស** នេះ ជាសភាវៈដែលត្រូវប្រកបជាមួយនឹងទោមនស្សវេទនា និងកើតព្រមជាមួយវេទនាដទៃៗ មិនបាន ។

ពាក្យដែលពោលមកនេះបញ្ជាក់ឲ្យឃើញថា **ទោមនស្ស** និង **បដិឃ** មានសភាពផ្សេងគ្នា គឺ

**ទោមនស្ស** ជា **វេទនាចេតសិក** និងជាធម៌ម្យ៉ាង ដែលរាប់ចូលក្នុងវេទនាខន្ធ មានការសោយអនិដ្ឋារម្មណ៍ (ជាអារម្មណ៍មិនល្អ) ជាលក្ខណៈ។

ចំណែក **បដិឃ** គឺ ជាទោសចេតសិកនិងជាធម៌ម្យ៉ាង ដែលរាប់ចូលក្នុងសង្ខារក្ខន្ធ មានសេចក្ដីប្រទូសរ៉ាយអារម្មណ៍ ជាលក្ខណៈ ។

រួមទាំង ២ ប្រការនេះ សូម្បីផ្សេងគ្នាដោយសភាវលក្ខណៈ តែដោយអំណាចនៃទោសចិត្តុប្បាទហើយ **ទោមនស្សវេទនា** ត្រូវកើតរួមជាមួយ **បដិឃ** ជានិច្ច ។

**៣. អសង្ខារិកំ** ជាអាការដែលបដិឃចិត្តមានកម្លាំងខ្លាំងក្លា កើតឡើងដោយមិនមានអ្នកដឹកនាំ ចំណែក **សសង្ខារិកំ** នោះជា **បដិឃចិត្ត** ដែលកើតឡើងដោយមានអ្នកដឹកនាំឲ្យកើតឡើង ទើបជាចិត្តដែលមានកម្លាំងខ្សោយ ទំនងដូចគ្នាជាមួយនឹង **អសង្ខរិក** និង**សសង្ខារិក** ក្នុងលោភមូលចិត្តនោះឯង ។

**ទោមនស្ស** និង **បដិឃ** នេះ អាស្រ័យការបានប្រសព្វជាមួយអនិដ្ឋារម្មណ៍ និងអាឃាតវត្ថុ ១០ យ៉ាង ជាហេតុជិតឲ្យកើត ។

## អាឃាតវត្ថុ ១០ ប្រការ

១. អាឃាតគេ ដោយគិតថា ធ្លាប់បានធ្វើសេចក្ដីវិនាសដល់យើង ។

២. អាឃាតគេ ដោយគិតថា កំពុងធ្វើសេចក្ដីវិនាសដល់យើង ។

៣. អាឃាតគេ ដោយគិតថា នឹងធ្វើសេចក្ដីវិនាសដល់យើង ។

៤. អាឃាតគេ ដោយគិតថា ធ្លាប់បានធ្វើសេចក្ដីវិនាសដល់បុគ្គលដែលយើងស្រលាញ់ ។

៥. អាឃាតគេ ដោយគិតថា កំពុងធ្វើសេចក្តីវិនាសដល់បុគ្គលដែលយើងស្រលាញ់ ។

៦. អាឃាតគេ ដោយគិតថា នឹងធ្វើសេចក្តីវិនាសដល់បុគ្គលដែលយើងស្រលាញ់ ។

៧. អាឃាតគេ ដោយគិតថា ធ្លាប់បានធ្វើគុណប្រយោជន៍ ដល់បុគ្គលដែលយើងស្អប់ ។

៨. អាឃាតគេ ដោយគិតថា កំពុងធ្វើគុណប្រយោជន៍ ដល់បុគ្គលដែលយើងស្អប់ ។

៩. អាឃាតគេ ដោយគិតថា នឹងធ្វើគុណប្រយោជន៍ ដល់បុគ្គលដែលយើងស្អប់ ។

១០. អាឃាត ក្នុងឋានៈដែលមិនគួរ ដូចជាខណៈដែលដើរជំពប់ជើង ឬក៏ជាន់បន្លាជាដើម ។

តែបើពោលរួមដល់អតីតហេតុ គឺ ហេតុឆ្ងាយ ហេតុឲ្យកើតទោសៈឬបដិឃៈ មាន ៥ ប្រការ គឺ

**១. ទោសជ្ឈាសយតា** មានអធ្យាស្រ័យជាអ្នកក្រោធ ។

**២. អគម្ភីរប្បកតិតា** មានប្រក្រតីគិតមិនសុខុម ។

**៣. អប្បស្សុតតា** មានការស្តាប់តិច ។

**៤. អនិដ្ឋារម្មណសមាយោគោ** ប្រកបអារម្មណ៍ដែលមិនល្អ ។

**៥. អាឃាតវត្ថុសមាយោគោ** ប្រកបជាមួយនឹងអាឃាតវត្ថុ ១០ ។

**ចំណុចសម្គាល់** ក្នុងទោសមូលចិត្តនេះ ជាចិត្តដែលមានតែបដិឃ-សម្បយុត្ត គឺ ប្រកបដោយសេចក្តីក្រោធ តែមិនមានសេចក្តីយល់ឃើញខុសប្រកប គឺទិដ្ឋិគតសម្បយុត្ត ព្រោះទិដ្ឋិការយល់ឃើញខុសនោះរមែងទទួលសភាវអារម្មណ៍ដែលគួរត្រេកអរពេញចិត្ត តែទោសចិត្តនោះមានការទទួលសភាវអារម្មណ៍ដែលមិនពេញចិត្ត ដូច្នោះសេចក្តីត្រេកអរពេញចិត្តនឹងកើតព្រមជាមួយសេចក្តីមិនពេញចិត្ត ក្នុងខណៈជាមួយគ្នាមិនបាន ដោយហេតុនេះ ទោសចិត្តទើបមិនមានទិដ្ឋិ គឺ សេចក្តីយល់ឃើញខុសប្រកបជាមួយ ។

## ផលដែលកើតពីទោសមូលចិត្ត

**ទោសមូលចិត្ត** នេះជាចិត្តដែលប្រកបដោយទោសៈ មិនពេញចិត្តក្នុងអារម្មណ៍ ដែលកំពុងប្រសព្វ ដូច្នោះកាលទោសប្រាកដដល់បុគ្គលណាហើយ បុគ្គលនោះរមែងសៅហ្មងក្តៅក្រហាយ ដើម្បីទម្លាយអារម្មណ៍ដែលមិនពេញចិត្តនោះឲ្យវិនាសបាត់ទៅ សម្តែងអាការមុខក្រញូវមិនរីករាយ ដែលជាហេតុឲ្យអ្នកដទៃឃើញក្នុងខណៈនោះដឹងថាកំពុងក្រោធ និងចិត្តក៏សៅហ្មងក្តៅក្រហាយផងដែរ ។

សម័យណាមនុស្សមានសន្តានច្រើនទៅដោយទោសៈ សម័យនោះរមែងកើតសត្ថន្តរាយ គឺ អន្តរាយដែលកើតពីសស្ត្រាវុធផ្សេងៗ ជាហេតុឲ្យធ្វើសង្គ្រាមសម្លាប់គ្នា សេចក្តីភ័យផ្សេងៗ នឹងប្រាកដដល់មនុស្សលោកគួរឲ្យខ្លាច ។ សម្រាប់ផលនៃទោសៈក្នុងអនាគត គឺ ក្នុង

ភពខាងមុខ ជាតិមុខ រមែងបន្សាត់ទៅឲ្យកើតជាសត្វនរកក្នុងនិរយភូមិ ដូចអដ្ឋសាលិនីអដ្ឋកថាដែលសម្ដែងថា

**ទោសេន ហិ ចណ្ឌជាតិតាយ ទោសសទិសំ និរយំ ឧបបជ្ជន្តិ ។**

សត្វទាំងឡាយរមែងទៅកើតក្នុងនរក ភាគច្រើនដោយអំណាចនៃទោសៈដែលជាហេតុធ្វើឲ្យសត្វក្ដៅក្រហាយ ដូចគ្នានឹងសភាវៈរបស់ទោសៈ ដែលធ្វើឲ្យខ្លួនឯងក្ដៅក្រហាយជារឿយៗ ។ ដូច្នោះការសម្ដែងទោសមូលចិត្តបន្ទាប់អំពីលោភមូលចិត្ត ព្រោះទោសៈរមែងកើតឡើងដោយអាស្រ័យកាមរាគៈ (លោភ) បើបុគ្គលលះកាមរាគៈបានហើយ ទោសៈក៏កើតឡើងមិនបាន ដូចជាព្រះអនាគាមីទាំងឡាយ លោកលះកាមរាគៈបានហើយ ទោសៈក៏ត្រូវលះបានផងដែរ ។

## មោហមូលចិត្ត ២ ដួង

**មោហមូលចិត្ត** ជាចិត្តដែលវង្វេង គឺមិនដឹងនាមរូបតាមសេចក្ដីពិត ឬចិត្តដែលមិនអាចដឹងហេតុផលតាមសេចក្ដីពិតរបស់សភាវធម៌បាន ពោលគឺ ជាចិត្តដែលកើតឡើងដោយមានមោហចេតសិកជាប្រធាន ឬជាមូល ទើបហៅចិត្តនេះថា **មោហមូលចិត្ត** ។

ចិត្តដែលត្រូវមោហចេតសិកគ្របសង្កត់នោះ រមែងវង្វេងមិនដឹងសភាវធម៌តាមសេចក្ដីពិត ព្រោះធម្មជាតិរបស់មោហចេតសិកនោះ មានលក្ខណៈពិសេស ៤ យ៉ាងគឺ (ក្នុងអដ្ឋសាលិនី)

**១. អញ្ញាណលក្ខណោ** មានការមិនដឹងក្នុងអរិយសច្ច ជាលក្ខណៈ ។

**២. អារម្មណសភាវច្ឆាទនរសោ** មានការបិទបាំងសភាវៈនៃអារម្មណ៍ ជាកិច្ច ។

**៣. អន្ធការបច្ចុប្បដ្ឋានោ** មានការងងឹត ជាផល ។

**៤. អយោនិសោមនសិការបទដ្ឋានោ** មានការធ្វើទុកក្នុងចិត្ត ដោយឧបាយមិនត្រូវទំនង ជាហេតុជិត ។

## មោហមូលចិត្ត មាន ២ ដួង

**១. ឧបេក្ខាសហគតំ វិចិកិច្ឆាសម្បយុត្តំ ។**

ចិត្តដែលកើតឡើងព្រមជាមួយនឹងឧបេក្ខា ប្រកបដោយការសង្ស័យ ។

**២. ឧបេក្ខាសហគតំ ឧទ្ធច្ចសម្បយុត្តំ ។**

ចិត្តដែលកើតឡើងព្រមជាមួយនឹងឧបេក្ខា ប្រកបដោយការរាយមាយ ។

**មោហមូលចិត្ត** មួយដួងៗ ប្រកបដោយធម៌ ២ ប្រការ គឺ **ឧបេក្ខា-សហគតំ** កើតព្រមជាមួយនឹងវេទនាម្យ៉ាង និង **វិចិកិច្ឆា** ឬ **ឧទ្ធច្ចសម្បយុត្ត** ប្រកបដោយសេចក្ដីសង្ស័យ ឬការរាយមាយម្យ៉ាង ។

**ឧបេក្ខាសហគតំ** បានសេចក្ដីថា កើតព្រមជាមួយនឹងវេទនា ដែលមានវេទនា ១ គឺ **ឧបេក្ខាវេទនា ។**

តែសភាវៈរបស់ឧបេក្ខាវេទនាក្នុងមោហមូលចិត្តនេះ ផ្សេងគ្នានឹងឧបេក្ខាវេទនាក្នុងលោភមូលចិត្ត ឧបេក្ខាវេទនាក្នុងមោហមូលចិត្តនេះបានដល់ ការដឹងដែលព្រងើយៗ ចំពោះអារម្មណ៍ ដែលប្រាកដនោះ ព្រោះការវង្វេងមិនដឹងគុណតម្លៃរបស់សភាវអារម្មណ៍ ដែលប្រាកដតាមសេចក្ដីពិត ។ ចំណែកឧបេក្ខាវេទនាក្នុងលោភមូលចិត្តនោះ បានដល់សេចក្ដីត្រេកអរត្រឹមតែបន្តិចបន្តួច មិនដល់ថ្នាក់ធ្វើឲ្យកើតសេចក្ដីត្រេកអរខ្លាំងជាសោមនស្សវេទនា ។

**វិចិកិច្ឆាសម្បយុត្តំ** ប្រែថា ប្រកបដោយសេចក្ដីសង្ស័យ សេចក្ដីសង្ស័យ មាន ២ យ៉ាង គឺ

**១. នីវរណវិចិកិច្ឆា** សេចក្ដីសង្ស័យជានីវរណៈដែលរារាំងកុសលកម្ម ។

**២. បដិរូបកវិចិកិច្ឆា** សេចក្ដីសង្ស័យក្នុងឈ្មោះមនុស្ស សត្វ វត្ថុរបស់ដែលនៅមិនទាន់ស្គាល់ ឬសង្ស័យក្នុងចំណោះវិជ្ជាផ្សេងៗ ដែលនៅមិនទាន់យល់ ឬព្រះអរហន្តសង្ស័យក្នុងអាបត្តិ ទាំងនេះមិនចាត់ថាជាវិចិកិច្ឆាក្នុងមោហមូលចិត្តទេ ។

សេចក្ដីសង្ស័យដែលប្រកបជាមួយមោហមូលចិត្ត ដែលជាវិចិកិច្ឆាសម្បយុត្តនោះ សំដៅយក **នីវរណវិចិកិច្ឆា** គឺ សេចក្ដីសង្ស័យដែលប្រព្រឹត្តទៅដើម្បីរារាំងមគ្គ ផល និព្វាន មាន ៨ ប្រការ គឺ

**១. ពុទ្ធេ កង្ខតិ** មានសេចក្ដីសង្ស័យក្នុងព្រះសម្មាសម្ពុទ្ធជាម្ចាស់ បានដល់ សង្ស័យក្នុងព្រះសរីរៈ ដូចជាសង្ស័យថា ព្រះពុទ្ធជាម្ចាស់

មិនមានតួខ្លួនពិតៗ ទេ ប្រហែលជាសន្មតឡើងមកដើម្បីជាឧបាយឲ្យមនុស្សមានភាពសាមគ្គី មិនឈ្លោះវិវាទគ្នា ឬសង្ស័យក្នុងព្រះពុទ្ធគុណ ៩ ប្រការដូចជាសង្ស័យថា ព្រះពុទ្ធជាម្ចាស់នោះជាអ្នកឆ្ងាយចាកកិលេស ដូចព្រះពុទ្ធគុណបទថា "**អរហំ**", ជាអ្នកត្រាស់ដឹងធម៌ដោយខ្លួនឯង "**សម្មាសម្ពុទ្ធោ**", ជាអ្នកដល់ព្រមដោយសេចក្ដីដឹង និងការបដិបត្តិយ៉ាងប្រសើរ "**វិជ្ជាចរណសម្បន្នោ**", ស្ដេចយាងទៅដោយល្អហើយ "**សុគតោ**", ជាអ្នកជ្រាបច្បាស់នូវលោកទាំង ៣ គឺ សត្វលោក ឱកាសលោក សង្ខារ-លោក ក្នុងព្រះគុណបទថា "**លោកវិទូ**", ជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបានយ៉ាងប្រសើរ "**អនុត្តរោ បុរិសទម្មសារថិ**", ជាសាស្ដារបស់មនុស្ស ទេវតា ព្រហ្មទាំងឡាយ "**សត្ថាទេវមនុស្សានំ**", ជាអ្នកដឹងច្បាស់នូវអរិយសច្ចៈដោយត្រឹមត្រូវ ហើយអាចញ៉ាំងសត្វទាំងឡាយឲ្យដឹងតាមផង "**ពុទ្ធោ**", ជាអ្នកមានបុញ្ញាធិការដ៏យ៉ាងអស្ចារ្យក្រៃលែង "**ភគវា**" ។

សេចក្ដីសង្ស័យក្នុងព្រះពុទ្ធគុណផ្សេងៗ ទាំងនេះ ព្រះពុទ្ធគុណផ្សេងៗ ដូចពោលនោះនឹងមានពិត ឬមិនពិត ឬជាពាក្យពោលដើម្បីលើកសរសើរក្នុងឋានៈជាអ្នកវិសេស ។

**២. ធម្មេ កង្ខតិ** សង្ស័យក្នុងព្រះធម៌ថា **ស្វាក្ខាតធម៌** គឺ មគ្គ ៤ ផល ៤ និព្វាន ១ និងព្រះត្រៃបិដកនោះមានពិតឬ ឬសង្ស័យថាព្រះធម្មគុណដែលព្រះមានព្រះភាគត្រាស់ទុកល្អហើយ ដូចបទថា "**ស្វាក្ខាតោ**", ជារបស់ដែលបុគ្គលគប្បីចូលទៅឃើញដោយខ្លួនឯង "**សន្ទិដ្ឋិកោ**", ជារបស់មិនមានកាលវេលា "**អកាលិកោ**", ជារបស់ដែលហៅអ្នកដទៃឲ្យចូល

មកមើលបាន **"ឯហិបស្សិកោ"**, ជារបស់ដែលបុគ្គលគប្បីបង្អោនចូលមកទុកក្នុងចិត្តបាន **"ឱបនយិកោ"**, ជារបស់ដែលវិញ្ញូជនទាំងឡាយគប្បីដឹងដោយចំពោះខ្លួន **"បច្ចត្តំ វេទិតព្វោវិញ្ញូហិ"**, អ្នកសង្ស័យរមែងកើតសេចក្តីសង្ស័យផ្សេងៗ បាន ដូចជាសង្ស័យថា ស្វាក្ខាតធម៌នឹងនាំឲ្យផុតចាកទុក្ខបានពិតឬ ? ។

**៣. សង្ឃេ កង្ខតិ** សង្ស័យក្នុងព្រះសង្ឃថា ព្រះអរិយសង្ឃមានពិតឬ ឬសង្ស័យថា ព្រះសង្ឃសាវ័ករបស់ព្រះមានព្រះភាគជាម្ចាស់ជាអ្នកបដិបត្តិល្អហើយ **"សុបដិបន្នោ"**, ជាអ្នកបដិបត្តិដោយត្រង់ហើយ **"ឧជុបដិបន្នោ"**, ជាអ្នកបដិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វានហើយ **"ញាយបដិបន្នោ"**, ជាអ្នកបដិបត្តិដ៏សមគួរដល់សាមីចិកម្ម **"សាមីចិបដិ-បន្នោ"**, ជាអ្នកគួរទទួលនូវចតុប្បច្ច័យ **"អាហុនេយ្យោ"**, ជាអ្នកគួរទទួលនូវអាគន្តុកទាន **"បាហុនេយ្យោ"**, ជាអ្នកទទួលនូវទាន ដែលបុគ្គលជឿនូវកម្មនិងផលនៃកម្ម **"ទក្ខិណេយ្យោ"**, ជាអ្នកគួរដល់អញ្ជលិកម្ម **"អញ្ជលិ-ករណីយោ"**, ជាបុញ្ញក្ខេត្ត គឺ ជាទីដុះឡើងនៃពូជ គឺ បុណ្យនៃសត្វលោករកខេត្តដទៃក្រៃលែងជាងគ្មាន **"អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស"**, ទាំងនេះមានពិតឬ? ។

**៤. សិក្ខាយ កង្ខតិ** សង្ស័យថា សិក្ខា ៣ គឺ សីល សមាធិ បញ្ញា ដែលជាការបដិបត្តិតាម ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធអង្គនោះ មានផលពិតឬ និងផលានិសង្សនៃការបដិបត្តិក្នុងសិក្ខា ៣ នោះ នឹងការពារអ្នកបដិបត្តិមិនឲ្យធ្លាក់ទៅក្នុងទុគ្គតិភូមិ តែត្រឡប់ជាផលនាំឲ្យប្រព្រឹត្ត

ទៅក្នុងសុគតិភូមិ និងអាចនាំឲ្យចូលដល់ការផុតចាកទុក្ខបានយ៉ាងពិតប្រាកដ គឺ ព្រះនិព្វាន នឹងប្រព្រឹត្តទៅបានដូច្នោះឬ ? ។

**៥. បុព្វន្តេ កង្ខតិ** សង្ស័យក្នុងខន្ធ អាយតនៈ ធាតុ គឺ សភាវៈតួខ្លួន មនុស្ស សត្វ ដែលធ្លាប់ប្រាកដជាអតីតនោះមានពិតឬ គឺ សង្ស័យថា ជាតិមុននោះមានពិតឬទេ? ។

**៦. អបរន្តេ កង្ខតិ** សង្ស័យក្នុងខន្ធ អាយតនៈ ធាតុ គឺ សភាវៈដែលជាតួខ្លួន មនុស្ស សត្វ នឹងប្រាកដថ្មីទៀតក្នុងអនាគតមានពិតឬ គឺសង្ស័យថា ជាតិមុខនឹងមានពិតឬទេ ? ។

**៧. បុព្វន្តាបរន្តេ កង្ខតិ** សង្ស័យក្នុងខន្ធ អាយតនៈ ធាតុ គឺ សភាវៈជាតួខ្លួន មនុស្ស សត្វ ដែលធ្លាប់ប្រាកដហើយក្នុងជាតិមុននិងជាតិមុខព្រមទាំងជាតិនេះ មានពិតឬទេ ? ។

**៨. បដិច្ចសមុប្បាទេ កង្ខតិ** សង្ស័យថាធម៌ គឺ នាមរូប ដែលកើតឡើងនោះ ជាហេតុជាផល ទាក់ទងអាស្រ័យគ្នាកើតឡើងជាប់តគ្នាដោយមិនដាច់ក្រសៃ ជាបច្ចយាការ តាមន័យក្នុងបដិច្ចសមុប្បាទ នឹងប្រព្រឹត្តទៅបាននិងមានពិតឬ វត្ថុដែលកើតឡើងដោយមិនបាច់អាស្រ័យហេតុឲ្យកើត នឹងមិនមានខ្លះទេឬ ? ។

**វិចិកិច្ឆាសម្បយុត្តចិត្តនេះ** សំដៅយកចិត្ត ដែលប្រកបដោយសេចក្ដីសង្ស័យ ៨ ប្រការដូចពោលមកហើយប៉ុណ្ណោះ ចំណែកសេចក្ដីសង្ស័យដទៃទៀតក្រៅពីនេះ មិនមែនជាសេចក្ដីសង្ស័យដែលកើតអំពីវិចិកិច្ឆា ដែលប្រកបក្នុងមោហមូលចិត្តទេ ។

**ឧទ្ធច្ចសម្បយុត្តំ** ប្រកបដោយសេចក្តីរាយមាយ សំដៅយកចិត្តនោះ រាយមាយទៅក្នុងអារម្មណ៍ផ្សេងៗ តែអារម្មណ៍ទាំងនោះ មិនមាំទាំទើបប្រែប្រួលទៅរឿយៗ ។

**មោហមូលចិត្តទាំង ២** ដូងនេះ ក្នុងព្រះបាលីមិនបានសម្តែងសេចក្តីផ្សេងគ្នារបស់សង្ខារភេទ គឺ ប្រភេទនៃសង្ខារ បានដល់អសង្ខារិក និងសសង្ខារិកទុកទេ។

ក្នុងវិសុទ្ធិមគ្គ និងក្នុងអភិធម្មត្ថវិភាវិនីដីកា ពោលទុកថា ចិត្តដែលសង្ស័យមិនជឿជាក់ក្តី ចិត្តដែលរាយមាយក្តី ជាចិត្តដែលវៀរចាកចំណង់សេចក្តីត្រេកអរ និងវៀរចាកការថ្នាំងថ្នាក់ចិត្ត ឬទោមនស្សទើបជាចិត្តដែលមានកម្លាំងខ្សោយ និងខ្វះឧស្សាហៈក្នុងកិច្ចការងារផ្សេងៗ សេចក្តីផ្សេងគ្នាក្នុងសភាវៈនៃសង្ខារទើបមិនមាន តែក៏សង្គ្រោះមោហមូលចិត្តទាំង ២ ដូងនេះ ថាជាអសង្ខារិកចិត្ត ព្រោះសេចក្តីល្ងង់ សេចក្តីមិនដឹងក្នុងហេតុផលតាមសេចក្តីពិតនោះ រមែងមិននៅក្រោមឥទ្ធិពលរបស់អ្នកណា គឺ សេចក្តីល្ងង់នោះ រមែងកើតឡើងដោយខ្លួនឯង អ្នកដទៃណានឹងមកដឹកនាំឲ្យល្ងង់រមែងមិនបាន ។

**មោហមូលចិត្ត** ២ ដូងនេះ មិនប្រកបដោយទិដ្ឋិ គឺ សេចក្តីយល់ឃើញខុស និងបដិឃៈ គឺ សេចក្តីក្រោធ ព្រោះមោហមូលចិត្តមានការមិនដឹងអារម្មណ៍តាមសេចក្តីពិត ជាមូលដ្ឋាន ឬជាហេតុម្យ៉ាង ទើបទទួលអារម្មណ៍ដោយភាពព្រងើយៗ មិនសោមនស្ស មិនទោមនស្សក្នុងអារម្មណ៍ ព្រោះដូច្នោះ ទិដ្ឋិដែលអាស្រ័យសេចក្តីត្រេកអរក្នុង

អារម្មណ៍ និងបដិឃៈ ដែលអាស្រ័យសេចក្តីមិនត្រេកអរក្នុងអារម្មណ៍ ជាអ្នកធ្វើឲ្យកើតមោហមូលចិត្ត មានតែការមិនដឹងក្នុងអារម្មណ៍តាមសេចក្តីពិតស្រាប់ហើយ ទើបមិនមានទិដ្ឋិនិងបដិឃៈប្រកបជាមួយ ។

## ហេតុនាំឲ្យកើតមោហៈ មាន ២ ប្រការ

១. **អយោនិសោមនសិការ** មានការធ្វើទុកក្នុងចិត្តដោយឧបាយមិនត្រូវទំនង ។

២. **អាសវសមុប្បាទ** មានការកើតឡើងនៃអាសវៈជាហេតុ ។

## អធិប្បាយអយោនិសោមនសិការៈ

ការធ្វើទុកក្នុងចិត្តដោយឧបាយមិនត្រូវទំនងនោះ គឺ ខ្វះការពិចារណាអារម្មណ៍ឲ្យហ្មត់ចត់ ក្នុងហេតុនិងផលដោយល្អ ព្រោះការគិតពិចារណាអារម្មណ៍ មិនល្អិតសុខុមជ្រាលជ្រៅនោះ រមែងឲ្យកើតសេចក្តីសង្ស័យនិងការរាយមាយ សេចក្តីសង្ស័យនិងការរាយមាយនេះក៏នឹងត្រឡប់ជាហេតុឲ្យកើតការមិនដឹង គឺ មោហៈតទៅទៀត ។

**"អាសវសមុប្បាទ"** មានអាសវៈជាហេតុឲ្យកើតអវិជ្ជា ជាគ្រឿងត្រាំកិលេសដែលត្រាំទុកក្នុងចិត្តមានកាមាសវៈ គឺ ត្រាំកាមគុណារម្មណ៍ទុកក្នុងចិត្តជាដើម កាលបានប្រសព្វជាមួយកាមគុណារម្មណ៍ថ្មី ក៏នឹងជាប់ចិត្តក្នុងកាមគុណារម្មណ៍នោះទៀត ទើបធ្វើឲ្យបិទបាំងសភាវៈនៃអារម្មណ៍តាមសេចក្តីពិត ដែលជាធម្មជាតិរបស់មោហៈ ឬអវិជ្ជានោះឯង។

# ផលដែលកើតពីមោហមូលចិត្ត

**មោហមូលចិត្ត** ជាចិត្តដែលសាងហេតុវង្វេង ដូច្នោះបុគ្គលណា ត្រូវគ្របសង្កត់ដោយអំណាចមោហៈ រមែងវង្វេងភ្លើតភ្លើនទៅតាមការមិនដឹងអារម្មណ៍នោះៗ ។

អំណាចនៃមោហៈនេះ បើសម័យណាមនុស្សមានសន្តានច្រើនទៅដោយមោហៈ សម័យនោះរមែងកើតរោគន្តរាយ គឺ អន្តរាយដែលកើតអំពីជំងឺតម្កាត់បៀតបៀន ជាហេតុឲ្យកើតរោគរាតត្បាតស្លាប់ជាច្រើន រោគទាំងពួងនឹងប្រាកដផ្តាច់ជីវិតមនុស្សទាំងឡាយឲ្យអស់ទៅ ។

សម្រាប់ផលរបស់មោហៈដែលកើតឡើងក្នុងអនាគតនោះ រមែងឲ្យកើតក្នុងតិរច្ឆានភូមិ ដូចក្នុងអដ្ឋសាលិនីអដ្ឋកថាសម្តែងថា

**មោហេន ហិ និច្ចសម្មុឡ្ហំ តិរច្ឆានយោនឹ ឧបបជ្ជន្តិ ។**

សត្វទាំងឡាយរមែងទៅកើតជាតិរច្ឆាន ដោយអំណាចនៃមោហៈ ព្រោះជាសភាវៈដែលញ៉ាំងសត្វឲ្យងឹតល្ងង់ទៅរឿយៗ ។

# សម្តែងសម្បយុត្តក្នុងអកុសលចិត្ត

ក្នុងអកុសលចិត្ត ១២ ដួង គឺ លោភមូលចិត្ត ៨ ដួង ទោសមូលចិត្ត ២ ដួង និងមោហមូលចិត្ត ២ ដួង ដែលពោលមកហើយនោះ ព្រះអនុរុទ្ធាចារ្យ សម្តែងសម្បយុត្តទុកត្រឹម ៤ ប្រការ គឺ

១. **ទិដ្ឋិគតសម្បយុត្ត** មានសេចក្តីយល់ឃើញខុសប្រកបក្នុងលោភមូលចិត្ត ៤ ដួង ។

**២. បដិឃសម្បយុត្ត** សេចក្ដីក្រោធប្រកបក្នុងទោសមូលចិត្ត ២ ដួង
**៣. វិចិកិច្ឆាសម្បយុត្ត** សេចក្ដីសង្ស័យប្រកបក្នុងមោហាមូលចិត្ត ១ ដួង ។
**៤. ឧទ្ធច្ចសម្បយុត្ត** សេចក្ដីរាយមាយប្រកបយ៉ាងជាក់ច្បាស់ក្នុង មោហាមូលចិត្ត ១ ដួង ។

ពាក្យថា **សម្បយុត្ត** នេះ ប្រែថា ប្រកប (ជាមួយចិត្ត) ជាវិសេសនបទ មាននាទីសម្ដែងឲ្យដឹងដល់សេចក្ដីផ្សេងគ្នារបស់ចិត្ត ដូចជា

**ទិដ្ឋិគតសម្បយុត្ត** ប្រែថា ចិត្តដែលប្រកបដោយសេចក្ដីយល់ឃើញខុស សម្ដែងឲ្យឃើញថា **ទិដ្ឋិ** គឺ សេចក្ដីយល់ឃើញខុសនេះ ជាធម៌ដែលប្រកបជាមួយចិត្ត តែមិនបានប្រកបជាមួយចិត្តគ្រប់ដួង ដូចជា **ផស្ស វេទនា សញ្ញា ចេតនា** ទាំងនេះជាដើមទេ តែអកុសលលោភមូលចិត្ត ដែលមានចំនួនទាំងអស់ ៨ ដួងនោះ គឺ មានទិដ្ឋិប្រកបត្រឹមតែ ៤ ដួង ប៉ុណ្ណោះ មិនបានប្រកបក្នុងលោភមូលចិត្តទាំងអស់ទេ ព្រោះដូច្នោះ **បដិឃសម្បយុត្ត វិចិកិច្ឆាសម្បយុត្ត** ឬ **ឧទ្ធច្ចសម្បយុត្ត** ក៏សុទ្ធតែជាវិសេសនបទ ដែលសម្ដែងឲ្យឃើញសេចក្ដីផ្សេងគ្នារបស់ចិត្ត ដោយទំនងដូចគ្នា ជាការសម្ដែងសភាវធម៌ដែលប្រកបជាមួយចិត្ត ដោយចំពោះយ៉ាងដាច់ខាត ធ្វើឲ្យឃើញសេចក្ដីផ្សេងគ្នារបស់ចិត្តបានយ៉ាងច្បាស់លាស់ ។

# សង្គ្រោះអកុសលកម្មបថ ១០ ចូលក្នុងអកុសលចិត្ត ១២ ដួង

**អកុសលកម្មបថ** គឺ ផ្លូវនៃការធ្វើបាបមាន ១០ ហៅថា អកុសល-កម្មបថ ១០ ឬទុច្ចរិត ១០ ដែលកើតបាន ៣ ទ្វារ គឺ បើកើតឡើងតាមទ្វារកាយ ហៅថា អកុសលកាយកម្ម ឬកាយទុច្ចរិត កើតតាមទ្វារវាចា ហៅថា អកុសលវចីកម្ម ឬវចីទុច្ចរិត និងបើកើតតាមទ្វារចិត្ត ហៅថា **អកុសលមនោកម្ម ឬ មនោទុច្ចរិត** ។

អកុសលដែលកើតឡើងតាមកាយទ្វារ ជាអកុសលកាយកម្ម ឬកាយទុច្ចរិតនោះ មាន ៣ ប្រការ គឺ

**១. បាណាតិបាត** សម្លាប់សត្វ ។

**២. អទិន្នាទាន** លួចទ្រព្យគេ ។

**៣. កាមេសុមិច្ឆាចារ** ប្រព្រឹត្តខុសក្នុងកាម ។

អកុសលដែលកើតតាមវចីទ្វារ ជាអកុសលវចីកម្ម ឬវចីទុច្ចរិតនោះមាន ៤ ប្រការ គឺ

**១. មុសាវាទ** និយាយពាក្យកុហក ។

**២. បិសុណាវាចា** និយាយញុះញង់ ។

**៣. ផរុសវាចា** និយាយគ្រោតគ្រាត ។

**៤. សម្ផប្បលាប** និយាយពាក្យរោយរាយឥតប្រយោជន៍ ។

**អកុសល** ដែលកើតឡើងក្នុងមនោទ្វារជាអកុសលមនោកម្ម ឬមនោទុច្ចរិត ៣ ប្រការ គឺ

**១. អភិជ្ឈា** ការសម្លឹងរំពៃចង់បានទ្រព្យរបស់អ្នកដទៃ ។

**២. ព្យាបាទ** គិតចងគំនុំព្យាបាទឲ្យគេវិនាស ។

**៣. មិច្ឆាទិដ្ឋិ** មានសេចក្តីយល់ឃើញខុស (**និយតមិច្ឆាទិដ្ឋិ**) ។

ក្នុងលោភមូលចិត្ត ៨ ដួង ទុច្ចរិតកើតបានទាំង ៣ ទ្វារ មាន ៧ ប្រការ គឺ

**កាយទ្វារ** មាន ២ គឺ **អទិន្នាទាន** និង **កាមេសុមិច្ឆាចារ** ។

**វចីទ្វារ** មាន ៣ គឺ **មុសាវាទ បិសុណាវាចា** និង **សម្ផប្បលាប** ។

**មនោទ្វារ** មាន ២ គឺ **អភិជ្ឈា** និង **មិច្ឆាទិដ្ឋិ** ។

ក្នុងទោសមូលចិត្ត ២ ដួង ទុច្ចរិតកើតបានទាំង ៣ ទ្វារ មាន ៧ ប្រការ គឺ

**កាយទ្វារ** មាន ២ គឺ **បាណាតិបាត** និង **អទិន្នាទាន** ។

**វចីទ្វារ** មាន ៤ គឺ **មុសាវាទ បិសុណាវាចា ផរុសវាចា** និង **សម្ផប្បលាប** ។

**មនោទ្វារ** មាន ១ គឺ **ព្យាបាទ** ។

ក្នុងមោហមូលចិត្ត ២ ដួង ទុច្ចរិតកើតបានទាំង ៣ ទ្វារ មាន ១០ ប្រការ គឺ

**កាយទ្វារ** មាន ៣ គឺ **បាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ** ។

**វចីទ្វារ** មាន ៤ គឺ **មុសាវាទ បិសុណាវាចា ផរុសវាចា សម្ផប្បលាប** ។

**មនោទ្វារ** មាន ៣ គឺ **អភិជ្ឈា ព្យាបាទ** និង **មិច្ឆាទិដ្ឋិ** ។

ក្នុងអកុសលកម្មបថ ១០ នេះ បើពិចារណាឲ្យល្អហើយ ក៏នឹង

ឃើញថា អកុសលកម្មបថ ៣ បានដល់ **បាណាតិបាត ផរុសវាចា** និង **ព្យាបាទ** កើតបានដោយអំណាចទោសមូលចិត្ត ដែលមាន **ទោស** ជាហេតុ ។

**អកុសលកម្មបថ ៣** ទៀត បានដល់ **កាមេសុមិច្ឆាចារ អភិជ្ឈា** និង **មិច្ឆាទិដ្ឋិ** កើតដោយអំណាចនៃលោភមូលចិត្ត ដែលមាន **លោភ** ជាហេតុ ។

ចំណែកអកុសលកម្មបថដ៏សេស គឺ **អទិន្នាទាន មុសាវាទ បិសុណាវាចា** និង **សម្ផប្បលាប** ទាំង ៤ ប្រការនេះ គ្រាខ្លះក៏កើតដោយលោភមូលចិត្ត ដូចជាលួចទ្រព្យគេព្រោះប្រាថ្នាចង់មាន ឬនិយាយកុហកដើម្បីស្វែងរកប្រយោជន៍ជាដើម ខណៈនោះក៏មាន **លោភ** ជាហេតុ ។

តែគ្រាខ្លះអកុសលកម្មបថ ដូចពោលមកនេះ ក៏កើតឡើងដោយទោសមូលចិត្ត ដែលមាន**ទោស**ជាហេតុ ដូចជាលួចទ្រព្យយកទៅចោលព្រោះស្អប់ម្ចាស់ទ្រព្យ ឬនិយាយកុហកដើម្បីឲ្យកើតសេចក្ដីក្ដៅក្រហាយដល់អ្នកដទៃជាដើម ។

**អកុសលកម្មបថ** ទាំង ១០ នេះ អាស្រ័យ **លោភមូលចិត្ត** និង **ទោសមូលចិត្ត** ជាហេតុឲ្យកើតឡើងដោយត្រង់ តែដែលពោលថា អកុសលកម្មបថកើតបានក្នុងមោហមូលចិត្តគ្រប់ ១០ ប្រការ បរិបូណ៌នោះ ព្រោះជាការពោលដោយអម ព្រោះអកុសលកម្មបថ ១០ អាស្រ័យអវិជ្ជាជាហេតុនោះឯង ដូច្នោះទើបពោលបានថា កាលលោភមូលចិត្តកើតឡើងមានលោភៈជាហេតុ មោហៈជាហេតុឧបត្ថម្ភ ។

ទោសមូលចិត្តកើតឡើងមានទោសៈជាហេតុ មោហៈជាហេតុឧបត្ថម្ភ ។

មោហមូលចិត្តកើតឡើង មានមោហៈជាហេតុតែម្យ៉ាង។

## ហេតុនាំឲ្យកើតអកុសលចិត្ត

ការកើតឡើងនៃអកុសលចិត្ត ១២ ដួងនោះ ព្រោះការមិនពិចារណាអារម្មណ៍ដោយឧបាយត្រូវទំនង ហៅថា **អយោនិសោមនសិការ** ។

ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់សម្តែងថា អ្នកដែលមានអយោនិសោមនសិការនោះ អកុសលចិត្តដែលនៅមិនទាន់កើតរមែងកើតឡើង អកុសលចិត្តដែលកើតឡើងហើយ រមែងចម្រើនក្រៃលែងឡើង កុសលចិត្តដែលនឹងកើតរមែងមិនមានឱកាសកើតហើយកុសលចិត្តដែលកំពុងកើតឡើង រមែងរលត់ទៅ ។

**អយោនិសោមនសិការ** នេះ រមែងកើតឡើងដោយអាស្រ័យហេតុ ៥ ប្រការ គឺ

**១. បុព្វេអកតបុញ្ញតា** មិនបានសន្សំបុណ្យទុកពីកាលមុន ។

**២. អប្បដិរូបទេសវាស** នៅក្នុងប្រទេសដែលមិនសមគួរ ។

**៣. អសប្បុរិសូបនិស្សយ** មិនបានគប់រកសប្បុរស ។

**៤. អសទ្ធម្មស្សវន** មិនបានស្តាប់ធម៌របស់សប្បុរស ។

**៥. អត្តមិច្ឆាបណិធិ** តម្កល់ខ្លួនទុកខុស ។

ហេតុឲ្យកើតអយោនិសោមនសិការ ៥ ប្រការនេះ រមែងមានឧបការៈដល់គ្នា គឺ មិនបានធ្វើបុណ្យទុកពីកាលមុនជាអតីតហេតុ ព្រោះមិនបានធ្វើបុណ្យទុកពីកាលមុន ទើបមកកើតក្នុងប្រទេសមិនសមគួរ គឺមិនមានសប្បុរស ទើបធ្វើឲ្យមិនបានស្តាប់ធម៌ និងព្រោះហេតុដែលមិនបានស្តាប់ធម៌ ទើបធ្វើឲ្យគិតខុស តាំងចិត្តទុកមិនប្រពៃ គឺ តម្កល់ខ្លួនទុកខុសនោះឯង ទើបធ្វើឲ្យអកុសលចិត្តកើតឡើង ដោយអាស្រ័យអយោនិសោមនសិការ ហេតុឲ្យកើតអយោនិសោមនសិការនេះ ទើបស្មើគ្នាជាមួយហេតុដែលឲ្យកើតអកុសលចិត្តនោះឯង ។

## អកុសលចិត្តជាធម៌ដែលគួរលះ

អកុសលចិត្ត ជាចិត្តអាក្រក់ជាបាបមានទោស និងឲ្យផលជាទុក្ខ តាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធសាសនានោះ ប្រដៅឲ្យលះអំពើអាក្រក់ជាប្រការដំបូង ឲ្យប្រព្រឹត្តល្អជាប្រការទី ២ និងការធ្វើចិត្តឲ្យ 0បរិសុទ្ធប្រាសចាកគ្រឿងសៅហ្មង ជាប្រការចុងក្រោយ ព្រោះដូច្នោះ អកុសលចិត្តជាហេតុឲ្យកើតការធ្វើការនិយាយ និងការគិតដែលមិនល្អ ជាការងារដែលអាក្រក់ជាបាប ទើបត្រូវលះអកុសលចិត្តមុន ការលះអកុសលចិត្តនោះ រមែងធ្វើបាន ៣ ប្រភេទ គឺ

**១. តទង្គប្បហាន** លះបានជាខណៈៗ ដោយសីល ។

**២. វិក្ខម្ភនប្បហាន** លះដោយការគ្របសង្កត់ដោយសមាធិ ។

**៣. សមុច្ឆេទប្បហាន** លះដាច់ជាសមុច្ឆេទដោយបញ្ញា ។

ការលះអកុសលចិត្តបានមួយគ្រានោះ បានដល់ ការដែលបុគ្គលសង្រួមមិនឲ្យអកុសលចិត្ត គឺ លោភមូលចិត្ត ទោសមូលចិត្ត និងមោហមូលចិត្តកើតឡើង ត្រូវអាស្រ័យធម៌ជាបដិបក្ខដល់ការកើតឡើងរបស់អកុសលចិត្តទាំងនោះ គឺ

**លោភមូលចិត្ត** ជាចិត្តដែលកើតពីការលោភ គឺ ការចង់បាន បើមិនសង្រួមឲ្យល្អហើយ សេចក្ដីលោភចង់បានក្នុងអារម្មណ៍ដែលគួរត្រេកអរនោះ ក៏នឹងរីករាលដាលធំទូលាយចេញទៅរកទីបំផុតប្រមាណមិនបាន ដើម្បីការពារមិនឲ្យសេចក្ដីលោភចង់បានប៉ោងឡើងក្នុងចិត្ត ត្រូវអាស្រ័យធម៌ដែលឈ្មោះថា **សន្តោស** គឺ សេចក្ដីពេញចិត្តតាមមានតាមបាន គឺ ការដឹងប្រមាណក្នុងការទទួល ដែលអង្គធម៌បានដល់អលោភចេតសិក ការលះលោភៈដោយអលោភៈមានសន្តោសជាដើមនេះ ជាការលះបានត្រឹមតែមួយគ្រាប៉ុណ្ណោះ ដែលមានការសង្រួមមិនឲ្យសេចក្ដីលោភកើតឡើងជាខណៈៗ ប៉ុណ្ណោះ ហៅថាលះបានដោយ **តទង្គប្បហាន** បើនឹងលះដោយអាការគ្របសង្កត់លោភៈទុកមិនឲ្យកើតឡើងជាវេលាយូរៗ នោះត្រូវអាស្រ័យសមាធិ ឬឈាន ជាគ្រឿងគ្របសង្កត់ទុក ការលះអកុសលចិត្តដោយការគ្របសង្កត់ទុកនេះហៅថាលះដោយ **វិក្ខម្ភនប្បហាន** ចំណែកការលះលោភមូលចិត្តដោយដាច់ជាសមុច្ឆេទនោះ ត្រូវអាស្រ័យបញ្ញាក្នុងមគ្គចិត្ត ជាអ្នកលះដែលអាចលះសេចក្ដីលោភយ៉ាងគ្រោតគ្រាតទៅរហូតដល់ថ្នាក់ល្អិតជាទីបំផុត ក្នុងអរហត្តមគ្គចិត្ត ការលះដោយបញ្ញានេះជាការលះដោយដាច់ជាសមុច្ឆេទ

ហៅថា **សមុច្ឆេទប្បហាន** ។

**ទោសមូលចិត្ត** ជាចិត្តដែលកើតពីសេចក្តីក្រោធ ស្អប់ ខ្លាច ការប្រទូសរ៉ាយអារម្មណ៍ ដែលមិនគួរប្រាថ្នា អ្នកណាក៏ដោយកាលមានការយល់ឃើញចូលខាងខ្លួនជាធំហើយ រមែងមានតែការជំរុញចិត្តឲ្យក្តៅក្រហាយ នាំឲ្យកើតទោសប្រទូសរ៉ាយខ្លួនឯងនិងអ្នកដទៃ ដែលមកសមាគមជាមួយ ព្រោះការនិយមលើកតម្កើងសរសើរខ្លួនឯង ឲ្យខ្លាំងពេកនោះឯង ទើបសម្លឹងមើលទោសរបស់ខ្លួនឯងមិនឃើញៗ តែទោសអ្នកដទៃ និងរកឱកាសបៀតបៀនជារឿយៗ ដូច្នោះដើម្បីកាត់បន្ថយការបៀតបៀនដែលមានសភាពជាទោសមូលចិត្តនេះ ទើបត្រូវលះទោសៈដោយវិធីចម្រើនមេត្តា គឺ ត្រូវពិចារណារឿយៗ ថា ខ្លួនយើងស្អប់ទុក្ខប្រាថ្នាសុខយ៉ាងណា អ្នកដទៃសត្វដទៃក៏ស្អប់ទុក្ខប្រាថ្នាសុខដូចយើងក៏យ៉ាងនោះដែរ កាលពិចារណាដូច្នេះហើយ រមែងកាត់បន្ថយការបៀតបៀននូវគ្នានិងគ្នាបាន ជាការលះអកុសលទោសមូលចិត្តបានមួយគ្រា ដែលហៅថា **តទង្គប្បហាន** ។

ក្នុងសតិប្បដ្ឋានអដ្ឋកថា សម្តែងហេតុដែលប្រហារទោសៈ ៦ ប្រការទុក គឺ

**១. មេត្តានិមិត្តស្ស ឧគ្គហោ** សិក្សាក្នុងនិមិត្តនៃការចម្រើនមេត្តា។

**២. មេត្តាភាវនានុយោគោ** ប្រកបភាវនាក្នុងមេត្តារឿយៗ ។

**៣. កម្មស្សកតាបច្ចវេក្ខណា** ពិចារណារឿយៗ ថា ជាកម្មរបស់ខ្លួន ។

**៤. បដិសង្ខានពហុលតា** ធ្វើឲ្យច្រើនដោយបញ្ញា ។

**៥. កល្យាណមិត្តតា** គប់រកមិត្តដែលល្អមានមេត្តា ។

**៦. សប្បាយកថា** បានស្តាប់ពាក្យដែលជាទីសប្បាយ (មេត្តាកថា) ។

ក្រៅពីការលះទោសៈដោយមេត្តានិងហេតុដទៃៗ ទាំង ៦ ប្រការ ដូចពោលហើយ អប់រំសមាធិ ឬឈានលះបានដោយការគ្របសង្កត់ ដរាបណាដែលនៅក្នុងឈាន ឬសមាធិដែលស្ថិតនៅ ហៅការលះនេះថា **វិក្ខម្ភនប្បហាន** ចំណែកការលះទោសៈដាច់ជាសមុច្ឆេទ មិនឲ្យកើតឡើងជាថ្មីទៀតនោះ ត្រូវលះដោយបញ្ញានៃអនាគាមិមគ្គចិត្ត ជាការលះដល់ទីបំផុតជា **សមុច្ឆេទប្បហាន** ។

**មោហមូលចិត្ត** ជាចិត្តដែលមិនបានសម្តែងទោសចេញមកឲ្យប្រចក្ស តែជាឫសគល់នៃអកុសលចិត្តទាំងពួង មានសភាពបិទបាំងសេចក្តីពិត ប្រៀបដូចជាភាពងងឹត ដូច្នោះការប្រហារភាពងងឹតនោះត្រូវអាស្រ័យពន្លឺ បានដល់បញ្ញានោះឯង ។ ក្នុងសតិប្បដ្ឋានអដ្ឋកថាសម្តែងហេតុប្រហារមោហៈប្រកបដោយវិចិកិច្ឆា និងឧទ្ធច្ចទុកដូច្នេះ គឺ

## ហេតុដែលប្រហារវិចិកិច្ឆា ៦ ប្រការ

**១. ពហុស្សុតតា** ភាពជាអ្នកបានស្តាប់ច្រើន ។

**២. បរិបុច្ឆកតា** ភាពជាអ្នកចេះសាកសួរ ។

**៣. វិនយេ បកតញ្ញុតា** ភាពជាអ្នកឆ្លាតឈ្លាសក្នុងព្រះវិន័យ ។

**៤. អធិមោក្ខពហុលតា** ភាពជាអ្នកច្រើនទៅដោយអធិមោក្ខ ។

**៥. កល្យាណមិត្តតា** ភាពជាអ្នកមានកល្យាណមិត្ត ។

**៦. សប្បាយកថា** បានស្តាប់ពាក្យដែលជាទីសប្បាយ ។

## ហេតុដែលត្រូវលះឧទ្ធច្ចៈ ៦ ប្រការ

**១. ពហុស្សុតតា** ភាពជាអ្នកបានស្តាប់ច្រើន ។

**២. បរិបុច្ឆកតា** ភាពជាអ្នកចេះសាកសួរ ។

**៣. វិនយេ បកតញ្ញុតា** ភាពជាអ្នកឆ្លាតឈ្លាសក្នុងព្រះវិន័យ ។

**៤. ពុទ្ធសេវិតា** ភាពជាអ្នកបានស្តាប់ធម៌របស់ព្រះពុទ្ធជាម្ចាស់ ។

**៥. កល្យាណមិត្តតា** ភាពជាអ្នកមានកល្យាណមិត្ត ។

**៦. សប្បាយកថា** បានស្តាប់ពាក្យដែលជាទីសប្បាយ ។

ការលះមោហៈ ឬអវិជ្ជានោះត្រូវអាស្រ័យបញ្ញា តាំងពីសុតមយបញ្ញា ចិន្តាមយបញ្ញា និងភាវនាមយបញ្ញា តាមលំដាប់ ព្រោះបញ្ញានោះជាពន្លឺដែលនឹងទម្លាយភាពងងឹត គឺ មោហៈដោយត្រង់ តែការលះមោហៈ គឺអវិជ្ជាដោយដាច់ជាសមុច្ឆេទ មិនឲ្យមាននៅសេសសល់នោះ ត្រូវអាស្រ័យបញ្ញាក្នុងអរហត្តមគ្គចិត្តជាអ្នកលះ ។

## ចប់ អកុសលចិត្ត ១២

# អហេតុកចិត្ត ១៨

ពាក្យថា **អហេតុក** បានដល់ មិនប្រកបដោយហេតុ ។

**អហេតុកចិត្ត** បានដល់ ចិត្តដែលមិនប្រកបដោយហេតុ ។

តាមធម្មតាចិត្តដែលប្រាកដឡើង ដោយច្រើនត្រូវប្រកបដោយហេតុ មិនហេតុបុណ្យ ក៏ហេតុបាបណាមួយដែលហៅថា កុសលហេតុ ឬ អកុសលហេតុ ។

**ហេតុបាប** ឬ **អកុសលហេតុ** នោះ បានដល់ **លោភហេតុ ទោសហេតុ** និង**មោហហេតុ** ចំណែក **ហេតុបុណ្យ** ឬ **កុសលហេតុ** ក៏បានដល់ **អលោភហេតុ អទោសហេតុ** និង**អមោហហេតុ** រួមហេតុបុណ្យ និងហេតុបាបមានត្រឹមតែ ៦ ហេតុនេះប៉ុណ្ណោះ ធម៌ដែលជាហេតុនេះជាចេតសិកធម៌ ដែលប្រកបជាមួយចិត្ត ។

ចិត្តដែលកើតឡើងដោយមានហេតុប្រកបជាមួយ ដូចពោលមកនេះ ឈ្មោះថា **សហេតុកចិត្ត** តែនៅមានចិត្តមួយប្រភេទទៀត ដែលមិនបានប្រកបដោយហេតុណាមួយក្នុងហេតុទាំង ៦ ដូចពោលមកនោះឡើយ ចិត្តប្រភេទនោះឈ្មោះថា **អហេតុកចិត្ត** ជាចិត្តដែលមិនមានទាំងហេតុបុណ្យ និងហេតុបាបប្រកបជាមួយឡើយ ។

ហេតុដែលប្រកបនេះ សំដៅយក **សម្បយុត្តហេតុ** គឺហេតុដែលប្រកបជាមួយចិត្ត តែឧប្បត្តិហេតុ គឺហេតុដែលធ្វើឲ្យចិត្តមួយដួងៗប្រាកដឡើង ទាំងនេះរមែងមាន នឹងពោលតទៅ ។

**អហេតុកចិត្ត** គឺចិត្តដែលមិនប្រកបដោយហេតុនេះមាន ១៨ ដួង ចែកតាមការសម្តែងទុកក្នុងគាថាសង្គហ: ៣ ពួក

## គាថាសង្គហទី ៤

**៤. សត្តាកុសលបាកានិ បុញ្ញបាកានិ អដ្ឋធា**
**ក្រិយចិត្តានិ តីណីតិ អដ្ឋារស អហេតុកា ។**

ប្រែថា អកុសលវិបាកចិត្ត ៧ ដួង កុសលវិបាកចិត្ត ៨ ដួង កិរិយាចិត្ត ៣ ដួង រួមចិត្តទាំង ១៨ ដួងនេះជាអហេតុកចិត្ត ។

## សម្តែងអហេតុកចិត្ត ១៨ ដួង

**អកុសលវិបាកចិត្ត ៧ ដួង ។**

**អហេតុកកុសលវិបាកចិត្ត ៨ ដួង ។**

**អហេតុកកិរិយាចិត្ត ៣ ដួង សរុបចិត្ត ១៨ ដួង ។**

**អកុសលវិបាកចិត្ត ៧** គឺចិត្តដែលជាផលរបស់អកុសលកម្ម បានសេចក្តីថា អកុសលកម្មជាកម្មផ្នែកអាក្រក់ផ្នែកបាប ដែលបានធ្វើទុកហើយពីអតីត ដែលមិនទាន់ឲ្យផល នឹងមានឱកាសកើតឡើងដើម្បីទទួលផលដែលជាអកុសលវិបាកចិត្ត ៧ ដួង មានការឃើញ ការឮ ដឹងក្លិន ដឹងរស ដឹងផោដ្ឋព្វ: ទទួលអារម្មណ៍ និងពិចារណាអារម្មណ៍មិនល្អផ្សេងៗ ដែលជាផលឲ្យចិត្តត្រូវទទួលដឹងអារម្មណ៍ដែលមិនល្អ ៧ ប្រការ ចិត្តដែលទទួលផលរបស់អកុសលកម្មទាំងនេះ ទើបឈ្មោះថា

អកុសលវិបាកចិត្ត មានចំនួន ៧ ដួង ។

**អហេតុកកុសលវិបាកចិត្ត ៨** ជាចិត្តដែលជាផលរបស់កុសលកម្ម បានសេចក្តីថា កុសលកម្មដែលជាកម្មផ្នែកល្អ គឺបុណ្យដែលបានធ្វើទុកមកហើយក្នុងអតីត ដែលនៅមិនទាន់ឲ្យផល នឹងមានឱកាសកើតឡើងដើម្បីទទួលផល ដែលជាអហេតុកកុសលវិបាកចិត្ត ៨ ដួង តែបើកុសលកម្មដែលបានធ្វើទុកហើយ ក្នុងអតីតនោះមានកម្លាំងខ្សោយ គឺជាកុសលកម្មប្រភេទដែលមានអកុសលជាបរិវារ ឬកុសលជវនៈដួងទី ១ ក្នុងបច្ចុប្បន្នភពនេះ រមែងមានកម្លាំងខ្សោយក្នុងការឲ្យផលជាអហេតុកកុសលវិបាកចិត្ត ៨ មានការឃើញ ការឮ ដឹងក្លិន ដឹងរសដឹងផោដ្ឋព្វៈដែលល្អៗ ជាដើម ផលរបស់កុសលកម្មដែលមានកម្លាំងខ្សោយនេះ រមែងឲ្យចិត្តទទួលដឹងបានដោយភាពជាអហេតុកកុសល-វិបាកចិត្ត គឺជាចិត្តដែលទទួលដឹងអារម្មណ៍ល្អមាន ៨ ដួង ។

**អហេតុកកិរិយាចិត្ត ៣** ជាចិត្តដែលមិនមែនជាផលរបស់អកុសលកម្ម ឬកុសលកម្មណាមួយឡើយ ហើយក៏មិនមែនជាកុសលចិត្ត ឬអកុសលចិត្តដែរ តែជាចិត្តដែលកើតឡើងតាមនាទីរបស់ខ្លួនប៉ុណ្ណោះ គឺធ្វើនាទីបើកទ្វារឲ្យអារម្មណ៍ ដែលប្រាកដចំពោះមុខ បានឆ្លងកាត់ចូលមកប៉ះខ្ទប់ជាមួយចិត្ត ឬន័យម្យ៉ាងទៀត ជាចិត្តធ្វើឲ្យកើតការញញឹមរបស់ព្រះអរហន្ត ព្រោះប្រសព្វជាមួយអនិដ្ឋារម្មណ៍ ត្រឹមតែជាកិរិយាចិត្ត ដែលធ្វើនាទីរាវរកអារម្មណ៍និងទទួលអារម្មណ៍ ដូច្នេះទើបឈ្មោះថា ជាអហេតុកកិរិយាចិត្ត មានចំនួន ៣ ដួង ។

**ចំណុចសម្គាល់** ចិត្តជាផលរបស់អកុសលកម្ម ហៅថា អកុសល-វិបាកចិត្ត តែចំណែកចិត្តដែលជាផលរបស់កុសលកម្ម ហៅថា អហេតុក-កុសលវិបាកចិត្ត ដែលហៅដូច្នេះព្រោះអកុសលកម្មនោះមានកម្លាំងខ្សោយ ឲ្យផលតែក្នុងប្រភេទអហេតុកចិត្តតែម្យ៉ាង ទាំងនេះព្រោះអកុសលកម្ម រមែងកើតពីអកុសលចិត្ត ហើយអកុសលចិត្តគ្រប់ដួងសម្បយុត្តដោយឧទ្ធច្ចៈ គឺសេចក្តីរាយមាយ ដែលធ្វើឲ្យចិត្តចាប់យកអារម្មណ៍មិនបានមាំទាំ ធ្វើឲ្យអកុសលចេតនាដែលប្រកបដោយហេតុនោះមានកម្លាំងខ្សោយចុះ និងមិនអាចឲ្យផលជាអកុសលវិបាក ដែលប្រកបដោយហេតុបាន ដូច្នោះផលរបស់អកុសលកម្ម ទើបមានតែប្រភេទអហេតុកចិត្តតែម្យ៉ាង មិនមានផលជាសហេតុកចិត្ត ដូចផលរបស់មហាកុសលឡើយ ទើបមិនចាំបាច់ហៅអហេតុកអកុសលវិបាកចិត្ត ហៅត្រឹមតែ **អកុលសវិបាកចិត្ត** ប៉ុណ្ណោះ ។

ចំណែកផលរបស់កុសលកម្មនោះ បើកុសលកម្មមានកម្លាំងខ្លាំង ក៏ឲ្យផលជាសហេតុកចិត្ត គឺមានកុសលហេតុចូលប្រកប បានដល់ **អលោភហេតុ អទោសហេតុ** និង**អមោហហេតុ** សម្បយុត្តជាមួយ តែបើកុសលកម្មមានកម្លាំងខ្សោយក្នុងការឲ្យផល ព្រោះកុសលមានអកុសលជាបរិវារហើយ ក៏នឹងឲ្យផលជាអហេតុកចិត្ត គឺមិនមានកុសល-ហេតុសម្បយុត្ត ដោយហេតុនេះផលរបស់កុសលទើបមាន ២ ផ្នែក គឺសហេតុកកុសលវិបាកចិត្ត និងអហេតុកកុសលវិបាកចិត្ត ដូច្នោះផលរបស់កុសលដែលមានកម្លាំងខ្សោយ ទើបត្រូវចែកជា អហេតុកកុសល-

វិបាកចិត្ត ។

**កិរិយាចិត្ត** ក៏មាន ២ ផ្នែកដូចកុសលវិបាកចិត្តដែរ គឺមានទាំងសហេតុកកិរិយាចិត្ត បានដល់ ចិត្តរបស់ព្រះអរហន្តដែលធ្វើកិច្ចផ្សេងៗ ជាកិរិយាចិត្តដែលប្រកបដោយហេតុដែលហៅថា មហាកិរិយាចិត្តមានចំនួន ៨ ដួង និងអហេតុកកិរិយាចិត្ត បានដល់ ចិត្ត ដែលធ្វើកិច្ចបើកទ្វារទទួលប៉ះខ្ទប់អារម្មណ៍ថ្មី តាមភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងចិត្តរបស់សត្វទាំងឡាយមានចំនួន ២ ដួង និងចិត្តដែលធ្វើឲ្យកើតការញញឹមរបស់ព្រះអរហន្ត ដែលហៅថា ហសិតុប្បាទចិត្តកើតឡើងព្រោះប្រសព្វអនិដ្ឋារម្មណ៍មួយដួងទៀត ចិត្តទាំង ៣ ប្រភេទដែលពោលមកនេះ មិនមានសម្បយុត្តហេតុ ទើបឈ្មោះថា អហេតុកចិត្ត ត្រឹមតែថាមាននាទីក្នុងការធ្វើកិច្ចទើបឈ្មោះថា អហេតុកកិរិយាចិត្ត ដែលនឹងត្រូវសិក្សាលម្អិតតទៅ ។

## អកុសលវិបាកចិត្ត ៧

**អកុសលវិបាកចិត្ត** បានដល់ចិត្តដែលជាផលរបស់អកុសលកម្ម ដែលបានធ្វើទុកហើយក្នុងអតីតមានចំនួន ៧ ដួង បានដល់

**១. ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណំ អកុសលវិបាកចិត្តំ ។**

ចិត្តដែលអាស្រ័យចក្ខុវត្ថុកើតព្រមជាមួយឧបេក្ខា ជាផលរបស់អកុសលកម្មឃើញរូបដែលជាអនិដ្ឋារម្មណ៍ គឺអារម្មណ៍មិនល្អ ។

**២. ឧបេក្ខាសហគតំ សោតវិញ្ញាណំ អកុសលវិបាកចិត្តំ ។**

ចិត្តដែលអាស្រ័យសោតវត្ថុកើតព្រមជាមួយឧបេក្ខា ជាផលរបស់អកុសលកម្មឮសំឡេងមិនល្អ ។

**៣. ឧបេក្ខាសហគតំ ឃានវិញ្ញាណំ អកុសលវិបាកចិត្តំ ។**

ចិត្តដែលអាស្រ័យឃានវត្ថុកើតព្រមជាមួយឧបេក្ខា ជាផលរបស់អកុសលកម្មដឹងក្លិនមិនល្អ ។

**៤. ឧបេក្ខាសហគតំ ជិវ្ហាវិញ្ញាណំ អកុសលវិបាកចិត្តំ ។**

ចិត្តដែលអាស្រ័យជិវ្ហាវត្ថុកើតព្រមជាមួយឧបេក្ខា ជាផលរបស់អកុសលកម្មដឹងរសមិនល្អ ។

**៥. ទុក្ខសហគតំ កាយវិញ្ញាណំ អកុសលវិបាកចិត្តំ ។**

ចិត្តដែលអាស្រ័យកាយវត្ថុកើតព្រមជាមួយទុក្ខវេទនា ជាផលរបស់អកុសលកម្មដឹងផោដ្ឋព្វៈមិនល្អ ។

**៦. ឧបេក្ខាសហគតំ មនោធាតុ អកុសលវិបាកចិត្តំ ។**

ចិត្តដែលកើតព្រមជាមួយឧបេក្ខា ជាផលរបស់អកុសលកម្មទទួលអារម្មណ៍ ទាំង ៥ (រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ) មិនល្អ ។

**៧. ឧបេក្ខាសហគតំ មនោវិញ្ញាណធាតុ អកុសលវិបាកចិត្តំ ។**

ចិត្តដែលកើតព្រមជាមួយឧបេក្ខា ជាផលរបស់អកុសលកម្មធ្វើកិច្ចពិចារណាអារម្មណ៍ទាំង ៥ (រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ( ឬ ៦) មិនល្អ ។

# សម្តែងអកុសលវិបាកចិត្ត ៧ ដួង

- អកុសលវិបាកចិត្ត
  - ឧបេក្ខាសហគត
    - ចក្ខុវិញ្ញាណចិត្ត...........១
    - សោតវិញ្ញាណចិត្ត........១
    - ឃានវិញ្ញាណចិត្ត.........១
    - ជិវ្ហាវិញ្ញាណចិត្ត...........១
  - ទុក្ខសហគត —— កាយវិញ្ញាណចិត្ត.........១
  - ឧបេក្ខាសហគត
    - សម្បដិច្ឆនចិត្ត............១
    - សន្តីរណចិត្ត...............១
- ៧ ដួង

ក្នុងអកុសលវិបាកចិត្ត ៧ ដួងនេះ ធម៌ដែលគួរយល់មាន ២ ប្រការគឺ

**១. អកុសលវិបាកចិត្ត ៧** ដួងនេះ មានឈ្មោះហៅផ្សេងគ្នា គឺ ហៅថា វិញ្ញាណខ្លះ ហៅថា ចិត្តខ្លះ ។

ដែលហៅថា **វិញ្ញាណ** នេះគឺ

**ចក្ខុវិញ្ញាណ** បានដល់ ចិត្តដែលដឹងអារម្មណ៍តាមទ្វារភ្នែក គឺ ឃើញរូប ។

**សោតវិញ្ញាណ** បានដល់ ចិត្តដែលដឹងអារម្មណ៍តាមទ្វារត្រចៀក គឺ ឮសំឡេង ។

**ឃានវិញ្ញាណ** បានដល់ ចិត្តដែលដឹងអារម្មណ៍តាមទ្វារច្រមុះ គឺ ធុំក្លិន ។

**ជិវ្ហាវិញ្ញាណ** បានដល់ ចិត្តដែលដឹងអារម្មណ៍តាមទ្វារអណ្តាត គឺ ដឹងរស ។

**កាយវិញ្ញាណ** បានដល់ ចិត្តដែលដឹងអារម្មណ៍តាមទ្វារកាយ គឺដឹងផោដ្ឋព្វៈ ។

ការបញ្ញត្តឈ្មោះហៅ **ចិត្ត** ធម្មជាតិដែលទទួលដឹងអារម្មណ៍នោះ បញ្ញត្តឡើងដោយអាស្រ័យ វេទនា ហេតុ កិច្ច ទ្វារ អារម្មណ៍ និងវត្ថុណាមួយតាមសមគួរ ក្នុងទីនេះចក្ខុវិញ្ញាណជាចិត្តដែលអាស្រ័យចក្ខុ-វត្ថុដឹងអារម្មណ៍តាមចក្ខុទ្វារ កាលរូបារម្មណ៍មកប៉ះខ្ទប់តាមចក្ខុទ្វារ ហៅថា ចក្ខុចិត្ត នឹងឲ្យយល់ថា ចក្ខុនោះជាចិត្ត សេចក្តីពិតចក្ខុមានសភាពជារូបធម៌ដែលមិនអាចដឹងអារម្មណ៍បាន សភាពដែលដឹងអារម្មណ៍ បានដល់វិញ្ញាណដែលជានាមធម៌ តែវិញ្ញាណនេះ អាស្រ័យរូបារម្មណ៍តាមចក្ខុទ្វារទើបហៅថា ចក្ខុវិញ្ញាណ វិញ្ញាណដទៃៗ មានសោតវិញ្ញាណជាដើម ក៏ប្រព្រឹត្តទៅដោយទំនងដូចគ្នា តែចំណែកអកុសលវិបាកចិត្តដ៏សេស ២ ដួង គឺ សម្បដិច្ឆនចិត្ត និងសន្តីរណចិត្តនោះហៅថា ចិត្ត មិនហៅថាវិញ្ញាណ ព្រោះដូចដែលពោលមកហើយ មានចក្ខុវិញ្ញាណជាដើម បញ្ញត្តឡើងដោយអាស្រ័យទ្វារនិងវត្ថុ ដែលជាឈ្មោះរបស់រូបធម៌ជាគោល ដើម្បីការពារមិនឲ្យយល់ខុសថា រូបធម៌នោះជាចិត្ត ចំណែកសម្បដិច្ឆនចិត្ត និងសន្តីរណចិត្តនេះ បញ្ញត្តដោយអាស្រ័យកិច្ច គឺតួនាទីរបស់ចិត្ត ដែលជានាមធម៌ ទើបមិនត្រូវយកពាក្យថា វិញ្ញាណមកប្រើ

ជាន់គ្នាជាមួយចិត្តទៀត ដែលហៅឈ្មោះដោយត្រង់ថា សម្បដិច្ឆនចិត្ត ជាចិត្តដែលធ្វើកិច្ចទទួលបញ្ចារម្មណ៍ដោយត្រង់ និងសន្តីរណចិត្ត ជាចិត្តដែលធ្វើកិច្ចពិចារណាបញ្ចារម្មណ៍ដោយត្រង់ ។

**២. វេទនា** ដែលកើតព្រមជាមួយអកុសលវិបាកចិត្តនោះ មាន ២ វេទនា គឺ **ឧបេក្ខាវេទនា** និង**ទុក្ខវេទនា** **ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ សម្បដិច្ឆនចិត្ត** និង **សន្តីរណចិត្ត** ចិត្តទាំង ៦ ដួងនេះ កើតព្រមជាមួយឧបេក្ខាវេទនា គឺភាពព្រងើយៗ ជាកណ្តាល មិនជាសុខ ឬមិនជាទុក្ខ ព្រោះចិត្តទាំងនោះកើតឡើងដោយការប៉ះខ្ទប់គ្នា រវាងឧបាទាយរូបជាមួយឧបាទាយរូប គឺរូបារម្មណ៍ជាមួយចក្ខុបសាទជាដើម ឧបមាដូចសំឡីប៉ះខ្ទប់ជាមួយសំឡី រមែងមានកម្លាំងនៃការប៉ះខ្ទប់នោះស្រាល ទើបមិនជាហេតុឲ្យកើតសុខវេទនា ឬជាទុក្ខ-វេទនាប្រាកដឡើងបាន ។

ចំណែកកាយវិញ្ញនោះ ចិត្តដឹងផោដ្ឋព្វៈតាមទ្វារកាយ អកុសល-វិបាកកាយវិញ្ញាណចិត្ត រមែងកើតព្រមជាមួយទុក្ខវេទនា ព្រោះកាយវិញ្ញាណនោះ នឹងកើតឡើងបានដោយអាស្រ័យការប៉ះខ្ទប់គ្នារវាងមហាភូតរូប គឺ **បឋវី តេជោ វាយោធាតុ** (វៀរ**អាបោ** គឺធាតុទឹក) ជាមួយឧបាទាយរូប **(កាយបសាទ)** ឧបមាដូចយកញញួរទៅវាយសំឡីដែលដាក់លើដែកទ្រនាប់ រមែងមានកម្លាំងក្នុងការប៉ះខ្ទប់ខ្លាំង

ទើបជាហេតុឲ្យកើតទុក្ខវេទនាប្រាកដឡើងបាន ។

## អហេតុកកុសលវិបាកចិត្ត ៨ ដួង

**អហេតុកកុសលវិបាកចិត្ត** បានដល់ចិត្តដែលជាផលរបស់កុសលកម្ម ឬចិត្តដែលកើតពីអំណាចរបស់កុសលចេតនាក្នុងមហាកុសលចិត្ត ៨ ដួង ដែលកើតឡើងហើយក្នុងអតីត តែព្រោះការខ្វះខាតនៃចេតនាក្នុងកាលទាំង ៣ គឺ ចេតនាមុនការធ្វើកុសលកម្ម ចេតនាខណ:កំពុងធ្វើកុសលកម្ម និងចេតនាខាងក្រោយដែលបានធ្វើកុសលកម្មនោះហើយ ចេតនាក្នុងកាលណាមួយ ទើបធ្វើឲ្យផលនៃកុសលចេតនានោះ មានកម្លាំងខ្សោយ និងឲ្យផលជាអហេតុក គឺ ជាចិត្តដែលកើតឡើងដោយមិនមានកុសលហេតុ បានដល់អលោភហេតុ អទោសហេតុ និងអមោហហេតុ ប្រកបក្នុងឋាន:ជាសម្បយុត្តហេតុ អហេតុកកុសលវិបាកចិត្ត ៨ ដួង ទើបប្រាកដឡើង ជាផលរបស់កុសលកម្មក្នុងអតីត មានចំនួន ៨ ដួង គឺ

**១. ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណំ កុសលវិបាកចិត្តំ ។**

ចិត្តដែលអាស្រ័យចក្ខុវត្ថុកើតព្រមជាមួយឧបេក្ខា ជាផលរបស់កុសលកម្មឃើញរូបដែលជាឥដ្ឋារម្មណ៍ គឺអារម្មណ៍ល្អៗ ។

**២. ឧបេក្ខាសហគតំ សោតវិញ្ញាណំ កុសលវិបាកចិត្តំ ។**

ចិត្តដែលអាស្រ័យសោតវត្ថុកើតព្រមជាមួយឧបេក្ខា ជាផលរបស់

កុសលកម្មឮសំឡេងល្អ ។

**៣. ឧបេក្ខាសហគតំ ឃានវិញ្ញាណំ កុសលវិបាកចិត្តំ ។**

ចិត្តដែលអាស្រ័យឃានវត្ថុកើតព្រមជាមួយឧបេក្ខា ជាផលរបស់កុសលកម្មដឹងក្លិនល្អ ។

**៤. ឧបេក្ខាសហគតំ ជិវ្ហាវិញ្ញាណំ កុសលវិបាកចិត្តំ ។**

ចិត្តដែលអាស្រ័យជិវ្ហាវត្ថុកើតព្រមជាមួយឧបេក្ខា ជាផលរបស់កុសលកម្មដឹងរសល្អ ។

**៥. សុខសហគតំ កាយវិញ្ញាណំ កុសលវិបាកចិត្តំ ។**

ចិត្តដែលអាស្រ័យកាយវត្ថុកើតព្រមជាមួយសុខវេទនា ជាផលរបស់កុសលកម្មដឹងផោដ្ឋព្វៈល្អ ។

**៦. ឧបេក្ខាសហគតំ មនោធាតុ កុសលវិបាកចិត្តំ ។**

ចិត្តដែលកើតឡើងព្រមជាមួយឧបេក្ខា ជាផលរបស់កុសលកម្មធ្វើកិច្ចទទួលអារម្មណ៍ទាំង ៥ ដែលល្អ ។

**៧. ឧបេក្ខាសហគតំ មនោវិញ្ញាណធាតុ អហេតុកកុសលវិបាកចិត្តំ**

ចិត្តដែលកើតឡើងព្រមជាមួយឧបេក្ខា ជាផលរបស់កុសលកម្មធ្វើកិច្ចពិចារណាអារម្មណ៍ទាំង ៥ (ឬ ៦) ដែលជាឥដ្ឋារម្មណ៍។

**៨. សោមនស្សសហគតំ មនោវិញ្ញាណធាតុកុសលវិបាកចិត្តំ**

ចិត្តដែលកើតឡើងព្រមជាមួយសោមនស្ស ជាផលរបស់កុសល-កម្មធ្វើកិច្ចពិចារណាអារម្មណ៍ទាំង ៥ (ឬ ៦) ជាអតិឥដ្ឋារម្មណ៍ ។

# សម្តែងអហេតុកកុសលវិបាកចិត្ត ៨ ដួង

| | | | | |
|---|---|---|---|---|
| អហេតុកកុសល-វិបាកចិត្ត | ឧបេក្ខាសហគត... | ចក្ខុវិញ្ញាណចិត្ត......១<br>សោតវិញ្ញាណចិត្ត...១<br>ឃានវិញ្ញាណចិត្ត... ១<br>ជិវ្ហាវិញ្ញាណចិត្ត...... ១ | = ៤ | ៨ ដួង |
| | សុខសហគត......... | កាយវិញ្ញាណចិត្ត... ១ | = ១ | |
| | ឧបេក្ខាសហគត... | សម្បដិច្ឆនចិត្ត...... ១<br>សន្តីរណចិត្ត......... ១ | = ២ | |
| | សោមនស្សសហគត... | សន្តីរណចិត្ត......... ១ | = ១ | |

អហេតុកកុសលវិបាកចិត្ត ៨ ដួងនេះ ជាចិត្តដែលទទួលអារម្មណ៍តាមបញ្ចទ្វារ ទំនងដូចគ្នាជាមួយអកុសលវិបាកចិត្ត ៧ ដួង ដែលពោលហើយ តែផ្សេងគ្នាត្រង់ថា អហេតុកកុសលវិបាកចិត្តនេះ ជាផលរបស់កុសលកម្មឲ្យឃើញរូប ឮសំឡេង ដឹងក្លិន ដឹងរស ដឹងផោដ្ឋព្វៈ ដែលជាឥដ្ឋារម្មណ៍ និងអតិឥដ្ឋារម្មណ៍ដែលប្រព្រឹត្តទៅដោយន័យផ្ទុយគ្នាជាមួយអកុសលវិបាកចិត្ត ។

**ចំណុចសម្គាល់** អហេតុកកុសលវិបាកចិត្តនោះ មានចំនួន ៨ ដួង ដែលមានច្រើនជាងអកុសលវិបាកចិត្ត ១ ដួង គឺ សោមនស្សសន្តីរណចិត្ត បានជាដូច្នេះ ព្រោះសន្តីរណចិត្ត ជាចិត្តដែលធ្វើកិច្ចក្នុងការពិចារណាអារម្មណ៍ ហើយអារម្មណ៍របស់កុសលវិបាកចិត្តនោះ ចែកជា ២ ប្រភេទ គឺ ឥដ្ឋមជ្ឈត្តារម្មណ៍ ជាអារម្មណ៍ដែលល្អធម្មតាមួយ និង

អតិឥដ្ឋារម្មណ៍ ជាអារម្មណ៍ដែលល្អយ៉ាងក្រៃលែងមួយ កុសលវិបាក-សន្តីរណចិត្តនោះ កាលណាទទួលឥដ្ឋមជ្ឈត្តារម្មណ៍ រមែងកើតឡើងព្រមដោយឧបេក្ខាវេទនា កុសលវិបាកសន្តីរណចិត្តនោះទើបឈ្មោះថា **ឧបេក្ខាសន្តីរណកុសលវិបាកចិត្ត** កាលណាទទួលអតិឥដ្ឋារម្មណ៍ រមែងកើតឡើងព្រមដោយសោមនស្សវេទនា កុសលវិបាកប្រភេទនោះទើបឈ្មោះថា **សោមនស្សសន្តីរណកុសលវិបាកចិត្ត** តែចំណែកអកុសល-វិបាកសន្តីរណចិត្តនោះ កាលណាទទួលអនិដ្ឋមជ្ឈត្តារម្មណ៍ គឺ អារម្មណ៍ដែលមិនល្អធម្មតា ឬបានទទួលអតិអនិដ្ឋារម្មណ៍ អារម្មណ៍ដែលមិនល្អយ៉ាងក្រៃលែង រមែងកើតព្រមដោយឧបេក្ខាវេទនាតែម្យ៉ាង មិនអាចកើតព្រមដោយទោមនស្សវេទនាបាន ព្រោះទោមនស្សវេទនានោះ នឹងត្រូវប្រកបជាមួយទោសមូលចិត្តតែប៉ុណ្ណោះ ដូចបានពោលហើយថា ទោសមូលចិត្តនេះ កាលពោលដោយជាតិរបស់ចិត្តហើយ ក៏ជាអកុសលជាតិ និងកាលពោលដោយហេតុហើយ ក៏ជាអកុសលហេតុ គឺ ទោស-ហេតុ តែសន្តីរណចិត្តនោះ រមែងជាចិត្តដែលជាវិបាកជាតិតែម្យ៉ាង គឺជាចិត្តដែលជាផល និងជាចិត្តដែលមិនប្រកបដោយហេតុផ្សេងៗ ទៀតផង ដូច្នោះអកុសលវិបាកសន្តីរណចិត្ត សូម្បីនឹងទទួលអារម្មណ៍ដែលជាអតិអនិដ្ឋារម្មណ៍ ក៏កើតព្រមដោយទោមនស្សវេទនាមិនបានឡើយ ត្រូវកើតព្រមដោយឧបេក្ខាវេទនានោះឯង ដោយហេតុនេះ អកុសល-វិបាកចិត្ត ទើបត្រូវមានត្រឹម ៧ ដួង តិចជាង **អហេតុកកុសលវិបាកចិត្ត ១ ដួង** ។

ម្យ៉ាងទៀត **ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ** និង **កាយវិញ្ញាណ** ដែលប្រព្រឹត្តទៅទាំងផ្នែកអកុសលវិបាក និងកុសលវិបាកនោះ និយមហៅថា ទ្វិបញ្ចវិញ្ញាណចិត្ត បានដល់ចិត្ត ១០ ដួង ដែលអាស្រ័យកើតតាមទ្វារភ្នែក ត្រចៀក ច្រមុះ អណ្តាត និងកាយ ទាំងផ្នែកល្អនិងមិនល្អដើម្បីប្រយោជន៍ដល់ការចងចាំ និងហៅឈ្មោះចិត្តទាំងនោះឯង ។

## អហេតុកកិរិយាចិត្ត

អហេតុកកិរិយាចិត្ត ជាចិត្តដែលកើតឡើង ដើម្បីធ្វើកិច្ចក្នុងការទទួលអារម្មណ៍ថ្មីតាមទ្វារទាំង ៦ និងធ្វើកិច្ចកាត់ក្តីបញ្ចារម្មណ៍ រហូតដល់ចិត្តដែលធ្វើកិច្ចញញឹម របស់ព្រះអរហន្តទាំងឡាយ ចិត្តដែលកើតឡើងដើម្បីធ្វើកិច្ចនេះ ត្រឹមតែជាចិត្តធ្វើកិច្ច មិនបានកើតឡើងព្រោះអាស្រ័យកុសលហេតុ អកុសលហេតុ ទើបមិនមែនជាចិត្តបុណ្យចិត្តបាប និងមិនមែនជាវិបាកចិត្តដែលជាផលរបស់បុណ្យឬបាប អហេតុកកិរិយាចិត្តនេះមានចំនួន ៣ ដួង ។

## សម្តែងអហេតុកកិរិយាចិត្ត ៣ ដួង

| | | | |
|---|---|---|---|
| អហេតុកកិរិយា | ឧបេក្ខាសហគត... | បញ្ចទ្វារាវជ្ជនចិត្ត.........១ | ៣ ដួង |
| | | មនោទ្វារាវជ្ជនចិត្ត........១ | |
| | សោមនស្សសហគត... | ហសិតុប្បាទចិត្ត....... ១ | |

**១. ឧបេក្ខាសហគតំ មនោធាតុ កិរិយាចិត្តំ ។**

ចិត្តដែលកើតឡើងព្រមដោយឧបេក្ខា ដើម្បីរាវរកអារម្មណ៍តាមបញ្ចទ្វារ ។

សេចក្ដីថា ចិត្តដួងនេះ ជាចិត្តដែលធ្វើកិច្ចរាវរកអារម្មណ៍ ដែលមកប៉ះខ្ទប់ទ្វារនោះៗ ឧបមាដូចនាយទ្វារដែលរក្សាទ្វារព្រះរាជវាំងដែលចាំបើកទ្វារឲ្យភ្ញៀវចូលមកតាមឋានៈរបស់បុគ្គល មិនបានគិតតាមទៅធ្វើកិច្ចយ៉ាងដទៃឡើយ ។

**២. ឧបេក្ខាសហគតំ មនោវិញ្ញាណធាតុ អហេតុកកិរិយាចិត្តំ ។**

ចិត្តដែលកើតឡើងព្រមដោយឧបេក្ខា រាវរកអារម្មណ៍តាមមនោទ្វារ ។

សេចក្ដីថា ចិត្តដួងនេះ ជាចិត្តដែលមានកិច្ចរាវរកអារម្មណ៍ ៦ ឬជាចិត្តដែលធ្វើកិច្ចកាត់ក្ដីបញ្ចារម្មណ៍តាមបញ្ចទ្វារ ។

**៣. សោមនស្សសហគតំ មនោវិញ្ញាណធាតុអហេតុកកិរិយាចិត្តំ**

ចិត្តដែលកើតឡើងព្រមដោយសោមនស្សធ្វើការញញឹម របស់ព្រះអរហន្តដែលកើតឡើង ។ ព្រោះការឃើញប្រេតដែលកំពុងទទួលទុក្ខជាការឃើញដោយអភិញ្ញាកិរិយាចិត្ត ដែលប្រព្រឹត្តទៅព្រមដោយការពិចារណាថា សភាពបែបនេះនឹងមិនប្រាកដដល់អាត្មាអញតទៅទៀតឡើយ ជាការពិចារណាដោយមហាកិរិយាញាណសម្បយុត្តចិត្តមុន កាលពិចារណាហើយហសិតុប្បាទចិត្តទើបកើតឡើង ដូចជាប្រាកដក្នុងអភិធម្មត្ថសង្គហៈថា **ហសិតុប្បាទចិត្តេន បន បវត្តិយមានម្បិ តេសំ**

**សិតករណំ បុព្វេនិវាសអនាគតំសសព្វញ្ញុតញ្ញាណានំ អនុវត្តកត្តា ញ្ញាណានុបរិវត្តិយេវាតិ** ។ ការញញឹមរបស់ព្រះអរហន្តទាំងនោះ សូម្បីដោយហសិតុប្បាទចិត្ត ក៏ឈ្មោះថាប្រព្រឹត្តទៅតាម បុព្វេនិវាសានុស្សតិ-ញ្ញាណ អនាគតំសញ្ញាណ សព្វញ្ញុតញ្ញាណ ។

បានសេចក្តីថា កាលអភិញ្ញាចិត្តឃើញសត្វទាំងនោះហើយ មហាកិរិយាចិត្តក៏ពិចារណាថា សភាពបែបនេះមិនមានដល់អាត្មាអញឡើយ ហសិតុប្បាទចិត្តទើបកើតឡើង ទាំងនេះព្រោះអភិញ្ញាចិត្ត រមែងកើតតែមួយខណៈប៉ុណ្ណោះ តទៅទើបជានាទីរបស់មហាកិរិយាចិត្ត ជាអ្នកពិចារណា ហើយក៏សេពអារម្មណ៍ដោយហសិតុប្បាទចិត្ត ទើបធ្វើឲ្យអាការញញឹម ប្រភេទដែលជា **សិត** និង**ហសិត** ប្រាកដឡើងមក ។

## ការញញឹមនិងការសើច

ការញញឹមនិងការសើច ក្នុងគម្ពីរសុពោធាលង្ការបានចែកទុក ៦ យ៉ាង គឺ

**១. សិត** ញញឹមមិនឃើញធ្មេញជាការញញឹមរបស់ព្រះពុទ្ធជាម្ចាស់

**២. ហសិត** ញញឹមល្មមឃើញធ្មេញជាការញញឹមដែលកើតអំពីចិត្តរបស់ព្រះអរហន្ត ឬព្រះអនាគាមី ព្រះសកទាគាមី ព្រះសោតាបន្ន និងបុថុជ្ជន តែការញញឹមប្រភេទនេះក្រៅពីព្រះអរហន្តហើយ រមែងជាការញញឹមដែលប្រកបដោយកុសលហេតុ ឬអកុសលហេតុ ។

**៣. វិហសិត** ការសើចសំឡេងតិចៗ កើតអំពីចិត្តរបស់បុថុជ្ជន និង ព្រះអរិយបុគ្គល ៣ ពួក គឺ ព្រះសោតាបន្ន ព្រះសកទាគាមី និង ព្រះអនាគាមី ។

**៤. អតិហសិត** ការសើចមានសំឡេងខ្លាំងដែលមានក្នុងបុថុជ្ជន ព្រះសោតាបន្ន និងព្រះសកទាគាមី ។

**៥. អបហសិត** ការសើចរហូតដល់ញ័រទាំងកាយ ជាការសើច របស់បុថុជ្ជន ។

**៦. ឧបហសិត** ការសើចរហូតដល់ហូរទឹកភ្នែក ជាការសើច របស់បុថុជ្ជនប៉ុណ្ណោះ ។

ការញញឹមនិងការសើចទាំង ៦ ប្រការ ដែលពោលមកនេះ ក៏ រមែងឃើញបានថា ការញញឹមខាងក្នុងមិនឃើញធ្មេញ ឈ្មោះថា **សិត** ដែលកើតបានចំពោះព្រះសម្មាសម្ពុទ្ធជាម្ចាស់ប៉ុណ្ណោះ និងការញញឹម ឃើញធ្មេញដែលកើតជាមួយព្រះអរហន្តនោះ ជាចិត្តដែលធ្វើឲ្យកើត ការញញឹមដោយមិនប្រកាន់មាំក្នុងអារម្មណ៍ ដូចយ៉ាងចិត្តដែលកើតការ សើចដទៃៗ ចិត្តនេះទើបមានកម្លាំងតិច ជាចិត្តពិសេស ហៅថា **ហសិតុប្បាទចិត្ត** ដែលអាចធ្វើឲ្យកើតការញញឹមបានត្រឹមតែប្រភេទជា **សិត** និង **ហសិត** ប៉ុណ្ណោះ និងការដែលចិត្តនេះមានកម្លាំងតិចនេះឯង ទើបជាអហេតុកចិត្ត ចំណែកចិត្តដែលកើតការសើចនោះ រមែងជាចិត្ត ដែលមានកម្លាំងខ្លាំង និងប្រកាន់មាំក្នុងអារម្មណ៍ ជាហេតុឲ្យដល់ការ សើចក្នុងលក្ខណៈផ្សេងៗ ទើបជាសហេតុកចិត្ត ។

# សង្ខារភេទនៃអហេតុកចិត្ត

**អហេតុកចិត្ត** ទាំង ១៨ ដួងនេះ មិនបានសម្តែងទុកថា ជាចិត្តប្រភេទអសង្ខារិកចិត្ត ឬសសង្ខារិកចិត្តណាមួយឡើយ តាមសាធកៈដែលប្រាកដក្នុងវាទផ្សេងៗ ដែលទាក់ទងនឹងសង្ខារភេទរបស់អហេតុកចិត្តនេះ រួមបានជា ៣ ន័យ គឺ

១. ក្នុងមូលដីកា និងអភិធម្មត្ថវិភាវិនីដីកា ពោលថា ជាសង្ខារវិមុត្តិទាំង ១៨ ដួង ព្រោះមិនមានព្រះបាលីបញ្ជាក់ទុកទីណាឡើយថា ជាអសង្ខារិក ឬសសង្ខារិក កាលមិនមានបាលីសម្តែងទុកក៏ត្រូវកាន់យកថា ជាសង្ខារវិមុត្តិ គឺ ផុតចាកអសង្ខារិក និងសសង្ខារិក ។

២. ក្នុងបរមត្ថទីបនីដីកា ពោលថា បានទាំងអសង្ខារិក និងសសង្ខារិកទាំង ១៨ ដួង ព្រោះក្នុងមរណាសន្នកាល គឺ វេលាដែលជិតស្លាប់ វីថិចិត្តផ្សេងៗ នឹងប្រាកដឡើងឯង ឬអាចនឹងមានអ្នកណាម្នាក់ដឹកនាំឲ្យមើលព្រះពុទ្ធរូប ឬឲ្យស្តាប់សំឡេងសូត្រធម៌ជាដើមក៏បាន ទើបចាត់ថាជាសង្ខារបានទាំង ២ យ៉ាង ។

៣. បូរាណាចារ្យ ពោលថា ជាអសង្ខារិកចិត្តទាំង ១៨ ដួង ព្រោះការឃើញរូប ឮសំឡេង ដឹងក្លិន ដឹងរស ដឹងផោដ្ឋព្វៈ ទាំងនេះ រមែងឃើញ ឮ ដឹងក្លិន ដឹងរស បានប៉ះត្រូវផោដ្ឋព្វៈដោយខ្លួនឯង អាស្រ័យឧប្បត្តិហេតុ ឲ្យចិត្តទាំងនេះកើតឡើង ទើបពោលថាជាអសង្ខារិកទាំង ១៨ ដួង ។

អហេតុកចិត្តទាំង ១៨ ដួង ទើបសង្គ្រោះចូលក្នុងអសង្ខារិក ព្រោះ អហេតុកចិត្តនេះរមែងកើតឡើងឯង ដោយអាស្រ័យឧប្បត្តិហេតុ ប្រជុំគ្នាឲ្យកើត សូម្បីមានអ្នកណាមកដឹកនាំក្តី តែបើឧប្បត្តិហេតុ មានមិនគ្រប់អង្គដោយបរិបូណ៌ហើយ ចិត្តដែលឃើញរូប ឮសំឡេង ដឹងក្លិនជាដើម ក៏កើតឡើងមិនបាន ។

**អហេតុកចិត្ត** ជាចិត្តដែលមិនមានហេតុ ៦ គឺ **លោភហេតុ ទោស-ហេតុ មោហហេតុ អលោភហេតុ អទោសហេតុ និង អមោហហេតុ** ប្រកបជាមួយឡើយ បើចិត្តណាមានហេតុមួយ ឬហេតុច្រើន ក្នុងហេតុ ៦ ដូចពោលនោះ ប្រកបជាមួយចិត្តទាំងនោះ ហៅថា **សហេតុកចិត្ត** ព្រោះការប្រកបដោយហេតុរបស់ចិត្តទាំងនោះ ហៅថា **សម្បយុត្តហេតុ** ។

ព្រោះដូច្នោះ **អហេតុកចិត្ត** ទើបសំដៅដល់ ចិត្តដែលមិនមាន **សម្បយុត្តហេតុ** តែធម៌ទាំងឡាយរមែងកើតពីហេតុ ឬមានហេតុជាដែនកើត ហេតុដែលពោលនេះមិនមែនហេតុ ៦ ដែលប្រកបជាមួយចិត្តដែលជាសម្បយុត្តហេតុដូចពោលឡើយ តែជាហេតុដែលធ្វើឲ្យចិត្តកើតឡើងបាន ព្រោះអាស្រ័យហេតុនោះ ហេតុដែលធ្វើឲ្យចិត្តកើតឡើងនេះហៅថា ឧប្បត្តិហេតុ ព្រោះដូច្នោះ អហេតុកចិត្តនឹងប្រាកដឡើងបានក៏ត្រូវអាស្រ័យឧប្បត្តិហេតុ គឺ ហេតុដែលធ្វើឲ្យចិត្តកើតដោយប្រការផ្សេងៗ ដូច្នេះ គឺ

# ឧប្បត្តិហេតុនៃអហេតុកចិត្ត ១៨ ដួង

ហេតុដែលធ្វើឲ្យអហេតុកចិត្ត ១៨ ដួង កើតឡើងបាននោះមានដូចតទៅនេះ គឺ

## ហេតុនាំឲ្យកើតចក្ខុវិញ្ញាណចិត្ត ២ ដួង

១. **អសម្ភិន្នត្តា ចក្ខុស្ស** ព្រោះចក្ខុបសាទមិនទាន់បែកធ្លាយ

២. **អាបាថគតត្តា រូបានំ** ព្រោះរូបមកកាន់គន្លងនៃចក្ខុបសាទ

៣. **អាលោកសន្និស្សិតំ** អាស្រ័យដោយពន្លឺ

៤. **មនសិការហេតុកំ** មានមនសិការជាហេតុ(**បញ្ចទ្វារាវជ្ជនចិត្ត**) ។

## ហេតុនាំឲ្យកើតសោតវិញ្ញាណចិត្ត ២ ដួង

១. **អសម្ភិន្នត្តា សោតស្ស** ព្រោះសោតបសាទមិនទាន់បែកធ្លាយ

២. **អាបាថគតត្តា សទ្ទានំ** ព្រោះសំឡេងមកកាន់គន្លងនៃសោតប្បសាទ

៣. **អាកាសសន្និស្សិតំ** អាស្រ័យអាកាស (លំហ)

៤. **មនសិការហេតុកំ** មានមនសិការជាហេតុ (**បញ្ចទ្វារាវជ្ជនចិត្ត**)។

## ហេតុនាំឲ្យកើតឃានវិញ្ញាណចិត្ត ២ ដួង

១. **អសម្ភិន្នត្តា ឃានស្ស** ព្រោះឃានបសាទមិនទាន់បែកធ្លាយ

**២. អាបាថគតត្តា គន្ធានំ** ព្រោះក្លិនមកកាន់គន្លងនៃឃានបសាទ

**៣. វាយោសន្និស្សិតំ** អាស្រ័យវាយោ(ខ្យល់)

**៤. មនសិការហេតុកំ** មានមនសិការជាហេតុ (**បញ្ចទ្វារាវជ្ជនចិត្ត**)។

## ហេតុនាំឲ្យកើតជិវ្ហាវិញ្ញាណចិត្ត ២ ដួង

**១. អសម្ភិន្នត្តា ជិវ្ហាយ** ព្រោះជិវ្ហាបសាទមិនទាន់បែកធ្លាយ

**២. អាបាថគតត្តា រសានំ** ព្រោះរសមកកាន់គន្លងនៃជិវ្ហាបសាទ

**៣. អាបោសន្និស្សិតំ** អាស្រ័យអាបោ គឺទឹក

**៤. មនសិការហេតុកំ** មានមនសិការជាហេតុ(**បញ្ចទ្វារាវជ្ជនចិត្ត**) ។

## ហេតុនាំឲ្យកើតកាយវិញ្ញាណចិត្ត ២ ដួង

**១. អសម្ភិន្នត្តា កាយស្ស** ព្រោះកាយបសាទមិនទាន់បែកធ្លាយ

**២. អាបាថគតត្តា ផោដ្ឋព្វានំ** ព្រោះផោដ្ឋព្វៈមកកាន់គន្លងនៃកាយបសាទ

**៣. បឋវីសន្និស្សិតំ** អាស្រ័យបឋវី

**៤. មនសិការហេតុកំ** មានមនសិការជាហេតុជិត(**បញ្ចទ្វារាវជ្ជន-ចិត្ត**) ។

ចក្ខុវិញ្ញាណចិត្ត ២ ដួង សោតវិញ្ញាណចិត្ត ២ ដួង ឃានវិញ្ញាណចិត្ត ២ ដួង ជិវ្ហាវិញ្ញាណចិត្ត ២ ដួង និងកាយវិញ្ញាណចិត្ត ២ ដួង រួមចិត្ត ១០ ដួងនេះហៅថា ទ្វិបញ្ចវិញ្ញាណចិត្ត ។

## ហេតុនាំឲ្យកើតមនោធាតុ ៣[១] ដួង

**១. អសម្ភិន្នត្តា បសាទស្ស** ព្រោះបសាទរូប មិនទាន់បែកធ្លាយ

**២. អាបាថគតត្តា បញ្ចារម្មណានំ** មានអារម្មណ៍ទាំង ៥ គឺរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ មកកាន់គន្លង

**៣. ហទយសន្និស្សិតំ** អាស្រ័យហទយវត្ថុរូប

**៤. មនសិការហេតុកំ** មានមនសិការជាហេតុ ។

**មនោធាតុ** ជាចិត្តដែលដឹងអារម្មណ៍តិចជាងចិត្តដួងដទៃៗ មាន ៣ ដួង គឺ បញ្ចទ្វារាវជ្ជនចិត្ត ១ ដួង និងសម្បដិច្ឆនចិត្ត ២ ដួង រួមចិត្ត ៣ ដួងនេះហៅថា មនោធាតុ ។

## ហេតុនាំឲ្យកើតមនោវិញ្ញាណធាតុនៃអហេតុកចិត្ត ៥ ដួង

**១. អសម្ភិន្នត្តា មនស្ស** ព្រោះមនោមិនទាន់បែកធ្លាយ

**២. អាបាថគតត្តា ធម្មានំ** ព្រោះមានធម្មារម្មណ៍មកកាន់គន្លង

**៣. វត្ថុសន្និស្សិតំ** អាស្រ័យហទយវត្ថុរូប (វៀរអរូបព្រហ្ម)

**៤. មនសិការហេតុកំ** មានមនសិការជាហេតុ ។

## មនោវិញ្ញាណធាតុ

មនោវិញ្ញាណធាតុ ជាចិត្តដែលមានការដឹងអារម្មណ៍បានច្រើនជាងបញ្ចវិញ្ញាណ និងមនោធាតុ ក្នុងអហេតុកចិត្តមានមនោវិញ្ញាណធាតុ

[១] នៅក្នុងអដ្ឋសាលិនី មិនបានសម្តែងហេតុកើតឡើងរបស់ មនោធាតុ ៣ គឺ បញ្ចទ្វារាវជ្ជនចិត្ត ១ និងសម្បដិច្ឆនចិត្ត ២ ទេ ។

៥ ដួង គឺ មនោទ្វារាវជ្ជនចិត្ត ១ ហសិតុប្បាទចិត្ត ១ និងសន្តីរណចិត្ត ៣ រួមជាមនោវិញ្ញាណធាតុ ៥ តាមពិតនោះចិត្តទាំងអស់មាន ៨៩ ឬ ១២១ ដួង ក្រៅអំពីទ្វិបញ្ចវិញ្ញាណចិត្ត ១០ ដួង និងមនោធាតុ ៣ ដួង ហើយក្រៅពីនោះចិត្តដ៏សេស ៧៦ ឬ ១០៨ ដួង ទាំងអស់នោះ ជាមនោវិញ្ញាណធាតុ ។

ហេតុផ្សេងៗ ដែលធ្វើឲ្យចក្ខុវិញ្ញាណជាដើមកើតឡើងបាននោះ សម្តែងឲ្យឃើញថា កាលមានហេតុប្រជុំគ្នាទាំង ៤ យ៉ាង គ្រប់បរិបូណ៌ ហើយ ការឃើញ ឬចក្ខុវិញ្ញាណជាដើម រមែងកើតឡើងភ្លាម មិនមានវត្ថុដទៃណា នឹងហាមឃាត់ការឃើញបានឡើយ បើខ្វះហេតុណាមួយ មិនគ្រប់បរិបូណ៌ទាំង ៤ ហើយ ក៏មិនមានអ្នកណានឹងជួយឲ្យការឃើញកើតឡើងបានឡើយ ។

ដូច្នោះ បើនឹងពិចារណាឲ្យល្អហើយ សភាវៈដែលប្រព្រឹត្តទៅក្នុងការឃើញ ការឮជាដើមនោះ ត្រូវអាស្រ័យមានហេតុបច្ច័យធ្វើឲ្យប្រាកដផលឡើង និងធម៌ដែលជាហេតុបច្ច័យនោះ ក៏សុទ្ធតែមានភាពជាអនត្តា មិននៅក្នុងអំណាចបង្គាប់បញ្ជារបស់អ្នកណាបាន រកតួខ្លួនមិនបាន មានតែនាមរូបប៉ុណ្ណោះ តែព្រោះមោហៈគឺអវិជ្ជាបិទបាំងនូវសភាវៈពិត ធ្វើឲ្យបុថុជ្ជនទាំងឡាយ វង្វេងត្រេកអរជាប់ចិត្តក្នុងអារម្មណ៍ដែលកើតតាមទ្វារផ្សេងៗ ។

## ក្នុងអដ្ឋសាលិនីនិងវិសុទ្ធិមគ្គអដ្ឋកថាបានឧបមាទ្វារិកចិត្តទាំង ៦ ទុកថា

ភ្នែកដូចជាពស់ ចូលចិត្តនៅក្នុងទីកំបាំង ភ្នែកក៏ចង់ឃើញវត្ថុដែលបិទបាំងទុក ។

ត្រចៀកដូចជាក្រពើ ដែលចូលចិត្តនៅក្នុងអន្លង់ទឹកដែលត្រជាក់ៗ ត្រចៀកក៏ចូលចិត្តស្តាប់ពាក្យដែលទន់ភ្លន់ ។

ច្រមុះដូចជាសត្វបក្សី ដែលចូលចិត្តហើរទៅក្នុងអាកាស ច្រមុះក៏ចូលចិត្តស្រូបក្លិនក្រអូបដែលអណ្តែតតាមខ្យល់បក់មក ។

អណ្តាតដូចជាឆ្កែស្រុក ដែលចូលចិត្តឲ្យទឹកមាត់ហូររៀយៗ អណ្តាតក៏ចង់ភ្លក់រសរៀយៗ ដូចគ្នា ។

កាយដូចជាឆ្កែព្រៃ ដែលចូលចិត្តស៊ីសាច់មនុស្សក្នុងព្រៃស្មសាន កាយក៏ចូលចិត្តប៉ះខ្ទប់តាមផ្លូវកាយ ។

ចិត្តដូចជាស្វា ដែលចូលចិត្តរពឹសនៅមិនស្ងៀម ចិត្តក៏ចូលចិត្តត្រាច់ទៅក្នុងអារម្មណ៍ផ្សេងៗ ដែលនៅមិនស្ងៀមដូចគ្នា ។

## កិច្ចរបស់អហេតុកចិត្ត ១៨ ដួង

**ចក្ខុវិញ្ញាណ** ២ ដួង ធ្វើទស្សនកិច្ច គឺកិច្ចឃើញរូបារម្មណ៍ ។

**សោតវិញ្ញាណ** ២ ដួង ធ្វើសវនកិច្ច គឺកិច្ចឮសទ្ទារម្មណ៍ ។

**ឃានវិញ្ញាណ** ២ ដួង ធ្វើឃាយនកិច្ច គឺកិច្ចដឹងគន្ធារម្មណ៍ ។

**ជិវ្ហាវិញ្ញាណ** ២ ដួង ធ្វើសាយនកិច្ច គឺកិច្ចដឹងរសារម្មណ៍ ។

**កាយវិញ្ញាណ** ២ ដួង ធ្វើផុសនកិច្ច គឺកិច្ចដឹងផោដ្ឋព្វារម្មណ៍។

**វិបាកមនោធាតុ** ២ ដួង ធ្វើសម្បដិច្ឆនកិច្ច គឺកិច្ចទទួលបញ្ចារម្មណ៍។

ឧបេក្ខាអហេតុកវិបាក មនោវិញ្ញាណធាតុ ២ ដួង ធ្វើ
- **បដិសន្ធិកិច្ច** គឺកិច្ចកើតក្នុងភពថ្មី
- **ភវង្គកិច្ច** គឺកិច្ចរក្សាភព
- **ចុតិកិច្ច** គឺកិច្ចឃ្លាតចាកភព
- **សន្តីរណកិច្ច** គឺកិច្ចពិចារណាអារម្មណ៍
- **តទាលម្ពនកិច្ច** គឺកិច្ចទទួលអារម្មណ៍-តពីជវនៈ ។

សោមនស្សអហេតុកវិបាក មនោវិញ្ញាណធាតុ ១ ដួង ធ្វើ
- **សន្តីរណកិច្ច** គឺពិចារណាអារម្មណ៍
- **តទាលម្ពនកិច្ច** គឺទទួលអារម្មណ៍តពីជវនៈ។

**បញ្ចទ្វារាវជ្ជនចិត្ត** ១ ដួង ធ្វើ**អាវជ្ជនកិច្ច** គឺរាវរកបញ្ចារម្មណ៍តាមបញ្ចទ្វារ ។

**មនោទ្វារាវជ្ជន** ១ ដួង ធ្វើ
- **អាវជ្ជនកិច្ច** គឺទទួលអារម្មណ៍ ៦ តាមមនោទ្វារ
- **វោដ្ឋព្វនកិច្ច** គឺកាត់ក្តីបញ្ចារម្មណ៍ ថាល្អឬមិនល្អតាមបញ្ចទ្វារ ។

**ហសិតុប្បាទចិត្ត** ១ ដួង ធ្វើជវនកិច្ច គឺសេពអារម្មណ៍ធ្វើឲ្យកើតការញញឹមរបស់ព្រះអរហន្ត ។

## ទ្វាររបស់អហេតុកចិត្ត ១៨ ដួង

-**ចក្ខុវិញ្ញាណ** ២ ដួង អាស្រ័យកើតតាម ចក្ខុទ្វារ

-**សោតវិញ្ញាណ** ២ ដួង អាស្រ័យកើតតាម សោតទ្វារ

-**ឃានវិញ្ញាណ** ២ ដួង អាស្រ័យកើតតាម ឃានទ្វារ

-**ជិវ្ហាវិញ្ញាណ** ២ ដួង អាស្រ័យកើតតាម ជិវ្ហាទ្វារ

-**កាយវិញ្ញាណ** ២ ដួង អាស្រ័យកើតតាម កាយទ្វារ

-**មនោធាតុអហេតុកកិរិយាចិត្ត ១ ដួង**
-**មនោធាតុអហេតុកវិបាកចិត្ត ២ ដួង**
} អាស្រ័យកើតតាមបញ្ចទ្វារ

-មនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ១ ដួង
-មនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត ៣ ដួង
-សោមនស្សមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ១ ដួង
} កើតតាមទ្វារទាំង ៦

## វត្ថុរបស់អហេតុកចិត្ត ១៨ ដួង

-**ចក្ខុវិញ្ញាណ** ២ ដួង កើតអាស្រ័យចក្ខុវត្ថុ

-**សោតវិញ្ញាណ** ២ ដួង កើតអាស្រ័យសោតវត្ថុ

-**ឃានវិញ្ញាណ** ២ ដួង កើតអាស្រ័យឃានវត្ថុ

-**ជិវ្ហាវិញ្ញាណ** ២ ដួង កើតអាស្រ័យជិវ្ហាវត្ថុ

-**កាយវិញ្ញាណ** ២ ដួង កើតអាស្រ័យកាយវត្ថុ

-**វិបាកមនោធាតុ** ២ ដួង កើតអាស្រ័យហទយវត្ថុ

-**អហេតុកវិបាកមនោវិញ្ញាណធាតុ** ៣ ដួង កើតអាស្រ័យហទយវត្ថុ

-**បញ្ចទ្វារាវជ្ជនចិត្ត** ១ ដួង កើតអាស្រ័យហទយវត្ថុ

-**មនោទ្វារាវជ្ជនចិត្ត** ១ ដួង កើតអាស្រ័យហទយវត្ថុ

-**ហសិតុប្បាទចិត្ត** ១ ដួង កើតអាស្រ័យហទយវត្ថុ ។

# អារម្មណ៍របស់អហេតុកចិត្ត ១៨

-**ចក្ខុវិញ្ញាណ** ២ ដួង ដឹងរូបារម្មណ៍ គឺឃើញពណ៌ផ្សេងៗ

-**សោតវិញ្ញាណ** ២ ដួង ដឹងសទ្ទារម្មណ៍ គឺឮសំឡេងផ្សេងៗ

-**ឃានវិញ្ញាណ** ២ ដួង ដឹងគន្ធារម្មណ៍ គឺដឹងក្លិនផ្សេងៗ

-**ជិវ្ហាវិញ្ញាណ** ២ ដួង ដឹងរសារម្មណ៍ គឺដឹងរសផ្សេងៗ

-**កាយវិញ្ញាណ** ២ ដួង ដឹងផោដ្ឋព្វារម្មណ៍ គឺត្រជាក់ ក្តៅ រឹង ទន់ តឹង ញ័រ ។

| | | |
|---|---|---|
| **បញ្ចទ្វារាវជ្ជនចិត្ត** ១ ដួង<br>**វិបាកមនោធាតុ** ២ ដួង | ដឹងរូបារម្មណ៍<br>ដឹងសទ្ទារម្មណ៍<br>ដឹងគន្ធារម្មណ៍<br>ដឹងរសារម្មណ៍<br>ដឹងផោដ្ឋព្វារម្មណ៍ | អារម្មណ៍ ៥ |
| **មនោទ្វារាវជ្ជនចិត្ត** ១ ដួង<br>**អហេតុកវិបាកមនោវិញ្ញាណធាតុ** ៣ ដួង<br>**ហសិតុប្បាទចិត្ត** ១ ដួង | ដឹងរូបារម្មណ៍<br>ដឹងសទ្ទារម្មណ៍<br>ដឹងគន្ធារម្មណ៍<br>ដឹងរសារម្មណ៍<br>ដឹងផោដ្ឋព្វារម្មណ៍<br>ដឹងធម្មារម្មណ៍ | អារម្មណ៍ ៦ |

# សម្តែងការកើតរបស់អហេតុកចិត្ត ១៨ ដោយវីថិ

បញ្ចទ្វារវីថិ អតិមហន្តារម្មណ៍

| | | | |
|---|---|---|---|
| ផុតវីថិ | វិបាក | ១ អតីតភវង្គ | ភវង្គដើម |
| | | ២ ភវង្គចលនៈ | ភវង្គញ័រ |
| | | ៣ ភវង្គុបច្ឆេទៈ | កាត់ផ្តាច់ខ្សែភវង្គ |
| វីថិ | កិរិយា | ៤ បញ្ចទ្វារាវជ្ជនៈ | វាររកបញ្ចារម្មណ៍ដែលមកប៉ះខ្ទប់ |
| | វិបាក | ៥ បញ្ចវិញ្ញាណ | ចក្ខុ សោត ឃាន ជិវ្ហា កាយវិញ្ញាណ (ទ្វិបញ្ចវិញ្ញាណ ១០ ដួង) |
| | | ៦ សម្បដិច្ឆនៈ | ទទួលបញ្ចារម្មណ៍ (សម្បដិច្ឆនចិត្ត ២ ដួង) |
| | | ៧ សន្តីរណៈ | ពិចារណាបញ្ចារម្មណ៍ (សន្តីរណចិត្ត ៣ ដួង) |
| | កិរិយា | ៨ វោដ្ឋព្វនៈ | កាត់ក្តីអារម្មណ៍ជាកុសល អកុសល ឬកិរិយា (មនោទ្វារាវជ្ជនចិត្ត ១ ដួង) |
| | កុសល អកុសល ឬកិរិយា | ៩ ជវនៈ<br>១០ ជវនៈ<br>១១ ជវនៈ<br>១២ ជវនៈ<br>១៣ ជវនៈ<br>១៤ ជវនៈ<br>១៥ ជវនៈ | ជវនៈក្នុងអហេតុកចិត្ត បានដល់ ហសិតុប្បាទចិត្ត ១ ដួង សេពអារម្មណ៍ឲ្យសម្រេចជាកិរិយា |
| | វិបាក | ១៦ តទាលម្ពនៈ<br>១៧ តទាលម្ពនៈ | ទទួលអារម្មណ៍តពីជវនៈ (សន្តីរណ ៣ ដួង-មហាវិបាក ៨ ដួង) សម្រាប់អហេតុកចិត្ត បានដល់ តទាលម្ពនចិត្ត គឺសន្តីរណចិត្ត ៣។ |

# ប្លង់អហេតុកចិត្ត ១៨ ដួង

- អហេតុកចិត្ត =១៨
  - អកុសលវិបាក ៧
    - ឧបេក្ខាសហគត ៤
      - ចក្ខុវិញ្ញាណចិត្ត ១
      - សោតវិញ្ញាណចិត្ត១
      - ឃានវិញ្ញាណចិត្ត ១
      - ជិវ្ហាវិញ្ញាណចិត្ត ១
    - ទុក្ខសហគត — កាយវិញ្ញាណចិត្ត ១
    - ឧបេក្ខាសហគត ២
      - មនោធាតុ ១
      - មនោវិញ្ញាណធាតុ១
  - អហេតុកកុសលវិបាក ៨
    - ឧបេក្ខាសហគត ៤
      - ចក្ខុវិញ្ញាណចិត្ត ១
      - សោតវិញ្ញាណចិត្ត១
      - ឃានវិញ្ញាណចិត្ត១
      - ជិវ្ហាវិញ្ញាណចិត្ត ១
    - សុខសហគត — កាយវិញ្ញាណចិត្ត ១
    - ឧបេក្ខាសហគត ២
      - មនោធាតុ ១
      - មនោវិញ្ញាណធាតុ១
    - សោមនស្សសហគត—មនោវិញ្ញាណធាតុ១
  - អហេតុកកិរិយា ៣
    - ឧបេក្ខាសហគត ២
      - បញ្ចទ្វារាវជ្ជនចិត្ត ១
      - មនោទ្វារាវជ្ជនចិត្ត ១
    - សោមនស្សសហគត—ហសិតុប្បាទចិត្ត ១

# អហេតុកចិត្ត ១៨ ជាវិញ្ញាណធាតុ ៧

**ចក្ខុវិញ្ញាណ** ២ ដួង ជា**ចក្ខុវិញ្ញាណធាតុ**
**សោតវិញ្ញាណ** ២ ដួង ជា**សោតវិញ្ញាណធាតុ**
**ឃានវិញ្ញាណ** ២ ដួង ជា**ឃានវិញ្ញាណធាតុ** } **បញ្ចវិញ្ញាណធាតុ ៥**
**ជិវ្ហាវិញ្ញាណ** ២ ដួង ជា**ជិវ្ហាវិញ្ញាណធាតុ**
**កាយវិញ្ញាណ** ២ ដួង ជា**កាយវិញ្ញាណធាតុ**

**សម្បដិច្ឆនចិត្ត** ២ ដួង
**បញ្ចទ្វារាវជ្ជនចិត្ត** ១ ដួង } ជា......មនោធាតុ......... ១

**សន្តីរណចិត្ត** ៣ ដួង
**មនោទ្វារាវជ្ជនចិត្ត** ១ ដួង } ជា **មនោវិញ្ញាណធាតុ** ១
**ហសិតុប្បាទចិត្ត** ១ ដួង

=៧

**វិញ្ញាណធាតុ** សំដៅដល់ ធាតុដឹងអារម្មណ៍របស់ចិត្ត ចិត្តទាំងអស់ ៨៩ ឬ ១២១ ដួងនោះ មានការដឹងអារម្មណ៍មិនស្មើគ្នា គឺមានការដឹងអារម្មណ៍ ៣ យ៉ាង គឺ

## បញ្ចវិញ្ញាណធាតុ

ជាចិត្តដែលមាននាទីដឹងអារម្មណ៍ដែលមកប៉ះខ្ទប់ដោយចំពោះទ្វាររបស់ខ្លួនៗ ដោយត្រង់ ទើបដឹងអារម្មណ៍បានច្រើន យ៉ាងកណ្តាលបានដល់ ចិត្ត ១០ ដួង គឺ ទ្វិបញ្ចវិញ្ញាណចិត្ត ១០ ។

## មនោធាតុ

ជាចិត្តដែលដឹងអារម្មណ៍បានតិចបំផុត ព្រោះបញ្ចទ្វារាវជ្ជនចិត្ត ជាចិត្តដែលកើតឡើងទទួលអារម្មណ៍ជាខណៈដំបូង និងសម្បដិច្ឆនក៏ ជាចិត្តដែលកើតអាស្រ័យហទយវត្ថុ ទទួលបញ្ចារម្មណ៍តពីបញ្ចវិញ្ញាណ ដែលចិត្តទាំង ២ នេះអាស្រ័យវត្ថុផ្សេងគ្នាកើតឡើង គឺបញ្ចវិញ្ញាណចិត្ត អាស្រ័យបញ្ចវត្ថុ សម្បដិច្ឆនចិត្តអាស្រ័យហទយវត្ថុ ព្រោះចិត្តអាស្រ័យ វត្ថុផ្សេងគ្នា រមែងមានកម្លាំងខ្សោយ មនោធាតុនេះទើបដឹងអារម្មណ៍ តិចបំផុត បានដល់ ចិត្ត ៣ ដួង គឺ បញ្ចទ្វារាវជ្ជនចិត្ត ១ និងសម្បដិច្ឆន ចិត្ត ២ ។

## មនោវិញ្ញាណធាតុ

ជាចិត្តដែលដឹងអារម្មណ៍ច្រើនបំផុត ព្រោះបានទទួលបច្ច័យពី បញ្ចវិញ្ញាណធាតុ និងមនោធាតុ រមែងមានកម្លាំងខ្លាំង ទើបដឹងអារម្មណ៍ ច្រើន បានដល់ ចិត្ត ៧៦ ដួង (វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ និង មនោធាតុ ៣) ។

## អកុសលចិត្ត និង អហេតុកចិត្ត

**អកុសលចិត្ត** ១២ ដួង និង **អហេតុកចិត្ត** ១៨ ដួង រួមចិត្ត ៣០ ដួងនេះ ឈ្មោះថា **អសោភណចិត្ត** ដែលឈ្មោះថា **អសោភណចិត្ត** នោះ មិនបានសំដៅយកចិត្តដែលមិនល្អ មិនស្អាត ឬជាចិត្តដែលជាបាបថោក

ទាបតែម្យ៉ាងទេ តែជាការសម្ដែងសភាពរបស់ចិត្តដោយបរិយាយថា **អសោភណចិត្ត** ជាចិត្តដែលក្រៅអំពី **សោភណចិត្ត** ជាចិត្តដែលមិនបានកើតព្រមជាមួយ **សោភណចេតសិក** ។

## សម្ដែងអសោភណចិត្ត ៣០ ដួង

អសោភណចិត្ត ៣០
- អកុសលចិត្ត ១២
  - លោភមូលចិត្ត ៨
  - ទោសមូលចិត្ត ២
  - មោហមូលចិត្ត ២
- អហេតុកចិត្ត ១៨
  - អកុសលវិបាកចិត្ត៧
  - អហេតុកកុសល-វិបាកចិត្ត ៨
  - អហេតុកកិរិយាចិត្ត៣

=៣០ ដួង

ហេតុអ្វីអសោភណចិត្តទើបមិនបានសំដៅយកថា ជាចិត្តដែលមិនល្អ មិនស្អាតដូចអកុសលចិត្ត ព្រោះអកុសលចិត្តនោះកើតគ្រប់មនុស្សមិនបាន ដូចយ៉ាងអហេតុកចិត្ត អកុសលចិត្តដួងខ្លះកើតមិនបានក្នុងព្រះសោតាបន្ន មានលោភចិត្តដែលកើតរួមជាមួយទិដ្ឋិជាដើម ឬព្រះអនាគាមិបុគ្គល អកុសលចិត្តប្រភេទមានកាមរាគៈ ឬទោសចិត្ត រមែងកើតមិនបានទៀត ក្នុងសន្តានរបស់ព្រះអនាគាមិបុគ្គលទាំងឡាយ ព្រះអរហន្តទាំងឡាយអកុសលចិត្តកើតមិនបានឡើយ តែព្រះអរហន្តដែលនៅមានជីវិតមិនទាន់បរិនិព្វាន រមែងឃើញ ឮ ដឹងក្លិន ដឹងរស

ដឹងដោយផ្ទាល់ៈ និងនឹកគិតប្រព្រឹត្តទៅដូចគ្នាជាមួយបុគ្គលដទៃទាំងឡាយ សម្តែងថា លោកនៅមានអហេតុកចិត្ត ដែលជាអសោភណចិត្ត តែមិនមែនចិត្តដែលមិនល្អ មិនស្អាតព្រោះព្រះអរហន្តទាំងឡាយ អ្នកអស់កិលេសាសវៈទាំងពួងហើយ បើអសោភណចិត្ត ប្រែថា ជាចិត្តមិនល្អមិនស្អាតហើយ ក៏ព្រះអរហន្តនៅមានចិត្តមិនល្អ មិនស្អាតទៀត ដូច្នោះអសោភណចិត្ត ទើបសំដៅយកត្រឹមតែចិត្តដែលក្រៅពីសោភណចិត្ត ឬចិត្តដែលមិនមានសោភណចេតសិកប្រកប តាមហេតុផលដូចពោលហើយប៉ុណ្ណោះ ។

## អសោភណចិត្ត និង សោភណចិត្ត

ចំនួនចិត្តទាំងអស់រាប់ដោយសង្ខេប ៨៩ ដួង ឬរាប់ដោយពិស្តារ ១២១ ដួងនោះ កាលចែកជាអសោភណចិត្ត និងសោភណចិត្តហើយ បានអសោភណចិត្ត ៣០ និងសោភណចិត្ត ៥៩ ដួង ឬ ៩១ ដួង ។

# សម្តែងការចែកចិត្តដោយអសោភណ និង សោភណ

- ៨៩ ចិត្ត ១២១
  - អសោភណចិត្ត (៣០)
    - អកុសលចិត្ត (១២)
      - លោភមូលចិត្ត ៨
      - ទោសមូលចិត្ត ២
      - មោហមូលចិត្ត ២
    - អហេតុកចិត្ត (១៨)
      - អកុសលវិបាកចិត្ត ៧
      - អហេតុកកុសលវិបាកចិត្ត ៨
      - អហេតុកកិរិយាចិត្ត ៣
  - សោភណចិត្ត (៥៩ ឬ ៩១)
    - កាមាវចរសោភណចិត្ត (២៤)
      - មហាកុសលចិត្ត ៨
      - មហាវិបាកចិត្ត ៨
      - មហាកិរិយាចិត្ត ៨
    - រូបាវចរចិត្ត (១៥)
      - រូបាវចរកុសលចិត្ត ៥
      - រូបាវចរវិបាកចិត្ត ៥
      - រូបាវចរកិរិយាចិត្ត ៥
    - អរូបាវចរចិត្ត (១២)
      - អរូបាវចរកុសលចិត្ត៤
      - អរូបាវចរវិបាកចិត្ត ៤
      - អរូបាវចរកិរិយាចិត្ត ៤
    - លោកុត្តរចិត្ត (៨ឬ៤០)
      - មគ្គចិត្ត ៤.២០
      - ផលចិត្ត ៤.២០

**អសោភណចិត្ត** បានដល់ ចិត្តដែលក្រៅអំពីសោភណចិត្ត ឬបានដល់ចិត្តដែលមិនកើតព្រមជាមួយសោភណចេតសិក អសោភណចិត្តនេះមានចំនួន ៣០ ដួង គឺ អកុសលចិត្ត ១២ និងអហេតុកចិត្ត ១៨ រួមជាអសោភណចិត្ត ៣០ ដូចបានសម្តែងមកហើយ ។

## ចប់ អហេតុកចិត្ត ១៨

# សោភណចិត្ត

តទៅនេះនឹងបានសម្តែងសោភណចិត្ត ៥៩ ដួង ឬ ៩១ ដួង តាមគាថាសង្គហៈសម្តែងថា

## គាថាសង្គហទី ៥

**៥. បាបាហេតុកមុត្តានិ សោភនានីតិ វុច្ចរេ**
**ឯកូនសដ្ឋិ ចិត្តានិ អថេកនវុតីបិ វា ។**

ប្រែថា ចិត្តទាំងឡាយ ៥៩ ឬ ៩១ ដួង ដែលផុតអំពីអកុសលចិត្ត និងអហេតុកចិត្តនោះ ហៅថា **សោភណចិត្ត** ។

អធិប្បាយ **សោភណចិត្ត** ជាចិត្តដែលល្អស្អាត ឬជាចិត្តដែលមានសោភណចេតសិកប្រកប ដែលរាប់ដោយសង្ខេប ៥៩ ដួង ឬដោយពិស្តារ ៩១ ដួង កាលចែកចិត្តទាំងនេះ ដោយភូមិហើយបាន ៤ ភូមិ ។

## សម្តែងការចែកសោភណចិត្តដោយភូមិ

| | | |
|---|---|---|
| សោភណចិត្ត | កាមាវចរសោភណចិត្ត ២៤ | ៥៩ ឬ ៩១ |
| | រូបាវចរចិត្ត ១៥ | |
| | អរូបាវចរចិត្ត ១២ | |
| | លោកុត្តរចិត្ត ៨ ឬ ៤០ | |

ចិត្តដែលត្រាច់នៅក្នុងកាមភូមិ ឬក្នុងកាមារម្មណ៍នោះ មានទាំង **អសោភណចិត្ត** និង **សោភណចិត្ត** ដូច្នេះ កាលចែកសោភណចិត្តដោយកាមភូមិហើយ ទើបត្រូវមានពាក្យថា សោភណមកជាមួយឲ្យជាក់ច្បាស់ ។ ចំណែកក្នុងរូបភូមិ អរូបភូមិ និងលោកុត្តរភូមិ ចិត្តនឹងកើតឡើងបានតែសោភណចិត្តតែម្យ៉ាង ទើបមិនត្រូវមានពាក្យសោភណមកជាមួយ ដូចយ៉ាងសោភណចិត្តដែលកើតក្នុងកាមភូមិទេ ។

តទៅនេះនឹងបានសម្ដែងសោភណចិត្ត ៥៩ ឬ ៩១ ដួង ដោយលំដាប់ រាប់តាំងពីកាមាវចរសោភណចិត្តជាដើមទៅ ។

## កាមាវចរសោភណចិត្ត ២៤

**កាមាវចរសោភណចិត្ត** ជាចិត្តដែលត្រាច់ទៅក្នុងកាមភូមិ គឺ ភូមិដែលជាដែនកើតនៃកិលេសកាម និងវត្ថុកាម តែជាចិត្តដែលល្អស្អាត ព្រោះប្រកបដោយសោភណចេតសិក ដែលតាក់តែងចិត្តឲ្យប្រព្រឹត្តទៅដើម្បីប្រយោជន៍ ប្រាសចាកទោសភ័យវិបត្តិ កាមាវចរសោភណចិត្តនេះ ចែកចេញជា ៣ ប្រភេទតាមគាថាសង្គហៈដែលសម្ដែងថា

## គាថាសង្គហទី ៦

**៦. វេទនាញាណសង្ខារ- ភេទេន ចតុវីសតិ**
**សហេតុកាមាវចរ- បុញ្ញបាកក្រិយា មតា ។**

ប្រែថា ចិត្ត ២៤ ដួង កាលពោលដោយប្រភេទនៃវេទនា ញាណ និងសង្ខារ ហៅថា សហេតុកកាមាវចរកុសលចិត្ត សហេតុកកាមាវចរ-វិបាកចិត្ត និងសហេតុកកាមាវចរកិរិយាចិត្ត ។

អធិប្បាយ **កាមាវចរសោភណចិត្ត ២៤** ដួង ជាចិត្តដែលប្រកប ដោយហេតុហៅថា "**សម្បយុត្តហេតុ**" ហេតុដែលប្រកបជាមួយចិត្តនេះ ជាផ្នែកសោភណហេតុ ឬកុសលហេតុ បានដល់ អលោភហេតុ អទោសហេតុ និងអមោហហេតុតាមសមគួរ ចិត្តដែលមានហេតុផ្សេងៗ ប្រកបនេះ ហៅថា "**សហេតុកចិត្ត**" ក្នុងកាមាវចរសោភណចិត្តទាំង ២៤ ដួងនេះ មានហេតុប្រកបគ្រប់ដួង ទើបឈ្មោះថា ជាសហេតុកចិត្ត ទាំងអស់ ដូច្នោះការចែកដោយជាតិភេទន័យជា ៣ ប្រភេទហើយ ទើបមិនត្រូវយកពាក្យ "**សហេតុក**" នាំមុខទៀត ប្រើតែពាក្យថា កាមាវចរកុសលចិត្ត កាមាវចរវិបាកចិត្ត និងកាមាវចរកិរិយាចិត្តប៉ុណ្ណោះ ។

## សម្ដែងការចែកកាមាវចរសោភណចិត្ត ៣ ប្រភេទ

| | | |
|---|---|---|
| កាមាវចរសោភណចិត្ត | កាមាវចរកុសលចិត្ត ៨ ដួង | ២៤ ដួង |
| | កាមាវចរវិបាកចិត្ត ៨ ដួង | |
| | កាមាវចរកិរិយាចិត្ត ៨ ដួង | |

កាមាវចរកុសលចិត្ត កាមាវចរវិបាកចិត្ត និងកាមាវចរកិរិយាចិត្ត ទាំង ៣ ប្រភេទនេះ មានឈ្មោះហៅម្យ៉ាងទៀតថា មហាកុសលចិត្ត មហាវិបាកចិត្ត និង មហាកិរិយាចិត្ត ។

## អត្ថរបស់កុសល

**កុច្ឆិតេ បាបធម្មេ សលយតិ ចលយតិ កម្បេតិ វិទ្ធំសេតីតិ = កុសលំ**

ធម្មជាតិណាមែងធ្វើឲ្យញាប់ញ័រ ឬមែងកំចាត់នូវបាបធម៌ ដែលបណ្ឌិតទាំងឡាយគប្បីខ្ពើម ដូច្នេះធម្មជាតិនោះ ឈ្មោះថា **កុសល** ។ ពាក្យថា "**កុសល**" បានដល់ កុសលចិត្ត ជាចិត្តដែលល្អស្អាត ប្រាសចាកសេចក្តីសៅហ្មង ក្តៅក្រហាយមិនមានទោស និងឲ្យផលជាសុខមានអត្ថ ៥ ប្រការ គឺ

**១. អរោគ្យត្ថ** ដោយអត្ថថា មិនមានរោគ គឺមិនមានកិលេស រាគៈជាដើម ចាក់ដោតចិត្ត និងរាងកាយ រាគៈ ទោសៈ មោហៈ ជាដើម ទាំងនេះឈ្មោះថា "**រោគ**" ព្រោះចាក់ដោតប្រទូសរ៉ាយចិត្តនិងរាងកាយរបស់សត្វទាំងឡាយ ។

**២. សុន្ទរត្ថ** ដោយអត្ថថា ជាធម្មជាតិល្អស្អាត គឺ ជាប្រយោជន៍ដល់សត្វទាំងឡាយបាន ។

**៣. ឆេកត្ថ** ដោយអត្ថថា ជាធម្មជាតិដែលឆ្លាតឈ្លាសវាងវៃ គឺជាអ្នកមានចិត្តជាកុសល ទើបមានកិរិយាវាចាសុភាពទន់ភ្លន់ ។

**៤. អនវជ្ជត្ថ** ដោយអត្ថថា មិនមានទោសដែលគួរតិះដៀលបាន ។

**៥. សុខវិបាកត្ថ** ដោយអត្ថថា ឲ្យផលជាសុខសមតាមប្រាថ្នា ។

## អត្ថរបស់បុណ្យ

**អត្តនោ សន្តានំ បុណាតិ សោធេតីតិ = បុញ្ញំ**

ប្រែថា ធម្មជាតិណា រមែងជម្រះសន្តានចិត្តរបស់ខ្លួនឲ្យបរិសុទ្ធ ដូច្នោះធម្មជាតិនោះ ឈ្មោះថា បុណ្យ ។

## មហាកុសលចិត្ត ៨

### កាមាវចរកុសលចិត្ត (មហាកុសលចិត្ត) ។

កាមាវចរកុសលចិត្ត ឬមហាកុសលចិត្ត ជាចិត្តដែលប្រកបដោយចេតនាដែលល្អស្អាត ទើបជាចិត្តដែលមិនមានទោស និងឲ្យផលជាសុខ ហើយអាចឲ្យផលកើតឡើងបានច្រើនជាងខ្លួន គឺឲ្យកើតផលជាអហេតុកកុសលវិបាកចិត្ត ៨ ដួង និងមហាវិបាកចិត្ត ៨ ដួង ប្រសើរជាងនោះ ដែលឈ្មោះថា "**មហាកុសលចិត្ត**" នោះ គឺ

**ក.** ជាចិត្តដែលកើតបានធំទូលាយក្នុងអារម្មណ៍ ៦ គឺកើតបានក្នុងអារម្មណ៍ដែលជារូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ ទាំងជាចិត្តដែលល្អស្អាត ដែលកើតឡើងបានធំទូលាយទូទៅមិនកំណត់ ភពភូមិ និងប្រភេទនៃសត្វនិងបុគ្គល ពោលគឺ កើតបានក្នុងភូមិផ្សេងៗ រហូតដល់ ៣០ ភូមិ តាំងពីនិរយភូមិ ដល់នេវសញ្ញានាសញ្ញាយតនភូមិ (វៀរអសញ្ញសត្តភូមិ) និងកើតបានក្នុងចិត្តសន្តានរបស់សត្វទាំងឡាយ តាំងពីអបាយសត្វ មនុស្ស ទេវតា រូបព្រហ្ម (វៀរអសញ្ញសត្តព្រហ្ម) និងអរូបព្រហ្ម កើតបានក្នុងបុគ្គលទូទៅ វៀរតែចិត្តសន្តានរបស់មគ្គបុគ្គល និងព្រះអរហន្តទាំងឡាយប៉ុណ្ណោះ ។

**ខ.** ជាចិត្តដែលជាទីតាំងនៃការបំពេញទាន រក្សាសីល និងភាវនា ខាងដើមឲ្យកើតឈាន មគ្គ ផល រហូតដល់បង្អោនយកនូវអារម្មណ៍ព្រះនិព្វាន (ខណៈដែលមហាកុសលចិត្តចូលដល់គោត្រភូញាណ និងបច្ចវេក្ខណញ្ញាណ) ទៀតផង ។

សភាវចិត្ត ដែលប្រកបដោយចេតនាល្អ ជាកាមាវចរកុសល ទើបឈ្មោះថា **"មហាកុសលចិត្ត"** ដោយហេតុដូចពោលហើយ និងមហាកុសលចិត្តនេះ ចែកចេញបាន ៨ ប្រភេទ គឺ

**១. សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ ។**

ចិត្តដែលកើតឡើងព្រមដោយសោមនស្ស ប្រកបដោយបញ្ញា មិនមានការដឹកនាំ ។

**២. សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ ។**

ចិត្តដែលកើតឡើងព្រមដោយសោមនស្ស ប្រកបដោយបញ្ញា មានការដឹកនាំ ។

**៣. សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ ។**

ចិត្តដែលកើតឡើងព្រមដោយសោមនស្ស មិនប្រកបដោយបញ្ញា មិនមានការដឹកនាំ ។

**៤. សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ ។**

ចិត្តដែលកើតឡើងព្រមដោយសោមនស្ស មិនប្រកបដោយបញ្ញា មានការដឹកនាំ ។

**៥. ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ ។**

ចិត្តដែលកើតឡើងព្រមដោយឧបេក្ខា ប្រកបដោយបញ្ញា មិនមានការដឹកនាំ ។

**៦. ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ ។**

ចិត្តដែលកើតឡើងព្រមដោយឧបេក្ខា ប្រកបដោយបញ្ញា មានការដឹកនាំ ។

**៧. ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ ។**

ចិត្តដែលកើតឡើងព្រមដោយឧបេក្ខា មិនប្រកបដោយបញ្ញា មិនមានការដឹកនាំ ។

**៨. ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ ។**

ចិត្តដែលកើតឡើងព្រមដោយឧបេក្ខា មិនប្រកបដោយបញ្ញា មានការដឹកនាំ ។

## សម្ដែងការចែកមហាកុសលចិត្ត ៨ ដួង

- មហាកុសលចិត្ត
  - សោមនស្ស (៤)
    - ញាណសម្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១
    - ញាណវិប្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១
  - ឧបេក្ខា (៤)
    - ញាណសម្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១
    - ញាណវិប្បយុត្ត
      - អសង្ខារិក ១
      - សសង្ខារិក ១

៨ ដួង

**ចំណុចសម្គាល់** មហាកុសលចិត្តដែលចែកចេញទៅបានជា ៨ ដួងនោះ ព្រោះអាស្រ័យសភាវធម៌ ៣ ប្រការ គឺ វេទនា ញាណ និង សង្ខារ ជាអ្នកតាក់តែងចិត្តឲ្យផ្សេងគ្នា ស្រដៀងគ្នានឹងសភាវៈរបស់ វេទនា ទិដ្ឋិ និងសង្ខារ ដែលចែកលោភមូលចិត្តឲ្យផ្សេងគ្នាបាន ៨ ដួង ដូច្នោះ

## សម្ដែងការចែកមហាកុសលចិត្ត ៨ ដោយធម៌ ៣ ប្រការ

១. មហាកុសលចិត្ត ៨ ដោយប្រភេទនៃវេទនា { សោមនស្ស........៤ / ឧបេក្ខា..............៤ } ៨

២. មហាកុសលចិត្ត ៨ ដោយប្រភេទនៃញាណ { ញាណសម្បយុត្ត..៤ / ញាណវិប្បយុត្ត.....៤ } ៨

៣.មហាកុសលចិត្ត ៨ ដោយប្រភេទនៃសង្ខារ { អសង្ខារិក............៤ / សសង្ខារិក...........៤ } ៨

**១. មហាកុសលចិត្ត ៨ ដួង**នោះ កាលពោលដោយប្រភេទនៃ វេទនាហើយ មហាកុសលចិត្តរមែងកើតព្រមជាមួយវេទនាបាន ២ គឺ កើត ព្រមជាមួយសោមនស្សវេទនា និងកើតព្រមជាមួយឧបេក្ខាវេទនា បាន សេចក្ដីថា ចិត្តដែលប្រព្រឹត្តទៅក្នុងការធ្វើសេចក្ដីល្អរបស់សត្វទាំងឡាយ ដែលទាក់ទងជាមួយការធ្វើសេចក្ដីល្អរបស់សត្វទាំងឡាយនោះ រមែង

ប្រព្រឹត្តទៅព្រមជាមួយបីតិត្រេកអរខ្លាំង ដែលហៅថា **សោមនស្សវេទនា** ឬមិនដូច្នោះក៏ប្រព្រឹត្តទៅព្រមជាមួយភាពព្រងើយៗ ដែលហៅថា **ឧបេក្ខាវេទនា** នឹងប្រព្រឹត្តទៅព្រមជាមួយភាពព្រងើយៗ នោះ រមែងអាស្រ័យទៅលើសទ្ធារបស់អ្នកធ្វើ បើអ្នកធ្វើមានសទ្ធាខ្លាំង ការធ្វើសេចក្តីល្អនោះ ប្រព្រឹត្តទៅព្រមដោយសេចក្តីត្រេកអរខ្លាំង តែអ្នកធ្វើមានសទ្ធាតិច ការធ្វើសេចក្តីល្អនោះ ប្រព្រឹត្តទៅព្រមដោយភាពព្រងើយៗ ។

**២. មហាកុសលចិត្ត ៨ ដួង** កាលពោលដោយប្រភេទនៃញាណ គឺការប្រកបដោយបញ្ញាហើយក៏មាន ២ យ៉ាង គឺចិត្តដែលប្រកបដោយបញ្ញា ហៅថា **ញាណសម្បយុត្ត** និងចិត្តដែលមិនបានប្រកបដោយបញ្ញា ហៅថា **ញាណវិប្បយុត្ត** ។

## ញាណសម្បយុត្ត

**ញាណសម្បយុត្ត** បានដល់ ប្រកបដោយបញ្ញា គឺមានការយល់ត្រូវតាមសភាវៈពិត បញ្ញាដែលពោលនេះសំដៅយកបញ្ញាដែលប្រកបជាមួយកាមាវចរកុសលចិត្តប៉ុណ្ណោះ គឺកម្មស្សកតាបញ្ញានិងវិបស្សនាបញ្ញា ។

**កម្មស្សកតាបញ្ញា** បានដល់ បញ្ញាដែលដឹងថា សត្វទាំងឡាយមានសិទ្ធិក្នុងការធ្វើរបស់ខ្លួន ទាំងដែលប្រព្រឹត្តទៅក្នុងផ្នែកល្អនឹងផ្នែកមិនល្អដូចគ្នាទាំងអស់ ដូចជាទ្រព្យសម្បត្តិ មាស ប្រាក់ មាតា បិតា ស្វាមី ភរិយា ឬបុត្តធីតាទាំងឡាយ មិនមែនជាសិទ្ធិរបស់សត្វទាំងនោះដោយពិត ព្រោះមិនអាចជាប់តាមសត្វទាំងឡាយទៅក្នុងភពដទៃបាន ស្វម្បី

ក្នុងភពនេះ ក៏នៅតែមិនមានសិទ្ធិយ៉ាងពិតប្រាកដទៀតផង ព្រោះអាចមានភ័យវិបត្តិត្រូវឲ្យវិនាស ត្រូវស្លាប់ ត្រូវព្រាត់ប្រាសចាកគ្នា ។

**កម្ម សកំ យេសន្តិ = កម្មស្សកា** ប្រែថា កម្មដែលជាកម្មសិទ្ធិរបស់ខ្លួនមានដល់សត្វទាំងឡាយ ដូច្នោះសត្វទាំងឡាយទើបឈ្មោះថា **កម្មស្សក** ។

**កម្មស្សកានំ ភាវោ = កម្មស្សកតា** ប្រែថា ភាពរស់នៅនៃសត្វទាំងឡាយមានកម្មជាកម្មសិទ្ធិរបស់ខ្លួន ឈ្មោះថា **កម្មស្សកតា** ។

**កម្មស្សកតា ញាណំ = កម្មស្សកតាញាណំ** ប្រែថា ការដឹងហេតុផល ក្នុងការរស់នៅនៃសត្វ ឈ្មោះថា **កម្មស្សកតាបញ្ញា** ។

ដូច្នោះ ការដឹងហេតុផលក្នុងការរស់នៅរបស់សត្វ ដែលថាសត្វទាំងឡាយមានសិទ្ធិក្នុងការធ្វើរបស់ខ្លួន ឬដឹងថាសត្វទាំងឡាយមានកម្មជារបស់ខ្លួន ការដឹងនោះឈ្មោះថា **កម្មស្សកតាបញ្ញា** និងបញ្ញារមែងកើតឡើងតជាប់គ្នា ៣ ប្រការ ។

## ការកើតឡើងរបស់បញ្ញា ៣ ប្រការ

**១. សុតមយបញ្ញា** បញ្ញាណាដែលកើតឡើងដោយការសិក្សារៀនសូត្រ ឬបានឮ បានស្តាប់មក បញ្ញានោះហៅថា **សុតមយបញ្ញា** បញ្ញានេះ ដោះស្រាយការយល់ខុសដែលធ្លាប់បានឮបានស្តាប់មក ឬឲ្យយល់ដឹង ក្នុងវត្ថុដែលមិនធ្លាប់ដឹងមកពីមុន ។

**២. ចិន្តាមយបញ្ញា** បញ្ញាដែលកើតពីការគិតពិចារណា ក្នុងបុគ្គលជាអ្នកធម្មតាតែងកើតព្រោះការស្តាប់ជាដំបូងសិន ទើបកើតឡើងបាន ប៉ុន្តែចំពោះអ្នកមានបារមីអប់រំមកល្អហើយ មិនចាំបាច់ស្តាប់ពីអ្នកដទៃក៏អាចកើតឡើងបានដែរ ។ ក្នុងអដ្ឋកថា សម្មោហវិនោទនី បានលើកយកព្រះពោធិសត្វទាំង ២ ជាឧទាហរណ៍ គឺ សព្វញ្ញូពោធិសត្វ និងបច្ចេកពោធិសត្វ ។ ព្រះពោធិសត្វទាំង ២ នេះ ក្នុងជាតិចុងក្រោយ អាចត្រឹមតែចិន្តាមយបញ្ញា ក៏សម្រេចមគ្គផលបានដែរ ។

**៣. ភាវនាមយបញ្ញា** បញ្ញាដែលកើតពីការចម្រើនភាវនា បានដល់ វិបស្សនាភាវនា បញ្ញាណាចូលទៅដឹងការពិតរបស់នាមរូបថា មិនទៀងជាដើម បញ្ញានោះហៅថា **ភាវនាមយបញ្ញា** ។

**បញ្ញា** តាមដែលបានសម្តែងមកហើយ ទើបចែកបានជា ២ យ៉ាង គឺបញ្ញាដែលជាហេតុ បានដល់ បញ្ញាទាំង ៣ ដូចពោលនោះ និងបញ្ញាដែលជាផល បានដល់ **កម្មស្សកតាបញ្ញា** ឬ **វិបស្សនាបញ្ញា** សូម្បីជនទាំងឡាយនៅមិនទាន់អាចលះសក្កាយទិដ្ឋិ (ការប្រកាន់មាំក្នុងខន្ធ ៥ ថាជាតួខ្លួន) បានក្តី តែកាលបើមានការយល់ឃើញត្រូវក្នុងអារម្មណ៍ ១០ ប្រការ ដែលហៅថា **ទសវត្ថុកសម្មាទិដ្ឋិ** ដូចនឹងពោលតទៅនេះ ក៏ឈ្មោះថា ជាអ្នកដឹងថាសត្វទាំងឡាយមានកម្មជារបស់ខ្លួនៗ ជា **កម្មស្សកតាបញ្ញា** តែវិបស្សនាបញ្ញានោះ ត្រូវដឹងនាមរូបមិនទៀងជាដើម រមែងលះសក្កាយទិដ្ឋិ ។

# ទសវត្ថុកសម្មាទិដ្ឋិ ១០ ប្រការ

**១. អត្ថិ ទិន្នំ** ទានដែលបុគ្គលឲ្យហើតមានផល ។

**២. អត្ថិ យិដ្ឋំ** ការបូជាធំមានផល ។

**៣. អត្ថិ ហុតំ** ការបូជាតូចមានផល (គ្រឿងសក្ការៈដែលគេធ្វើដល់ភ្ញៀវ) ។

**៤. អត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ** ផលវិបាករបស់កម្មដែលសត្វធ្វើល្អនិងធ្វើអាក្រក់មាន ។

**៥. អត្ថិ អយំ លោកោ** លោកនេះមាន (លោកនេះមានដល់សត្វដែលឋិតនៅក្នុងលោកដទៃ) ។

**៦. អត្ថិ បរោ លោកោ** លោកខាងមុខមាន (លោកដទៃមានដល់សត្វដែលឋិតនៅក្នុងលោកនេះ នឹងទៅកើតភពខាងមុខក្នុងអនាគតមាន) ។

**៧. អត្ថិ មាតា** មាតាមានគុណ (បុណ្យបាប) ។

**៨. អត្ថិ បិតា** បិតាមានគុណ (បុណ្យបាប) ។

**៩. អត្ថិ សត្តា ឱបបាតិកា** សត្វឱបបាតិកកំណើតមាន (គឺសត្វនរកប្រេត អសុរកាយ ទេវតា និងព្រហ្មនោះមាន) ។

**១០. អត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តិ ។** សមណៈព្រាហ្មណ៍ក្នុងលោក ដែលព្រមព្រៀង ប្រតិបត្តិត្រូវ ធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ក្រៃលែងខ្លួនឯង ត្រាស់ដឹងនូវលោកនេះនិងលោក-

ខាងមុខក៏មាន ។ (បិដកលេខ ២៦ ទំព័រ ៣៣៧)

ការយល់ឃើញត្រូវតាមគោលរបស់ទសវត្ថុកសម្មាទិដ្ឋិគ្រប់ប្រការនោះហើយ ឈ្មោះថា **កម្មស្សកតាញាណ** បានកើតឡើងហើយ ការបរិច្ចាគទាន ការរក្សាសីល ចម្រើនភាវនារបស់បុគ្គលនោះ មានអានិសង្សពេញបរិបូណ៌ ដូចការបណ្ដុះគ្រាប់ពោធិ៍ឲ្យចម្រើនឡើងជាដើមពោធិ៍ធំផ្ទុយគ្នាពីទាន សីល ភាវនារបស់អ្នកដែលមិនមានកម្មស្សកតាញាណមានអានិសង្សតិច ដូចដើមពោធិ៍ដែលឲ្យផលកើតជាគ្រាប់ពោធិ៍ប៉ុណ្ណោះ **ទសវត្ថុកសម្មាទិដ្ឋិ** ឧបមាដូចថ្មដុស ដែលដុសមើលសាច់មាសថាពិតឬមិនពិត ឬក៏ដូចទឹកក្រុតដែលប្រើបន្តក់មើលសាច់ប្រាក់ មាស ដឹងថាពិតឬមិនពិត យ៉ាងណាមិញ ការយល់ឃើញប្រពៃប្រកបដោយបញ្ញាអាស្រ័យ **ទសវត្ថុកសម្មាទិដ្ឋិ** ជាគ្រឿងជាក់ច្បាស់នៃកម្មរបស់សត្វទាំងឡាយ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។

**វិបស្សនាបញ្ញា** ជាបញ្ញាដែលដឹងខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ឥន្ទ្រិយ ២២ សច្ចៈ ៤ និងបដិច្ចសមុប្បាទ ១២ ថា ជាសភាវៈរបស់នាមរូបដែលជា **អនិច្ចំ ទុក្ខំ** និង **អនត្តា** ពោលគឺ មានបញ្ញាដឹងថា បណ្ដាវត្ថុទាំងឡាយក្នុងលោកនេះ ទាំងដែលមានជីវិតនិងមិនមានជីវិតក្ដីគង់មានតែនាមនិងរូប ២ យ៉ាងប៉ុណ្ណោះ ហើយនាមរូបនេះក៏ជារបស់មិនទៀង កាលកើតឡើងហើយរមែងរលត់ទៅវិញ មានសភាពជា **អនិច្ចំ ទុក្ខំ អនត្តា**ទាំងអស់ បញ្ញាណាចូលទៅដឹងសេចក្ដីពិតរបស់នាមរូបថា

មិនទៀងជាដើម ដោយចូលទៅពិសោធហើយដោយខ្លួនឯង បញ្ញានោះ ហៅថា **វិបស្សនាបញ្ញា** ។

ចំណែក **ញាណវិប្បយុត្ត** នោះ ប្រែថា មិនបានប្រកបដោយបញ្ញា ទាំងដែលជា **កម្មស្សកតាបញ្ញា** និង **វិបស្សនាបញ្ញា** ។

ដូច្នោះ **មហាកុសលចិត្ត** ប្រភេទដែលជាញាណវិប្បយុត្តនោះ ទើបបានដល់ចិត្តដែលមានចេតនាធ្វើអំពើល្អ តែមិនបានប្រព្រឹត្តទៅ ដោយប្រកបជាមួយបញ្ញាផង ដូចជាការធ្វើបុណ្យឲ្យទានតាមប្រពៃណី ជាដើម អាស្រ័យសទ្ធាជាប្រធាន ។

**៣. មហាកុសលចិត្ត ៨ ដួង** កាលពោលដោយប្រភេទនៃសង្ខារ គឺ ត្រូវអាស្រ័យការដឹកនាំ និងមិនត្រូវអាស្រ័យការដឹកនាំ បានដល់ អសង្ខារិកចិត្ត ៤ ដួង សសង្ខារិកចិត្ត ៤ ដួង តាមន័យដូច លោភមូល-ចិត្ត ៨ ដួង នោះឯង ។

## សម្តែងការចែកកាមាវចរកុសលដោយហេតុ

**កាមាវចរកុសល** នេះ កាលចែកដោយហេតុហើយមាន ២ យ៉ាង គឺ តិហេតុកកុសល និង ទ្វិហេតុកកុសល

## តិហេតុកកុសល

ក្នុងការធ្វើកុសលផ្សេងៗ មានការឲ្យទាន រក្សាសីល ចម្រើន ភាវនាជាដើម ធ្វើដោយកាយ វាចា និងចិត្តក្តី បើកុសលចិត្តរបស់អ្នក

កំពុងធ្វើកុសលនោះ ប្រកបដោយ **កម្មស្សកតាញាណ** ឬ **វិបស្សនាញាណ** ណាមួយហើយ កុសលកម្មប្រភេទនេះ ឈ្មោះថា **តិហេតុកកុសល** ព្រោះជាកុសលកម្មដែលប្រកបដោយហេតុ ៣ ប្រការ គឺ **អលោភហេតុ អទោសហេតុ** និង **អមោហហេតុ** អង្គធម៌បានដល់ **មហាកុសលញាណ-សម្បយុត្តចិត្ត ៤ ដួង** ។

## ទ្វិហេតុកកុសល

ក្នុងការធ្វើកុសលផ្សេងៗ មានការឲ្យទាន រក្សាសីល ចម្រើនភាវនាជាដើម នឹងធ្វើដោយកាយ វាចា ចិត្តក្តី បើកុសលចិត្តរបស់អ្នកដែលកំពុងធ្វើកុសលនោះ មិនបានប្រកបដោយ **កម្មស្សកតាញាណ** ឬ **វិបស្សនាញាណ** ណាមួយទេ កុសលកម្មប្រភេទនេះ ឈ្មោះថា **ទ្វិហេតុកកុសល** ព្រោះជាកុសលកម្ម ដែលប្រកបដោយកុសលហេតុត្រឹមតែ ២ ប្រការ គឺ **អលោភហេតុ** និង **អទោសហេតុ** ប៉ុណ្ណោះ (មិនប្រកបដោយ **អមោហហេតុ**) ដូច្នោះអង្គធម៌ទើបបានដល់ **មហាកុសលញាណវិប្បយុត្តចិត្ត ៤ ដួង** ។

## សម្តែងការចែកភាគរបស់កុសលដោយចេតនា

ក្នុងការធ្វើកុសលណាមួយនោះ មិនថានឹងជា **តិហេតុកកុសល** ឬ **ទ្វិហេតុកកុសល** ក្តី រមែងប្រកបដោយចេតនាក្នុងកាលទាំង ៣ គឺ

**១. បុព្វចេតនា** ចេតនាដែលកើតឡើងមុនការធ្វើ ។

**២. មុញ្ចនចេតនា** ចេតនាដែលកើតឡើងក្នុងខណៈកំពុងធ្វើ ។

**៣. អបរចេតនា** ចេតនាដែលកើតឡើងខាងក្រោយ ខណៈពេលដែលធ្វើរួចហើយ ។

**តិហេតុកកុសល** និង **ទ្វិហេតុកកុសល** នោះ កាលចែកចេញដោយអំណាចនៃចេតនាដូចពោលហើយ រមែងបាន ២ ប្រភេទ គឺ

**១. ឧក្កដ្ឋកុសល** បានដល់ កុសលថ្នាក់ខ្ពស់ ។

**២. ឱមកកុសល** បានដល់ កុសលថ្នាក់ទាប ។

**(១) ឧក្កដ្ឋកុសល** គឺ ក្នុងការធ្វើកុសលផ្សេងៗ មានទាន សីល ភាវនាជាដើម មុននឹងធ្វើក្តី ខណៈកំពុងធ្វើក្តី ឬខាងក្រោយពេលដែលធ្វើស្រេចហើយក្តី បើចិត្តរបស់បុគ្គលអ្នកធ្វើនោះ មិនមានអកុសលលាយ គឺមានចេតនាបរិសុទ្ធក្នុងកាលទាំង ៣ ដោយហេតុនេះ ទានកុសល សីលកុសល ឬភាវនាកុសលដែលកើតឡើងដល់បុគ្គលនោះ ទោះជា **តិហេតុកកុសល** ឬ **ទ្វិហេតុកកុសល** ក្តី ចាត់ជាឧក្កដ្ឋកុសល គឺ កុសលថ្នាក់ខ្ពស់ ។

**(២) ឱមកកុសល** គឺ ក្នុងការធ្វើកុសលផ្សេងៗ មានទាន សីល ភាវនាជាដើម មុននឹងធ្វើក្តី ខណៈកំពុងធ្វើក្តី ឬខាងក្រោយពេលធ្វើរួចហើយក្តី បើចិត្តរបស់បុគ្គលអ្នកធ្វើនោះ មានអកុសលចូលលាយ គឺ មានចេតនាមិនបរិសុទ្ធក្នុងកាលទាំង ៣ ដោយហេតុនេះ ទានកុសល សីលកុសល ឬ ភាវនាកុសល ដែលកើតឡើងដល់បុគ្គលនោះ ទោះជាតិហេតុកកុសល ឬ ទ្វិហេតុកកុសល ចាត់ជាឱមកកុសល គឺ កុសលថ្នាក់

ទាបទាំងអស់ ។

## ចែកតិហេតុកកុសល និង ទ្វិហេតុកកុសលដោយឧក្កដ្ឋ និង ឱមក

តិហេតុកកុសល { ឧក្កដ្ឋ គឺ កុសលថ្នាក់ខ្ពស់
ឱមក គឺ កុសលថ្នាក់ទាប

ទ្វិហេតុកកុសល { ឧក្កដ្ឋ គឺ កុសលថ្នាក់ខ្ពស់
ឱមក គឺ កុសលថ្នាក់ទាប

បណ្ដា **ចេតនា** ដែលជាគ្រឿងកាត់ក្ដីកុសលកម្មថា ជាប្រភេទឧក្កដ្ឋកុសល ឬឱមកកុសលនោះ អបរចេតនាមានសេចក្ដីសំខាន់ជាងបុព្វចេតនា និងមុញ្ចនចេតនា ព្រោះអបរចេតនាជាចេតនាដែលកើតឡើងខាងក្រោយ អំពីការធ្វើកុសលនោះៗ សម្រេចហើយ សូម្បីបុព្វចេតនា ឬមុញ្ចនចេតនា មិនបរិសុទ្ធ តែអបរចេតនាបរិសុទ្ធក៏ចាត់ថាជាឧក្កដ្ឋកុសល តែបើបុព្វចេតនា និងមុញ្ចនចេតនាបរិសុទ្ធ អបរចេតនាមិនបរិសុទ្ធ កុសលនោះចាត់ជាឱមកកុសល ដោយហេតុនេះ អបរចេតនាទើបមានសេចក្ដីសំខាន់ច្រើនជាងក្នុងការកាត់ក្ដីថា កុសលនោះជាកុសលប្រភេទឧក្កដ្ឋកុសល ឬឱមកកុសល ។

**អបរចេតនានេះ** អដ្ឋកថាចារ្យបានចែកពិស្ដារចេញទៅទៀតជា **អបរាបរចេតនា** ។

**អបរាបរចេតនានោះ** គឺចេតនាដែលកើតឡើងខាងក្រោយអបរៈ-ចេតនាបានកើតកន្លងទៅហើយមួយថ្ងៃ ឬមួយខែជាដើម ពោលគឺ កាលបាននឹកដល់ការបរិច្ចាគទាន រក្សាសីល ចម្រើនភាវនារបស់ខ្លួនដែលបានធ្វើទៅហើយ សូម្បីកន្លងទៅច្រើនថ្ងៃច្រើនខែហើយក្តី តែបីតិសោមនស្ស សទ្ធានិងបញ្ញាដែលមានក្នុងកុសលរបស់ខ្លួននោះនៅកើតជារឿយៗ ចេតនាដែលគិតក្នុងពេលខាងក្រោយនេះ ចាត់ជាកុសលអបរាបរចេតនា បើការបរិច្ចាគទាន រក្សាសីល ចម្រើនភាវនារបស់ខ្លួនដែលបានធ្វើទៅហើយ ក្នុងវេលាតៗ មក កើតការស្តាយក្រោយ ឬមិនដូច្នោះកើតសេចក្តីត្រេកអរភ្លើតភ្លើនជាប់ដោយតណ្ហា ឬកើតសេចក្តីក្រអឺតក្នុងចិត្តថា យើងធ្វើបានល្អជាងអ្នកដទៃ ដែលជាតួមានះ អបរាបរចេតនាជាអកុសល កុសលកម្មនោះៗ ក៏ចាត់ជាកុសលប្រភេទឱមក ដូច្នេះកាលនឹងចែកឧក្កដ្ឋកុសល និងឱមកកុសលទាំងដែលជាតិហេតុកកុសលនិងទ្វិហេតុកកុសលដោយអបរាបរចេតនាហើយ រមែងចែកបាន ៨ ប្រការ ។

# សម្ដែងការចែកឧក្កដ្ឋ និង ឱមករបស់តិហេតុកកុលសនិង ទ្វិហេតុកកុសលដោយអបរាបរចេតនា

- តិហេតុកកុសល
  - ឧក្កដ្ឋ
    - តិហេតុកឧក្កដ្ឋុក្កដ្ឋ
    - តិហេតុកឧក្កដ្ឋោមក
  - ឱមក
    - តិហេតុកឱមកុក្កដ្ឋ
    - តិហេតុកឱមកោមក

- ទ្វិហេតុកកុសល
  - ឧក្កដ្ឋ
    - ទ្វិហេតុកឧក្កដ្ឋុក្កដ្ឋ
    - ទ្វិហេតុកឧក្កដ្ឋោមក
  - ឱមក
    - ទ្វិហេតុកឱមកុក្កដ្ឋ
    - ទ្វិហេតុកឱមកោមក

ការប្រព្រឹត្តទៅរបស់តិហេតុកកុសល និងទ្វិហេតុកកុសលទាំង ៨ ប្រការនេះ អាស្រ័យមុញ្ចនចេតនាជាអ្នកនាំ និងអាស្រ័យអបរចេតនា និងអបរាបរចេតនាជាអ្នកចែក ពោលគឺ

ខណៈដែលមុញ្ចនចេតនាកើតឡើង ប្រកបដោយត្រៃហេតុ ឈ្មោះថា **តិហេតុកកុសល** តែបើខណៈមុញ្ចនចេតនាប្រកបដោយ **ទ្វិហេតុ** (មិនមានអមោហៈប្រកប) ក៏ឈ្មោះថា **ទ្វិហេតុកកុសល** ទាំង **តិហេតុកកុសល** និង**ទ្វិហេតុកកុសល** ទាំងនេះ បើកើតឡើងខណៈដែលមាន

**អបរចេតនាល្អ** និងអបរាបរចេតនាល្អ ក៏ចាត់ជា **ឧក្កដ្ឋុក្កដ្ឋ**

**អបរចេតនាល្អ** តែអបរាបរចេតនាមិនល្អ ចាត់ជា **ឧក្កដ្ឋោមក**

**អបរចេតនាមិនល្អ** តែអបរាបរចេតនាល្អ ចាត់ជា **ឱមកុក្កដ្ឋ**

**អបរចេតនាមិនល្អ** និងអបរាបរចេតនាក៏មិនល្អ ចាត់ជា **ឱមកោមក** ។

## កាមាវចរកុសលកម្ម

**កាមាវចរកុសលកម្ម** បានដល់ ការធ្វើសេចក្ដីល្អ ឬការធ្វើសុចរិត ដែលជាប់ទាក់ទងដោយកាមារម្មណ៍មាន រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ជាដើម និងកម្មល្អឬសុចរិតកម្មនោះ រមែងកើតឡើងបានដោយអំណាច នៃចេតនា ដែលមាននៅក្នុងមហាកុសលចិត្ត ជាសំខាន់ទើបសម្រេច ជាកម្មដែល ឈ្មោះថា **កាមាវចរកុសលកម្ម** ឬ**កាមកុសលកម្ម** ។

**កាមាវចរកុសលកម្ម** ឬ**កាមកុសលកម្ម** នេះ មានការសម្ដែងទុក ជា ២ ន័យគឺ

**១. ដោយកម្មទ្វារ, ២. ដោយបុញ្ញកិរិយាវត្ថុ** នឹងបានសម្ដែងន័យ ទាំង ២ នេះ តទៅតាមលំដាប់

### ក. **កាមាវចរកុសល** ពោលដោយកម្មទ្វារ

**កាមាវចរកុសល** កាលពោលដោយកម្មទ្វារហើយមាន ៣ ទ្វារគឺ

១. កម្មដែលកើតឡើងផ្លូវកាយហៅថា **កាយកម្ម** ។

២. កម្មដែលកើតឡើងផ្លូវវាចាហៅថា **វចីកម្ម** ។

៣. កម្មដែលកើតឡើងផ្លូវចិត្តហៅថា **មនោកម្ម** ។

កាលពោលដោយប្រភេទនៃកុសលកម្មហើយមាន ១០ យ៉ាង

## កាមាវចរកុសលកម្ម ១០

### កាយកម្ម ៣ គឺ

**១. បាណាតិបាត វិរតិ** វៀរចាកការសម្លាប់សត្វ ។

**២. អទិន្នាទាន វិរតិ** វៀរចាកការលួចទ្រព្យគេ ។

**៣. កាមេសុមិច្ឆាចារ វិរតិ** វៀរចាកការប្រព្រឹត្តខុសក្នុងកាម ។

### វចីកម្ម ៤ គឺ

**១. មុសាវាទ វិរតិ** វៀរចាកការពោលកុហក ។

**២. បិសុណាវាចា វិរតិ** វៀរចាកការពោលស៊ិកសៀត ។

**៣. ផរុសវាចា វិរតិ** វៀរចាកការពោលពាក្យគ្រោតគ្រាត ។

**៤. សម្ផប្បលាប វិរតិ** វៀរចាកការពោលពាក្យដែលមិនជាប្រយោជន៍ ។

### មនោកម្ម ៣ គឺ

**១. អនភិជ្ឈា** មិនរំពៃចង់បានទ្រព្យរបស់អ្នកដទៃ ។

**២. អព្យាបាទ** មិនគិតព្យាបាទគេឲ្យវិនាស ។

**៣. សម្មាទិដ្ឋិ** មានការយល់ឃើញត្រូវ ។

**កាមាវចរកុសលកម្ម ១០** ប្រការនេះ ហៅថា **កុសលកម្មបថ ១០ ឬសុចរិត ១០** ក៏បាន ។

## អង្គធម៌របស់កុសលកម្មបថ ១០

**កាយកម្ម ៣** អង្គធម៌បានដល់ **សម្មាកម្មន្តចេតសិក សម្មាអាជីវ-ចេតសិក** ។

**វចីកម្ម ៤** អង្គធម៌ បានដល់ **សម្មាវាចាចេតសិក សម្មាអាជីវ-ចេតសិក** ។

**មនោកម្ម ៣ អនភិជ្ឈា** អង្គធម៌ បានដល់ **អលោភចេតសិក** ។

**អព្យាបាទ** អង្គធម៌ បានដល់ **អទោសចេតសិក** ។

**សម្មាទិដ្ឋិ** អង្គធម៌ បានដល់ **បញ្ញាចេតសិក** ។

### ខ. **កាមាវចរកុសល** ដោយបុញ្ញកិរិយាវត្ថុ ១០

**បុញ្ញកិរិយាវត្ថុ** ១០ មកពីពាក្យបាលីថា **បុញ្ញក្រិយាវត្ថុ**

**បុញ្ញ** បានដល់ សេចក្តីល្អដែលជម្រះសេចក្តីសៅហ្មងក្តៅក្រហាយ ។

**ក្រិយ** បានដល់ គួរធ្វើ ។

**វត្ថុ** បានដល់ ជាហេតុ ជាទីតាំងនៃផល ។

ដូច្នោះ **បុញ្ញកិរិយាវត្ថុ** ទើបប្រែថា សេចក្តីល្អដែលគួរធ្វើ ព្រោះជាហេតុជាទីតាំងនៃផលល្អដែលកើតឡើង គឺ ជាវត្ថុដែលឲ្យសម្រេចជាបុណ្យ ជាកុសល ព្រមទាំងអានិសង្សផលដែលអ្នកធ្វើគប្បីបានទទួល

តាមសមគួរដល់ឱកាស ។

## កាមាវចរកុសលកម្មជាបុញ្ញកិរិយាវត្ថុមាន ១០ ប្រការ

**១. ទាន** ការឲ្យវត្ថុដែលជាប្រយោជន៍សុខដល់អ្នកទទួល ។

**២. សីល** ការរវាំងរក្សាកាយ វាចា ឲ្យតាំងនៅក្នុងសីល ។

**៣. ភាវនា** បានដល់ ការចម្រើនសមថៈ និងវិបស្សនា ។

**៤. អបចាយន** ការគោរពឱនលំទោនដល់អ្នកចម្រើនដោយជាតិ ចម្រើនដោយវ័យ និងចម្រើនដោយគុណ ។

**៥. វេយ្យាវច្ច** ការជួយខ្វល់ខ្វាយកិច្ចការងារទាក់ទងជាមួយ បរិយត្តិនិងបដិបត្តិ ។

**៦. បត្តិទាន** ការចែកចំណែកបុណ្យដល់អ្នកដទៃ ។

**៧. បត្តានុមោទនា** ការអនុមោទនាចំណែកបុណ្យអំពីអ្នកដទៃ ។

**៨. ធម្មទេសនា** ការសម្តែងធម៌ ។

**៩. ធម្មស្សវន** ការស្តាប់ធម៌ ។

**១០. ទិដ្ឋុជុកម្ម** ការយល់ឃើញត្រូវតាមសេចក្តីពិត ។

**បុញ្ញកិរិយាវត្ថុទាំង ១០** ប្រការនេះ ជាការងាររបស់ចិត្ត ទើបប្រកបដោយចេតនាដែលល្អស្អាត ដែលជាហេតុឲ្យកើតផលល្អជាសុខ ដូច្នោះ ចិត្តដែលចាត់ថាជាមហាកុសលចិត្តនោះ ទើបជាចិត្តដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ នៃបុញ្ញកិរិយាវត្ថុ ១០ ប្រការ ដូចពោលហើយនេះ ។

## សង្គ្រោះបុញ្ញកិរិយាវត្ថុ ១០ ដោយ ទាន សីល ភាវនា

**បុញ្ញកិរិយាវត្ថុ ១០** ប្រការ កាលសង្គ្រោះចូលក្នុងប្រភេទនៃ**ទាន សីល** និង **ភាវនា** បានដូច្នេះគឺ

សង្គ្រោះក្នុងទាន បានដល់
- ១. ទាន
- ២. បត្តិទាន
- ៣. បត្តានុមោទនា

សង្គ្រោះក្នុងសីល បានដល់
- ១. សីល
- ២. អបចាយនៈ
- ៣. វេយ្យាវច្ចៈ

សង្គ្រោះក្នុងភាវនា បានដល់
- ១. ភាវនា
- ២. ធម្មទេសនា
- ៣. ធម្មស្សវនៈ
- ៤. ទិដ្ឋុជុកម្ម

ម្យ៉ាងទៀត តាមន័យនៃពុទ្ធភាសិតអដ្ឋកថា សម្តែងថា **ធម្មស្សវន** គឺ ការស្តាប់ធម៌ដោយគោរព និង **ធម្មទេសនា** គឺ ការសម្តែងធម៌ ដើម្បីជាធម្មទានសង្គ្រោះចូលក្នុងទានក៏បាន ដូចពុទ្ធវចនៈ ពោលថា **សព្វទានំ ធម្មទានំ ជិនាតិ** ការឲ្យធម៌រមែងឈ្នះការឲ្យទាំងពួង និងចំណែកទិដ្ឋុជុកម្ម នោះ ក៏សង្គ្រោះចូលក្នុងទាន សីល ភាវនា បានទាំង ៣ ប្រការ ព្រោះក្នុងបរមត្ថទីបនី សម្តែងថា **ទិដ្ឋុជុកម្មំ សព្វេសំ និយមលក្ខណំ** សេចក្តីថា **ទិដ្ឋុជុកម្ម** គឺ បញ្ញាដែលឃើញត្រូវតាមសេចក្តីពិត បើការបំពេញទាន

រក្សាសីល និងចម្រើនភាវនា ដោយមិនមានទិដ្ឋុជុកម្មប្រកបហើយ ការឲ្យផលរបស់ទាន សីល ភាវនា ទាំងនោះក៏មិនបរិបូណ៌ មានការខ្វះខាត និងក្រៃលែងជាងនោះ ទិដ្ឋុជុកម្មនេះជាទីតាំងនិងជាបច្ច័យឲ្យកើតបុញ្ញកិរិយាវត្ថុដទៃៗ ទាំងពួង ទើបសង្គ្រោះចូលក្នុងទាន សីល និងភាវនា បានទាំងអស់ ។

## ហេតុឲ្យកើតមហាកុសល

ហេតុដែលធ្វើឲ្យកាមាវចរកុសលចិត្ត ឬមហាកុសលចិត្តកើតឡើងបាននោះ រមែងអាស្រ័យយោនិសោមនសិការ គឺការពិចារណាអារម្មណ៍ដោយឧបាយត្រូវទំនង ពោលគឺ កាលចិត្តប៉ះខ្ទប់ជាមួយអារម្មណ៍ណាមួយតាមទ្វារទាំង ៦ ក៏មានការពិចារណាកំណត់ដល់សភាវៈពិត ដែលប្រាកដឡើងនៃអារម្មណ៍នោះៗ ការពិចារណាតាមសភាវៈពិតដែលប្រាកដនោះ ឈ្មោះថា មាន **យោនិសោមនសិការ** តែការមាន **យោនិសោមនសិការ** ចំពោះអារម្មណ៍ដែលប៉ះខ្ទប់ចិត្តនោះ រមែងអាស្រ័យហេតុអតីត និងបច្ចុប្បន្ន ៥ ប្រការ គឺ

**១. បុព្វេកតបុញ្ញតា** ភាពជាអ្នកបានធ្វើបុណ្យទុកហើយពីជាតិមុនមក ។

**២. បដិរូបទេសវាស** បាននៅក្នុងប្រទេសដែលសមគួរមានព្រះពុទ្ធសាសនា ។

**៣. សប្បុរិសូបនិស្សយ** បានសេពគប់ជាមួយនឹងសប្បុរស ។

**៤. សទ្ធម្មស្សវន** បានស្តាប់ធម៌របស់សប្បុរស ។

**៥. អត្តសម្មាបណិធិ** តម្កល់ខ្លួនទុកដោយល្អ ។

ហេតុឲ្យកើតយោនិសោមនសិការទាំង ៥ ប្រការ ដូចពោលមកនេះ ប្រការដំបូងអាស្រ័យអតីតកម្មជាហេតុ ចំណែកដ៏សេស ៤ ប្រការទៀត អាស្រ័យបច្ចុប្បន្នកម្មជាហេតុ ។

## ផលរបស់មហាកុសលចិត្ត

ការឲ្យផលរបស់កាមាវចរកុសល ឬមហាកុសលចិត្តនេះ រមែងមានការឲ្យផលបាន ២ យ៉ាងគឺ

១. ឲ្យផលក្នុងបដិសន្ធិកាល (ខណៈកើត) ។

២. ឲ្យផលក្នុងបវត្តិកាល (ក្រោយអំពីកើតហើយទល់នឹងអស់ជីវិត) ។

## ១. ឲ្យផលក្នុងបដិសន្ធិកាល

មហាកុសលកម្ម ដែលកើតឡើងដោយអំណាចរបស់បុញ្ញកិរិយាវត្ថុ ១០ ឬកុសលកម្មបថ ១០ នោះ រមែងឲ្យផលជា មហាវិបាកចិត្ត ៨ ឧបេក្ខាសន្តីរណកុសលវិបាកចិត្ត ១ និង កម្មជរូប កើតឡើងបានក្នុងបដិសន្ធិកាល និងកើតក្នុងកាមសុគតិភូមិ ៧ ប៉ុណ្ណោះ ពោលគឺ មហាវិបាកចិត្ត ៨ ដួង ជាផលឲ្យបដិសន្ធិជាមនុស្សនិងទេវតា ក្នុងកាមសុគតិភព ៧ គឺ មនុស្សភូមិ ១ និងទេវភូមិ ៦ ។

ឧបេក្ខាសន្តីរណាកុសលវិបាកចិត្ត ១ ដួង ឲ្យផលបដិសន្ធិជាមនុស្ស និងទេវតាជាន់ចាតុម្មហារាជកាភូមិ ដែលខ្វះបុណ្យ (ខ្វាក់ ខ្វិន គ ថ្លង់ពីកំណើត) ទើបកើតបាន ២ ភូមិប៉ុណ្ណោះ គឺ មនុស្សភូមិ ១ និង ចាតុម្មហារាជកាភូមិ ១ ។

## ២. ឲ្យផលក្នុងបវត្តិកាល

ផលដែលបានទទួលពីមហាកុសល ៨ ក្នុងបវត្តិកាលមាន ២ យ៉ាង

**១. មហាវិបាកចិត្ត ៨ ដួង** ជាសហេតុកផល គឺ ផលដែលប្រកបដោយហេតុ តាមកម្លាំងចេតនារបស់មហាកុសលចិត្ត ៨ ជាផលដែលបានទទួលចំពោះក្នុងកាមសុគតិភូមិ ៧ ប៉ុណ្ណោះ ដោយមាននាទីរក្សាភពជាតិ (ភវង្គចិត្ត) ទទួលអារម្មណ៍តពីជវនៈដែលសោយហើយ (តទាលម្ពនកិច្ច) និងធ្វើនាទីឃ្លាតចាកភពដែលនៅនោះ (ចុតិកិច្ច) ។

**២. អហេតុកកុសលវិបាកចិត្ត ៨ ដួង** ជាអហេតុកផល គឺ ផលដែលមិនបានប្រកបដោយហេតុ ជាផលដែលឲ្យបានទទួល ក្នុងកាមភូមិ ១១ គឺ អបាយភូមិ ៤ មនុស្សភូមិ ១ ទេវភូមិ ៦ និងរូបភូមិ ១៥ (វៀរអសញ្ញីសត្តភូមិ) តាមសមគួរដល់ទ្វារនិងអារម្មណ៍ ដោយធ្វើនាទីក្នុងការឃើញ ការឮ ដឹងក្លិន ដឹងរស ដឹងផោដ្ឋព្វៈក្នុងអារម្មណ៍ដែលល្អផ្សេងៗ ជាដើម ។

ការកើតឡើងរបស់កាមាវចរកុសលចិត្ត ឬមហាកុសលចិត្ត ៨ ដួងនោះ អាស្រ័យសេចក្តីផ្សេងគ្នានៃវេទនាខ្លះ ញាណខ្លះ និងសង្ខារខ្លះ

ដូចដែលបានពោលមកហើយ តទៅនេះ គួរនឹងបានជ្រាបហេតុឲ្យកើតចិត្តប្រភេទផ្សេងៗ ទាំងនោះ ។

## ហេតុនាំឲ្យកើតសោមនស្សកុសលចិត្ត ៦ ប្រការ

**១. សោមនស្សបដិសន្ធិកតា** ភាពជាអ្នកបដិសន្ធិដោយសោមនស្ស។
**២. សទ្ធាពហុលតា** ភាពជាអ្នកមានសទ្ធាច្រើន ។
**៣. វិសុទ្ធទិដ្ឋិតា** ភាពជាអ្នកមានការយល់ឃើញបរិសុទ្ធ ។
**៤. អានិសំសទស្សាវិតា** ភាពជាអ្នកឃើញអានិសង្សនៃកុសលកម្មនោះៗ ។
**៥. ឥដ្ឋារម្មណសមាយោគោ** បានប្រកបជាមួយនឹងឥដ្ឋារម្មណ៍។
**៦. កស្សចិបិឡាភាវោ** មិនមានឧបសគ្គណាៗ មករារាំង ។

## ហេតុនាំឲ្យកើតឧបេក្ខាកុសលចិត្ត ៦ ប្រការ

**១. ឧបេក្ខាបដិសន្ធិកតា** ភាពជាអ្នកបដិសន្ធិដោយឧបេក្ខា ។
**២. អប្បសទ្ធតា** ភាពជាអ្នកមានសទ្ធាតិច ។
**៣. អវិសុទ្ធទិដ្ឋិតា** ភាពជាអ្នកមានការយល់ឃើញមិនបរិសុទ្ធ។
**៤. អានិសំសអទស្សាវិតា** ភាពជាអ្នកមិនឃើញឬមិនយល់ក្នុងអានិសង្សនៃកុសលកម្មនោះៗ ។
**៥. មជ្ឈត្តារម្មណសមាយោគោ** ប្រកបជាមួយអារម្មណ៍ជាកណ្តាល។
**៦. កស្សចិបិឡិកតា** មានឧបសគ្គមករារាំងខ្លះ ។

# សេចក្តីផ្សេងគ្នារបស់សោមនស្សនិងឧបេក្ខាក្នុងកាមកុសល និងអកុសលចិត្ត

**សោមនស្សអកុសល** កើតព្រមជាមួយសោមនស្សលោភមូលចិត្ត ៤ ដួង ជាសេចក្តីត្រេកអរក្នុងបាប ឬអកុសលកម្ម រមែងបានទទួលផលអាក្រក់ច្រើន ជាបាបធ្ងន់ ។

**សោមនស្សកុសល** កើតព្រមជាមួយសោមនស្សកុសលចិត្ត ៤ ដួង ជាសេចក្តីត្រេកអរក្នុងបុណ្យ ឬកុសលកម្ម រមែងបានទទួលផលល្អច្រើន ជាបុណ្យ ជាកុសលច្រើន ។

**ឧបេក្ខាអកុសល** កើតព្រមជាមួយឧបេក្ខាលោភមូលចិត្ត ៤ ដួង ជាសេចក្តីត្រេកអរក្នុងបាប ឬអកុសលកម្មត្រឹមតែបន្តិចបន្តួច ទើបព្រងើយៗ មិនដល់ថ្នាក់ត្រេកអរ និងឧបេក្ខាមោហមូលចិត្ត ២ ដួង ជាភាពព្រងើយៗ ព្រោះមិនដឹងសេចក្តីពិតនៃអារម្មណ៍ **ឧបេក្ខាអកុសលចិត្ត** ទើបមានបាបតិចជាងសោមនស្សអកុសល ។

**ឧបេក្ខាកុសល** ក្នុងទីនេះ បានដល់ឧបេក្ខាកាមកុសល ដែលកើតព្រមជាមួយឧបេក្ខាមហាកុសលចិត្ត ៤ ដួង រមែងមានភាពព្រងើយៗ ព្រោះសទ្ធាតិច ទើបបីតិសេចក្តីត្រេកអរមិនកើត កុសលកម្មឬបុណ្យដែលកើតពីឧបេក្ខាកាមកុសលនេះ ទើបបានបុណ្យតិចជាងសោមនស្សកុសល ។

## ហេតុនាំឲ្យកើតញាណសម្បយុត្តធម៌មាន ៤ ប្រការ (ន័យទី ១)

**១. បញ្ញាសំវត្តនិកកម្មតោ** បដិសន្ធិដោយកុសលកម្មដែលប្រកបព្រមដោយបញ្ញា ។

**២. អព្យាបជ្ឈលោកូបបត្តិតោ** កើតក្នុងជាតិដែលមិនមានកង្វល់ប្រាសចាកអាឃាតព្យាបាទ មានឱកាសស្វែងរកធម៌បាន ។

**៣. កិលេសទូរីភាវតោ** ឆ្ងាយចាកកិលេសគ្រឿងសៅហ្មង ។

**៤. ឥន្ទ្រិយបរិបាកតោ** មានបញ្ចិន្ទ្រិយចាស់ក្លា (មានអាយុ ៤០ ដល់ ៥០ ឆ្នាំ ហៅថា បញ្ញាទសកវ័យ ជាវ័យដែលមានបញ្ញាពិចារណាដោយល្អិតល្អន់ដល់ហេតុនិងផល) ។

## ហេតុនាំឲ្យកើតញាណសម្បយុត្តមាន ៧ ប្រការ (ន័យទី ២)

ដើម្បីការកើតឡើងនៃធម្មវិចយសម្ពោជ្ឈង្គ

**១. បរិបុច្ឆកតា** ចូលចិត្តសាកសួរបញ្ហាផ្សេងៗ ។

**២. វត្ថុវិសទកិរិយា** ចូលចិត្តសម្អាតកាយនិងចិត្ត រហូតដល់វត្ថុគ្រឿងប្រើប្រាស់ផ្សេងៗ ។

**៣. ឥន្ទ្រិយសមត្តបដិបាទនា** រក្សាឥន្ទ្រិយទាំង ៥ ដែលមានសទ្ធិន្ទ្រិយជាដើម ឲ្យស្ថិតនៅស្មើគ្នាជានិច្ច ។

**៤. ទុប្បញ្ញបុគ្គលបរិវជ្ជនា** គេចចេញចាកបុគ្គលដែលមិនមានបញ្ញា។

**៥. បញ្ញវន្តបុគ្គលសេវនា** សេពគប់ជាមួយបណ្ឌិតអ្នកមានបញ្ញា។

**៦. គម្ភីរញាណចរិយបច្ចវេក្ខណា** ពិចារណាធម៌ដែលជ្រាលជ្រៅ។

**៧. តទធិមុត្តតា** ពេញចិត្តក្នុងការបង្អោនចិត្តស្វែងរកធម្មរសដែលធ្វើឲ្យកើតបញ្ញា ។

## ហេតុនាំឲ្យកើតញាណវិប្បយុត្តធម៌ ៤ ប្រការ (ន័យទី ១)

**១. បញ្ញាអសំវត្តនិកកម្មតោ** បដិសន្ធិដោយកុសលកម្ម ដែលមិនបានប្រកបព្រមដោយបញ្ញា ។

**២. សព្យាបជ្ឈលោកូបបត្តិតោ** កើតក្នុងជាតិដែលមានការកង្វល់មានអាឃាតព្យាបាទ មិនមានឱកាសស្វែងរកធម៌ ។

**៣. កិលេសាទូរីភាវតោ** មិនឆ្ងាយចាកកិលេសស្វែងរកកិលេសមកជាគ្រឿងកង្វល់ ។

**៤. ឥន្ទ្រិយអបរិបាកតោ** មានបញ្ចិន្ទ្រិយទន់ខ្សោយ (មានអាយុរវាង ១ ទៅ ១០ ឆ្នាំ ហៅថា មណ្ឌសកវ័យ ជាវ័យដែលមិនទាន់មានបញ្ញាពិចារណាហេតុផលបានល្អិតល្អន់) ។

## ហេតុនាំឲ្យកើតញាណវិប្បយុត្តធម៌ ៧ ប្រការ (ន័យទី ២)

**១. អបរិបុច្ឆកតា** ភាពជាអ្នកមិនចូលចិត្តសួរបញ្ហាធម៌ផ្សេងៗ។

**២. វត្ថុអវិសទកិរិយា** មិនចូលចិត្តសម្អាតទាំងកាយនិងចិត្តរហូតដល់វត្ថុគ្រឿងប្រើប្រាស់ផ្សេងៗ ។

**៣. ឥន្ទ្រិយអសមត្តបដិបាទនា** មិនរក្សាឥន្ទ្រិយទាំង ៥ មានសទ្ធិន្ទ្រិយជាដើម ឲ្យស្ថិតនៅស្មើគ្នាជានិច្ច ។

**៤. ទុប្បញ្ញបុគ្គលសេវនា** គប់រកបុគ្គលអ្នកមិនមានបញ្ញា ។

**៥. បញ្ញវន្តបុគ្គលបរិវជ្ជនា** មានការគេចចេញពីបុគ្គលអ្នកមានបញ្ញា។

**៦. គម្ភីរញាណចរិយអបច្ចវេក្ខណា** មិនពិចារណាធម៌ដែលជ្រាលជ្រៅ ។

**៧. អតទធិមុត្តតា** ភាពជាអ្នកមិនពេញចិត្តក្នុងការបង្អោនចិត្តស្វែងរកធម្មរសដែលធ្វើឲ្យកើតបញ្ញា ។

## ហេតុនាំឲ្យកើតកុសលអសង្ខារិក ៦ ប្រការ

**១. អសង្ខារិកកម្មជនិតបដិសន្ធិកតា** ភាពជាអ្នកមានបដិសន្ធិកើតពីកុសលអសង្ខារិក ។

**២. កល្លកាយចិត្តតា** មានសេចក្តីសុខកាយសប្បាយចិត្ត ។

**៣. សីតុណ្ហាទីនំ ខមនពហុលតា** មានការអត់ធន់ចំពោះត្រជាក់ក្តៅជាដើម ។

**៤. កត្តព្វកម្មេសុ ទិដ្ឋានិសំសតា** ធ្លាប់ឃើញផលក្នុងការងារដែលគប្បីធ្វើ ។

**៥. កម្មេសុ ចិណ្ណវសិតា** មានភាពជំនាញក្នុងការងារដែលធ្វើនោះ។

**៦. ឧតុភោជនាទិសប្បាយលាភោ** បានទទួលអាកាសល្អ អាហារល្អជាដើម ។

## ហេតុនាំឲ្យកើតកុសលសសង្ខារិក ៦ ប្រការ

**១. សសង្ខារិកកម្មជនិតបដិសន្ធិកតា** ភាពជាអ្នកមានបដិសន្ធិកើតពីកុសលសសង្ខារិក ។

**២. អកល្លកាយចិត្តតា** មិនមានសេចក្ដីសុខកាយសប្បាយចិត្ត ។

**៣. សីតុណ្ហាទីនំ អខមនពហុលតា** មិនមានការអត់ធន់ចំពោះត្រជាក់និងក្ដៅជាដើម ។

**៤. កត្តព្វកម្មេសុ អទិដ្ឋានិសំសតា** មិនធ្លាប់ឃើញផលក្នុងការងារដែលគប្បីធ្វើ ។

**៥. កម្មេសុ អចិណ្ណវសិតា** មិនមានភាពជំនាញក្នុងការងារដែលធ្វើ។

**៦. ឧតុភោជនាទិអសប្បាយលាភោ** មិនបានទទួលអាកាសល្អអាហារល្អជាដើម ។

ហេតុឲ្យកើតសង្ខារភេទក្នុងមហាកុសលនេះ ក៏ប្រព្រឹត្តទៅដោយន័យដូចគ្នានឹងសង្ខារភេទ ក្នុងលោភមូលចិត្តដែលពោលហើយខាងដើមនោះឯង ។

## អត្ថនៃវិបាក

**អញ្ញមញ្ញវិសិដ្ឋានំ កុសលាកុសលានំ បាកាតិ = វិបាកា**

ប្រែថា ធម៌ទាំងឡាយដែលជាផលរបស់កុសល និងអកុសលដែលពិសេសជាងគ្នានិងគ្នា ឈ្មោះថា **វិបាក** ។

ផលដែលពិសេសជាងគ្នានោះ គឺ កុសលឲ្យផលដែលល្អជាឥដ្ឋផល ចំណែកអកុសលឲ្យផលមិនល្អជាអនិដ្ឋផល ។

## ធម៌ដែលជាផលនេះមាន ២ យ៉ាង គឺ

១. **មុខ្យផល** ជាផលដោយត្រង់ បានដល់ វិបាកចិត្តនិងចេតសិកប្រកប ដែលជាផលដោយត្រង់ នេះព្រោះជានាមធម៌ ដឹងអារម្មណ៍បានដូចគ្នានឹងធម៌ដែលជាហេតុ គឺកុសលចិត្ត ឬអកុសលចិត្តនោះឯង ។

២. **សាមញ្ញផល** ជាផលធម្មតាសាមញ្ញ(ផលដោយអម) បានដល់ **កម្មជរូប** ដែលជារូបធម៌ បានដល់ **ហទយវត្ថុរូប** និងបសាទរូបជាដើម ។

វិបាកនេះ រមែងសំដៅយកមុខ្យផលដោយត្រង់ ដូច្នោះ វិបាកទើបសំដៅយកចំពោះវិបាកចិត្ត ដែលជានាមធម៌ប៉ុណ្ណោះ ។

## វិបាកចិត្តមានចំនួនទាំងអស់ ៣៦ ដួង គឺ

- វិបាកចិត្ត (៣៦ ដួង)
  - កាមាវចរ
    - អហេតុកៈ
      - អកុសលវិបាកចិត្ត ៧ ដួង
      - អហេតុកកុសលវិបាកចិត្ត ៨ ដួង
    - សហេតុកៈ កាមាវចរវិបាកចិត្ត ៨ ដួង
  - មហគ្គត
    - ......................រូបាវចរវិបាកចិត្ត ៥ ដួង
    - ......................អរូបាវចរវិបាកចិត្ត ៤ ដួង
  - លោកុត្តរ ......................លោកុត្តរវិបាកចិត្ត ៤ ដួង

សម្រាប់ **អកុសលវិបាកចិត្ត** និង**អហេតុកកុសលវិបាកចិត្ត**នោះ បានសម្តែងមកហើយក្នុង **អហេតុកចិត្ត** តទៅនេះនឹងបានសម្តែង **សហេតុកកាមាវចរវិបាកចិត្ត** ឬ **មហាវិបាកចិត្ត** ។

## មហាវិបាកចិត្ត ៨ ដួង

**វិបាកចិត្ត** មានសភាពដូច្នេះ គឺ

**១.** មិនមែនជាចិត្តដែលត្រូវធ្វើឲ្យកើតឡើង បើមានកុសលកម្ម អកុសលកម្ម ជាហេតុហើយ វិបាកចិត្ត គឺផលក៏ត្រូវមានពិតប្រាកដ ។

**២. វិបាកចិត្ត** ជាចិត្តដែលស្ងប់ មិនប្រាកដអាការយ៉ាងណាមួយ ជាចិត្តដែលមិនមានសេចក្តីខ្វល់ខ្វាយ **វីរិយៈ ឧស្សាហៈ** នៅមានកម្លាំងខ្សោយ ផ្សេងគ្នាពី កុសល អកុសល និងកិរិយា ។

**៣. វិបាកចិត្ត** មិនប្រាកដច្បាស់ ដែលដឹងប្រាកដច្បាស់ចំពោះ ខណៈដេកលក់ ចំណែកវេលាភ្ញាក់ ចិត្តកើតឡើងកាន់វីថិ ជាកុសលខ្លះ ជាអកុសលខ្លះ និងកិរិយាខ្លះ រមែងប្រាកដច្បាស់ជាងវិបាកចិត្ត ។

**៤. ចេតសិក** ដែលកើតជាមួយវិបាកចិត្ត ក៏មានកម្លាំងខ្សោយផង ដែរ រួមទាំងបដិសន្ធិកម្មជរូប និងចិត្តជរូប ដែលកើតពីវិបាកចិត្តនោះ ក៏មិនប្រាកដអាការណាមួយដូចកុសលចិត្ត អកុសលចិត្ត និងកិរិយាចិត្ត ដែរ ដូចជាជរារមែងកើតដល់បុគ្គលគ្រប់រូប កាលបើជាតិមានហើយ ជរានឹងត្រូវមានពិតប្រាកដ ។

## សហេតុកកាមាវចរវិបាកចិត្ត (មហាវិបាក)

**សហេតុកកាមាវចរវិបាកចិត្ត** និយមហៅថា **កាមាវចរវិបាក** ឬ **មហាវិបាក** ព្រោះជាចិត្តដែលជាផលរបស់ **កាមាវចរកុសលចិត្ត** ឬ **មហាកុសលចិត្ត ៨ ដួង** ដោយត្រង់ពោលគឺ **មហាកុសលចិត្ត ៨ ដួង** ជាហេតុឲ្យ **មហាវិបាកចិត្ត ៨ ដួង** កើតជាផល និងរមែងឲ្យផលត្រូវគ្នា ដូចជា **មហាកុសលចិត្ត** ជា **សោមនស្សញ្ញាណសម្បយុត្តអសង្ខារិក** ក៏ឲ្យផលជា **មហាវិបាកសោមនស្សញ្ញាណសម្បយុត្តអសង្ខារិក** ដូចគ្នាជាដើម ។

**កាមាវចរវិបាកចិត្ត** នោះ កាលពោលដោយទូទៅហើយ រមែងមាន ២៣ ដួង គឺ

កាមាវចរវិបាកចិត្ត
- អហេតុក
  - អកុសលវិបាក ៧
  - កុសលវិបាក ៨
- សហេតុក — កាមាវចរវិបាក ៨

(សរុប ២៣)

ក្នុងកាមាវចរវិបាកចិត្ត ២៣ ដួងនោះ អកុសលវិបាកចិត្ត ៧ ដួង ជាផលរបស់អកុសលចិត្ត ១២ ដួង អហេតុកកុសលវិបាកចិត្ត ៨ ដួង និងសហេតុកកាមាវចរវិបាកចិត្ត ៨ ដួង រួមចិត្ត ១៦ ដួង នេះជាផលរបស់កាមាវចរកុសលចិត្ត ៨ ឬដែលហៅថា មហាកុសលចិត្ត ៨ ដួង ព្រោះហេតុដែលឲ្យផលច្រើនជាងខ្លួនដូច្នេះឯង ។

សូម្បីអហេតុកកុសលវិបាកចិត្ត និងមហាវិបាកចិត្ត ជាប់ទាក់ទង ពីមហាកុសលចិត្តដូចគ្នាក្តី តែភាពផ្សេងគ្នារវាងអហេតុកកុសលវិបាកចិត្ត ជាមួយនឹងមហាវិបាកចិត្ត រមែងមានជានិច្ច គឺ

**អហេតុកកុសលវិបាកចិត្ត** គឺចិត្តដែលជាផលរបស់មហាកុសល តែមិនប្រកបដោយហេតុណាមួយ កាលកើតឡើងទទួលអារម្មណ៍ក៏មិនមាំទាំ និងកើតបានទូលំទូលាយទាំងក្នុងកាមភូមិ និងរូបភូមិតាមសមគួរ។

**មហាវិបាកចិត្ត** គឺចិត្តដែលជាផលរបស់មហាកុសលចិត្ត តែងប្រកបដោយហេតុ កាលកើតឡើងទទួលអារម្មណ៍មាំទាំ និងកើតបានចំពោះក្នុងកាមសុគតិភូមិ ៧ ប៉ុណ្ណោះ ។

ដូច្នោះ **សហេតុកកាមាវចរវិបាកចិត្ត** ឬ**មហាវិបាកចិត្ត** ដែលនឹងពោលតទៅនេះ ទើបបានដល់ចិត្តដែលជាផលរបស់មហាកុសល ព្រោះកាលពោលដោយវេទនា សម្បយោគ និងសង្ខារហើយ ក៏ដូចគ្នាជាមួយមហាកុសលចិត្តគ្រប់ប្រការ ទើបឈ្មោះថា **មហាវិបាកចិត្ត** ។

**សហេតុកកាមាវចរវិបាកចិត្ត** នេះ មានចំនួន ៨ ដួង និងមានឈ្មោះដូចគ្នាជាមួយនឹង **មហាកុសលចិត្ត** គឺ

**១. សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ ។**

មហាវិបាកចិត្តដួងទី ១ កើតឡើងព្រមដោយសោមនស្ស ប្រកបដោយបញ្ញា មិនមានការដឹកនាំ ។

**២. សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ ។**

មហាវិបាកចិត្តដួងទី ២ កើតឡើងព្រមដោយសោមនស្ស ប្រកបដោយបញ្ញា មានការដឹកនាំ ។

**៣. សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ ។**

មហាវិបាកចិត្តដួងទី ៣ កើតឡើងព្រមដោយសោមនស្ស មិនប្រកបដោយបញ្ញា មិនមានការដឹកនាំ ។

**៤. សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ ។**

មហាវិបាកចិត្តដួងទី ៤ កើតឡើងព្រមដោយសោមនស្ស មិនប្រកបដោយបញ្ញា មានការដឹកនាំ ។

**៥. ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ ។**

មហាវិបាកចិត្តដួងទី ៥ កើតឡើងព្រមដោយឧបេក្ខា ប្រកបដោយបញ្ញា មិនមានការដឹកនាំ ។

**៦. ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ ។**

មហាវិបាកចិត្តដួងទី ៦ កើតឡើងព្រមដោយឧបេក្ខា ប្រកបដោយបញ្ញា មានការដឹកនាំ ។

**៧. ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ ។**

មហាវិបាកចិត្តដួងទី ៧ កើតឡើងព្រមដោយឧបេក្ខា មិនប្រកបដោយបញ្ញា មិនមានការដឹកនាំ ។

**៨. ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ ។**

មហាវិបាកចិត្តដួងទី ៨ កើតឡើងព្រមដោយឧបេក្ខា មិនប្រកបដោយបញ្ញា មានការដឹកនាំ ។

# មហាវិបាកជាអព្យាកតធម៌

**មហាវិបាក** ដែលជាអព្យាកតធម៌ គឺ

ក្នុងសម័យណា កាមាវចរកុសល ដែលបានធ្វើទុកហើយ ទើបឲ្យកើតផលជាមនោវិញ្ញាណធាតុ ដែលជាវិបាកកើតព្រមជាមួយសោមនស្សខ្លះ ឧបេក្ខាខ្លះ ប្រកបដោយបញ្ញាខ្លះ មិនប្រកបដោយបញ្ញាខ្លះ មានរូបារម្មណ៍ ឬប្រារព្ធអារម្មណ៍ណាៗ កើតឡើងឯង ដោយមិនមានការដឹកនាំ ឬមានការដឹកនាំ ជាមហាវិបាកចិត្ត ៨ ដួង ។

ក្នុងសម័យនោះ រមែងកើត **ផស្ស វេទនា សញ្ញា ចេតនា ឯកគ្គតា ជីវិតិន្ទ្រិយ មនសិការ សទ្ធា ។ល។** កើត **អវិក្ខេប** គឺសភាវៈដែលស្ងប់មិនរវើរវាយ សភាវធម៌ទាំងនោះឈ្មោះថា ធម៌ជាអព្យាកតៈ ព្រោះមានអព្យាកតមូល គឺ អលោភៈ អទោសៈ ឬអមោហៈជាមូលឲ្យសភាវធម៌ទាំងនោះប្រាកដឡើង ។

# មហាវិបាកផ្សេងពីមហាកុសល

**មហាវិបាក** ផ្សេងពីមហាកុសល គឺ ក្នុងមហាកុសលទាំងឡាយមានសេចក្តីផ្សេងគ្នានៃកម្ម ទ្វារ កម្មបថ និង បុញ្ញកិរិយាវត្ថុ តែសេចក្តីផ្សេងគ្នាដូចក្នុងមហាកុសលនោះ មិនមានក្នុងមហាវិបាកទេ ទាំងនេះព្រោះមហាវិបាកមិនញុំាងវិញ្ញត្តិឲ្យកើត ព្រោះមហាវិបាកជាផលដ៏ឆ្អិនហើយមិនមានវិបាកតទៅទៀត និងព្រោះមហាវិបាកមិនបានធ្វើសត្វបញ្ញត្តិឲ្យជាអារម្មណ៍ គឺ ករុណា មុទិតា និងសម្បវិរតិ គឺ សម្មាកម្មន្ត សម្មាវាចា

និងសម្មាអាជីវៈក៏មិនមាន ធម៌ទាំង ៥ ប្រការ ដូចពោលនេះ ទើបកើតជាមួយមហាវិបាកចិត្តមិនបានឡើយ ។

ចំណែកសភាវៈនៃសង្ខារធម៌នោះ គឺ ប្រភេទនៃអសង្ខារិក និងសសង្ខារិក ដូចគ្នាជាមួយនឹងមហាកុសលគ្រប់ប្រការ ។

## ឋានៈដែលឲ្យផលរបស់មហាវិបាក

មហាវិបាកចិត្តទាំង ៨ ដួងនោះ រមែងឲ្យផលក្នុងឋានៈ ៤ ប្រការ គឺ

ក្នុងឋានៈដែលកើតឡើងគ្រាដំបូងក្នុងភពថ្មី ហៅថា **បដិសន្ធិកិច្ច។**

ក្នុងឋានៈដែលរក្សាភពជាតិកំណើតនោះទុក ហៅថា **ភវង្គកិច្ច** ។

ក្នុងឋានៈដែលឃ្លាតចាកភពនោះ ហៅថា **ចុតិកិច្ច** ។

ក្នុងឋានៈដែលទទួលអារម្មណ៍សល់អំពីជវនៈសោយហើយ ហៅថា **តទាលម្ពនកិច្ច** ។

## ឋានៈដែលឲ្យផលជាបដិសន្ធិកិច្ច

អ្នកដែលធ្លាប់ធ្វើបុណ្យកុសល ទាំងប្រភេទដែលប្រកបដោយបញ្ញាក្តី អំណាចនៃកុសលចិត្តដួងណាមួយក្នុង ៨ ដួងនោះ រមែងញ៉ាំងផលឲ្យបដិសន្ធិជាមនុស្ស និងជាទេវតា ជាន់កាមាវចរ អ្នកបដិសន្ធិ គឺមហាវិបាកចិត្ត ៨ និងកម្មជរូប ។

## ឋានៈដែលឲ្យផលជាភវង្គកិច្ច

កាលសត្វទាំងឡាយបានបដិសន្ធិហើយ ក៏ឲ្យផលជាភវង្គ ធ្វើនាទីក្នុងការរក្សាភពជាតិរបស់មនុស្ស ឬទេវតាជាន់កាមាវចរទាំងនោះទុកក្នុងបវត្តិកាលរហូតអស់អាយុក្ខ័យ ៧៥ ឆ្នាំខ្លះ ១០០ ឆ្នាំខ្លះ តាមសមគួរដល់អាយុក្ខ័យនៃសត្វក្នុងភពភូមិនោះៗ ។

## ឋានៈឲ្យផលជាតទាលម្ពនកិច្ច

ការទទួលអារម្មណ៍ដែលសល់តអំពីខណៈសោយអារម្មណ៍នោះបានដល់ ទទួលអារម្មណ៍ដែលសល់ពីជវនចិត្ត វិបាកចិត្តនឹងឲ្យផលជាតទាលម្ពនកិច្ចនេះ បានតែចំពោះកាមសត្វ ក្នុងកាមភូមិប៉ុណ្ណោះ គឺជាកាមបុគ្គល មានកាមារម្មណ៍និងកាមជវនៈប៉ុណ្ណោះ ។

## ឋានៈឲ្យផលជាចុតិកិច្ច

ក្នុងមរណកាលនៃភពជាតិដែលនៅនោះ មហាវិបាកចិត្តដែលប្រាកដគ្រាដំបូងក្នុងភពជាតិនោះៗ និងកើតជាប់តគ្នាមករឿយៗ រហូតដល់វេលាដែលត្រូវឃ្លាតចាកភពជាតិដែលនៅនោះ ដូច្នោះមហាវិបាកចិត្ត ប្រភេទដូចគ្នានឹងបដិសន្ធិនោះឯង ជាអ្នកចុតិឃ្លាតចាកភពជាតិនោះ ។

ដូច្នេះទើបឃើញបានថា មហាវិបាកទាំង ៨ ដួងនេះ រមែងជាអ្នកតាក់តែងសត្វឲ្យប្រាកដឡើងជាថ្មី ក្នុងកាមសុគតិភូមិ ៧ តាមសមគួរ

ដល់កម្លាំងរបស់មហាកុសល ដែលធ្វើឲ្យសត្វផ្សេងគ្នាដោយភូមិ ឬកំណើត និងសូម្បីនៅក្នុងភូមិជាមួយគ្នា ក៏នៅតែផ្សេងគ្នាដោយអំណាចនៃកិលេស និងផ្សេងគ្នាដោយអំណាចនៃសទ្ធា បញ្ញារបស់កុសលចេតនាក្នុងអតីតដែលញុំាងវិបាកឲ្យសត្វទាំងនោះ គប្បីបានទទួលខាងក្រោយអំពីបានកើតមកហើយ សត្វទាំងនោះ ពួកខ្លះមានលោភៈជាចំណែកច្រើន ពួកខ្លះមានទោសៈជាចំណែកច្រើន និងពួកខ្លះមានមោហៈជាចំណែកច្រើន បើនឹងតាំងបញ្ហាសួរថា ធម៌ណាដែលជាអ្នកកំណត់ សភាវៈដែលជាចំណែកខាងច្រើន ក៏ឲ្យប្រាកដជាផលឡើងដល់សត្វទាំងនោះ? ឆ្លើយថា ព្រោះហេតុ ៦ ប្រការ គឺ លោភៈ ទោសៈ មោហៈ ឬអលោភៈ អទោសៈ និងអមោហៈ ដែលសត្វទាំងនោះបានធ្វើទុកហើយនោះឯងជាអ្នកកំណត់ឲ្យ ដោយហេតុនេះ ក្នុងខណៈដែលខ្វល់ខ្វាយប្រកបកម្មក្នុងបច្ចុប្បន្ន សេចក្ដីផ្សេងគ្នាក្នុងការខ្វល់ខ្វាយរបស់បណ្ដាសត្វទាំងនោះរមែងប្រាកដជាផលដែលផ្សេងគ្នា គឺ

បុគ្គលណាមានលោភៈ អទោសៈ អមោហៈខ្លាំង តែអលោភៈ ទោសៈ និងមោហៈខ្សោយ បុគ្គលនោះរមែងជាអ្នកលោភលន់ ចូលចិត្តសប្បាយ មិនក្រោធ តែរមែងជាអ្នកមានបញ្ញា ។

បុគ្គលណាមានលោភៈ ទោសៈ និងអមោហៈខ្លាំង តែមានអលោភៈ អទោសៈ និងមោហៈខ្សោយ បុគ្គលនោះរមែងជាអ្នកលោភលន់ និងខឹងក្រោធ តែរមែងជាអ្នកមានបញ្ញា ។

បុគ្គលណាមានលោភៈ អទោសៈ និងមោហៈខ្លាំង បុគ្គលនោះរមែងជាអ្នកលោភលន់ ចូលចិត្តសប្បាយ ល្ងង់ខ្លៅ តែមិនសូវខឹងក្រោធ ។

បុគ្គលណាមានលោភៈ ទោសៈ មោហៈខ្លាំង រមែងជាអ្នកលោភលន់ ខឹងក្រោធ និងល្ងង់ខ្លៅ ។

បុគ្គលណាមានអលោភៈ ទោសៈ មោហៈខ្លាំង បុគ្គលនោះរមែងមិនសូវលោភលន់ តែជាអ្នកខឹងក្រោធ និងមានបញ្ញាទន់ខ្សោយ ។

បុគ្គលណាមានអលោភៈ អទោសៈ និងមោហៈខ្លាំង បុគ្គលនោះរមែងមិនសូវលោភលន់ មិនសូវខឹងក្រោធ និងជាអ្នកមានបញ្ញាទន់ខ្សោយ ។

បុគ្គលណាមានអលោភៈ ទោសៈ និងអមោហៈខ្លាំង បុគ្គលនោះរមែងជាអ្នកមិនសូវលោភលន់ និងមានបញ្ញា តែជាអ្នកខឹងក្រោធច្រើន ។

បុគ្គលណាមានអលោភៈ អទោសៈ និងអមោហៈទាំង ៣ នេះខ្លាំង រមែងជាអ្នកមិនសូវលោភលន់ មិនសូវខឹងក្រោធ និងមានបញ្ញាច្រើន ។

តាមដែលពោលមកនេះ រមែងឃើញបានថា ហេតុខាងដើមរមែងកំណត់ផលឲ្យប្រាកដឡើង ដើម្បីជាឧបការៈក្នុងការប្រកបកម្មក្នុងបច្ចុប្បន្ន សេចក្តីផ្សេងគ្នាទើបរមែងប្រាកដឡើង ក្នុងខណៈខ្វល់ខ្វាយប្រកបកម្មនោះៗ ភាវៈដែលជាប់មកពីអតីតនោះ គប្បីយល់ថាជាវិបាកនោះឯង ។

តែការបង្ហាញដោយចំពោះថា វិបាកណាជាផលរបស់កម្មណាបានធ្វើទុកហើយកាលណា រមែងមិនអាចបង្ហាញដោយចំពោះបាន និង

ក្រៃលែងជាងនោះទៅទៀត ព្រះពុទ្ធអង្គទ្រង់ត្រាស់សម្ដែងទុកក្នុងព្រះបាលី អង្គុត្តរនិកាយចតុក្កនិបាទថា ការរាវរកវិបាកកម្មនោះ ជាវត្ថុមិនគួរគិត ព្រោះមិនមែនជាវិស័យរបស់អ្នកណា វៀរតែព្រះសម្មាសម្ពុទ្ធជាម្ចាស់ប៉ុណ្ណោះដែលអាចដឹងបាន ព្រះអង្គត្រាស់សម្ដែងថា

ម្នាលភិក្ខុទាំងឡាយ អចិន្ត្រៃយ៍ (ហេតុដែលមិនគួរគិត) នេះមាន ៤ ប្រការ ដែលបុគ្គលមិនគួរគិតទេ តែអ្នកណាគិត អ្នកនោះគប្បីបាននូវចំណែកនៃសេចក្ដីឆ្កួតនិងសេចក្ដីលំបាក ។ អចិន្ត្រៃយ៍ ៤ ប្រការដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពុទ្ធវិស័យរបស់ព្រះពុទ្ធទាំងឡាយជាអចិន្ត្រៃយ៍ ដែលបុគ្គលមិនគួរគិត តែអ្នកណាគិត អ្នកនោះគប្បីបាននូវចំណែកនៃសេចក្ដីឆ្កួតនិងសេចក្ដីលំបាកទទេ ១ ម្នាលភិក្ខុទាំងឡាយឈានវិស័យរបស់បុគ្គលអ្នកបានឈាន ជាអចិន្ត្រៃយ៍ ដែលបុគ្គលមិនគួរគិត តែអ្នកណាគិត អ្នកនោះគប្បីបាននូវចំណែកនៃសេចក្ដីឆ្កួតនិងសេចក្ដីលំបាកទទេ ១ ម្នាលភិក្ខុទាំងឡាយ វិបាករបស់កម្មជាអចិន្ត្រៃយ៍ ដែលបុគ្គលមិនគួរគិត តែអ្នកណាគិត អ្នកនោះគប្បីបាននូវចំណែកនៃសេចក្ដីឆ្កួតនិងសេចក្ដីលំបាកទទេ ១ ម្នាលភិក្ខុទាំងឡាយលោកចិន្តា[២] (ការគិតអំពីលោក) ជាអចិន្ត្រៃយ៍ ដែលបុគ្គលមិនគួរគិត តែអ្នកណាគិត អ្នកនោះគប្បីបាននូវចំណែកនៃសេចក្ដីឆ្កួតនិងសេចក្ដីលំបាកទទេ ១ ។ ម្នាលភិក្ខុទាំងឡាយ អចិន្ត្រៃយ៍ មាន ៤ ប្រការប៉ុណ្ណោះ

[២] គិតថាព្រះចន្ទ្រ ព្រះអាទិត្យ ផែនដី មហាសមុទ្រ អ្នកណាសាង ពួកសត្វនិងភ្នំ និងព្រៃព្រឹក្សាមានដើមស្វាយ ដើមចេកនិងដើមដូងជាដើម អ្នកណាបង្កើតជាដំបូង គំនិតយ៉ាងនេះ ហៅថា លោកន្តា ។ អដ្ឋកថា ។

ដែលមិនគួរគិត តែអ្នកណាគិត អ្នកនោះគប្បីបាននូវចំណែកនៃសេចក្ដីឆ្កួតនិងសេចក្ដីលំបាកទទេៗ ។ (បិដកភាគ ៤២ ទំព័រ ១៩៧)

ការដែលព្រះពុទ្ធអង្គទ្រង់បានហាមគិត ក្នុងរឿងរបស់វិបាកទុកនោះ ក៏ព្រោះសភាវៈដែលប្រាកដដល់សត្វទាំងឡាយគ្រប់ពេលវេលានោះ រមែងនឹងហាមវិបាកមិនឲ្យកើតមិនបាន ព្រោះសត្វទាំងឡាយរមែងជាអ្នកប្រកបកម្ម ឲ្យប្រព្រឹត្តទៅតាមកុសល និងអកុសលកម្មនៃខ្លួន រមែងប្រព្រឹត្តទៅដើម្បីការវិលវល់ទៅក្នុងគតិទាំង ៥ ប្រការ ដែលហៅថា **សមង្គិតា** ។

**សមង្គិតា ៥** បានដល់ កុសលកម្ម ឬអកុសលកម្មដែលសម្រេចបានមួយគ្រាៗ នោះ រមែងញ៉ាំងសេចក្ដីដល់ព្រមនៃធម៌ ៥ ប្រការ ឲ្យកើតឡើង គឺ

**១. អាយូហនសមង្គិតា** បានដល់ ការព្យាយាមក្នុងខណៈធ្វើកុសលកម្ម អកុសលកម្ម ។

**២. ចេតនាសមង្គិតា** បានដល់ ចេតនាក្នុងកាលទាំង ៣ គឺ បុព្វចេតនា មុញ្ចនចេតនា និងអបរចេតនា ក្នុងការធ្វើកុសលកម្ម អកុសលកម្ម ចេតនាសមង្គិតានេះ មានក្នុងបុគ្គលទូទៅ វៀរតែព្រះអរហន្ត ។

**៣. កម្មសមង្គិតា** បានដល់ កុសលកម្ម អកុសលកម្ម ដែលជាហេតុនឹងឲ្យកើតផលក្នុងអនាគត គ្រប់អង្គនៃកម្មបថ ។

**៤. វិបាកសមង្គិតា** បានដល់ ផលរបស់កុសលកម្ម អកុសលកម្ម ក្នុងអតីត ដែលប្រកបព្រមដោយកម្មក្នុងបច្ចុប្បន្ន បើនៅមិនទាន់ដល់ព្រះនិព្វានដរាបណា រមែងមិនរួចផុតពីវិបាកសមង្គិតា ដរាបនោះ គឺ នឹងត្រូវទទួលផលរបស់កម្មនោះៗ ។

**៥. ឧបដ្ឋានសមង្គិតា** បានដល់ កម្មារម្មណ៍ កម្មនិមិត្តារម្មណ៍ គតិនិមិត្តារម្មណ៍ ដែលប្រាកដឡើងក្នុងវេលាជិតស្លាប់ ឧបដ្ឋានសមង្គិតានេះ មានកម្លាំងខ្សោយជាងសមង្គីទាំងពួង អំណាចរបស់កម្មដែលនឹងឲ្យផល រមែងធ្វើអារម្មណ៍ឲ្យប្រាកដកាលជិតនឹងស្លាប់ ។

## មហាកិរិយាចិត្ត ៨ ដួង

**កិរិយាចិត្ត** បានដល់ ចិត្តដែលមិនមែនកុសល អកុសល និងវិបាក ត្រឹមតែជាចិត្តដែលធ្វើនាទីទទួលអារម្មណ៍តាមទ្វារទាំង ៦ ឬធ្វើនាទីឲ្យសម្រេចការគិត ការធ្វើ ការនិយាយ ជាកិរិយាដោយភាវៈដែលកើតឡើងដល់ព្រះខីណាស្រព មិនមានបច្ច័យនៃកុសល និងអកុសលក្នុងអនាគតទៀត កិរិយាចិត្តទើបមាន ២ ប្រភេទ គឺ

**១. អហេតុកកិរិយាចិត្ត** គឺជាចិត្តដែលមិនមែនជាផលរបស់កុសល និងអកុសល និងទាំងមិនមែនចិត្តដែលជាតួកុសល និងអកុសលផង ជាចិត្តដែលត្រឹមតែធ្វើនាទីទទួលអារម្មណ៍តាមទ្វារទាំង ៦ ប៉ុណ្ណោះ នៅមិន

ទាន់ឲ្យដល់ជវនៈ (វៀរតែហសិតុប្បាទជវនៈ) ។

ទើបមិនមានឱកាសសាងហេតុ ដូច្នោះរមែងមិនមានហេតុផល ដូចផ្កាឈើជ្រុះ ពោលគឺ ជាផ្កាឈើដែលមិនមានផ្លែ ។

**២. សហេតុកកាមាវចរកិរិយាចិត្ត ឬមហាកិរិយាចិត្ត** ជាចិត្តដែលធ្វើឲ្យសម្រេច ការធ្វើ ការនិយាយ ការគិតរបស់ព្រះអរហន្ត អ្នកអស់កិលេសទាំងពួង ជាកិរិយាចិត្តចូលដល់ជវនៈ សោយអារម្មណ៍ដែលជាសោមនស្ស ឬឧបេក្ខា ត្រឹមតែជាវេទនាមួយប្រភេទ ដែលមិនមែនជាហេតុនៃតណ្ហានិងឧបាទាន ទើបមិនអាចឲ្យកើតផលក្នុងអនាគតបន្តទៀតបាន ប្រៀបដូចផ្កាឈើដែលមានដើមដាច់ឫសហើយ ។

**អហេតុកកិរិយាចិត្ត** បានសម្តែងមកហើយក្នុងបទខាងដើម តទៅនេះនឹងបានសម្តែងដល់សហេតុកកាមាវចរកិរិយាចិត្ត ឬ**មហាកិរិយាចិត្ត**។

## សហេតុកកាមាវចរកិរិយាចិត្ត (មហាកិរិយាចិត្ត)

**សហេតុកកាមាវចរកិរិយាចិត្ត ឬមហាកិរិយាចិត្ត**នេះ ជាចិត្តដែលមានហេតុប្រកបកើតឡើងទទួលកាមារម្មណ៍ ដោយច្រើននឹងកើតឡើងបានទូលំទូលាយក្នុងភូមិផ្សេងៗ បានដល់ទៅ ២៦ ភូមិ (វៀរអបាយភូមិ ៤ និងអសញ្ញីសត្តភូមិ ១ ដែលមិនមានព្រះអរហន្ត) មហាកិរិយាចិត្តនេះ ទើបមានសភាវៈស្រដៀងគ្នានឹងមហាកុសលចិត្ត ខុសគ្នាតែថា មហាកុសលចិត្តនោះឯង បើកើតឡើងដល់បុគ្គលដទៃ ដែលមិនមែនព្រះអរហន្ត ចិត្តទាំងនោះគង់ហៅថាមហាកុសលចិត្ត តែបើកើតជាមួយ

ព្រះអរហន្តដោយចំពោះហើយ ចិត្តទាំងនោះក៏ហៅថា មហាកិរិយាចិត្ត ដូច្នោះ មហាកិរិយាចិត្ត ទើបមានចំនួនដូចគ្នានឹង **មហាកុសលចិត្ត ៨ ដួង** ។

## មហាកិរិយាចិត្ត ៨

**១. សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ ។**

មហាកិរិយាចិត្តដួងទី ១ កើតឡើងព្រមដោយសោមនស្ស ប្រកបដោយបញ្ញា មិនមានការដឹកនាំ ។

**២. សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ ។**

មហាកិរិយាចិត្តដួងទី ២ កើតឡើងព្រមដោយសោមនស្ស ប្រកបដោយបញ្ញា មានការដឹកនាំ ។

**៣. សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ ។**

មហាកិរិយាចិត្តដួងទី ៣ កើតឡើងព្រមដោយសោមនស្ស មិនប្រកបដោយបញ្ញា មិនមានការដឹកនាំ ។

**៤. សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ ។**

មហាកិរិយាចិត្តដួងទី ៤ កើតឡើងព្រមដោយសោមនស្ស មិនប្រកបដោយបញ្ញា មានការដឹកនាំ ។

**៥. ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ ។**

មហាកិរិយាចិត្តដួងទី ៥ កើតឡើងព្រមដោយឧបេក្ខា ប្រកបដោយបញ្ញា មិនមានការដឹកនាំ ។

**៦. ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ ។**

មហាកិរិយាចិត្តដួងទី ៦ កើតឡើងព្រមដោយឧបេក្ខា ប្រកបដោយបញ្ញា មានការដឹកនាំ ។

**៧. ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ ។**

មហាកិរិយាចិត្តដួងទី ៧ កើតឡើងព្រមដោយឧបេក្ខា មិនប្រកបដោយបញ្ញា មិនមានការដឹកនាំ ។

**៨. ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ ។**

មហាកិរិយាចិត្តដួងទី ៨ កើតឡើងព្រមដោយឧបេក្ខា មិនប្រកបដោយបញ្ញា មានការដឹកនាំ ។

## មហាកិរិយាចិត្តដែលកើតព្រមជាមួយសោមនស្សវេទនា

**មហាកិរិយាចិត្ត** ជាចិត្តដែលកើតតែក្នុងចំពោះសន្តានរបស់ព្រះអរហន្ត អ្នកប្រហារកិលេសដាច់ជាសមុច្ឆេទហើយ ដូច្នោះកាលអារម្មណ៍មកប្រាកដតាមទ្វារទាំង ៦ រមែងពិចារណាអារម្មណ៍នោះៗដោយភាពជាឧបេក្ខាមិនមានសេចក្តីត្រេកអរ ថ្នាំងថ្នាក់ឡើយ មហាកិរិយាចិត្តទើបមិនកើតព្រមជាមួយសោមនស្សវេទនាបាន ។

**មហាកិរិយាចិត្ត** រមែងកើតព្រមជាមួយសោមនស្សវេទនាបាន ដូចជាចក្ខុទ្វាររបស់ព្រះអរហន្ត បានឃើញស្ថានទីដែលជាទីសប្បាយសមគួរដល់ការចម្រើនកម្មដ្ឋាន រមែងចូលដល់សភាពជាសោមនស្សដោយមហាកិរិយាចិត្តដួងនេះ ។

**សោតទ្វារ** ឮសំឡេងអ៊ូអរ របស់អ្នកលោភលន់ក្នុងរោងទាន ក៏ជាអ្នកចូលដល់ភាពសោមនស្ស ដោយមហាកិរិយាចិត្តនេះ ដោយគិតថា យើងលះតណ្ហាដែលឡេះឡោះដូច្នេះបានហើយ ។

**ឃានទ្វារ ជិវ្ហាទ្វារ កាយទ្វារ** និង**មនោទ្វារ** ក៏ប្រព្រឹត្តទៅដោយទំនងដូចគ្នានឹងជាអ្នកដល់ភាពសោមនស្ស ដោយមហាកិរិយាចិត្តបានសោមនស្សដែលកើតព្រមជាមួយមហាកិរិយាចិត្តរបស់ព្រះខីណាស្រពនេះ ត្រឹមតែជាវេទនាដែលជាផលរបស់ផស្សៈប៉ុណ្ណោះ ។

មិនមែនជាហេតុនៃតណ្ហា ឧបាទាន និងកម្មទេ មហាកិរិយាចិត្តទើបកើតព្រមជាមួយសោមនស្សវេទនាបាន ។

ចំណែកមហាកិរិយាចិត្តដែលកើតព្រមជាមួយឧបេក្ខាវេទនានោះ រមែងប្រាកដក្នុងខណៈពិចារណាអារម្មណ៍នោះ ដោយឆឡង្គុបេក្ខា មិនមានការត្រេកអរប្រការណាឡើយ ។

## មហាកិរិយាចិត្តប្រកបដោយបញ្ញា

**មហាកិរិយាចិត្ត** ដែលកើតក្នុងសន្តានរបស់ព្រះខីណាស្រពនោះ រមែងជាចិត្តដែលបរិសុទ្ធស្អាតប្រាសចាកមន្ទិល គឺ កិលេស ចិត្តដែលបរិសុទ្ធ ដូច្នេះគួរនឹងជាចិត្តដែលប្រកបដោយបញ្ញាតែម្យ៉ាង ដែលមិនបានប្រកបដោយបញ្ញា គឺ ប្រភេទដែលជាញាណវិប្បយុត្តនោះ មិនគួរនឹងមានបាន ។

**មហាកិរិយាចិត្ត** ដែលមិនបានប្រកបដោយបញ្ញា រមែងមានបាន ពោលគឺ ក្នុងខណៈដែលព្រះអរហន្តទាំងឡាយ ត្រូវប្រកបកិច្ចការដែលប្រព្រឹត្តទៅតាមធម្មតារបស់សង្ខារ ឬកិច្ចការដែលធ្លាប់បានធ្វើ មិនត្រូវប្រកបដោយបញ្ញាក៏មានបាន ដូចជាការដើរ ឈរ អង្គុយ ដេក បន្ទោបង់ឧច្ចារៈ បស្សាវៈជាដើម ការងារផ្សេងៗ ទាំងនេះ រមែងត្រូវអាស្រ័យមហាកិរិយាចិត្តជាអ្នកចាត់ចែង នឹងមិនត្រូវប្រើបញ្ញាមកប្រកបផងឡើយ ។

**មហាកិរិយាចិត្ត ៨** ជាចិត្តដែលធ្វើកិច្ចការងាររបស់កុសលនោះឯង តែការងាររបស់កុសលនោះ រមែងឲ្យផលជាសេចក្ដីសុខតទៅទៀត ចំណែកព្រះអរហន្តលោកធ្វើកិច្ចការងារ មិនត្រូវការផលដែលជាសេចក្ដីសុខតទៅទៀត ទើបហៅថា គ្រាន់តែធ្វើ និយាយ គិត ដោយមហាកិរិយាចិត្តប៉ុណ្ណោះឯង ដែលជាការងាររបស់កុសលនោះ បានសេចក្ដីថា ការងារដែលព្រះអរហន្តធ្វើនោះ បើមិនមែនព្រះអរហន្ត គឺបុថុជ្ជន ឬព្រះសេក្ខបុគ្គលធ្វើ ក៏សុទ្ធតែជាការងារដែលជាកុសលទាំងអស់ ចំណែកការងារដែលជាអកុសលនោះ សូម្បីត្រឹមតែគិតដោយចិត្តដែលជាអកុសល ក៏មិនមានដល់ចិត្តព្រះអរហន្តទាំងឡាយឡើយ ។

## គាថាសង្គហទី ៧

**៧. កាមេ តេវីស បាកានិ បុញ្ញាបុញ្ញានិ វីសតិ**
**ឯកាទស ក្រិយា ចេតិ ចតុបញ្ញាស សព្វថា ។**

ប្រែថា កាមាវចរវិបាកចិត្តមាន ២៣ កាមាវចរកុសលចិត្ត និង អកុសលចិត្តមាន ២០ កាមាវចរកិរិយាចិត្តមាន ១១ រួមកាមាវចរចិត្តមាន ៥៤ ដោយប្រការទាំងពួង ។

## ចប់ កាមាវចរសោភណចិត្ត ២៤

## រូបាវចរចិត្ត ១៥

**រូបាវចរចិត្ត** បានដល់ ចិត្តដែលចូលដល់អារម្មណ៍របស់រូបជ្ឈាន ឬបានដល់ចិត្តត្រាច់ទៅកើតក្នុងភូមិ ដែលជាទីកើតនៃវត្ថុរូប និងកិលេសរូបដោយច្រើន ។

**វត្ថុរូប** បានដល់ រូបាវចរចិត្ត ១៥ ចេតសិក ៣៥ (វត្ថុធម៌) ។

**កិលេសរូប** បានដល់ លោភចេតសិកដែលជាប់ដោយរូបតណ្ហា គឺ ការពេញចិត្តក្នុងរូប ឈាន អភិញ្ញា និងរូបភព មានព្រះបាលីថា

**រូបស្ស ភវោតិ = រូបំ**

ភូមិណា ជាទីកើតនៃវត្ថុរូប និងកិលេសរូប ភូមិនោះឈ្មោះថា រូប បានដល់ រូបភូមិ ១៥ ឬ **រូបេ អវចរតីតិ = រូបាវចរំ**

ចិត្តណា រមែងត្រាច់ទៅកើតក្នុងភូមិដែលជាទីកើតនៃវត្ថុរូប និងកិលេសរូប ចិត្តនោះឈ្មោះថា **រូបាវចរចិត្ត** ។

## គាថាសង្គហទី ៨

**៨. បញ្ចធា ឈានភេទេន រូបាវចរមានសំ**
**បុញ្ញបាកក្រិយាភេទា តំ បញ្ចទសធា ភវេ ។**

ប្រែថា រូបាវចរចិត្ត ពោលដោយប្រភេទនៃឈានមាន ៥ ដួង កាលចែកដោយកុសល វិបាក កិរិយា ហើយមាន ១៥ ដួង ។

# អធិប្បាយរូបាវចរចិត្ត

រូបាវចរចិត្តនោះ កាលពោលដោយប្រភេទនៃឈានមាន ៥ គឺ

**រូបាវចរបឋមជ្ឈានចិត្ត ១**

**រូបាវចរទុតិយជ្ឈានចិត្ត ១**

**រូបាវចរតតិយជ្ឈានចិត្ត ១**

**រូបាវចរចតុត្ថជ្ឈានចិត្ត ១**

**រូបាវចរបញ្ចមជ្ឈានចិត្ត ១**

រូបាវចរឈានចិត្តទាំង ៥ នេះ កាលចែកដោយប្រភេទនៃជាតិ គឺ កុសល វិបាក កិរិយាហើយ បានរូបាវចរកុសលចិត្ត ៥ រូបាវចរវិបាកចិត្ត ៥ រូបាវចរកិរិយាចិត្ត ៥ រួមរូបាវចរចិត្តមាន ១៥ ដួង ។

## អត្ថរបស់ឈាន

**ឈាន** បានដល់ ការសម្លឹងអារម្មណ៍ដើម្បីឲ្យចិត្តជិតជាប់ក្នុងអារម្មណ៍កម្មដ្ឋាន បានដល់ ការដែលចិត្តចូលទៅសម្លឹងអារម្មណ៍ មានបឋវីកសិណជាដើម ដោយអំណាចនៃអប្បនាសមាធិម្យ៉ាង និងសំដៅយកធម្មជាតិ ដែលជាគ្រឿងដុតធម៌ដែលជាសត្រូវ ដល់ការសម្លឹងអារម្មណ៍ ដើម្បីឲ្យឈានចិត្តកើតឡើងម្យ៉ាង ។

ធម៌ដែលជាសត្រូវឬបដិបក្ខដល់ឈានចិត្តនោះ ហៅថា **នីវរណ** គឺជាគ្រឿងរាំងនៃការធ្វើសេចក្តីល្អ ក្នុងទីនេះសំដៅដល់ រាំងមិនឲ្យចូលដល់ឈានចិត្តបាន ។

# ឈានមាន ២ យ៉ាង គឺ

១. **អារម្មណូបនិជ្ឈាន** បានដល់ ការសម្លឹងនិមិត្តនៃអារម្មណ៍ ដើម្បីឲ្យចិត្តជិតជាប់នឹងអារម្មណ៍ អង្គធម៌បានដល់ មហគ្គតកុសលចិត្ត ៩ ដួង និងមហគ្គតកិរិយាចិត្ត ៩ ដួង ។

២. **លក្ខណូបនិជ្ឈាន** បានដល់ ការសម្លឹងសភាវលក្ខណៈនៃអារម្មណ៍ ដើម្បីឲ្យបញ្ញាដឹងបរមត្ថអារម្មណ៍ ដោយមានអនិច្ចលក្ខណៈជាដើម អង្គធម៌បានដល់ មហាកុសលញាណសម្បយុត្តចិត្ត ៤ និងលោកុត្តរចិត្ត ៨ ខណៈដែលវិបស្សនាញាណ មគ្គញាណ និងផលញាណកើតឡើង ។

ក្នុងឈានទាំង ២ នេះ ដោយអត្ថបំណងយកអារម្មណូបនិជ្ឈាន ព្រោះដូច្នោះ ឈានក្នុងទីនេះ ទើបមានសេចក្ដីថា សម្លឹងអារម្មណ៍ ឬព្រោះជាគ្រឿងដុតធម៌ដែលជាសត្រូវដល់ឈានចិត្ត ។

ក្នុងអដ្ឋសាលិនីសម្ដែងថា « **អារម្មណូបនិជ្ឈានតោ បច្ចនីកជ្ឈាបនតោ វា = ឈានំ** » ប្រែថា ធម្មជាតិណាដែលសម្លឹងអារម្មណ៍ក្ដី ឬធម្មជាតិដុតធម៌ដែលជាបដិបក្ខក្ដី ធម្មជាតិនោះឈ្មោះថា "**ឈាន**" ។

អារម្មណ៍សម្រាប់សម្លឹង បានដល់ អារម្មណ៍កម្មដ្ឋាន គឺសមថកម្មដ្ឋានមានចំនួនទាំងអស់ ៤០ គឺ កសិណ ១០ អសុភ ១០ អនុស្សតិ ១០ (ឲ្យចូលដល់ឈានបានត្រឹម ២ គឺកាយគតាសតិ ១ អានាបានស្សតិ ១ ប៉ុណ្ណោះ) អប្បមញ្ញា ៤ អាហារេបដិកូលសញ្ញា ១ ចតុធាតុវវត្ថាន ១ អរូបកម្មដ្ឋាន ៤ រួមអារម្មណ៍កម្មដ្ឋាន ៤០ ។

ធម៌ដែលជាបដិបក្ខរបស់ឈាន បានដល់ **នីវរណ** គឺជាគ្រឿងរារាំងការធ្វើសេចក្តីល្អក្នុងទីនេះ បានដល់ រារាំងមិនឲ្យចូលដល់ឈានបាន នីវរណៈមាន ៥ ប្រការ គឺ

**១. កាមច្ឆន្ទនីវរណ** បានដល់ លោភចេតសិក ដែលត្រេកអរជាប់ចិត្តក្នុងកាមគុណារម្មណ៍ មានរូប សំឡេង ក្លិន រស ផោដ្ឋព្វៈជាដើម កាមារម្មណ៍ទាំងនេះ ជាគ្រឿងរារាំងមិនឲ្យឈានចិត្តកើតឡើងបាន ។

**២. ព្យាបាទនីវរណ** បានដល់ ទោសចេតសិក ដែលជាសេចក្តីក្រោធខឹងនឹងប្រទូសរ៉ាយអ្នកដទៃ រមែងជាគ្រឿងរារាំងមិនឲ្យចិត្តចូលដល់ឈានបាន ។

**៣. ថីនមិទ្ធនីវរណ** បានដល់ ថីនៈនិងមិទ្ធចេតសិក ដែលមានការរួញរាថយចាកអារម្មណ៍ដែលត្រូវសម្លឹង រមែងជាគ្រឿងរារាំងមិនឲ្យចិត្តចូលដល់ឈាន ។

**៤. ឧទ្ធច្ចកុក្កុច្ចនីវរណ** បានដល់ ឧទ្ធច្ចចេតសិក និងកុក្កុច្ចចេតសិក ដែលជាការរាយមាយក្តៅក្រហាយចិត្ត រមែងជាបដិបក្ខដល់ឈាន ព្រោះត្រូវអាស្រ័យការសម្លឹងអារម្មណ៍ដោយសេចក្តីស្ងប់ ឈានទើបកើតមិនបាន ។

**៥. វិចិកិច្ឆានីវរណ** បានដល់ វិចិកិច្ឆាចេតសិក ដែលមានការសង្ស័យរារែកចិត្ត រមែងទម្លាយសេចក្តីស្វាហាប់នៃការសម្លឹងអារម្មណ៍ឲ្យវិនាសទៅ ទើបមិនអាចចូលដល់ឈានបាន ។

នីវរណធម៌ទាំង ៥ ប្រការ នេះ ឈ្មោះថា ជាបដិបក្ខធម៌ ឬធម៌ដែលជាសត្រូវ ដែលត្រូវប្រើអង្គឈានជាគ្រឿងរម្ងាប់ ។

## ឈានស្ងប់ចាកកាមគុណ និង អកុសលធម៌

ក្នុងអដ្ឋសាលិនីសម្ដែងថា **វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ** មានអត្ថថា ស្ងប់ចាកកាមទាំងឡាយ និងស្ងប់ចាកអកុសលធម៌ទាំងឡាយ ។

**វិវិច្ច** បានដល់ **វិវេក** ប្រែថា សេចក្ដីស្ងប់ស្ងាត់ គឺគេចចេញ ។

**វិវិច្ចេវ កាមេហិ** បានដល់ គេចចេញចាកកាមទាំងឡាយ គឺ ទាំងវត្ថុកាមនិងកិលេសកាម កាមទាំងឡាយដូចពោលនេះ ស្ងម្បីមិនមាននៅក្នុងវេលាចូលបឋមជ្ឈានក៏ពិត តែក៏នៅជាសត្រូវដល់បឋមជ្ឈានបាន ដូច្នេះការសម្រេចបឋមជ្ឈានបាន ក៏ត្រូវលះកាមចេញ ដែលហៅថា លះចាកកាមនោះឯង ។

ស្ងម្បីឈាននេះ នឹងប្រាកដផលថា ជាគ្រឿងលះកាមទាំងឡាយចេញទៅក៏ពិត តែក៏មិនបានសំដៅយក ត្រឹមតែលះបង់កាមទាំងឡាយចេញប៉ុណ្ណោះទេ ព្រះយោគាវចរក៏នឹងអាចចូលឈានបាន ព្រោះកាម ឬកាមច្ឆន្ទៈនោះ មានត្រឹមតែ ១ ក្នុង ៥ របស់នីវរណធម៌ប៉ុណ្ណោះ នីវរណធម៌ដទៃ ក្រៅអំពីកាមនៅមានសល់ទៀត ធម៌ទាំងនោះ ក៏ជាសត្រូវដល់ឈានដូចគ្នា ទើបត្រូវលះនីវរណធម៌ ឬអកុសលធម៌ទាំងនោះផង ទើបចូលដល់បាន សម្ដែងថា ឈានរមែងស្ងាត់ចាកកាមទាំងឡាយ

និងអកុសលធម៌ទាំងពួង សមដូចបាលីដែលលើកមកពោល ខាងលើនេះ ។

សរុបសេចក្តីថា **វិវិច្ចេវ កាមេហិ** នេះ រមែងសំដៅដល់ **វិវេក** ដែលជាគ្រឿងគ្របសង្កត់កាមច្ឆន្ទៈ និង **វិវិច្ច អកុសលេហិ ធម្មេហិ** រមែងសំដៅដល់ **វិវេក** ដែលជាគ្រឿងគ្របសង្កត់នីវរណធម៌ដ៏សេស គឺព្យាបាទនីវរណៈ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចកុក្កុច្ចនីវរណៈ និង វិចិកិច្ឆានីវរណៈ កាលពោលដោយអភិធម្មន័យហើយ រមែងសំដៅដល់ **វិវេក** ដែលជាគ្រឿងគ្របសង្កត់ការកើតឡើងនៃលោភមូលចិត្ត ៨ ដួង និងសំដៅដល់ **វិវេក** ដែលជាគ្រឿងគ្របសង្កត់ការកើតឡើងនៃទោសមូលចិត្ត ២ ដួង មោហមូលចិត្ត ២ ដួង ប៉ុណ្ណោះ ។

## អង្គនៃឈាន

ក្នុងការប្រកបកុសលកម្ម ដែលមានទានជាដើមនេះ កុសលចេតនាប្រាកដឡើងក្នុងខណៈណា មហាកុសលចិត្តរមែងកើតឡើងក្នុងខណៈនោះមួយរំពេច តែរូបាវចរកុសលចិត្ត មិនមែនកើតដូច្នោះទេ រូបាវចរចិត្តនឹងកើតឡើងបាន អាស្រ័យការចម្រើនសមថភាវនានោះ ចូលដល់អប្បនាសមាធិ គឺចិត្តចូលដល់ការជិតជាប់ក្នុងអារម្មណ៍ ឈាន មានកសិណជាដើម ពោលគឺ ខណៈដែលកំពុងចម្រើនភាវនានោះ ក្រុមចេតសិកធម៌ ដែលកើតព្រមជាមួយចិត្តមួយក្រុម នឹងធ្វើនាទីដុតឬគ្របសង្កត់នីវរណធម៌ ដែលជាគ្រឿងរារាំងមិនឲ្យឈានចិត្តកើតឡើងបាន

នីវរណធម៌ទាំង ៥ ណាមួយនៅមាន ឈានចិត្តនឹងកើតឡើងមិនបានឡើយ ដូច្នោះកាលក្រុមចេតសិកធម៌ដូចពោលនោះ ធ្វើនាទីកម្ចាត់ឬគ្របសង្កត់នីវរណធម៌ឲ្យវិនាសទៅ ឈានចិត្តរមែងកើតឡើងបាន ។

ខណៈដែលឈានចិត្តប្រាកដឡើងនេះឯង ក្រុមចេតសិកធម៌ គឺ វិតក្កចេតសិក វិចារចេតសិក បីតិចេតសិក វេទនាចេតសិក (សុខ ឬ ឧបេក្ខា) និងឯកគ្គតាចេតសិក ដែលធ្វើនាទីគ្របសង្កត់នីវរណធម៌បានហើយ ទើបប្រាកដច្បាស់ជាអង្គឈាន ព្រោះដូច្នោះ អង្គនៃឈានទើបបានដល់ វិតក្កៈ វិចារៈ បីតិ សុខ (វេទនាចេតសិក) និងឯកគ្គតា ត្រឹមតែអង្គ ៥ នេះ ។

## ឈានលះបង់នីវរណៈ

ការគ្របសង្កត់នីវរណៈ ឬប្រហារនីវរណៈដោយអំណាចនៃឈាន ហៅថា **វិក្ខម្ភនប្បហាន** ដរាបណាដែលឈានចិត្តមិនទាន់សាបសូន្យ ដរាបនោះនីវរណធម៌រមែងត្រូវគ្របសង្កត់ទុក មិនឲ្យប្រាកដឡើងមកបាន ឬពោលថា នីវរណធម៌កម្រើកឡើងកាលណា ឈានក៏សាបសូន្យទៅកាលនោះ ។

ការប្រហារនីវរណធម៌ ៥ ប្រការ បាននោះ រមែងត្រូវអាស្រ័យអង្គឈានជាគ្រឿងប្រហារ ដូច្នេះ គឺ

**វិតក្ក** ប្រហារថីនមិទ្ធនីវរណៈ ។

**វិចារ** ប្រហារវិចិកិច្ឆានីវរណៈ ។

**បីតិ** ប្រហារព្យាបាទនីវរណៈ ។

**សុខ** (វេទនា) ប្រហារឧទ្ធច្ចកុក្កុច្ចនីវរណៈ ។

**ឯកគ្គតា** ប្រហារកាមច្ឆន្ទនីវរណៈ ។

## អធិប្បាយអង្គឈាន

**១. វិតក្ក** គឺ ការលើកចិត្តឡើងកាន់អារម្មណ៍ក្នុងការធ្វើឈាន (រូបឈាន) នោះ ត្រូវសាងបញ្ញត្តារម្មណ៍ ដែលហៅថា អង្គកសិណ ជាដើម ទុកសម្រាប់ឲ្យចិត្តចូលទៅសម្លឹងអង្គកសិណនោះ ព្រោះដូច្នោះ ការសម្លឹងអង្គកសិណនេះ ព្រះយោគាវចរអ្នកបដិបត្តិត្រូវលើកចិត្តឡើង កាន់អារម្មណ៍កម្មដ្ឋាន ដែលកំណត់ទុកជានិច្ច ត្រូវព្យាយាមមិនបណ្តោយ ឲ្យចិត្តចេញចាកអារម្មណ៍ដែលកំណត់ទុក ទៅគិតរឿងដទៃ បើខណៈណា ចិត្តចេញចាកអារម្មណ៍ដែលសម្លឹង **ថីនមិទ្ធ** គឺសភាវៈដែលធ្វើឲ្យចិត្តរួញរា ថយចាកអារម្មណ៍ដែលសម្លឹង ឬរំសាយចិត្តចាកអារម្មណ៍ដែលសម្លឹង ខណៈនោះចិត្តរមែងធ្លាក់ចុះពីអង្គកសិណ ត្រូវលើកចិត្តឲ្យត្រឡប់មក ឡើងកាន់អង្គកសិណជាថ្មី គឺ ឲ្យសម្លឹងអង្គកសិណទៀតមិនឲ្យឃ្លាត ចេញចាកអង្គកសិណ ដូច្នោះ វិតក្កៈ គឺ ធម្មជាតិដែលលើកចិត្តឡើងកាន់ អារម្មណ៍នេះ ទើបធ្វើនាទីប្រហារថីនមិទ្ធ ដោយលក្ខណៈនៃការ គ្របសង្កត់ទុក ។

**២. វិចារ** គឺ ការផ្គងចិត្តឲ្យតាំងមាំនៅក្នុងអារម្មណ៍ដែលសម្លឹង កាលវិតក្កៈលើកចិត្តឡើងកាន់អារម្មណ៍ដែលសម្លឹងហើយ វិចារៈក៏ធ្វើនាទី

ផ្គងចិត្តមិនឲ្យធ្លាក់ចេញពីអារម្មណ៍ដែលសម្លឹងនោះ បើកើតការសង្ស័យឡើងក្នុងខណៈសម្លឹងអារម្មណ៍ថា ការសម្លឹងអារម្មណ៍ដូច្នោះ នឹងអាចធ្វើឲ្យឈានកើតឡើងបានពិតឬ? កាលសង្ស័យកើតឡើង ការផ្គងចិត្តឲ្យតាំងមាំក្នុងអារម្មណ៍ក៏នឹងសាបសូន្យទៅ សេចក្តីនឿយណាយក្នុងការផ្គងចិត្តក៏នឹងកើតឡើង ដូច្នោះព្រះយោគាវចរ ចាំបាច់ត្រូវប្រើវិចារៈផ្គងចិត្តឲ្យសម្លឹងអារម្មណ៍ ដោយប្រាសចាកសេចក្តីសង្ស័យព្រមជាមួយវិចារៈរមែងធ្វើនាទីគ្របសង្កត់វិចិកិច្ឆានីវរណៈ ក្នុងលក្ខណៈ**វិក្ខម្ភនប្បហាន** ។

**៣. បីតិ** គឺ សេចក្តីត្រេកអររីករាយ កាលវិតក្កៈបានធ្វើនាទីលើកចិត្តឡើងកាន់អារម្មណ៍ និងវិចារៈផ្គងចិត្តឲ្យតាំងមាំក្នុងអារម្មណ៍ហើយរមែងកើតសេចក្តីត្រេកអររីករាយចិត្ត ក្នុងការដែលអាចធ្វើបាន ដូច្នោះខណៈដែលចិត្តកំពុងត្រេកអររីករាយនោះ ការព្យាបាទរមែងមិនកើតឡើង ដូច្នោះបីតិនេះទើបអាចគ្របសង្កត់ព្យាបាទនីវរណៈបានដោយ**វិក្ខម្ភនប្បហាន** ។

## បីតិ នេះមាន ៥ យ៉ាង គឺ

**១. ខុទ្ទកាបីតិ** គឺ សេចក្តីត្រេកអរតិច ត្រឹមព្រឺរោមព្រឺស្បែក ។

**២. ខណិកាបីតិ** គឺ សេចក្តីត្រេកអរមួយខណៈៗ ប្រាកដដូចជាផ្លេកបន្ទោរ ។

**៣. ឱក្កន្តិកាបីតិ** គឺ សេចក្តីត្រេកអររឿយៗ មានអាការប្រាកដដូចជាទឹករលកបោកខ្ទប់មកត្រូវ ។

**៤. ឧព្វេង្គាបីតិ** គឺ សេចក្ដីត្រេកអរខ្លាំង អាចញ៉ាំងកាយឲ្យអណ្ដែតឡើង ។

**៥. ផរណាបីតិ** គឺ សេចក្ដីត្រេកអរផ្សព្វផ្សាយជ្រួតជ្រាបទូទៅក្នុងកាយ ។

**បីតិ** ដែលជាអង្គឈានអាចប្រហារព្យាបាទនីវរណៈបាននោះ ត្រូវដល់ថ្នាក់ **ផរណាបីតិ** ចំណែកបីតិក្រៅពីនោះ ៤ យ៉ាង មិនរាប់ថាជាអង្គឈាន ព្រោះនៅមានសភាពគ្រោតគ្រាត និងមានកម្លាំងខ្សោយ ។

**៤. សុខ** គឺ សុខវេទនាក្នុងអង្គឈាន បានដល់ សេចក្ដីសុខចិត្ត ឬសោមនស្សវេទនានោះឯង ខណៈបរិកម្ម គឺ លើកចិត្តឡើងកាន់អារម្មណ៍ និងផ្គងចិត្តឲ្យតាំងនៅក្នុងអារម្មណ៍រហូតដល់កើតបីតិ ដូច្នេះហើយ រមែងដឹងខ្លួនថាសុខ ព្រោះមានសេចក្ដីស្ងប់ប្រាសចាកការរវើរវាយចិត្ត ខណៈដែលកំពុងសោយសេចក្ដីសុខនេះ សុខវេទនាទើបមានសភាពជាអ្នកដុត ឬគ្របសង្កត់ឧទ្ធច្ចកុក្កុច្ចនីវរណៈ មិនឲ្យកើតឡើងបាន សុខវេទនាទើប ឈ្មោះថា ជាអ្នកប្រហារឧទ្ធច្ចកុក្កុច្ចនីវរណៈដោយ **វិក្ខម្ភនប្បហាន** ។

**បីតិ** និង **សុខ** មានសភាវៈស្រដៀងគ្នា ពោលគឺ បីតិ បានដល់សេចក្ដីត្រេកអររីករាយ ដែលបានប្រសព្វជាមួយឥដ្ឋារម្មណ៍ ចំណែកសុខ មានការសោយអារម្មណ៍ដែលបានប្រសព្វហើយ ។

**បីតិ** មានក្នុងទីណា សុខក៏មានក្នុងទីនោះ តែបើសុខមានក្នុងទីណា បីតិអាចមិនមានក្នុងទីនោះ បីតិជាសង្ខារក្ខន្ធ ចំណែកសុខជាវេទនាខន្ធ ។

**៥. ឯកគ្គតា** បានដល់ ការដែលចិត្តមានអារម្មណ៍តែមួយ កាលចិត្តតាំងនៅក្នុងអារម្មណ៍ដែលសម្លឹងតែមួយហើយ ឈ្មោះថា ចិត្តមានសមាធិ គឺ ការមិនរវើរវាយទៅក្នុងអារម្មណ៍ផ្សេងៗ មានរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ រឿងរ៉ាវជាប់ដោយកាមគុណារម្មណ៍ ចិត្តនឹងតាំងមាំនៅក្នុងអារម្មណ៍ដែលសម្លឹងតែម្យ៉ាង រមែងមានសមាធិ គឺ ការឈប់នឹងនៃចិត្ត ដូចការតាំងនៅនឹងរបស់អណ្តាតប្រទីបនៅក្នុងទីដែលស្ងប់ខ្យល់ ដូច្នោះ សមាធិចិត្តនោះ មិនរវើរវាយទៅកាន់អារម្មណ៍ដែលប្រាថ្នា ដូច្នេះ គឺ អំណាចនៃសមាធិ ឬឯកគ្គតានេះ រមែងដុតកិលេស ឬគ្របសង្កត់ **កាមច្ឆន្ទនីវរណៈ** ។

## សមាធិមាន ៣ យ៉ាង

**១. ខណិកសមាធិ** បានដល់ សមាធិដែលធ្វើឲ្យចិត្តតាំងមាំនៅក្នុងអារម្មណ៍បានមួយជួរខណៈ ។

**២. ឧបចារសមាធិ** បានដល់ សមាធិដែលធ្វើឲ្យចិត្តតាំងមាំនៅក្នុងអារម្មណ៍ជិតនឹងបានឈាន ។

**៣. អប្បនាសមាធិ** បានដល់ សមាធិដែលធ្វើឲ្យចិត្តតាំងមាំនៅក្នុងអារម្មណ៍ដែលកិលេសមិនអាចរុកកួនបាន ឈានចិត្តរមែងកើតឡើង បានដល់ អប្បនាសមាធិនេះឯង ។

## ប្រភេទនៃឈាន

តាមន័យនៃព្រះអភិធម្ម បានចែកប្រភេទនៃឈានទុក ៥ ប្រភេទ ហៅថា ឈានបញ្ចកន័យ បានដល់

**បឋមជ្ឈាន** មានអង្គឈាន ៥ គឺ **វិតក្ក វិចារ បីតិ សុខ ឯកគ្គតា**

**ទុតិយជ្ឈាន** មានអង្គឈាន ៤ គឺ - **វិចារ បីតិ សុខ ឯកគ្គតា**

**តតិយជ្ឈាន** មានអង្គឈាន ៣ គឺ - - **បីតិ សុខ ឯកគ្គតា**

**ចតុត្ថជ្ឈាន** មានអង្គឈាន ២ គឺ - - - **សុខ ឯកគ្គតា**

**បញ្ចមជ្ឈាន** មានអង្គឈាន ២ គឺ - - - **ឧបេក្ខា ឯកគ្គតា**

## អធិប្បាយឈាន

**១. បឋមជ្ឈាន** បានដល់ ឈានទី ១ ជាឈានដែលកើតឡើងគ្រាដំបូង ដែលឆ្លងពីកាមគោត្របាន បឋមជ្ឈាននេះ ទើបត្រូវអាស្រ័យអង្គឈានគ្រប់ទាំង ៥ ជាគ្រឿងគ្របសង្កត់នីវរណៈទាំង ៥ ប្រការនោះ ចិត្តដែលស្ងាត់ចាកនីវរណធម៌ ដោយការគ្របសង្កត់ទុកបានក្នុងគ្រាដំបូងនេះទើបឈ្មោះថា បឋមជ្ឈានកុសលចិត្ត អង្គឈានទាំង ៥ រមែងកើតព្រមគ្នានឹងខណៈជាមួយគ្នា រមែងធ្វើនាទីដុតឬគ្របសង្កត់នីវរណៈព្រមគ្នាទៀតផង មិនមែនថា អង្គឈាននឹងកើតឡើងម្តងមួយ និងមិនមែនគ្របសង្កត់នីវរណៈម្តងមួយទេ ។

**២. ទុតិយជ្ឈាន** បានដល់ ឈានទី ២ ដែលកើតឡើងបានក្នុងលំដាប់តទៅ ខាងក្រោយពីបឋមជ្ឈានដែលបានកើតឡើងហើយ ។

ក្នុងការបដិបត្តិដើម្បីឲ្យទុតិយជ្ឈានកើតឡើងបាននោះ ត្រូវធ្វើបឋមជ្ឈានឲ្យកើតឡើងជាប់តគ្នារឿយៗ ដើម្បីអប់រំចិត្តឲ្យមានសមាធិខ្លាំងក្លាឡើង និងមានជំនាញក្នុងការចូលឈាន និងចេញចាកឈាន សេចក្តីជំនាញទាក់ទងនឹងឈាននេះ ហៅថា **វសី** មាន ៥ យ៉ាង គឺ

**១. អាវជ្ជនវសី** បានដល់ សេចក្តីជំនាញក្នុងការពិចារណាអង្គឈាន មុនចូលឈានដើម្បីឲ្យចូលឈានបានដោយរហ័ស ។

**២. សមាបជ្ជនវសី** បានដល់ សេចក្តីជំនាញក្នុងការចូលសមាបត្តិ។

**៣. អធិដ្ឋានវសី** បានដល់ សេចក្តីជំនាញក្នុងការតាំងនៅក្នុងឈាន។

**៤. វុដ្ឋានវសី** បានដល់ សេចក្តីជំនាញក្នុងការចេញចាកឈាន។

**៥. បច្ចវេក្ខណវសី** បានដល់ សេចក្តីជំនាញក្នុងការពិចារណាអង្គឈានក្រោយពីចេញចាកឈាន ។

ពេលព្រះយោគាវចរបានបឋមជ្ឈានជំនាញព្រមដោយវសីទាំង ៥ ហើយ ក៏អាចចម្រើនទុតិយជ្ឈាបាន ដោយសម្លឹងបដិភាគនិមិត្តដែលធ្លាប់បានពីបឋមជ្ឈានមកហើយ មិនត្រូវសម្លឹងអង្គកសិណដូចកាលផ្តើមចម្រើនបឋមជ្ឈាន កាលសម្លឹងបដិភាគនិមិត្តនេះ ព្រោះសេចក្តីជំនាញរហូតដល់បានជាវសីហើយ ទើបមិនត្រូវអាស្រ័យវិតក្កៈលើកចិត្តឡើងកាន់អារម្មណ៍ និងព្រោះចិត្តដែលចូលឈានរហូតដល់ជំនាញហើយ ចិត្តរមែងមិនរួញរាថយចាកអារម្មណ៍ តែនឹងជាប់នៅជាមួយអារម្មណ៍ដែលសម្លឹងនោះយ៉ាងល្អ ទើបមិនត្រូវអាស្រ័យវិតក្កៈគ្របសង្កត់ថីនមិទ្ធ-នីវរណៈ ព្រោះគ្របសង្កត់មកហើយពីបឋមជ្ឈាន ដូច្នោះ ទុតិយជ្ឈាន

ទើបមានអង្គឈានត្រឹមតែ ៤ ដោយលះវិតក្កៈបានហើយ ។

**៣. តតិយជ្ឈាន** បានដល់ ឈានទី ៣ កាលបានទុតិយជ្ឈានហើយ ត្រូវព្យាយាមធ្វើទុតិយជ្ឈានឲ្យជំនាញជាវសីជាមុនសិន អ្នកដែលនឹងចម្រើនឲ្យចូលដល់តតិយជ្ឈាននោះ រមែងឃើញទោសរបស់វិចារៈថា មានសភាពគ្រោតគ្រាតមិនគង់វង្ស មានសភាពងាយសាបសូន្យ ទើបព្យាយាមលះវិចារៈ ជាអង្គឈានដែលខ្លួនឃើញថា មានសភាពគ្រោតគ្រាតនេះចេញ ដើម្បីចូលកាន់តតិយជ្ឈាន ដែលមានតែបីតិ សុខ និងឯកគ្គតា ដែលប្រណីតជាងទុតិយជ្ឈាន ទើបផ្តើមដោយការសម្លឹងបដិភាគនិមិត្ត និងបរិកម្មរហូតដល់តតិយជ្ឈានកើត តតិយជ្ឈានចិត្តទើបមានអង្គឈានត្រឹមតែ ៣ គឺ **បីតិ សុខ** និង**ឯកគ្គតា** ដោយលះបានទាំងវិតក្កៈ និងវិចារៈ ។

**៤. ចតុត្ថជ្ឈាន** បានដល់ ឈានទី ៤ តតិយជ្ឈានលាភីបុគ្គលកាលបានចូលតតិយជ្ឈានជំនាញជាវសីហើយ រមែងកើតការនឿយណាយក្នុងតតិយជ្ឈាននោះ ព្រមទាំងការពិចារណាឃើញថា បីតិដែលកើតក្នុងតតិយជ្ឈាន ជាការត្រេកអររីករាយទាំងក្នុងកាយនិងចិត្ត មានអាការទោរទន់ទៅក្នុងផ្លូវឃ្លេងឃ្លោង ចិត្តទើបរាប់ថាជាសភាពដែលនៅគ្រោតគ្រាត និងបំណងចង់បានឈានដែលប្រណីតឡើងទៅទៀត មិនគួរជាប់ចិត្តនៅក្នុងបីតិ ដែលជារបស់គ្រោតគ្រាតត្រឹមនេះ ទើបផ្តើមចម្រើនចតុត្ថជ្ឈានដោយសម្លឹងបដិភាគនិមិត្ត ដើម្បីលះបីតិចេញ កាលចតុត្ថជ្ឈានចិត្តកើត ទើបសល់អង្គឈានត្រឹមតែ ២ គឺ សុខ និង

ឯកគ្គតាប៉ុណ្ណោះ ។

**៥. បញ្ចមជ្ឈាន** ជាឈានចុងក្រោយរបស់រូបជ្ឈាន ចតុត្ថជ្ឈានលាភីបុគ្គលកាលនឹងចូលកាន់បញ្ចមជ្ឈាន ត្រូវពិចារណាឃើញទោសរបស់សុខ ដែលមានសភាពគ្រោតគ្រាតជាងឧបេក្ខាឯកគ្គតា ហើយក៏ផ្តើមសម្លឹងបដិភាគនិមិត្តដោយភាវនាទាំង ៣ តាមលំដាប់ គឺ បរិកម្មភាវនា ឧបចារភាវនា និងអប្បនាភាវនា ដើម្បីលះសុខតទៅ រហូតចូលដល់បញ្ចមជ្ឈាន ដូច្នេះក្នុងបញ្ចមជ្ឈាននេះ ទើបផ្លាស់វេទនាពីសុខវេទនាក្នុងចតុត្ថជ្ឈានមកជាឧបេក្ខាវេទនា អង្គឈាន ទើបមាន ២ បានដល់ **ឧបេក្ខា** និង**ឯកគ្គតា** ។

**សុខ** ជាអង្គឈាន ដែលចតុត្ថជ្ឈានលាភីបុគ្គលលះបាននោះ បានដល់ សុខផ្លូវចិត្ត គឺ សោមនស្សវេទនានោះឯង ចំណែកសេចក្តីសុខកាយនិងទោមនស្សនោះ សូម្បីព្រះពុទ្ធអង្គមិនបានត្រាស់ទុក ដោយលំដាប់នៃការលះអង្គឈានទាំងនេះក្តី តែក៏បានត្រាស់ទុកដោយលំដាប់នៃឥន្ទ្រិយទាំងឡាយ ក្នុងឥន្ទ្រិយវិភង្គ ដោយអត្ថថា ទុក្ខទោមនស្ស និងសុខកាយ រមែងលះបានក្នុងខណៈនៃឧបចារភាវនា របស់ឈានទី ១ ទី ២ និងទី ៣ ដោយអាការយ៉ាងនេះ ។

## អានិសង្សរបស់សោមនស្សវេទនា និង ឧបេក្ខាវេទនា

ក្នុងមហាកុសល ឬកាមាវចរកុសល សោមនស្សវេទនា រមែងមានអានិសង្សច្រើនជាងឧបេក្ខាវេទនា តែក្នុងឈានកុសល ឧបេក្ខាវេទនា រមែងមានអានិសង្សច្រើនជាងសោមនស្សវេទនា ។

## សេចក្ដីផ្សេងគ្នាដោយប្រភេទនៃឈាន

ប្រភេទរបស់ឈានទាំង ៥ មានបឋមជ្ឈានជាដើម រហូតដល់បញ្ចមជ្ឈានជាទីបំផុតនោះ រមែងមានសេចក្ដីផ្សេងគ្នាត្រង់អង្គឈាននីមួយៗ មានចំនួនអង្គឈានច្រើនឬតិចជាងគ្នាជាគ្រឿងសម្គាល់ ចំណែកអារម្មណ៍ដែលសម្លឹងនោះ រមែងជាអារម្មណ៍តែមួយមិនផ្សេងគ្នាក៏បាន ។

## អារម្មណ៍របស់ឈានដោយប្រភេទផ្សេងៗ

អារម្មណ៍ដែលប្រើសម្លឹង ដើម្បីឲ្យកើតឈានចិត្តប្រភេទផ្សេងៗ ក្នុងឈានទាំង ៥ នោះ ត្រូវអាស្រ័យបញ្ញត្តារម្មណ៍ទាំងអស់ គឺ ត្រូវសន្មតកំណត់និមិត្តណាមួយ មកជាគ្រឿងសម្លឹង និងអារម្មណ៍ដែលជាគ្រឿងសម្លឹងឲ្យឈានចិត្តកើតឡើងបាន តាំងពីបឋមជ្ឈានរហូតដល់បញ្ចមជ្ឈាននោះ រមែងកំណត់ចំពោះអារម្មណ៍ផ្សេងៗ ដូចតទៅនេះ គឺ

**បឋមជ្ឈាន** អាស្រ័យអារម្មណ៍ជាគ្រឿងសម្លឹងបាន ២៥ យ៉ាង បានដល់ កសិណបញ្ញត្តិ ១០ អសុភបញ្ញត្តិ ១០ អានាបានបញ្ញត្តិ ១

កោដ្ឋាសបញ្ញត្តិ ១ និងសត្វបញ្ញត្តិ ៣ គឺ បិយមនាបសត្វបញ្ញត្តិ ទុក្ខិតសត្វបញ្ញត្តិ សុខិតសត្វបញ្ញត្តិ ។

**ទុតិយជ្ឈាន តតិយជ្ឈាន** និង**ចតុត្ថជ្ឈាន** អាស្រ័យអារម្មណ៍ជាគ្រឿងសម្លឹងឲ្យឈានចិត្តកើតឡើងបាន ១៤ យ៉ាង បានដល់ កសិណ-បញ្ញត្តិ ១០ អានាបានបញ្ញត្តិ ១ និងសត្វបញ្ញត្តិ ៣ (វៀរមជ្ឈត្តសត្វបញ្ញត្តិ) ។

**បញ្ចមជ្ឈាន** អាស្រ័យអារម្មណ៍ជាគ្រឿងសម្លឹងឲ្យឈានចិត្តកើតឡើងបាន ១២ យ៉ាង គឺ កសិណបញ្ញត្តិ ១០ អានាបានបញ្ញត្តិ ១ និងសត្វបញ្ញត្តិ ១ គឺមជ្ឈត្តសត្វបញ្ញត្តិ ។

## ឈានចតុក្កន័យ និង បញ្ចកន័យ

ប្រភេទនៃឈានតាមដែលបានពោលមកហើយ មាន ៥ យ៉ាង ដែលជាការពោលតាមន័យរបស់ព្រះអភិធម្ម ដែលចែកប្រភេទរបស់ឈានទៅតាមអង្គឈាន ដែលបញ្ញារបស់មនុស្សបុគ្គលអ្នកមានបញ្ញាដឹងយឺត មិនអាចពិចារណាឃើញទោសរបស់វិតក្កៈ និងវិចារៈទាំង ២ នេះ ក្នុងវេលាជាមួយគ្នាបាន ទើបចែកឈានចេញជា ៥ ប្រភេទ ហៅថាបញ្ចកន័យ ។

ចំណែកតាមន័យរបស់ព្រះសូត្រ បានចែកប្រភេទរបស់ឈានចេញជា ៤ ប្រភេទ ដោយការសម្តែងដល់តិក្ខបុគ្គលអ្នកចម្រើនទុតិយជ្ឈាននោះ កាលនឹងចូលទុតិយជ្ឈាន ទើបមានអង្គឈានត្រឹមតែ ៣ គឺ បីតិ

សុខ និងឯកគ្គតា ទាំងនេះព្រោះអាចលះទាំងវិតក្កៈ និងវិចារៈបានក្នុងខណៈតែមួយ ទើបចែកចេញជា ៤ ប្រភេទហៅថា ចតុក្កន័យដែលមានអង្គឈាន ដូច្នេះ

**បឋមជ្ឈាន** មានអង្គឈាន ៥ គឺ **វិតក្ក វិចារ បីតិ សុខ ឯកគ្គតា**

**ទុតិយជ្ឈាន** មានអង្គឈាន ៣ គឺ - - **បីតិ សុខ ឯកគ្គតា**

**តតិយជ្ឈាន** មានអង្គឈាន ២ គឺ - - - **សុខ ឯកគ្គតា**

**ចតុត្ថជ្ឈាន** មានអង្គឈាន ២ គឺ - - - **ឧបេក្ខា ឯកគ្គតា** ។

តាមន័យរបស់ព្រះអភិធម្ម ដែលចែកឈានជាបញ្ចកន័យនោះ ក៏ដើម្បីឲ្យត្រូវតាមសភាវៈ ត្រូវតាមប្រភេទនិងចំនួនរបស់ចិត្ត ដែលមាននៅក្នុងចំណែកខាងច្រើន ព្រោះចិត្តរបស់មនុស្សបុគ្គលអ្នកដឹងយឺតនោះ នឹងលះអង្គឈានបានត្រឹមតែ ១ ប៉ុណ្ណោះ គឺ ទុតិយជ្ឈានលះវិតក្កៈ និងតតិយជ្ឈានលះវិចារៈ ។

តែបើជាតិក្ខបុគ្គល គឺ អ្នកដឹងរហ័សនោះ រមែងមានសតិបញ្ញាមុតស្រួច អាចនឹងលះអង្គឈានទាំងវិតក្កវិចារៈ បានក្នុងគ្រាតែមួយព្រមគ្នា ។

ដោយហេតុនេះ ព្រះយោគាវចរដែលអាចចូលឈានសមាបត្តិតាំងពីដើមរហូតដល់ទីបំផុតនោះ ទើបពោលថាបានឈានសមាបត្តិ ៨ និងក្នុងន័យខ្លះក៏ពោលថា បានឈានសមាបត្តិ ៩ ។

ដែលពោលបានថាសមាបត្តិ ៨ នោះ ជាការពោលតាមន័យរបស់ព្រះសូត្រដែលសម្តែងថា រូបជ្ឈានមាន ៤ អរូបជ្ឈានមាន ៤ រួមជាឈានសមាបត្តិ ៨ និងដែលពោលថាបានឈានសមាបត្តិ ៩ នោះ ជាការពោល

តាមន័យរបស់ព្រះអភិធម្មនោះ ដែលសម្ដែងថា រូបជ្ឈាននោះមាន ៥ អរូបជ្ឈានមាន ៤ រួមជាឈានសមាបត្តិ ៩ ។

**ឈានបញ្ចកន័យ** តាមន័យរបស់ព្រះអភិធម្មនេះ កាលចែកដោយប្រភេទនៃជាតិ គឺ កុសល វិបាក និងកិរិយាហើយ ទើបបានដល់រូបាវចរ-កុសលចិត្ត ៥ រូបាវចរវិបាកចិត្ត ៥ រូបាវចរកិរិយាចិត្ត ៥ រួមរូបាវចរចិត្តទាំងអស់ ១៥ ដែលមានសេចក្ដីលម្អិតដូច្នេះ ។

## រូបាវចរកុសលចិត្ត

***រូបាវចរកុសលចិត្ត*** ជាចិត្តដែលកើតឡើងដោយការចម្រើនសមថភាវនា រមែងត្រូវអាស្រ័យបញ្ញត្តិរបស់រូបធម៌ណាមួយជាអារម្មណ៍ ចិត្តដែលផ្ដើមសម្លឹងបញ្ញត្តារម្មណ៍ក្នុងគ្រាដំបូងនេះ រមែងជាមហាកុសលចិត្ត សមាធិដែលប្រកបជាមួយមហាកុសលចិត្តនោះ ថ្នាក់បរិកម្មសមាធិ និងឧបចារសមាធិ កាលចម្រើនភាវនាសមាធិ រហូតចូលដល់អប្បនាសមាធិហើយ ចិត្តនឹងប្ដូរពីមហាកុសលចិត្ត ទៅជារូបាវចរកុសលចិត្ត ដែលកើតព្រមដោយអង្គឈាន ៥ ជាកុសលចិត្តប្រភេទដែលនឹងត្រូវឲ្យផលបដិសន្ធិជារូបព្រហ្មក្នុងភូមិផ្សេងៗ បានតាមសមគួរដល់ឈានចិត្តនោះៗ ។

## រូបាវចរកុសលចិត្ត មាន ៥ ដួង

**១. វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានកុសលចិត្តំ ។**

រូបាវចរកុសលចិត្តដួងទី ១ កើតព្រមដោយ **វិតក្ក វិចារ បីតិ សុខ ឯកគ្គតា ។**

**២. វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានកុសលចិត្តំ ។**

រូបាវចរកុសលចិត្តដួងទី ២ កើតព្រមដោយ **វិចារ បីតិ សុខ ឯកគ្គតា។**

**៣. បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានកុសលចិត្តំ ។**

រូបាវចរកុសលចិត្តដួងទី ៣ កើតព្រមដោយ **បីតិ សុខ ឯកគ្គតា**

**៤. សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានកុសលចិត្តំ ។**

រូបាវចរកុសលចិត្តដួងទី ៤ កើតព្រមដោយ **សុខ ឯកគ្គតា ។**

**៥. ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានកុសលចិត្តំ ។**

រូបាវចរកុសលចិត្តដួងទី ៥ កើតព្រមដោយ **ឧបេក្ខា ឯកគ្គតា ។**

## រូបាវចរវិបាកចិត្ត មាន ៥ ដួង

**រូបាវចរវិបាកចិត្ត** ជាចិត្តដែលជាផលរបស់រូបាវចរកុសលចិត្ត ធ្វើកិច្ចបដិសន្ធិ ភវង្គ និងចុតិរបស់រូបព្រហ្ម ក្នុងរូបភូមិ ១៥ មានចំនួន ៥ ដួង ស្មើគ្នាជាមួយរូបាវចរកុសលចិត្ត ។

**១. វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានវិបាកចិត្តំ ។**

រូបាវចរវិបាកចិត្តដួងទី ១ កើតព្រមដោយ **វិតក្ក វិចារ បីតិ សុខ ឯកគ្គតា ។**

**២. វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានវិបាកចិត្តំ ។**

រូបាវចរវិបាកចិត្តដួងទី ២ កើតព្រមដោយ **វិចារ បីតិ សុខ ឯកគ្គតា។**

**៣. បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានវិបាកចិត្តំ ។**
រូបាវចរវិបាកចិត្តដួងទី ៣ កើតព្រមដោយ **បីតិ សុខ ឯកគ្គតា ។**
**៤. សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានវិបាកចិត្តំ ។**
រូបាវចរវិបាកចិត្តដួងទី ៤ កើតព្រមដោយ **សុខ ឯកគ្គតា ។**
**៥. ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានវិបាកចិត្តំ ។**
រូបាវចរវិបាកចិត្តដួងទី ៥ កើតព្រមដោយ **ឧបេក្ខា ឯកគ្គតា** ។

## រូបាវចរកុសលចិត្តឲ្យផលជារូបាវចរវិបាកចិត្ត

**រូបាវចរកុសលចិត្ត** ជាហេតុដែលធ្វើឲ្យរូបាវចរវិបាកចិត្តប្រាកដឡើងជាផលត្រូវគ្នា នឹងឲ្យបដិសន្ធិក្នុងរូបភូមិផ្សេងៗ ដូច្នេះ គឺ

**បឋមជ្ឈានកុសល** ឲ្យផលជា **បឋមជ្ឈានវិបាក** បដិសន្ធិក្នុងបឋមជ្ឈានភូមិ ។
**ទុតិយជ្ឈានកុសល** ឲ្យផលជា **ទុតិយជ្ឈានវិបាក** } បដិសន្ធិក្នុងទុតិយជ្ឈានភូមិ ។
**តតិយជ្ឈានកុសល** ឲ្យផលជា **តតិយជ្ឈានវិបាក** }
**ចតុត្ថជ្ឈានកុសល** ឲ្យផលជា **ចតុត្ថជ្ឈានវិបាក** បដិសន្ធិក្នុងតតិយជ្ឈានភូមិ។
**បញ្ចមជ្ឈានកុសល** ឲ្យផលជា **បញ្ចមជ្ឈានវិបាក** បដិសន្ធិក្នុងចតុត្ថជ្ឈានភូមិ។

**ចំណុចសម្គាល់ ទុតិយជ្ឈានវិបាក** និង**តតិយជ្ឈានវិបាក** ឲ្យផលបដិសន្ធិក្នុងទុតិយជ្ឈានភូមិជាមួយគ្នានោះ ព្រោះសភាពអង្គឈានរបស់វិតក្កៈនិងវិចារៈទាំង ២ នេះស្រដៀងគ្នា និងរមែងឧបត្ថម្ភដល់គ្នានិងគ្នា ដូច្នេះកាលព្រះយោគាវចរលះវិតក្កៈបាន តែលះវិចារៈមិនបាន ឬលះបានទាំងវិតក្កៈនិងវិចារៈ ក៏គង់ឲ្យផលបដិសន្ធិក្នុងទុតិយជ្ឈានភូមិ

ដូចគ្នានោះឯង តែផលដែលនឹងបានទទួលក្នុងបវត្តិកាលនោះ រមែងនឹងក្រៃលែងជាងគ្នាខ្លះ ។

## រូបាវចរកិរិយាចិត្ត មាន ៥ ដួង

**រូបាវចរកិរិយាចិត្ត** ជាចិត្តរបស់ព្រះអរហន្តដែលចូលដល់រូបជ្ឈាន ដោយន័យដូចគ្នានឹងរូបាវចរកុសលចិត្ត ទើបពោលបានថា រូបាវចរកិរិយាចិត្ត ក៏គឺរូបាវចរកុសលចិត្តនោះឯង តែងកើតឡើងក្នុងសន្តាននៃព្រះអរហន្តដោយចំពោះប៉ុណ្ណោះ ។

ដូច្នោះ រូបាវចរកិរិយាចិត្ត ទើបមានចំនួន ៥ ដួង ដូចគ្នានឹងរូបាវចរកុសលចិត្ត គឺ

**១. វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានក្រិយចិត្តំ ។**

រូបាវចរកិរិយាចិត្តដួងទី ១ កើតព្រមដោយ **វិតក្ក វិចារ បីតិ សុខ ឯកគ្គតា ។**

**២. វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានក្រិយចិត្តំ ។**

រូបាវចរកិរិយាចិត្តដួងទី ២ កើតព្រមដោយ **វិចារ បីតិ សុខ ឯកគ្គតា។**

**៣. បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានក្រិយចិត្តំ ។**

រូបាវចរកិរិយាចិត្តដួងទី ៣ កើតព្រមដោយ **បីតិ សុខ ឯកគ្គតា ។**

**៤. សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានក្រិយចិត្តំ ។**

រូបាវចរកិរិយាចិត្តដួងទី ៤ កើតព្រមដោយ **សុខ ឯកគ្គតា ។**

**៥. ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានក្រិយចិត្តំ ។**

រូបាវចរកិរិយាចិត្តដួងទី ៥ កើតព្រមដោយ **ឧបេក្ខា ឯកគ្គតា** ។

**ចំណុចសម្គាល់** ក្នុងការចម្រើនឈានដោយទូទៅនោះ កាលចូលដល់ឈាន អង្គឈានរមែងគ្របសង្កត់នីវរណៈ ក្នុងខណៈដែលឈានចិត្តកើតជាវិក្ខម្ភនប្បហាន កាលចិត្តផុតចាកឈានហើយ ឬឈានចិត្តសាបសូន្យហើយ នីវរណៈក៏កើតឡើងបានទៀត រមែងសម្តែងឲ្យឃើញថា អង្គឈាននោះ មាននាទីគ្របសង្កត់នីវរណៈ តែសម្រាប់ព្រះអរហន្តខីណាស្រព អ្នកប្រាសចាកកិលេសនីវរណៈអស់រលីងហើយ ការកំណត់អង្គឈាន ដើម្បីលះអង្គឈានដែលគ្រោតគ្រាត កាន់យកអង្គឈានដែលប្រណីត ដោយសភាវៈរបស់សម្បយុត្តធម៌ ដែលសម្លឹងអារម្មណ៍តាមធម្មនិយាម ដើម្បីចែកឲ្យកំណត់ដឹងបានថា ព្រះអរហន្តអ្នកចម្រើនឈាននោះ បានចូលដល់ឈានថ្នាក់ណា មិនដូច្នោះទេ និងមិនជាការកំណត់ដឹងឈានចិត្តសម្រាប់ព្រះអរហន្តបានឡើយ ។

## ភូមិដែលជាទីកើតរបស់រូបាវចរចិត្ត ១៥

**រូបាវចរកុសលចិត្ត ៥** កើតបាន ២២ ភូមិ គឺ កាមសុគតិភូមិ ៧ (មនុស្ស ១ ទេវតា ៦) រូបភូមិ ១៥ (វៀរអសញ្ញីសត្តភូមិ ១) ។

**រូបាវចរវិបាកចិត្ត ៥** កើតបាន ១៥ ភូមិ គឺ រូបភូមិ ១៥ (វៀរអសញ្ញីសត្តភូមិ ១) ។

**រូបាវចរកិរិយាចិត្ត ៥** កើតបាន ២២ ភូមិ (ស្មើគ្នាជាមួយរូបាវចរកុសលចិត្ត) គឺ កាមសុគតិភូមិ ៧ រូបភូមិ ១៥ ។

ចំណែកអរូបភូមិ រូបាវចរចិត្តរមែងកើតមិនបាន ព្រោះមិនមានកម្មដ្ឋានដែលជាអារម្មណ៍របស់រូបជ្ឈាន ។

ក្នុងអសញ្ញីសត្តភូមិនោះ មិនមានសញ្ញា បានដល់ មិនមានចិត្តនិងចេតសិកកើតឡើងបានឡើយ រូបាវចរចិត្តទើបកើតមិនបាន និងក្នុងអបាយភូមិ ៤ មិនមានតិហេតុកបុគ្គល គឺ អ្នកបដិសន្ធិដោយត្រៃហេតុនិងឈានចិត្តនោះ រមែងកើតបានចំពោះតែតិហេតុកបុគ្គលប៉ុណ្ណោះ អបាយភូមិមានតែទុគ្គតិអហេតុកបុគ្គល ឈានចិត្តទើបកើតមិនបាន ។

## ចប់ រូបាវចរចិត្ត ១៥

# អរូបាវចរចិត្ត មាន ១២ ដួង

**អរូបាវចរចិត្ត** ជាចិត្តដែលកើតឡើងដោយការចម្រើនសមថភាវនា របស់អ្នកដែលបានរូបាវចរបញ្ចមជ្ឈានហើយ កាលបានចម្រើនឈាន ឲ្យខ្ពស់ឡើងទៅ ក៏នឹងចូលដល់អរូបជ្ឈាន ដូច្នោះអរូបាវចរចិត្ត ទើបជា ចិត្តដែលត្រាច់ទៅក្នុងភូមិដែលជាទីកើតនៃវត្ថុអរូប និងកិលេសអរូប ដោយច្រើន ។

**វត្ថុអរូប** បានដល់ **អរូបាវចរចិត្ត ១២ ចេតសិក ៣០** (វត្ថុធម៌) ។

**កិលេសអរូប** បានដល់ **អរូបតណ្ហា** ឬសេចក្តីត្រេកអរពេញចិត្ត ក្នុងអរូបជ្ឈាននិងអរូបភព ។

**អរូបស្ស ភវោតិ = អរូបំ**

ភូមិណា ជាទីកើតនៃវត្ថុអរូបនិងកិលេសអរូប ដូច្នោះភូមិនោះ ឈ្មោះថា អរូបភូមិ បានដល់ **អរូបភូមិ ៤** ។

**អរូបេ អវចរតីតិ = អរូបាវចរំ**

ចិត្តណា រមែងត្រាច់ទៅកើតនៅក្នុងភូមិ ដែលជាទីកើតនៃកិលេស អរូប និងវត្ថុអរូប ដូច្នោះចិត្តនោះ ឈ្មោះថា **អរូបាវចរចិត្ត** ។

## គាថាសង្គហទី ៩

៩. អាលម្ពនប្បភេទេន ចតុធារុប្បមានសំ
បុញ្ញបាកក្រិយាភេទា បុន ទ្វាទសធា ឋិតំ ។

ប្រែថា អរូបាវចរចិត្តនោះ ពោលដោយប្រភេទនៃអារម្មណ៍មាន ៤ ដួង កាលចែកដោយប្រភេទនៃជាតិ គឺ កុសល វិបាក កិរិយាហើយ មានចំនួន ១២ ដួង ។

## អធិប្បាយអរូបាវចរចិត្ត

អរូបាវចរចិត្តនោះ កាលពោលដោយប្រភេទនៃអារម្មណ៍មាន ៤ យ៉ាង គឺ

**អាកាសានញ្ចាយតន ១ វិញ្ញាណញ្ចាយតន ១**

**អាកិញ្ចញ្ញាយតន ១ នេវសញ្ញានាសញ្ញាយតន ១ ។**

អរូបាវចរចិត្តទាំង ៤ យ៉ាងនេះ កាលចែកដោយប្រភេទនៃជាតិ គឺ កុសល វិបាក កិរិយាហើយ បានដល់ អរូបាវចរកុសលចិត្ត ៤ ដួង អរូបាវចរវិបាកចិត្ត ៤ ដួង អរូបាវចរកិរិយាចិត្ត ៤ ដួង រួមជាអរូបាវចរចិត្ត ១២ ដួង ។

**អរូបាវចរចិត្ត ១២** ដួងនេះ រាប់ដោយឈានចិត្តក្នុងថ្នាក់បញ្ចមជ្ឈានទាំងអស់ ព្រោះអង្គរបស់អរូបជ្ឈានប្រកបដោយឧបេក្ខា ឯកគ្គតា តែម្យ៉ាង ហើយដូចគ្នានឹងអង្គឈានរបស់រូបាវចរបញ្ចមជ្ឈាន តែសេចក្តីផ្សេងគ្នារបស់អរូបាវចរចិត្តនេះ ផ្សេងគ្នាតែអារម្មណ៍ មិនមែនផ្សេងគ្នាដោយអង្គឈានដូចយ៉ាងក្នុង **រូបាវចរចិត្ត** គឺ

**អាកាសានញ្ចាយតន** (បឋមារូបជ្ឈាន) មានអាកាសដែលបើកពីកសិណ (**កសិណុគ្ឃាដិមាកាសបញ្ញត្តិ**) ជាអារម្មណ៍ ។

**វិញ្ញាណញ្ចាយតន (ទុតិយារូបជ្ឈាន)** មានបឋមារូបជ្ឈានចិត្តជាអារម្មណ៍ ។

**អាកិញ្ចញ្ញាយតន (តតិយារូបជ្ឈាន)** មាន **នត្ថិភាវបញ្ញត្តិ** ជាអារម្មណ៍ ។

**នេវសញ្ញានាសញ្ញាយតន** (ចតុត្ថារូបជ្ឈាន) មានតតិយារូបជ្ឈានចិត្តជាអារម្មណ៍ ។

## អារម្មណ៍របស់អរូបាវចរចិត្ត

**អារម្មណ៍របស់អរូបាវចរចិត្ត** មាន ៤ យ៉ាង គឺ

**១. កសិណុគ្ឃាដិមាកាសបញ្ញត្តិ** ជាអារម្មណ៍ បានដល់ ការកំណត់យកអាកាសដែលបើកអំពីកសិណ ៩ (វៀរអាកាសកសិណ) ជាអាកាសដែលល្វល្វើរកទីបំផុតមិនបាន ដោយបរិកម្មថា **អាកាសោ អនន្តោ** អាកាសមិនមានទីបំផុតៗ រហូតដល់ឈានចិត្តកើត ឈានចិត្តដែលកើតឡើងដោយមានកសិណុគ្ឃាដិមាកាសបញ្ញត្តិ ជាអារម្មណ៍នេះ មានឈ្មោះថា អាកាសានញ្ចាយតនឈាន ឬ "បឋមារូបចិត្ត" ។

**២. អាកាសានញ្ចាយតនឈាន** ជាអារម្មណ៍ បានដល់ មានវិញ្ញាណដែលប្រព្រឹត្តទៅក្នុងអាកាស ដែលល្វល្វើរនោះជាអារម្មណ៍ ឬមានការសម្លឹងយកបឋមារូបចិត្តជាអារម្មណ៍ ដោយបរិកម្មថា **វិញ្ញាណំ អនន្តំ** វិញ្ញាណមិនមានទីបំផុតៗ រហូតដល់ឈានចិត្តកើតឡើង ឈានចិត្តដែលកើតដោយមានអាកាសានញ្ចាយតនឈានចិត្តជាអារម្មណ៍នេះ

ឈ្មោះថា **វិញ្ញាណញ្ចាយតនឈាន** ឬ "**ទុតិយារូបចិត្ត**" ។

**៣. នត្ថិភាវបញ្ញត្តិ** ជាអារម្មណ៍ គឺសភាវៈដែលមិនមានអ្វីសេសសល់ជាអារម្មណ៍ឡើយ បានសេចក្តីថា កាលត្រូវការចម្រើនអាកិញ្ចញ្ញាយតនឈាន គឺត្រូវចូលវិញ្ញាណញ្ចាយតនឈានរឿយៗ រហូតជាវសី ហើយពិចារណាឃើញទោសរបស់វិញ្ញាណញ្ចាយតនឈានថា បើខ្វះការចូលឈាននេះរឿយៗ ហើយ ឈាននេះអាចនឹងសាបសូន្យ ត្រឡប់ទៅតាំងនៅក្នុងអាកាសានញ្ចាយតនឈានដូចដើមវិញ ហើយសមាធិដែលកើតពីវិញ្ញាណញ្ចាយតនឈាននេះ ក៏នៅគ្រោតគ្រាត ទើបកើតសេចក្តីប្រាថ្នាដែលនឹងឲ្យអាកាសានញ្ចាយតនឈានរលត់សាបសូន្យទៅពីចិត្តសន្តានដោយមិនឲ្យមានសល់ឡើយ ដោយត្រឡប់ព្យាយាមឲ្យ **នត្ថិភាវបញ្ញត្តិ** ប្រាកដឡើងជំនួស ដោយបរិកម្មថា **នត្ថិ កិញ្ចិ** អ្វីតិចតួចមិនមានៗ រហូតដល់ឈានចិត្តកើតឡើង ដោយមាននត្ថិភាវបញ្ញត្តិជាអារម្មណ៍ នេះឈ្មោះថា **អាកិញ្ចញ្ញាយតនឈាន** ឬ **តតិយារូបចិត្ត** ។

**៤. អាកិញ្ចញ្ញាយតនឈាន** ជាអារម្មណ៍ គឺ យកតតិយារូបចិត្តជាអារម្មណ៍កំណត់យកសេចក្តីល្អិតប្រណីតរបស់តតិយារូបចិត្ត ដោយដឹងថាសញ្ញា គឺចិត្តដែលមិនមានសេសសល់ត្រឹមតែអ្វីបន្តិចបន្តួចនឹងថាមិនមានក៏មិនមែន ព្រោះនៅមានការដឹងខ្លួនថានៅមាន នឹងថាមិនមានក៏មិនប្រាកដ ព្រោះសញ្ញានោះប្រណីតល្អិតស្ងប់ រហូតដល់មិនដឹងថាមានអ្វី ហើយព្យាយាមយកអាកិញ្ចញ្ញាយតនឈានឲ្យមកប្រាកដ ជំនួសដោយបរិកម្មថា **សន្ត មេតំ បណីត មេតំ** ឬ **ឯតំ សន្តំ ឯតំ**

**បណីតំ** ស្ងប់ហ្ន៎ ប្រណីតហ្ន៎ រហូតដល់ឈានចិត្តកើតឡើង ឈានដែលកើតឡើង ដោយមានអាកិញ្ចញ្ញាយតនឈានជាអារម្មណ៍នេះ ឈ្មោះថា នេវសញ្ញានាសញ្ញាយតនឈាន ប្រែថា ឈានដែលមិនមានសញ្ញាគ្រោតគ្រាតមានតែសញ្ញាល្អិត ឬឈានដែលមិនមានសញ្ញាក៏មិនមែនមានសញ្ញាក៏មិនមែន ពេលខ្លះហៅឈាននេះថា **ចតុត្ថារូបចិត្ត** ។

## ចែកអរូបាវចរចិត្តដោយប្រភេទនៃជាតិ

**អរូបាវចរចិត្ត** កាលចែកដោយប្រភេទនៃជាតិ គឺ អរូបាវចរកុសលចិត្ត អរូបាវចរវិបាកចិត្ត និងអរូបាវចរកិរិយាចិត្តនីមួយៗ មាន ៤ ប្រភេទតាមប្រភេទនៃអារម្មណ៍ គឺ

## អរូបាវចរកុសលចិត្ត

**អរូបាវចរកុសលចិត្ត** ជាចិត្តដែលចម្រើនសមថភាវនារហូតដល់អរូបជ្ឈាន ប្រព្រឹត្តទៅព្រមដោយការតាក់តែងអរូបកុសលទុកឲ្យបានទទួលសម្បត្តិជាអរូបព្រហ្មក្នុងព្រហ្មលោក ឬអរូបភូមិមានចំនួន ៤ ដួង គឺ

**១. ឧបេក្ខេកគ្គតាសហិតំ អាកាសានញ្ចាយតនកុសលចិត្តំ ។**

អរូបាវចរកុសលចិត្តដួងទី ១ កើតព្រមដោយ **ឧបេក្ខា ឯកគ្គតា** ជា **អាកាសានញ្ចាយតនឈានកុសល ។**

**២. ឧបេក្ខេកគ្គតាសហិតំ វិញ្ញាណញ្ចាយតនកុសលចិត្តំ ។**

អរូបាវចរកុសលចិត្តដួងទី ២ កើតព្រមដោយ **ឧបេក្ខា ឯកគ្គតា**

ជា **វិញ្ញាណញ្ចាយតនឈានកុសល ។**

**៣. ឧបេក្ខេកគ្គតាសហិតំ អាកិញ្ចញ្ញាយតនកុសលចិត្តំ ។**

អរូបាវចរកុសលចិត្តដួងទី ៣ កើតព្រមដោយ **ឧបេក្ខា ឯកគ្គតា** ជា **អាកិញ្ចញ្ញាយតនឈានកុសល ។**

**៤. ឧបេក្ខេកគ្គតាសហិតំ នេវសញ្ញានាសញ្ញាយតនកុសលចិត្តំ ។**

អរូបាវចរកុសលចិត្តដួងទី ៤ កើតព្រមដោយ **ឧបេក្ខា ឯកគ្គតា** ជា **នេវសញ្ញានាសញ្ញាយតនឈានកុសល ។**

## អរូបាវចរវិបាកចិត្ត

**អរូបាវចរវិបាកចិត្ត** គឺជាផលរបស់អរូបាវចរកុសលចិត្ត ពោលគឺ អរូបាវចរកុសលចិត្តជាហេតុ អរូបាវចរវិបាកចិត្តជាផល ឲ្យបានសោយសម្បត្តិជាអរូបព្រហ្មក្នុងអរូបភូមិ ៤ ត្រូវគ្នានឹងអរូបាវចរកុសលចិត្តនោះឯង ទើបមានចំនួន ៤ ដួង គឺ

**១. ឧបេក្ខេកគ្គតាសហិតំ អាកាសានញ្ចាយតនវិបាកចិត្តំ ។**

អរូបាវចរវិបាកចិត្តដួងទី ១ កើតព្រមដោយ **ឧបេក្ខា ឯកគ្គតា** ជា **អាកាសានញ្ចាយតនឈានវិបាក ។**

**២. ឧបេក្ខេកគ្គតាសហិតំ វិញ្ញាណញ្ចាយតនវិបាកចិត្តំ ។**

អរូបាវចរវិបាកចិត្តដួងទី ២ កើតព្រមដោយ **ឧបេក្ខា ឯកគ្គតា** ជា **វិញ្ញាណញ្ចាយតនឈានវិបាក ។**

**៣. ឧបេក្ខេកគ្គតាសហិតំ អាកិញ្ចញ្ញាយតនវិបាកចិត្តំ ។**

អរូបាវចរវិបាកចិត្តដួងទី ៣ កើតព្រមដោយ **ឧបេក្ខា ឯកគ្គតា** ជា **អាកិញ្ចញ្ញាយតនឈានវិបាក** ។

**៤. ឧបេក្ខេកគ្គតាសហិតំ នេវសញ្ញានាសញ្ញាយតនវិបាកចិត្តំ ។**

អរូបាវចរវិបាកចិត្តដួងទី ៤ កើតព្រមដោយ **ឧបេក្ខា ឯកគ្គតា** ជា **នេវសញ្ញានាសញ្ញាយតនឈានវិបាក** ។

## អរូបាវចរកិរិយាចិត្ត

**អរូបាវចរកិរិយាចិត្ត** ជាចិត្តរបស់ព្រះអរហន្ត ដែលចូលដល់អរូបជ្ឈាន ដោយន័យដូចគ្នានឹងអរូបាវចរកុសលចិត្ត ទើបពោលបានថា អរូបាវចរកិរិយាចិត្ត ក៏គឺអរូបាវចរកុសលនោះឯង តែចិត្តនោះកើតឡើងក្នុងសន្តានរបស់ព្រះអរហន្តដោយចំពោះប៉ុណ្ណោះ ។

**អរូបាវចរកិរិយាចិត្ត** ទើបមានចំនួន ៤ ដួង គឺ

**១. ឧបេក្ខេកគ្គតាសហិតំ អាកាសានញ្ចាយតនក្រិយចិត្តំ ។**

អរូបាវចរកិរិយាចិត្តដួងទី ១ កើតព្រមដោយ **ឧបេក្ខា ឯកគ្គតា** ជា **អាកាសានញ្ចាយតនឈានកិរិយា** ។

**២. ឧបេក្ខេកគ្គតាសហិតំ វិញ្ញាណញ្ចាយតនក្រិយចិត្តំ ។**

អរូបាវចរកិរិយាចិត្តដួងទី ២ កើតព្រមដោយ **ឧបេក្ខា ឯកគ្គតា** ជា **វិញ្ញាណញ្ចាយតនឈានកិរិយា** ។

**៣. ឧបេក្ខេកគ្គតាសហិតំ អាកិញ្ចញ្ញាយតនក្រិយចិត្តំ ។**

អរូបាវចរកិរិយាចិត្តដួងទី ៣ កើតព្រមដោយ **ឧបេក្ខា ឯកគ្គតា**

ជា **អាកិញ្ចញ្ញាយតនឈានកិរិយា** ។

**៤. ឧបេក្ខេកគ្គតាសហិតំ នេវសញ្ញានាសញ្ញាយតនក្រិយចិត្តំ ។**

អរូបាវចរកិរិយាចិត្តដួងទី ៤ កើតព្រមដោយ **ឧបេក្ខា ឯកគ្គតា** ជា **នេវសញ្ញានាសញ្ញាយតនឈានកិរិយា** ។

## អត្ថរបស់អរូបជ្ឈាន ៤ គឺ

**១. អាកាសានញ្ចាយតន** ចែកបទបាន ៣ បទ គឺ

**អាកាស + អនញ្ច + អាយតន = អាកាសានញ្ចាយតន ។**

**អាកាស** = ទីល្ហល្ហេវ (បានដល់ អាកាសដែលបើកឬដកចេញ-ពីបដិភាគនិមិត្ត) ។

**អនញ្ច** = រកទីបំផុតមិនបាន (មកពីពាក្យថា អនន្ត) ។

**អាយតន** = ជាទីតាំង ។

**អាកាសានញ្ចាយតន** ទើបសំដៅដល់ អាកាសដែលបើកចេញពីបដិភាគនិមិត្ត ហើយរកទីបំផុតមិនបាន ជាទីតាំងនៃចិត្ត ឬចិត្តដែលកាន់យកទីល្ហល្ហេវ (អាកាសដែលបើកចេញពីបដិភាគនិមិត្ត) ឧបមាដូចសាលាធំមួយខ្នង ដែលពេញទៅដោយគ្រឿងប្រដាប់ ការបើកចេញពីបដិភាគនិមិត្ត ដូចការលើកយកគ្រឿងប្រដាប់ចេញទៅអស់សល់តែសាលាដែលល្ហល្ហេវប៉ុណ្ណោះ ចិត្តនេះទើបសម្លឹងទីល្ហល្ហេវ ខាងក្នុងបរិវេណនៃសាលា ។

**២. វិញ្ញាណញ្ចាយតន** ចែកបទបាន ៣ បទ គឺ

**វិញ្ញាណ + អនញ្ច + អាយតន = វិញ្ញាណញ្ចាយតន ។**

**វិញ្ញាណ** = ចិត្ត (ធម្មជាតិដឹងអារម្មណ៍) ។

**អនញ្ច** = រកទីបំផុតមិនបាន ។

**អាយតន** = ជាទីតាំង ។

**វិញ្ញាណញ្ចាយតន** ទើបសំដៅដល់ ចិត្តដែលកាន់យកចិត្តដួងមុន ដែលដឹងអាកាសនិមិត្ត ដែលរកទីបំផុតមិនបានមកជាអារម្មណ៍ ឧបមាដូចជាសាលាដែលល្ហល្ហេវនោះ ឥឡូវនេះមានព្រះសង្ឃមកប្រជុំគ្នាធ្វើសង្ឃកម្ម ចិត្តទើបសម្លឹងចំពោះព្រះសង្ឃដែលមកប្រជុំគ្នានោះ ដោយមិនបានយកចិត្តទុកដាក់ក្នុងបរិវេណនៃសាលានោះឡើយ ។

**៣. អាកិញ្ចញ្ញាយតន** ចែកបទបាន ៣ បទ គឺ

**ន + កិញ្ចន + អាយតន = អាកិញ្ចញ្ញាយតន ។**

**ន** = មិនមាន ។

**កិញ្ចន** = នៅសល់ ។

**អាយតន** = ជាទីតាំង ។

**អាកិញ្ចញ្ញាយតន** បានដល់ ចិត្តដែលកាន់យកសភាវៈមិនមានបឋមារូបចិត្តជាអារម្មណ៍ ឧបមាដូចជាសាលាធំដែលព្រះសង្ឃប្រជុំគ្នាធ្វើសង្ឃកម្មនោះ ឥឡូវនេះ បានចេញពីសាលានោះទៅអស់ហើយ មិនមានសល់សូម្បីតែមួយអង្គ ចិត្តដួងនេះ ទើបសម្លឹងទីដែលមិនមានព្រះសង្ឃនៅនោះ និងព្រមទាំងមិនយកចិត្តទុកដាក់ក្នុងបរិវេណនៃសាលានោះផង ។

**៤. នេវសញ្ញានាសញ្ញាយតន** ចែកបទបានដូច្នេះ គឺ

**ន+ឯវ+សញ្ញា+ន+អសញ្ញា+អាយតន=នេវសញ្ញានាសញ្ញាយតន។**

**ន** = មិនមែន ។

**ឯវ =** ប៉ុណ្ណោះ ។

**សញ្ញា =** មានសញ្ញា ។

**ន** = មិនមែន ។

**អសញ្ញា** = មិនមានសញ្ញា ។

**អាយតន** = ជាទីតាំង ។

**នេវសញ្ញានាសញ្ញាយតន** សំដៅដល់ សភាពចិត្តដែលកាន់យកអារម្មណ៍ដែលល្អិតក្រៃលែងប៉ុណ្ណោះ មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ឧបមាដូចជាសាមណេរយកប្រេងមកលាបបាត្រទុកដើម្បីការពារស្នឹម ព្រះថេរៈហៅឲ្យយកបាត្រពីសាមណេរដើម្បីដាក់ភត្ត សាមណេរទើបប្រាប់ថា បាត្រជាប់ប្រេង ព្រះថេរៈក៏ពោលថា យកមកចុះ យើងនឹងចាក់ទុកក្នុងបំពង់ប្រេង សាមណេរ ទើបតបថា ប្រេងនោះលាបបាត្រទុកត្រឹមតែល្មមការពារស្នឹមមិនមានសល់ច្រើន រហូតដល់អាចចាក់ទុកក្នុងបំពង់បាន អារម្មណ៍របស់នេវសញ្ញានាសញ្ញាយតន ទើបពោលថា មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន គឺ មានតែសភាពសញ្ញាដែលល្អិត ។

## ភូមិដែលជាទីកើតរបស់អរូបាវចរកុសលចិត្ត

**អរូបាវចរកុសលចិត្ត ៤** រមែងកើតបាន ២៦ ភូមិ គឺ កាមសុគតិភូមិ ៧ រូបភូមិ ១៥ (វៀរអសញ្ញីសត្តភូមិ ១) អរូបភូមិ ៤ (វៀរឈានដែលទាបជាងភូមិរបស់ខ្លួន) ។

**អរូបាវចរវិបាកចិត្ត ៤** រមែងកើតបានក្នុងអរូបភូមិ ៤ (ដោយចំពោះភូមិរបស់ខ្លួនៗ ) ។

**អរូបាវចរកិរិយាចិត្ត ៤** រមែងកើតបាន ២៦ ភូមិ គឺ កាមសុគតិភូមិ ៧ រូបភូមិ ១៥ (វៀរអសញ្ញីសត្តភូមិ ១) អរូបភូមិ ៤ ។

តិហេតុកបុគ្គលដែលនៅក្នុងកាមសុគតិភូមិក្ដី ដែលនៅក្នុងរូបភូមិ (វៀរអសញ្ញីសត្តភូមិ ១) ក្ដី អាចចម្រើនសមថភាវនាឲ្យអរូបជ្ឈានចិត្តកើតឡើងបានក្នុងសន្តាននៃខ្លួន បើអរូបជ្ឈានចិត្តកើតឡើងក្នុងសន្តានរបស់បុថុជ្ជន ឬព្រះសេក្ខបុគ្គលហើយ ក៏ឈ្មោះថា អរូបាវចរកុសលចិត្តកើត តែបើអរូបជ្ឈានចិត្តកើតឡើងក្នុងសន្តានរបស់ព្រះអរហន្ត ក៏ឈ្មោះថា អរូបាវចរកិរិយាចិត្តកើត ។

ចំណែកក្នុងអសញ្ញីសត្តភូមិនោះ អរូបាវចរចិត្តរមែងកើតឡើងមិនបាន ព្រោះជាភូមិដែលមិនមានចិត្តឡើយ មិនអាចនឹងធ្វើកិច្ចណាៗបាន ។

ក្នុងអរូបភូមិទាំង ៤ នោះភូមិនីមួយៗ រមែងចម្រើនតែអរូបជ្ឈានដែលជាឈានក្នុងភូមិរបស់ខ្លួនៗ ឬក្នុងអរូបជ្ឈានដែលខ្ពស់ជាងឈានរបស់ខ្លួនប៉ុណ្ណោះ នឹងមិនចម្រើនអរូបជ្ឈានដែលទាបជាងភូមិរបស់ខ្លួន

ឡើយ ទាំងនេះព្រោះបានឃើញទោសក្នុងអារម្មណ៍ដែលបានលះផុតមកហើយនោះ ។

**មហគ្គតចិត្ត** បានដល់ ចិត្តដែលចូលដល់សភាពជាធំនោះ សំដៅដល់មានកម្លាំង ចិត្តដែលអាចធ្វើឲ្យសម្រេចកិច្ចផ្សេងៗ បាន គឺ

**ក.** គ្របសង្កត់កិលេសទុកបានយូរតាមសមគួរ ដែលហៅថា **វិក្ខម្ភនប្បហាន** ។

**ខ.** ឲ្យផលបរិបូណ៌ គឺ មានព្រហ្មវិហារធម៌ ឲ្យបានសោយព្រហ្មសម្បត្តិក្នុងព្រហ្មលោក ។

គ. ឲ្យជវនចិត្តមានការកើតឡើងជាប់តគ្នាបានយូរជាពិសេស គឺ ឈានសមាបត្តិ ឬជារូបព្រហ្ម អរូបព្រហ្ម ដែលមានអាយុវែងជាងសត្វដទៃៗ ទាំងឡាយ សុទ្ធតែអាស្រ័យមហគ្គតបដិសន្ធិចិត្តទាំងអស់ ។

ចិត្តដែលចូលដល់សភាពជាធំ និងប្រសើរដូចពោលមកនេះ ឈ្មោះថា មហគ្គតចិត្ត មានចំនួន ២៧ ដួង គឺ រូបាវចរចិត្ត ១៥ អរូបាវចរចិត្ត ១២ រួមជា ២៧ ដួង ។

**រូបាវចរចិត្ត ១៥**
**អរូបាវចរចិត្ត ១២** } = ២៧ ដួង

## ចប់ មហគ្គតចិត្ត

## ៚ លោកុត្តរចិត្ត ៨ ៚

**លោកុត្តរចិត្ត** ជាចិត្តដែលផុតចាកលោក បានសេចក្តីថា ជាចិត្តដែលមានអារម្មណ៍ខ្ពង់ខ្ពស់ជាងសភាវធម៌ដែលមាននៅក្នុងលោក ឬជាចិត្តដែលមានអំណាចទទួលអារម្មណ៍ពិសេសខ្ពង់ខ្ពស់ជាងលោក គឺនិព្វានារម្មណ៍ ចិត្តទាំងនេះមានចំនួន ៨ ដួង និងអាចទទួលនិព្វានជាអារម្មណ៍ដោយពិតប្រាកដតែម្យ៉ាង ទើបហៅចិត្ត ៨ ដួងនេះថា **លោកុត្តរចិត្ត** ។

**លោកុត្តរចិត្ត** កាលចែកបទបានដូច្នេះ គឺ

**លោក + ឧត្តរ + ចិត្ត = លោកុត្តរចិត្ត ។**

**លោក** បានដល់ លោកទាំង ៣ គឺ កាមលោក (កាមភូមិ) រូបលោក (រូបភូមិ) និងអរូបលោក (អរូបភូមិ) ឬន័យម្យ៉ាងទៀត

**លោក** បានដល់ វត្ថុដែលបែកធ្លាយ សូន្យទៅជាធម្មតា ។

**ឧត្តរ** បានដល់ ប្រសើរ ឬខ្ពង់ខ្ពស់ ។

**លោកុត្តរចិត្ត** ទើបសំដៅដល់ចិត្តប្រសើរជាងលោកទាំង ៣ ឬចិត្តដែលផុតចាកការត្រាច់ទៅក្នុងលោកទាំង ៣ បានសេចក្តីថាចិត្តនេះមានអារម្មណ៍ដែលខ្ពង់ខ្ពស់ជាងលោក មានអារម្មណ៍ដែលផុតចាកលោក ពោលគឺ លោកុត្តរចិត្ត មាននិព្វានជាអារម្មណ៍ ហើយនិព្វាននេះ ចាត់ជាធម៌ដែលផុតចាកលោក ជាធម៌ដែលប្រសើរលើសលោកទាំង ៣ ។

**លោកុត្តរចិត្ត** ជាចិត្តដែលមានអារម្មណ៍ផុតចាកការកើតរលត់នោះ ក៏មិនបានសំដៅយកចិត្តនឹងមិនកើតរលត់ ចិត្តក៏គង់មានអាការកើតរលត់តាមសភាវៈរបស់ចិត្ត ជាចិត្តដែលទទួលអារម្មណ៍ពិសេសដែលផុតចាកការកើតរលត់ អារម្មណ៍ដែលពោលនេះ ក៏គឺនិព្វានជាអារម្មណ៍ដែលមិនមានការកើតរលត់ មិនមានការប្រែប្រួលទៅកាន់សេចក្ដីវិនាសជាធម៌ដែលផុតចាកការតាក់តែងជាអសង្ខតធម៌ ។

ធម្មតាធម៌ទាំងឡាយដែលប្រព្រឹត្តទៅក្នុងលោកទាំង ៣ រមែងកើតរលត់ទាំងអស់ តែនិព្វានជាធម៌ដែលមិនមានការកើតរលត់ ជាធម៌ដែលផុតចាកការកើតរលត់ និព្វានទើបជាធម៌ដែលផុតចាកលោក ជាធម៌ដែលប្រសើរលើសលោក ផុតចាកការតាក់តែងដោយបច្ច័យធម៌ គឺ កម្ម ចិត្ត ឧតុ និងអាហារទាំងអស់ ។

## គាថាសង្គហទី ១០

**១០. ចតុមគ្គប្បភេទេន ចតុធា កុសលំ តថា**
**បាកំ តស្ស ផលត្តាតិ អដ្ឋធានុត្តរំ មតំ ។**

ប្រែថា អនុត្តរចិត្ត (លោកុត្តរចិត្ត) ដោយសង្ខេបមាន ៨ ដួង គឺលោកុត្តរចិត្តពោលដោយប្រភេទនៃមគ្គមាន ៤ ដួង និងលោកុត្តរវិបាកចិត្ត ដែលជាផលរបស់លោកុត្តរកុសលចិត្ត ក៏មាន ៤ ដួង ។

# ចែកលោកុត្តរចិត្ត ៨ ដោយប្រភេទនៃជាតិ

**លោកុត្តរចិត្ត ៨** នោះ មាន ២ ជាតិ គឺ

**១. ជាតិជាកុសល** ឈ្មោះថា លោកុត្តរកុសលចិត្ត ឬមគ្គចិត្ត មានចំនួន ៤ ដួង ហៅតាមឈ្មោះរបស់ញាណដែលកើតក្នុងខណៈចិត្តនោះៗ ព្រោះជាប្រភេទចិត្តដែលប្រកបដោយអរិយមគ្គ ។

**២. ជាតិជាវិបាក** ឈ្មោះថា លោកុត្តរវិបាកចិត្ត ឬផលចិត្ត ព្រោះជាផលរបស់លោកុត្តរកុសលចិត្ត ទើបមានចំនួន ៤ ដួង ដូចគ្នា ។

រួមជាលោកុត្តរចិត្ត ៨ ដួង ចាំងាយៗ ថា មគ្គជាកុសល ផលជាវិបាក ដែលមានសេចក្តីថា មគ្គចិត្ត ជាតិជាកុសល និងផលចិត្ត ជាតិជាវិបាក ។

**ចំណុចសម្គាល់** លោកុត្តរចិត្តនេះ មានតែលោកុត្តរកុសល និងលោកុត្តរវិបាកប៉ុណ្ណោះ មិនមានលោកុត្តរកិរិយាផងឡើយ ទាំងនេះព្រោះបើមានលោកុត្តរកិរិយា ក៏រមែងសំដៅដល់លោកុត្តរកុសលដែលកើតឡើងក្នុងសន្តានរបស់ព្រះអរហន្ត ទំនងដូចគ្នានឹងមហាកុសល ឬមហគ្គតកុសល បើកើតឡើងក្នុងសន្តានរបស់ព្រះអរហន្ត ក៏ឈ្មោះថា មហាកិរិយា ឬមហគ្គតកិរិយា ទាំងមហាកិរិយា និងមហគ្គតកិរិយានោះរមែងអាចកើតឡើងបានរឿយៗ ក្នុងសន្តានរបស់ព្រះអរហន្ត ។

តែចំណែកមគ្គចិត្តនោះ ក្នុងមគ្គនីមួយៗ កើតបានតែមួយខណៈ

គឺសោតាបត្តិមគ្គ សកទាគាមិមគ្គ អនាគាមិមគ្គ និងអរហត្តមគ្គ នឹងកើតបានមគ្គម្តងមួយខណៈប៉ុណ្ណោះ ព្រោះមគ្គចិត្តនោះកើតឡើងបានតែម្តងមួយខណៈ ដើម្បីធ្វើកិច្ចប្រហារអនុស័យកិលេស ឲ្យជាសមុច្ឆេទប្បហាន កាលសម្រេចជាព្រះអរហន្តហើយ មិនមានកិលេសនៅសល់សូម្បីតិចតួច ទើបមិនត្រូវមានមគ្គចិត្ត ដើម្បីប្រហារកិលេសទៀត ដូច្នោះលោកុត្តរកិរិយាទើបមិនមាន ។

**លោកុត្តរធម៌** បានដល់ មគ្គចិត្ត ៤ ផលចិត្ត ៤ និងនិព្វាន ១ រួមសភាវៈដែលជាលោកុត្តរធម៌មាន ៩ ប្រភេទ

**លោកុត្តរចិត្ត ៨** សូម្បីជាលោកុត្តរធម៌ តែក៏នៅជាសង្ខតធម៌ និព្វានប៉ុណ្ណោះ ទាំងជាលោកុត្តរធម៌ និងជាអសង្ខតធម៌ផង ។

## លោកុត្តរកុសល ឬ មគ្គចិត្ត

**លោកុត្តរកុសល** មានន័យច្រើនយ៉ាង គឺ

**ន័យទី ១ លោកុត្តរកុសល** បានសេចក្តីថា ជាកុសលដែលធ្វើឲ្យឆ្លងផុតចាកលោកទាំង ៣ គឺកាមលោក បានដល់ កាមភូមិ ១១ រូបលោក បានដល់ រូបភូមិ ១៦ និងអរូបលោក បានដល់ អរូបភូមិ ៤ ។

**ន័យទី ២ លោកុត្តរកុសល** បានសេចក្តីថា ជាកុសលដែលឆ្លងផុតចាកភាពជាបុថុជ្ជន ចូលកាន់ភាពជាអរិយបុគ្គល ។

**ន័យទី ៣ លោកុត្តរកុសល** បានសេចក្ដីថា កុសលចិត្តដែលកើតឡើងទទួលលោកុត្តរារម្មណ៍ គឺ និព្វាន ។

**ន័យទី ៤ លោកុត្តរកុសល** បានសេចក្ដីថា ជាកុសលចិត្តដែលមានអំណាចលើលោកិយកុសល ដោយហេតុថា រំលត់អកុសលឬប្រហារកិលេសឲ្យជា **សមុច្ឆេទប្បហាន** ។

កុសលដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣ ដែលឈ្មោះថា លោកិយ-កុសលនោះ រមែងឲ្យចុតិ និងបដិសន្ធិធ្វើឲ្យសត្វនៅក្នុងវដ្តៈ ដូច្នោះ លោកិយកុសលដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣ ទើបឈ្មោះថា **អាចយគាមី** ឬ **វដ្តគាមិនីកុសល** តែក្នុងលោកុត្តរកុសលនោះ រមែងប្រព្រឹត្តទៅដោយន័យដែលផ្ទុយគ្នា គឺ លោកុត្តរកុសលនេះ រមែងទម្លាយចុតិ និងបដិសន្ធិនៃសត្វ ដែលលោកិយកុសលបង្កើតទុកហើយដោយធ្វើការតាក់តែងនៃបច្ច័យរបស់ធម៌ដែលជាហេតុឲ្យកើត លោកុត្តរកុសលនេះ ឈ្មោះថា **អបចយគាមី** ឬ **វិវដ្តគាមិនីកុសល** ។

**លោកុត្តរកុសលចិត្ត** ឬមគ្គចិត្តនេះ ពោលដោយសង្ខេបមានចំនួន ៤ ដួង គឺ

**១. សោតាបត្តិមគ្គ** ជាមគ្គចិត្តដួងទី ១ ។

**២ សកទាគាមិមគ្គ** ជាមគ្គចិត្តដួងទី ២ ។

**៣ អនាគាមិមគ្គ** ជាមគ្គចិត្តដួងទី ៣ ។

**៤ អរហត្តមគ្គ** ជាមគ្គចិត្តដួងទី ៤ ។

អធិប្បាយន័យទី ១ **លោកុត្តរកុសល** បានដល់ ជាកុសលដែលឆ្លងផុតចាកលោកទាំង ៣ នោះគឺ **សោតាបត្តិមគ្គចិត្ត** និង**សកទាគាមិមគ្គចិត្ត** ធ្វើឲ្យឆ្លងផុតចាកកាមលោកបាន ៤ ភូមិ គឺ អបាយភូមិ ៤ ។

**អនាគាមិមគ្គចិត្ត** ធ្វើឲ្យឆ្លងផុតចាកកាមលោកទាំងអស់ គឺ កាមភូមិទាំង ១១ ភូមិ ។

**អរហត្តមគ្គចិត្ត** ធ្វើឲ្យឆ្លងផុតចាកលោកទាំង ៣ គឺកាមលោក រូបលោក និងអរូបលោក ។

**ន័យទី ២ លោកុត្តរកុសល** បានដល់ កុសលដែលធ្វើឲ្យឆ្លងផុតចាកភាពជាបុថុជ្ជនចូលកាន់ភាពជាអរិយបុគ្គលគឺ

**សោតាបត្តិមគ្គចិត្ត** ធ្វើឲ្យជាសោតាបត្តិមគ្គបុគ្គល ។

**សកទាគាមិមគ្គចិត្ត** ធ្វើឲ្យជាសកទាគាមិមគ្គបុគ្គល ។

**អនាគាមិមគ្គចិត្ត** ធ្វើឲ្យជាអនាគាមិមគ្គបុគ្គល ។

**អរហត្តមគ្គចិត្ត** ធ្វើឲ្យជាអរហត្តមគ្គបុគ្គល ។

**ន័យទី ៣ លោកុត្តរកុសល** បានដល់ ចិត្តដែលកើតឡើងទទួលលោកុត្តរារម្មណ៍ គឺព្រះនិព្វាននោះ ព្រោះព្រះនិព្វានជាអារម្មណប្បច្ច័យឲ្យដល់មគ្គចិត្តទាំង ៤ ពោលគឺ លោកុត្តរកុសលចិត្ត ៤ ដួង នេះកើតឡើងបានដោយអំណាចនៃព្រះនិព្វានជាបច្ច័យ ព្រោះព្រះនិព្វាននោះជាលោកុត្តរធម៌ មគ្គចិត្តទាំង ៤ ដួងនេះ ទើបហៅថា លោកុត្តរកុសល ព្រោះជាកុសលធម៌ដែលកើតពីលោកុត្តរធម៌ ។

**ន័យទី ៤ លោកុត្តរកុសល** បានដល់ កុសលចិត្តដែលមានអំណាចរំលត់អកុសល ឬប្រហារកិលេសបានជា**សមុច្ឆេទប្បហាន** ។

## លក្ខណៈនៃការប្រហារកិលេស

**កិលេស** គឺ ជាធម៌ដែលសៅហ្មងក្តៅក្រហាយ ក្នុងព្រះអភិធម្មបានចែកកិលេសតាមអាការសម្តែងចេញបានជា ៣ ថ្នាក់គឺ

**ក. វីតិក្កមកិលេស** បានដល់ កិលេសយ៉ាងគ្រោតគ្រាត ដែលជាហេតុឲ្យកើតសកម្មភាពចេញមកតាមកាយទ្វារ ឬវចីទ្វារបាន ជាទុច្ចរិតកម្ម កិលេសប្រភេទនេះ ប្រហារបានដោយសីល ជាការស្ងប់រម្ងាប់មួយគ្រា មួយខណៈដែលនៅមានការរក្សាសីល ការប្រហារកិលេសបានមួយខណៈៗ នេះហៅថា **តទង្គប្បហាន** ។

**ខ. បរិយុដ្ឋានកិលេស** បានដល់ កិលេសយ៉ាងកណ្តាលដែលកើតខាងក្នុងមនោទ្វារ មិនដល់ថ្នាក់សម្តែងអាការចេញមកតាមកាយទ្វារ ឬវចីទ្វារ នីវរណកិលេសប្រភេទនេះ ប្រហារបានដោយសមាធិ គឺឈានរមែងរំលត់ ឬរម្ងាប់បានតាមអំណាចនៃឈានបានយូរ ដរាបណាដែលឈាននៅមិនទាន់សាបសូន្យ ហៅថា **វិក្ខម្ភនប្បហាន** ។

**គ. អនុស័យកិលេស** បានដល់ កិលេសយ៉ាងល្អិត ដែលដេកត្រាំនៅក្នុងខន្ធសន្តាន ដែលមិនមានអ្នកដទៃណាអាចនឹងដឹងបាន ក្រៅពីព្រះសម្មាសម្ពុទ្ធជាម្ចាស់ អនុស័យកិលេសប្រភេទនេះ ត្រូវប្រហារដោយបញ្ញាក្នុងមគ្គចិត្ត ហើយមគ្គចិត្តនេះឯង ដែលអាចប្រហារកិលេស

ឲ្យសាបសូន្យអស់ មិនត្រឡប់មានមកជាថ្មីទៀត ហៅការប្រហារនេះថា **សមុច្ឆេទប្បហាន** ។

សរុបសេចក្ដីថា **វីតិក្កមកិលេស** ត្រូវប្រហារដោយមហាកុសលចិត្ត ដែលជាប់ដោយសីលជា **តទង្គប្បហាន** ។

**បរិយុដ្ឋានកិលេស** ត្រូវប្រហារដោយមហគ្គតកុសលចិត្ត ជា **វិក្ខម្ភនប្បហាន** ។

**អនុស័យកិលេស** ត្រូវប្រហារដោយមគ្គចិត្តជា**សមុច្ឆេទប្បហាន** ។

## ការប្រហារកិលេសប្រភេទសមុច្ឆេទប្បហាន

**កិលេស** ដែលញ៉ាំងចិត្តឲ្យសៅហ្មងក្ដៅក្រហាយនេះ រមែងកើតព្រមគ្នា និងប្រកបជាមួយអកុសលចិត្តប៉ុណ្ណោះ ដូច្នោះការប្រហារកិលេស ក៏ស្មើគ្នានឹងការប្រហារអកុសលចិត្តនោះឯង ក្នុងព្រះអភិធម្មត្ថ-សង្គហៈសម្ដែងអកុសលទុក ៩ កង

**១. អាសវ** ធម៌ដែលជាគ្រឿងដេកត្រាំក្នុងសន្ដានមាន ៤ យ៉ាង

**-កាមាសវ** គ្រឿងដេកត្រាំ គឺកាម បានដល់ សេចក្ដីត្រេកអរក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ។

**-ភវាសវ** គ្រឿងដេកត្រាំ គឺភព បានដល់ សេចក្ដីត្រេកអរក្នុងភពភូមិផ្សេងៗ ។

**-ទិដ្ឋាសវ** គ្រឿងដេកត្រាំ គឺទិដ្ឋិ បានដល់ សេចក្ដីត្រេកអរតាមការយល់ឃើញខុស ។

**-អវិជ្ជាសវ** គ្រឿងដេកត្រាំគឺអវិជ្ជា ដែលមិនដឹងតាមសេចក្ដីពិត ។

**២. ឱឃ** ធម៌ដែលប្រៀបដូចជាអន្លង់ទឹក ដែលញ៉ាំងសត្វទាំងឡាយឲ្យលិចចុះក្នុងសង្សារវដ្ដ គឺ

**-កាមោឃ** អន្លង់ គឺកាម បានដល់ សេចក្ដីត្រេកអរក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ។

**-ភវោឃ** អន្លង់ គឺភព បានដល់ សេចក្ដីត្រេកអរក្នុងអត្តភាពនិងភពភូមិផ្សេងៗ ។

**-ទិដ្ឋោឃ** អន្លង់ គឺទិដ្ឋិ បានដល់ ការយល់ឃើញខុស ។

**-អវិជ្ជោឃ** អន្លង់ គឺអវិជ្ជា បានដល់ ការមិនដឹងតាមសេចក្ដីពិត ។

**៣. យោគ** ធម៌ដែលជាគ្រឿងប្រកបសត្វទុកក្នុងភពភូមិផ្សេងៗ មាន ៤ យ៉ាង គឺ

**-កាមយោគ** គ្រឿងប្រកប គឺកាម បានដល់ សេចក្ដីត្រេកអរក្នុងកាមគុណារម្មណ៍ទាំង ៥ ។

**-ភវយោគ** គ្រឿងប្រកប គឺភព បានដល់ សេចក្ដីត្រេកអរក្នុងភពភូមិផ្សេងៗ ។

**-ទិដ្ឋិយោគ** គ្រឿងប្រកប គឺទិដ្ឋិ បានដល់ ការយល់ឃើញខុស ។

**-អវិជ្ជាយោគ** គ្រឿងប្រកប គឺអវិជ្ជា បានដល់ ការមិនដឹងតាមសេចក្ដីពិត ។

**៤. គន្ថ** ធម៌ដែលជាគ្រឿងចងសត្វទុក មិនឲ្យរួចផុតចាកលោកបាន មាន ៤ យ៉ាង គឺ

**-អភិជ្ឈាកាយគន្ថ** បានដល់ សេចក្តីលោភទាំងឡាយ ។

**-ព្យាបាទកាយគន្ថ** បានដល់ សេចក្តីក្រោធទាំងឡាយ ។

**-សីលព្វតបរាមាសកាយគន្ថ** បានដល់ ស្ទាបអង្អែលសីលនិងវត្ត ។

**-ឥទំសច្ចាភិនិវេសកាយគន្ថ** បានដល់ ប្រកាន់ការយល់ឃើញខុសយ៉ាងមាំ ។

**៥. ឧបាទាន** ធម៌ដែលជាគ្រឿងប្រកាន់មាំ ឲ្យប្រព្រឹត្តទៅក្នុងលោក មាន ៤ យ៉ាង គឺ

**-កាមុបាទាន** បានដល់ សេចក្តីប្រកាន់មាំក្នុងភពនិងកាមគុណារម្មណ៍ ។

**-ទិដ្ឋុបាទាន** បានដល់ សេចក្តីប្រកាន់មាំក្នុងការយល់ឃើញខុស។

**-អត្តវាទុបាទាន** បានដល់ សេចក្តីប្រកាន់មាំក្នុងការយល់ឃើញខុសថាមានតួខ្លួន ។

**-សីលព្វតុបាទាន** បានដល់ សេចក្តីប្រកាន់មាំក្នុងការបដិបត្តិខុសព្រោះមិនដឹងកិច្ចបដិបត្តិណា ដែលនាំឲ្យផុតទុក្ខយ៉ាងត្រឹមត្រូវបាន ។

**៦. នីវរណ** ធម៌ដែលជាគ្រឿងរារាំងសេចក្តីល្អមាន ៦ យ៉ាង គឺ

**-កាមច្ឆន្ទនីវរណ** បានដល់ សេចក្តីត្រេកអរពេញចិត្តក្នុងកាម-គុណារម្មណ៍ ។

**-ព្យាបាទនីវរណ** បានដល់ ការមិនពេញចិត្តក្នុងអារម្មណ៍ផ្សេងៗ ។

**-ថីនមិទ្ធនីវរណ** បានដល់ ការងោកងក់រួញរាចាកអារម្មណ៍ផ្សេងៗ ។

**-ឧទ្ធច្ចកុក្កុច្ចនីវរណ** បានដល់ ការរវើរវាយក្តៅក្រហាយចិត្តក្នុងអារម្មណ៍ផ្សេងៗ ។

**-វិចិកិច្ឆានីវរណ** បានដល់ សេចក្តីសង្ស័យ ។

**-អវិជ្ជានីវរណ** បានដល់ ការមិនដឹងក្នុងសច្ចធម៌ ។

**៧. អនុស័យ** ធម៌ដែលដេកសម្ងំក្នុងខន្ធសន្តានមាន ៧ យ៉ាង គឺ

**-កាមរាគានុស័យ** បានដល់ សេចក្តីត្រេកអរក្នុងកាមគុណារម្មណ៍ ។

**-ទិដ្ឋានុស័យ** បានដល់ ការយល់ឃើញខុស ។

**-បដិឃានុស័យ** បានដល់ ការមិនពេញចិត្តក្នុងអារម្មណ៍ផ្សេងៗ ។

**-ភវរាគានុស័យ** បានដល់ សេចក្តីត្រេកអរក្នុងការតាំងនៅនៃភព។

**-មានានុស័យ** បានដល់ ការរឹងត្អឹង ។

**-វិចិកិច្ឆានុស័យ** បានដល់ ការសង្ស័យក្នុងសភាវធម៌ ។

**-អវិជ្ជានុស័យ** បានដល់ ការមិនដឹងសច្ចធម៌ ។

**៨. សញ្ញោជន** ធម៌ដែលជាគ្រឿងដោតក្រងសត្វទាំងឡាយទុកក្នុងសង្សារវដ្តមាន ១០ យ៉ាង គឺ

**-កាមរាគសញ្ញោជន** បានដល់ សេចក្តីត្រេកអរក្នុងកាមគុណារម្មណ៍ ។

**-ភវរាគសញ្ញោជន** បានដល់ សេចក្តីត្រេកអរក្នុងការតាំងនៅនៃភព ។

**-មានសញ្ញោជន** បានដល់ ការរឹងត្អឹង ។

**-ទិដ្ឋិសញ្ញោជន** បានដល់ ការយល់ឃើញខុស ។

**-វិចិកិច្ឆាសញ្ញោជន** បានដល់ សេចក្តីសង្ស័យក្នុងហេតុផលនៃធម៌។

**-សីលព្វតបរាមាសសញ្ញោជន** បានដល់ ប្រកាន់វត្តបដិបត្តិខុស គិតថាអាចផុតចាកទុក្ខបាន ។

**-ឥស្សាសញ្ញោជន** បានដល់ ការច្រណែនមិនចង់ឲ្យអ្នកដទៃល្អជាងខ្លួន ។

**-មច្ឆរិយសញ្ញោជន** បានដល់ សេចក្តីហួងហែងក្នុងសម្បត្តិរបស់ខ្លួន ឬអ្នកដទៃ ។

**-បដិឃសញ្ញោជន** បានដល់ ការមិនពេញចិត្តក្នុងអារម្មណ៍ផ្សេងៗ។

**-អវិជ្ជាសញ្ញោជន** បានដល់ ការមិនដឹងក្នុងសច្ចធម៌ ។

**៩. កិលេស** ធម៌ដែលជាគ្រឿងសៅហ្មងមាន ១០ យ៉ាង គឺ

**-លោភកិលេស** បានដល់ សេចក្តីលោភ ។

**-ទោសកិលេស** បានដល់ សេចក្តីក្រោធ ។

**-មោហកិលេស** បានដល់ សេចក្តីវង្វេង ។

**-មានកិលេស** បានដល់ សេចក្តីរឹងត្អឹង ។

**-ទិដ្ឋិកិលេស** បានដល់ ការយល់ឃើញខុស ។

**-វិចិកិច្ឆាកិលេស** បានដល់ ការសង្ស័យ ។

**-ថីនកិលេស** បានដល់ ការរួញរា ។

**-ឧទ្ធច្ចកិលេស** បានដល់ ការរាយមាយ ។

**-អហិរិកកិលេស** បានដល់ ការមិនខ្មាសបាប ។

**-អនោត្តប្បកិលេស** បានដល់ ការមិនខ្លាចបាប ។

# មគ្គចិត្តប្រហារអកុសល

**មគ្គចិត្ត** ឬ **លោកុត្តរចិត្ត** ប្រហារអកុសល ៩ កងដូចនេះគឺ

**សោតាបត្តិមគ្គចិត្ត** ប្រហារអាសវៈ បាន ១ គឺ ទិដ្ឋាសវៈ,

**ឱឃ** បាន ១ គឺ ទិដ្ឋោឃៈ,

**យោគ** បាន ១ គឺ ទិដ្ឋិយោគៈ,

**គន្ថ** បាន ២ គឺ សីលព្វតបរាមាស និង ឥទំសច្ចាភិនិវេស,

**ឧបាទាន** បាន ៣ គឺ ទិដ្ឋុបាទាន អត្តវាទុបាទាន និងសីលព្វតុបាទាន,

**នីវរណ** បាន ២ គឺ វិចិកិច្ឆានីវរណៈ កុក្កុច្ចនីវរណៈ,

**អនុស័យ** បាន ២ គឺ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ,

**សញ្ញោជន** បាន ៥ គឺ ទិដ្ឋិសញ្ញោជន វិចិកិច្ឆាសញ្ញោជន ឥស្សាសញ្ញោជន មច្ឆរិយសញ្ញោជន សីលព្វតបរាមាសសញ្ញោជន,

**កិលេស** បាន ២ គឺ ទិដ្ឋិ, វិចិកិច្ឆា ។

**សកទាគាមិមគ្គចិត្ត** ឬ **មគ្គចិត្តដួងទី ២** នោះ ប្រហារអកុសលចំណែកគ្រោតគ្រាត ដែលសល់ពីសោតាបត្តិមគ្គចិត្តបានប្រហារមកហើយ ការប្រហារអកុសលដោយសកទាគាមិមគ្គចិត្តនោះ ត្រឹមតែប្រហារអកុសលឲ្យស្រាលស្តើងប៉ុណ្ណោះ ។

**អនាគាមិមគ្គចិត្ត** ប្រហារ **អាសវ** បាន ១ គឺ **កាមាសវ**

**ឱឃ** បាន ១ គឺ កាមោឃៈ

**យោគ** បាន ១ គឺ កាមយោគៈ

**គន្ថ** បាន ១ គឺ ព្យាបាទកាយគន្ថៈ

**នីវរណ** បាន ២ គឺ កាមច្ឆន្ទនីវរណៈ ព្យាបាទនីវរណៈ

**អនុស័យ** បាន ២ គឺ កាមរាគានុស័យ និងបដិឃានុស័យ

**សញ្ញោជន** បាន ២ គឺ កាមរាគសញ្ញោជន បដិឃសញ្ញោជនៈ

**កិលេស** បាន ១ គឺ ទោសកិលេស ។

**អរហត្តមគ្គចិត្ត** ប្រហារអកុសលទាំងអស់ដែលជាចំណែកសល់ពីមគ្គខាងក្រោមទាំង ៣ ដែលមិនបានលះ ។

## ការលះអកុសលកម្មបថដោយលំដាប់នៃមគ្គចិត្ត

**បាណាតិបាត**
**អទិន្នាទាន**
**កាមេសុមិច្ឆាចារ** } សោតាបត្តិមគ្គចិត្តលះបានដោយដាច់ខាត ជាសមុច្ឆេទប្បហាន។
**មុសាវាទ**
**មិច្ឆាទិដ្ឋិ**

អកុសលកម្មបថដ៏សេស សកទាគាមិមគ្គចិត្តលះបានដោយការធ្វើឲ្យស្រាលស្តើងជាតនុករប្បហាន ។

**បិសុណាវាចា**
**ផរុសវាចា** } អនាគាមិមគ្គចិត្តលះបានដោយដាច់ខាត ជាសមុច្ឆេទប្បហាន ។
**ព្យាបាទ**

សម្ផប្បលាប
អភិជ្ឈា } អរហត្តមគ្គចិត្តលះបានដោយដាច់ខាត ជា**សមុច្ឆេទប្បហាន** ។

## លោកុត្តរវិបាក ឬ ផលចិត្ត

**លោកុត្តរវិបាកចិត្ត** ឬផលចិត្តនេះ ជាចិត្តដែលជាផលរបស់លោកុត្តរកុសលចិត្ត ឬមគ្គចិត្តនោះឯង ពោលគឺ កាលមគ្គចិត្តកើតឡើងព្រមជាមួយការប្រហារកិលេសទៅហើយ ផលចិត្តក៏កើតជាប់តគ្នាមួយរំពេច ដោយមិនមានរវាងចន្លោះ គឺ មិនមានចិត្តប្រភេទដទៃណាកើតក្នុងរវាងចន្លោះនោះឡើយ កាលមគ្គចិត្តកើតនិងរលត់ទៅហើយ ផលចិត្តក៏កើតភ្លាម ទើបហៅមគ្គចិត្តនិងផលចិត្តនោះថាជា **អកាលិកោ** គឺជាហេតុឲ្យផលចិត្តកើតឡើង ក្នុងបច្ចុប្បន្នមួយរំពេច មិនត្រូវរង់ចាំវេលានៃការកើតឡើងរបស់ចិត្តឡើយ ផលចិត្តនេះនឹងត្រូវកើតឡើងភ្លាមដែលមគ្គចិត្តរលត់ហើយ ដើម្បីសោយផលជាប់ពីការប្រហារកិលេសរបស់មគ្គចិត្តដោយចំពោះៗ របស់មគ្គចិត្តទាំង ៤ ដូច្នោះលោកុត្តរវិបាកចិត្ត ឬផលចិត្ត ទើបមានចំនួន ៤ ដួង ស្មើគ្នានឹងមគ្គចិត្ត គឺ

**១. សោតាបត្តិផលចិត្ត**

**២. សកទាគាមិផលចិត្ត**

**៣. អនាគាមិផលចិត្ត**

**៤. អរហត្តផលចិត្ត ។**

# អត្ថនៃលោកុត្តរចិត្ត ៨

តទៅនេះ នឹងបានសម្ដែងអត្ថរបស់លោកុត្តរចិត្ត ដោយមគ្គចិត្ត និងផលចិត្តទៅតាមលំដាប់

**១. សោតាបត្តិមគ្គចិត្ត** កាលចែកបទបាន ៤ បទ គឺ

**សោត + អាបត្តិ + មគ្គ + ចិត្ត ។**

**សោត** ប្រែថា ក្រសែ ឬបានដល់ អង្គមគ្គ ៨ ដែលមានសភាពដូចក្រសែទឹក ។

**អាបត្តិ** ប្រែថា ចូលដល់ (អរិយមគ្គគ្រាដំបូង) ។

**មគ្គ** ប្រែថា ផ្លូវ បានដល់ អង្គមគ្គ ៨ ។

**ចិត្ត** បានដល់ ចិត្តដែលប្រកបដោយអង្គមគ្គ ៨ ។

រួមសេចក្ដីថា សោតាបត្តិមគ្គចិត្ត មានអត្ថថា ជាចិត្តដែលប្រកបដោយអង្គមគ្គ ៨ ដែលមានសភាពដូចក្រសែទឹក ដែលហូរចូលកាន់អរិយមគ្គ ឬចូលដល់ព្រះនិញ្វានជាគ្រាដំបូង មានព្រះបាលីសម្ដែងថា **"សវតិ សុន្ទតីតិ = សោតោ"** ប្រែថា ក្រសែទឹកឈ្មោះថា **សោត** ព្រោះហូរទៅមិនត្រឡប់ បានដល់ ក្រសែទឹកដែលហូរទៅក្នុងទន្លេ ឬ **"សោតោ វិយាតីតិ = សោតោ"** អរិយមគ្គមានអង្គ ៨ ឈ្មោះថា **សោត** ព្រោះដូចក្រសែទឹក ។

**"អាទិតោ បជ្ជនំ = អាបត្តិ"** ការចូលដល់អរិយមគ្គគ្រាដំបូង ឈ្មោះថា **អាបត្តិ "សោតស្ស អាបត្តិ = សោតាបត្តិ"** ការចូលដល់អរិយមគ្គដែលមានសភាពដូចក្រសែទឹក របស់បុថុជ្ជនជាគ្រាដំបូង

ឈ្មោះថា **សោតាបត្តិ ។ "និព្វានត្ថិកេហិ មគ្គីយតីតិ = មគ្គោ"** ផ្លូវកណ្ដាល គឺ អង្គមគ្គ ៨ ដែលអ្នកប្រាថ្នានិព្វានទាំងឡាយគួរស្វែងរក ដូច្នោះ ផ្លូវកណ្ដាលទើបឈ្មោះថា មគ្គ ឬ **"កិលេសេ មារេន្តោ គច្ឆតិ = មគ្គោ"** ផ្លូវកណ្ដាល គឺ អង្គមគ្គ ៨ នេះ ជាអ្នកប្រហារកិលេស និងជាអ្នកចូលដល់ព្រះនិព្វាន ផ្លូវកណ្ដាលនេះទើប ឈ្មោះថា **មគ្គ** ។

**សោតាបត្តិ ច សា មគ្គោ ចាតិ = សោតាបត្តិមគ្គោ** ផ្លូវកណ្ដាល គឺ អង្គមគ្គ ៨ ជាអ្នកចូលដល់អរិយមគ្គ ដែលមានសភាពដូចក្រសែទឹក ជាគ្រាដំបូងផង និងជាផ្លូវដែលគួរស្វែងរកផង ទើបឈ្មោះថា សោតាបត្តិមគ្គ ឬន័យម្យ៉ាងទៀត ប្រែថា ផ្លូវកណ្ដាល គឺ អង្គមគ្គ ៨ ជាអ្នកចូលដល់អរិយមគ្គដែលមានសភាពដូចក្រសែទឹកជាគ្រាដំបូងផង ជាអ្នកប្រហារកិលេស និងជាអ្នកចូលដល់ព្រះនិព្វានផង ទើបឈ្មោះថា **សោតាបត្តិមគ្គ ។**

**សោតាបត្តិ មគ្គេន សម្បយុត្តំ ចិត្តន្តិ = សោតាបត្តិមគ្គចិត្តំ** ចិត្តដែលប្រកបដោយអង្គមគ្គ ៨ ដែលជាអ្នកចូលដល់អរិយមគ្គមានសភាពដូចក្រសែទឹកជាគ្រាដំបូងផង ជាផ្លូវដែលគួរស្វែងរកផង ទើបឈ្មោះថា **សោតាបត្តិមគ្គ** ឬន័យម្យ៉ាងទៀត ចិត្តដែលប្រកបដោយអង្គមគ្គ ៨ ជាអ្នកចូលដល់អរិយមគ្គដែលមានសភាពជាក្រសែទឹក ជាគ្រាដំបូងផង ជាអ្នកប្រហារកិលេស និងជាអ្នកចូលដល់ព្រះនិព្វានផងទើបឈ្មោះថា **សោតាបត្តិមគ្គ** ។

កាលសោតាបត្តិមគ្គចិត្តកើតឡើង រមែងសម្រេចកិច្ចដូច្នេះ គឺ

(១) **សោតាបត្តិមគ្គចិត្ត** កើតដល់បុគ្គលណា បុគ្គលនោះឈ្មោះថា សោតាបត្តិមគ្គបុគ្គល ។

(២) **សោតាបត្តិមគ្គចិត្ត** ធ្វើឲ្យផុតចាកកាមភូមិក្នុងចំណែកដែលជាអបាយភូមិ ៤ គឺ នរក ប្រេត តិរច្ឆាន និងអសុរកាយ ។

(៣) **សោតាបត្តិមគ្គចិត្ត** កើតឡើងព្រមជាមួយនឹងការប្រហារកិលេសទម្លាយអកុសលចិត្ត ៥ ដួង មិនឲ្យកើតឡើងតទៅទៀត គឺ លោភទិដ្ឋិសម្បយុត្តចិត្ត ៤ ដួង និងមោហវិចិកិច្ឆាសម្បយុត្តចិត្ត ១ ដួង ក្រៅពីនោះថែមទាំងធ្វើឲ្យកិលេសដែលប្រកបក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ដួង និងទោសមូលចិត្ត ២ ដួង ស្រាលស្តើងមិនអាចនឹងនាំទៅកាន់អបាយភូមិ ៤ បាន ។

**២. សោតាបត្តិផលចិត្ត** ជាលោកុត្តរចិត្តដួងទី ២ កើតឡើងដើម្បីសោយនូវសន្តិសុខ ដែលសោតាបត្តិមគ្គចិត្តប្រហារអនុស័យកិលេសហើយ ពោលគឺ កាលសោតាបត្តិមគ្គចិត្តកើតឡើងប្រហារអនុស័យកិលេសនិងរលត់ទៅ ខណៈនោះសោតាបត្តិផលចិត្តក៏កើតឡើងសោយផលជាសន្តិសុខដែលកើតពីសោតាបត្តិមគ្គចិត្ត បានប្រហារអនុស័យកិលេសហើយ ។

ឬន័យម្យ៉ាងទៀត **សោតាបត្តិផលចិត្ត** រមែងកើតឡើងបានក្នុងឱកាសដែលព្រះសោតាបន្នចូលផលសមាបត្តិ កាលសោតាបត្តិផលចិត្តកើតរមែងឲ្យសម្រេចកិច្ចដូច្នេះ គឺ

(១) **សោតាបត្តិផលចិត្ត** កើតឡើងដល់បុគ្គលណា បុគ្គលនោះបានឈ្មោះថា សោតាបត្តិផលបុគ្គល ឬដែលហៅថា ព្រះសោតាបន្ន ឬពេលខ្លះក៏ហៅថា សេក្ខបុគ្គល គឺបុគ្គលដែលនៅសិក្សាតទៅទៀត រហូតដល់ផុតចាកភាវៈដែលមិនត្រូវសិក្សាតទៅទៀត ជាអសេក្ខបុគ្គល ឬព្រះអរហន្ត ។

(២) **សោតាបត្តិផលចិត្ត** ធ្វើឲ្យផុតចាកអបាយភូមិដោយសមុច្ឆេទ ពោលគឺ ព្រះសោតាបន្ន កាលចុតិរមែងមិនទៅបដិសន្ធិក្នុងអបាយភូមិទៀតទេ ព្រោះបានប្រហារអកុសលកម្មដែលជាហេតុទៅកាន់អបាយភូមិបានហើយដោយសមុច្ឆេទ ។

(៣) **សោតាបត្តិផលចិត្ត** រមែងកើតឡើង ដើម្បីសោយនូវសន្តិសុខពីការប្រហារទិដ្ឋិនិងវិចិកិច្ឆា ដែលលះបានហើយជាសមុច្ឆេទ ។

## ប្រភេទរបស់ព្រះសោតាបន្ន

ព្រះពុទ្ធអង្គទ្រង់សម្តែងចែកព្រះសោតាបន្នបានជា ៣ ប្រភេទ កំណត់ភពជាតិទុកដោយពិតប្រាកដ គឺ

**១. ឯកពីជីសោតាបន្ន** គឺ ព្រះសោតាបន្នមានជាតិកំណើតតែមួយជាតិទៀត ។

**ឯកំ ពីជំ អស្សាតិ = ឯកពីជី** ជាព្រះសោតាបន្នដែលនឹងត្រូវបដិសន្ធិតទៅទៀតមួយជាតិប៉ុណ្ណោះ នឹងសម្រេចព្រះអរហត្ត ហើយក៏បរិនិព្វានក្នុងទីនោះ ។

**២. កោលំកោលសោតាបន្ន** គឺ ព្រះសោតាបន្នដែលនឹងត្រូវមានជាតិកំណើតរវាង ២ ទៅ ៦ ជាតិ ។

**កុលតោ កុលំ គច្ឆតីតិ = កោលំកោលោ** ជាព្រះសោតាបន្នដែលនឹងត្រូវបដិសន្ធិតទៅទៀតតាំងពី ២ ទៅ ៦ ជាតិ យ៉ាងច្រើន ក៏នឹងសម្រេចព្រះអរហត្តផលហើយទើបបរិនិព្វាន ។

**៣. សត្តក្ខត្តុបរមសោតាបន្ន** គឺព្រះសោតាបន្នដែលត្រូវមានជាតិកំណើត ៧ ជាតិទៀត ។

**សត្តក្ខត្តុ បរមំ អស្សាតិ = សត្តក្ខត្តុបរមោ** ជាព្រះសោតាបន្នដែលនឹងត្រូវបដិសន្ធិតទៅទៀតយ៉ាងច្រើនត្រឹម ៧ ជាតិ ក៏នឹងសម្រេចអរហត្តផលហើយទើបបរិនិព្វាន ។

## ហេតុដែលធ្វើឲ្យព្រះសោតាបន្នសម្រេចអរហត្តផលផ្សេងគ្នា

ការដែលព្រះសោតាបន្នសម្រេចអរហត្តផលផ្សេងគ្នា ចែកទៅបាន ៣ ប្រភេទ នោះព្រោះហេតុ ២ ប្រការ គឺ

១. ផ្សេងគ្នាដោយកម្លាំងនៃឥន្ទ្រិយ ដែលបានសាងសន្សំអប់រំមកពីអតីត ពោលគឺ បើក្នុងអតីតជាតិបានអប់រំឥន្ទ្រិយ គឺ សទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ និងបញ្ញិន្ទ្រិយ មកហើយយ៉ាងខ្លាំងក្លា កាលបានសម្រេចជាព្រះសោតាបន្ន ក៏នឹងជា **ឯកពីជីសោតាបន្ន** ។

បើក្នុងអតីតជាតិ បានសាងសន្សំអប់រំឥន្ទ្រិយមកជាកណ្តាល កាលបានសម្រេចជាព្រះសោតាបន្នក៏នឹងជា **កោលំកោលសោតាបន្ន** ។

បើក្នុងអតីតជាតិ បានសាងសន្សំអប់រំឥន្ទ្រិយទុកយ៉ាងទន់ខ្សោយ កាលបានសម្រេចជាព្រះសោតាបន្ន ក៏ជាសត្តក្ខត្តុបរមសោតាបន្ន។

២. ផ្សេងគ្នាដោយការតាំងមាំដល់អរិយមគ្គខាងលើ ៣ ពោលគឺ បើព្រះសោតាបន្ន ដែលមានចិត្តតាំងមាំដល់អរិយមគ្គថ្នាក់លើ ៣ ដោយឧស្សាហព្យាយាមចម្រើនវិបស្សនា ដោយកម្លាំងចេតនាដែលខ្លាំងក្លាក៏ជា **ឯកពីជីសោតាបន្ន** ។

បើព្រះសោតាបន្នដែលមានចិត្តតាំងមាំដល់អរិយមគ្គថ្នាក់លើ ៣ ដោយឧស្សាហព្យាយាមចម្រើនវិបស្សនា ដោយកម្លាំងចេតនាយ៉ាងកណ្ដាលក៏ជា **កោលំកោលសោតាបន្ន** ។

បើព្រះសោតាបន្ន មានចិត្តតាំងមាំដល់អរិយមគ្គថ្នាក់លើ ៣ ដោយឧស្សាហៈ ចម្រើនវិបស្សនាដោយកម្លាំងចេតនាយ៉ាងទន់ខ្សោយ ក៏ជា **សត្តក្ខត្តុបរមសោតាបន្ន** ។

ព្រះសោតាបន្នដែលពោលមកហើយទាំង ៣ ប្រភេទនេះ សូម្បីផ្សេងគ្នាដោយការអប់រំឥន្ទ្រិយដែលក្រៃលែងជាងគ្នា ឬកាលនឹងចែកផ្សេងគ្នាដោយចិត្ត ដែលតាំងមាំក្នុងអរិយមគ្គថ្នាក់លើ និងក្រៃលែងជាងគ្នាយ៉ាងណាក្ដី ព្រះសោតាបន្នទាំងនោះ ក៏នឹងមិនត្រូវបដិសន្ធិក្នុងភពជាតិទី ៨ ទៀត ដូចប្រាកដក្នុងខុទ្ទកនិកាយព្រះបាលីថា

**យេ អរិយសច្ចានិ វិភាវយន្តិ គម្ភីរបញ្ញេន សុទេសិតានិ កិញ្ចាបិ តេ ហោន្តិ ភុសប្បមត្តា ន តេ ភវំ អដ្ឋមមាទិយន្តិ** អរិយបុគ្គលទាំងឡាយណា ធ្វើឲ្យជាក់ច្បាស់នូវអរិយសច្ចៈទាំងឡាយ ដែលព្រះតថាគត ព្រះអង្គ

មានប្រាជ្ញាដ៏ជ្រាលជ្រៅសម្តែងប្រពៃហើយ អរិយបុគ្គលទាំងនោះ ទុកជាប្រមាទដ៏លើសលប់ក៏ដោយ អរិយបុគ្គលទាំងនោះ គង់មិនកាន់យកភពជាគម្រប់ទី ៨ គឺមិនកើតទៀតហួសពី ៧ ជាតិឡើយ ។ (បិដកភាគ ៥២ ទំព័រ ៩) ដូច្នោះព្រះអរិយសោតាបន្នទាំង ៣ ប្រភេទ ដែលពោលនេះ ព្រះពុទ្ធអង្គទ្រង់បានសម្តែងទីបំផុតនៃភពជាតិទុកដោយពិតប្រាកដ ។

តែនៅមានព្រះសោតាបន្នមួយប្រភេទទៀត ដែលមិនរាប់រួមចូលក្នុងព្រះសោតាបន្ន ៣ ប្រភេទដែលពោលមកនោះ ព្រះអរិយសោតាបន្នប្រភេទនេះ ហៅថា **វដ្តាភិរតសោតាបន្ន** ជាព្រះអរិយសោតាបន្ន ដែលមានអធ្យាស្រ័យនៅត្រេកអរពេញចិត្តក្នុងវដ្តៈ ដែលប្រាថ្នាត្រាច់ទៅ បដិសន្ធិក្នុងទេវលោកទាំង ៦ ជាន់ រហូតទៅដល់អកនិដ្ឋភព ដូចប្រាកដក្នុងបុគ្គលប្បញ្ញត្តិអដ្ឋកថា ថា

**ឯកច្ចោ ហិ សោតាបន្នោ វដ្តជ្ឈាសយោ ហោតិ វដ្តាភិរតោ បុនប្បុនំ វដ្តស្មឹយេវ វិចរតិ សន្ទិស្សតិ អនាថបិណ្ឌិកោ សេដ្ឋិ, វិសាខា ឧបាសិកា, ចូឡរថមហារថា ទេវបុត្តា, អនេកវណ្ណោ ទេវបុត្តោ, សក្កោ ទេវរាជា, នាគទត្តោ ទេវបុត្តោតិ ឥមេ ហិ ឯត្តកា ជនា វដ្តជ្ឈាសយា វដ្តាភិរតា អាទិតោ បដ្ឋាយ ឆ ទេវលោកេ សោធេត្វា អកនិដ្ឋេ ឋត្វា បរិនិព្វាយិស្សន្តិ ឥមេ ឥធ ន គហិតា ។**

ប្រែថា នៅមានព្រះសោតាបន្នពួកខ្លះ មានអធ្យាស្រ័យត្រេកអរពេញចិត្តក្នុងវដ្តៈ ត្រាច់ទៅប្រាកដក្នុងវដ្តៈរឿយៗ ជនទាំងនោះគឺ អនាថបិណ្ឌិកសេដ្ឋី ឧបាសិកាវិសាខា ចូឡរថទេវបុត្ត មហារថទេវបុត្ត

អនេកវណ្ណទេវបុត្ត ស្តេចសក្កទេវរាជ នាគទត្តទេវបុត្ត អ្នកទាំងនេះនៅមានអធ្យាស្រ័យត្រេកអរពេញចិត្តក្នុងវដ្តៈ ការធ្វើទេវលោកទាំង ៦ ឲ្យអស់តាំងពីដើមរហូតដល់តាំងនៅក្នុងអកនិដ្ឋភព ទើបបរិនិព្វាន ព្រះសោតាបន្នទាំងនោះ លោកមិនសង្គ្រោះចូលក្នុង **សត្តក្ខត្តុបរមសោតាបន្ន** ទេ ។

ដូច្នោះ ទើបមានការរៀរសម្រាប់វដ្តាភិរតសោតាបន្នថា ព្រះសោ-តាបន្នអាចកាន់យកបដិសន្ធិច្រើនជាង ៧ ជាតិក៏បាន តែមតិមួយទៀតថា វដ្តាភិរតសោតាបន្ននេះ បានដល់ ព្រះសោតាបន្នដែលមានអាយុក្ខ័យរហូតនឹងមិនអស់ជីវិតមុនអាយុក្ខ័យ តែនឹងមិនលើស ៧ ជាតិទេ ។

**៣. សកទាគាមិមគ្គចិត្ត** ចែកបទបាន ៤ បទ គឺ

**សកឹ**(មួយដង) + **អាគាមី**(ត្រឡប់មក) + **មគ្គ**(ផ្លូវ) + **ចិត្ត** ប្រែថា ចិត្តដែលនឹងត្រឡប់មកបដិសន្ធិក្នុងមនុស្សភូមិតែម្តងទៀត ឈ្មោះថា **សកទាគាមី** ដូចបាលីដែលសម្តែងក្នុងអភិធម្មត្ថសង្គហដីកាថា

**សកឹ ឯកវារំ បដិសន្ធិវសេន ឥមំ មនុស្សលោកំ អាគច្ឆតីតិ = សកទាគាមី** ប្រែថា ព្រះអរិយបុគ្គលដោយច្រើនដែលនឹងត្រឡប់មកបដិសន្ធិក្នុងមនុស្សភូមិត្រឹមតែម្តងទៀត ឈ្មោះថា **សកទាគាមី** ។

**តស្ស មគ្គោ = សកទាគាមិមគ្គោ**

ផ្លូវបដិបត្តិរបស់ព្រះសកទាគាមីនោះ ឈ្មោះថា **សកទាគាមិមគ្គ** ។

**តេន សម្បយុត្តំ ចិត្តំ = សកទាគាមិមគ្គចិត្តំ**

ចិត្តដែលប្រកបដោយអង្គរបស់សកទាគាមិមគ្គ ឈ្មោះថា **សកទាគាមិមគ្គចិត្ត** ។

កាលសកទាគាមិមគ្គចិត្តកើតឡើង រមែងឲ្យសម្រេចកិច្ចដូច្នេះ គឺ

(១) **សកទាគាមិមគ្គចិត្ត** កើតឡើងដល់បុគ្គលណា បុគ្គលនោះឈ្មោះថា **សកទាគាមិមគ្គបុគ្គល** ។

(២) **សកទាគាមិមគ្គចិត្ត** កើតឡើងព្រមជាមួយការប្រហារកិលេស ដែលសល់ពីសោតាបត្តិមគ្គចិត្ត បានប្រហារមកហើយដោយធ្វើកិលេសទាំងនោះ ឲ្យស្រាលស្តើងទៀត ហៅថា **តនុករប្បហាន** ។

**៤. សកទាគាមិផលចិត្ត** ជាចិត្តដែលកើតឡើងមួយរំពេចដែលសកទាគាមិមគ្គចិត្តរលត់ ឬកើតឡើងបានជាមួយសកទាគាមីដែលចូលផលសមាបត្តិ ។

កាលសកទាគាមិផលចិត្តប្រាកដឡើង រមែងសម្រេចកិច្ច គឺ

(១) **សកទាគាមិផលចិត្ត** កើតឡើងដល់បុគ្គលណា ក្នុងខណៈដំបូងមួយរំពេច បុគ្គលនោះបានឈ្មោះថា សកទាគាមិផលបុគ្គល សកទាគាមិផលបុគ្គលគឺ ដែលនិយមហៅថា ព្រះសកទាគាមី ឬពេលខ្លះហៅថា ព្រះសកទាគា ព្រះអរិយបុគ្គលក្នុងថ្នាក់នេះ នៅជាសេក្ខបុគ្គលព្រោះត្រូវសិក្សាបដិបត្តិតទៅ ដើម្បីឲ្យសម្រេចជាព្រះអរហន្ត ។

(២) **សកទាគាមិផល** កើតឡើងដើម្បីសោយផលដែលសកទាគាមិមគ្គចិត្តបានប្រហារកិលេសប្រភេទ **តនុករប្បហាន**ហើយដើម្បីសោយវិមុត្តិសុខខណៈចូលផលសមាបត្តិ ។

# ប្រភេទរបស់ព្រះសកទាគាមី

ក្នុងអភិធម្មត្ថសង្គហដីកា សម្តែងថា ព្រះសកទាគាមីនោះមាន ៥ ប្រភេទ គឺ

**(១) ឥធ បត្វា ឥធ បរិនិព្វាយី** សម្រេចជាព្រះសកទាគាមិបុគ្គលក្នុងមនុស្សភូមិហើយ នឹងបានសម្រេចអរហត្តផលក្នុងមនុស្សភូមិ ក៏បរិនិព្វនក្នុងទីនោះ ក្នុងជាតិតែមួយ ។

**(២) តត្ថ បត្វា តត្ថ បរិនិព្វាយី** សម្រេចជាព្រះសកទាគាមិបុគ្គលក្នុងទេវលោកហើយ នឹងបានសម្រេចអរហត្តផលក្នុងទេវលោក ក៏បរិនិព្វានក្នុងទីនោះ ក្នុងជាតិតែមួយ ។

**(៣) ឥធ បត្វា តត្ថ បរិនិព្វាយី** សម្រេចជាព្រះសកទាគាមិបុគ្គលក្នុងមនុស្សភូមិ ហើយចុតិចាកមនុស្សភូមិទៅបដិសន្ធិក្នុងទេវភូមិ និងសម្រេចអរហត្តផលក្នុងទេវភូមិនោះ ក៏បរិនិព្វានក្នុងទីនោះ ។

**(៤) តត្ថ បត្វា ឥធ បរិនិព្វាយី** សម្រេចជាព្រះសកទាគាមិបុគ្គលក្នុងទេវភូមិ ហើយចុតិចាកទេវភូមិមកបដិសន្ធិក្នុងមនុស្សភូមិ និងសម្រេចអរហត្តផលក្នុងមនុស្សភូមិនោះ ក៏បរិនិព្វានក្នុងទីនោះ ។

**(៥) ឥធ បត្វា តត្ថ និព្វត្តិត្វា ឥធ បរិនិព្វាយី** សម្រេចជាព្រះសកទាគាមិបុគ្គលក្នុងមនុស្សភូមិ ហើយចុតិចាកមនុស្សភូមិទៅបដិសន្ធិក្នុងទេវភូមិ ហើយចុតិចាកទេវភូមិ ត្រឡប់មកបដិសន្ធិក្នុងមនុស្សភូមិទៀត និងបានសម្រេចអរហត្តផលក្នុងមនុស្សភូមិនេះ ក៏បរិព្វានក្នុងទីនេះ ។

ព្រះសកទាគាមិបុគ្គលប្រភេទទី ១ រហូតដល់ប្រភេទទី ៤ ជាន័យដែលសម្តែងទុកដោយបរិយាយ ចំណែកប្រភេទទី ៥ ជាន័យដោយត្រង់តាមបាលីក្នុងអភិធម្មត្ថសង្គហដីកានេះថា

**សកឹ ឯកវារំ បដិសន្ធិវសេន ឥមំ មនុស្សលោកំ អាគច្ឆតីតិ = សកទាគាមី** ប្រែថា ព្រះអរិយបុគ្គលដោយច្រើនដែលនឹងត្រឡប់មកបដិសន្ធិក្នុងមនុស្សភូមិទៀតត្រឹមតែម្តង ឈ្មោះថា ព្រះសកទាគាមី ។

**៥. អនាគាមិមគ្គចិត្ត** ជាមគ្គចិត្តដួងទី ៣ កើតឡើងដើម្បីលះកាមរាគៈនិងព្យាបាទមិនឲ្យសល់ អនាគាមិមគ្គចិត្តកាលចែកបទហើយបានដូច្នេះគឺ

**ន** (មិន) **+ អាគាមី** (ត្រឡប់មក) **+ មគ្គ** (ផ្លូវ) **+ ចិត្ត** ប្រែថា ចិត្តដែលមិនត្រឡប់មកបដិសន្ធិក្នុងកាមភូមិទៀត ឈ្មោះថា អនាគាមី ដូចមានវចនត្ថៈថា

**បដិសន្ធិវសេន ឥមំ កាមធាតុំ ន អាគច្ឆតីតិ = អនាគាមី** អ្នកដែលមិនត្រឡប់មកបដិសន្ធិក្នុងកាមភូមិទៀត ឈ្មោះថា **អនាគាមី** ។

**តស្ស មគ្គោ = អនាគាមិមគ្គោ** ផ្លូវបដិបត្តិរបស់អ្នកសម្រេចអនាគាមីនោះ ឈ្មោះថា **អនាគាមិមគ្គ** ។

**តេន សម្បយុត្តំ ចិត្តំ = អនាគាមិមគ្គចិត្តំ** ចិត្តដែលប្រកបដោយអង្គនៃអនាគាមិមគ្គនោះ ឈ្មោះថា អនាគាមិមគ្គចិត្ត កាលអនាគាមិមគ្គចិត្តប្រាកដឡើង រមែងឲ្យសម្រេចកិច្ចដូច្នេះ គឺ

**(១) អនាគាមិមគ្គចិត្ត** កើតឡើងដល់បុគ្គលណា បុគ្គលនោះឈ្មោះថា អនាគាមិមគ្គបុគ្គល ។

**(២) អនាគាមិមគ្គចិត្ត** កើតឡើងដើម្បីឆ្លងផុតចាកការត្រឡប់មកកើតក្នុងកាមលោកទៀត នឹងកើតក្នុងព្រហ្មលោកពិតប្រាកដ ។

**(៣) អនាគាមិមគ្គចិត្ត** កើតឡើងដើម្បីប្រហារកាមរាគៈនិងព្យាបាទដោយមិនមានសល់ ។

**៦. អនាគាមិផលចិត្ត** ជាផលចិត្តដួងទី ៣ ដែលកើតឡើងក្នុងលំដាប់នៃអនាគាមិមគ្គចិត្តរលត់ទៅមិនមានរវាងចន្លោះជា **អកាលិកោ** ឬអនាគាមិផលចិត្ត រមែងកើតឡើងក្នុងខណៈដែលព្រះអនាគាមីចូលផលសមាបត្តិ ។

**អនាគាមិផលចិត្ត** កើតឡើងដល់បុគ្គលណា បុគ្គលនោះឈ្មោះថា អនាគាមិផលបុគ្គល ឬអនាគាមី ដែលនៅជាព្រះសេក្ខបុគ្គល នឹងត្រូវសិក្សា គឺចម្រើនបញ្ញាតទៅរហូតដល់សម្រេចអរហត្តផល ។

**អនាគាមិផលចិត្ត** ជាចិត្តដែលលោភៈនិងទោសៈ ទាក់ទងនឹងកាមរាគៈត្រូវប្រហារហើយដោយ **សមុច្ឆេទប្បហាន** ។

**អនាគាមិផលចិត្ត** ទើបជាចិត្តដែលផុតចាកកាមដោយពិតប្រាកដ គឺព្រះអនាគាមី កាលចុតិហើយ នឹងមិនបដិសន្ធិក្នុងកាមភូមិទៀតឡើយ នឹងទៅបដិសន្ធិជាព្រហ្មក្នុងរូបភូមិ ឬអរូបភូមិ តាមសមគួរដល់ការចម្រើនសមថភាវនារបស់ព្រះអរិយបុគ្គលអ្នកផុតចាកកាម ។

## ប្រភេទរបស់ព្រះអនាគាមី

ក្នុងវិសុទ្ធិមគ្គសម្តែងថា ព្រះអនាគាមិបុគ្គលមាន ៥ ប្រភេទ គឺ

(១) **អន្តរាបរិនិព្វាយី** បានដល់ ព្រះអនាគាមិបុគ្គលដែលបដិសន្ធិក្នុងព្រហ្មភូមិណាមួយ ហើយសម្រេចអរហត្តផល នឹងបរិនិព្វានខាងក្នុងពាក់កណ្តាលខាងដើមនៃអាយុក្ខ័យរបស់ភូមិនោះៗ ។

(២) **ឧបហច្ចបរិនិព្វាយី** បានដល់ ព្រះអនាគាមិបុគ្គលដែលបដិសន្ធិក្នុងព្រហ្មភូមិណាមួយ ហើយសម្រេចអរហត្តផល នឹងបរិនិព្វានលើសជាងពាក់កណ្តាលនៃអាយុក្ខ័យរបស់ភូមិនោះៗ ។

(៣) **អសង្ខារបរិនិព្វាយី** បានដល់ ព្រះអនាគាមិបុគ្គលដែលបដិសន្ធិក្នុងព្រហ្មភូមិណាមួយ ហើយសម្រេចអរហត្តផលបានយ៉ាងរហ័ស មិនត្រូវព្យាយាមខ្លាំងក៏សម្រេចបាន ។

(៤) **សសង្ខារបរិនិព្វាយី** បានដល់ ព្រះអនាគាមិបុគ្គលដែលបដិសន្ធិក្នុងព្រហ្មភូមិណាមួយ ហើយសម្រេចអរហត្តផលបានដោយលំបាក ត្រូវព្យាយាមយ៉ាងខ្លាំងក្លា ទើបសម្រេចអរហត្តផលបាន ។

(៥) **ឧទ្ធំសោតោ អកនិដ្ឋគាមី** បានដល់ ព្រះអនាគាមិបុគ្គលដែលបដិសន្ធិក្នុងសុទ្ធាវាសភូមិខាងក្រោម តាំងពីអវិហាភូមិ ហើយចុតិនិងបដិសន្ធិក្នុងភូមិដែលខ្ពស់ឡើងទៅដោយលំដាប់ គឺ **អតប្បាភូមិ សុទស្សា សុទស្សី** រហូតដល់ **អកនិដ្ឋាភូមិ** នឹងបានសម្រេចអរហត្តផលហើយបរិនិព្វានក្នុងភូមិនោះ ។

**៧. អរហត្តមគ្គចិត្ត** ជាមគ្គចិត្តដួងទី ៤ កាលព្រះអនាគាមីបានចម្រើនវិបស្សនាឲ្យក្រៃលែងឡើងហើយ អរហត្តមគ្គចិត្តនឹងកើតឡើងដើម្បីលះរូបរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ និងអវិជ្ជាមិនឲ្យមានសល់ ។

**អរហត្តមគ្គចិត្ត** កាលចែកបទហើយ បានដូច្នេះ គឺ

**អរហត្ត** (អ្នកគួរបូជាយ៉ាងក្រៃលែង) + **មគ្គ**(ផ្លូវ) + **ចិត្ត**

ប្រែថា ជាចិត្តដល់នូវផ្លូវដែលជាអ្នកគួរដល់ការបូជាយ៉ាងក្រៃលែង ដូចប្រាកដវចនត្ថៈថា

**(១) អគ្គទក្ខិណេយ្យភាវេន បូជាវិសេសំ អរហតីតិ = អរហា**

ព្រះអរិយបុគ្គលអ្នកគួរដល់ការបូជារបស់ទេវតា និងមនុស្សទាំង-ឡាយ ព្រោះជាអ្នកគួរដល់ទក្ខិណាដ៏លើសលប់នោះ ទើបឈ្មោះថា **អរហន្ត** ។

**(២) តស្ស ភាវោ អរហត្តំ ចតុត្ថផលស្សេតំ អធិវចនំ**

ជាអរិយបុគ្គលដែលគួរដល់ការបូជាដ៏វិសេស ឈ្មោះថា **អរហត្ត** បានដល់ **អរហត្តផល** ។

**(៣) តស្ស អាគមនភូតោ មគ្គោ អរហត្តមគ្គោ**

ផ្លូវដែលជាទីមកនៃអរហត្តផលនោះ ឈ្មោះថា **អរហត្តមគ្គ** ។

**(៤) តេន សម្បយុត្តំ ចិត្តំ អរហត្តមគ្គចិត្តំ**

ចិត្តដែលប្រកបដោយអង្គនៃអរហត្តមគ្គ ឈ្មោះថា **អរហត្តមគ្គចិត្ត ។**

កាលអរហត្តមគ្គចិត្តប្រាកដឡើង រមែងឲ្យសម្រេចកិច្ចដូច្នេះ គឺ

**-អរហត្តមគ្គចិត្ត** កើតឡើងដល់បុគ្គលណា បុគ្គលនោះឈ្មោះថា **អរហត្តមគ្គបុគ្គល** ។

**-អរហត្តមគ្គចិត្ត** ជាចិត្តដែលកំពុងឆ្លងផុតរូបលោក អរូបលោក

ដោយពិតប្រាកដ ។

**-អរហត្តមគ្គចិត្ត** ជាចិត្តដែលកំពុងប្រហារកិលេស ពោលដោយចិត្ត ក៏ជាការកំពុងប្រហារអកុសលចិត្ត ដែលសល់ពីអរិយមគ្គចិត្តថ្នាក់ក្រោមបានប្រហារហើយ នៅសល់តែ ៥ ដួងទៀត គឺ លោភមូលចិត្តដែលជាទិដ្ឋិវិប្បយុត្ត ៤ មោហមូលចិត្តដែលជាឧទ្ធច្ចសម្បយុត្ត ១ ដួង ពោលដោយអកុសលកម្មបថ ១០ អរហត្តមគ្គចិត្តជាចិត្តដែលកំពុងប្រហារអកុសលកម្មបថដែលសល់ ២ ដួង ទៀត គឺ សម្ផប្បលាប និងអភិជ្ឈា ។

**(៨) អរហត្តផលចិត្ត** ជាផលចិត្តដួងទី ៩ និងជាលោកុត្តរចិត្តដួងចុងក្រោយ ដែលកើតឡើងភ្លាម កាលអរហត្តមគ្គចិត្តរលត់ទៅ ដោយមិនមានចិត្តដទៃកើតរវាងចន្លោះ ឬន័យម្យ៉ាងទៀតថា អរហត្តផលចិត្តរមែងកើតឡើងក្នុងខណៈ ដែលព្រះអរហន្តចូលផលសមាបត្តិ ។

កាលអរហត្តផលចិត្តកើតឡើងដល់បុគ្គលណា បុគ្គលនោះបានឈ្មោះថា **អរហត្តផលបុគ្គល** ។

**អរហត្តផលចិត្ត** ជាចិត្តដែលផុតចាកការកើតនៅក្នុងលោកណាៗ ពោលគឺ ព្រះអរហន្តកាលបរិនិព្វានហើយ មិនត្រូវទៅបដិសន្ធិទីណាទៀតឡើយ ជាការអស់ភពអស់ជាតិ ផុតចាកសង្សារវដ្ត ដែលមិនត្រូវត្រាច់ទៅវិលវល់ស្លាប់កើត នៅក្នុងភពតូចភពធំតទៅទៀតឡើយ ។

**អរហត្តផលចិត្ត** ជាចិត្តដែលត្រូវប្រហារអកុសលអស់ហើយ ដោយសមុច្ឆេទប្បហាន ឬពោលបានថា ព្រះអរហន្តមិនមានអកុសលចិត្តទាំង ១២ ដួង កើតឡើងក្នុងសន្តានទៀតឡើយ ។

**អរហត្តផលចិត្ត** ជាចិត្តដែលត្រូវប្រហារអកុសលកម្មបថអស់ហើយដោយសមុច្ឆេទប្បហាន ឬពោលបានថាព្រះអរហន្តនោះ មិនមានអកុសលកម្មបថ ១០ កើតឡើងក្នុងសន្តានទៀតឡើយ ។

## ព្រះអរហន្ត

**អរហត្តផលចិត្ត** កើតឡើងដល់បុគ្គលណា បុគ្គលនោះឈ្មោះថា អរហត្តផលបុគ្គល និងអរហត្តផលបុគ្គលនេះ មានឈ្មោះហៅបានច្រើនយ៉ាង គឺ

**ព្រះអរហន្ត** បានដល់ បុគ្គលអ្នកគួរគោរពសក្ការបូជាយ៉ាងក្រៃលែង ដូចមានបាលីថា

**បូជាទិវិសេសំ អរហតីតិ = អរហំ**

ព្រះខីណាស្រព បានដល់ បុគ្គលអ្នកអស់កិលេសាសវៈហើយ ។

**ព្រះអសេក្ខបុគ្គល** បានដល់ អ្នកមិនត្រូវសិក្សាតទៅទៀតឡើយ (ព្រោះបរិបូណ៌ហើយដោយសីលសិក្ខា ចិត្តសិក្ខា និងបញ្ញាសិក្ខា) ដូចមានបាលីថា

**ឧបរិសិក្ខិតព្វា ភាវតោ ន សេក្ខាតិ = អសេក្ខា**

បុគ្គលទាំងឡាយណា មិនមែនជាសេក្ខបុគ្គលព្រោះមិនមានធម៌

ដែលនឹងត្រូវបដិបត្តិតទៅ ដូច្នោះបុគ្គលនោះ ឈ្មោះថា **អសេក្ខ** ។

## ប្រភេទរបស់ព្រះអរហន្ត

**ព្រះអរហន្តនោះ** ចែកចេញជាប្រភេទផ្សេងៗ បានច្រើនប្រភេទ ដែលចែកជា ២ ប្រភេទ គឺ

**១. ព្រះអរហន្ត** ដែលសម្រេចដោយបញ្ញាវិមុត្តិ ។

**២. ព្រះអរហន្ត** ដែលសម្រេចដោយចេតោវិមុត្តិ ។

## អធិប្បាយព្រះអរហន្ត

**១. ព្រះអរហន្ត** ដែលសម្រេចដោយបញ្ញាវិមុត្តិនោះ បានដល់ព្រះអរហន្តដែលសម្រេចដោយការបដិបត្តិវិបស្សនាភាវនាសុទ្ធៗ មិនបានបដិបត្តិសមថភាវនា គឺ មិនបានចម្រើនឈានឡើយ កាលមគ្គផលកើតឡើងក៏មិនមានអារម្មណ៍បនិជ្ឈានកើតឡើងផងទេ ព្រះអរហន្តអ្នកដែលមិនបានឈាននោះ ហៅម្យ៉ាងទៀតថា **សុក្ខវិបស្សក ព្រះអរហន្ត** ។

**២. ព្រះអរហន្ត** ដែលសម្រេចដោយចេតោវិមុត្តិនោះ បានដល់ព្រះអរហន្តដែលសម្រេចដោយវិបស្សនាភាវនា ព្រមទាំងសម្រេចសមថភាវនា រហូតដល់បានឈានផង ហើយការបានមកនូវឈានអាចបាន ២ វិធី គឺ

**ក. ឈាន** អាចបានមកដោយការបដិបត្តិសមថភាវនា រហូតដល់សម្រេចឈាន ហៅការបានឈានដោយវិធីនេះថា បដិបទាសុទ្ធិឈាន

គឺបានឈានពីការបដិបត្តិសមថភាវនាហើយ ទើបលើកឈានឡើងមកចម្រើនវិបស្សនា រហូតដល់បានសម្រេចជាព្រះអរហន្ត ។

**ខ. ឈាន** អាចបានមកសូម្បីមិនបានបដិបត្តិសមថភាវនា តែកាលបានចម្រើនវិបស្សនាភាវនាតាមលំដាប់ រហូតដល់បានសម្រេចអរហត្តមគ្គ អរហត្តផល និងខណៈបានមគ្គផលនោះ អារម្មណ៍បនិជ្ឈានក៏កើតឡើងព្រមគ្នា ដោយអំណាចនៃបុញ្ញាធិការ ពីក្នុងកាលមុន ឈានដែលកើតឡើងនេះ ហៅថា មគ្គសុទ្ធិឈាន គឺបានឈានដោយអំណាចនៃមគ្គ ហើយឈានប្រភេទនេះ អាចបានអភិញ្ញាផងក៏មានដូចជាព្រះចូឡបន្ថក កាលសម្រេចជាព្រះអរហន្តក៏បានអភិញ្ញាហើយសម្ដែងឥទ្ធិបាដិហារិយ៍បាន ។

ព្រះអរហន្តប្រភេទចេតោវិមុត្តិនេះ ជាអ្នកដែលសម្រេចឈានផងហៅថា ព្រះអរហន្តឈានលាភីបុគ្គល ហើយព្រះអរហន្តឈានលាភី-បុគ្គលនេះ អង្គខ្លះមិនបានអភិញ្ញាក៏មាន តែអង្គខ្លះបានអភិញ្ញាផងក៏មាន ។

ព្រះអរហន្តឈានលាភីបុគ្គល ដែលបានឈានអភិញ្ញាផងនោះ អាចបានសម្រេចអភិញ្ញាផ្សេងគ្នាក៏មាន គឺអង្គខ្លះបានត្រឹមអភិញ្ញា ៣ អង្គខ្លះក៏បានដល់អភិញ្ញា ៦ ក៏មាន ។

**អភិញ្ញា ៣** ឬដែលហៅថា **វិជ្ជា ៣** នោះ បានដល់

**១. បុព្វេនិវាសានុស្សតិញ្ញាណ** មានបញ្ញាដែលរលឹកជាតិក្នុងអតីតបាន ។

**២. ទិព្វចក្ខុញ្ញាណ ឬចុតូបបាតញ្ញាណ** មានភ្នែកទិព្វ ឬដឹងចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយ ។

**៣. អាសវក្ខយញ្ញាណ** មានបញ្ញាដឹងពីការអស់ទៅនៃអាសវក្កិលេស។

សុក្ខវិបស្សកព្រះអរហន្ត ឬឈានលាភីព្រះអរហន្ត ដែលបាន អភិញ្ញា ឬមិនបានអភិញ្ញាក្តី កាលសម្រេចជាព្រះអរហន្តហើយ ត្រូវមាន អភិញ្ញាចំណុចទី ៣ នេះគ្រប់ៗ អង្គ ។

**អភិញ្ញា ៦** ឬ **វិជ្ជា ៦** នោះ បានដល់ **អភិញ្ញា ៣** ឬ **វិជ្ជា ៣** នោះឯង នឹងមានការដឹងបន្ថែមឡើង ៣ ប្រការទៀត គឺ

**៤. បរចិត្តវិជ្ជានន** ឬ **ចេតោបរិយញ្ញាណ** គឺ មានការដឹងចិត្តអ្នកដទៃ

**៥. ទិព្វសោតញ្ញាណ** មានត្រចៀកទិព្វ

**៦. ឥទ្ធិវិធ** អាចសម្តែងឫទ្ធិបាន ។

## ព្រះអរហន្តចែកជា ២ ប្រភេទ ន័យម្យ៉ាងទៀត

ការចែកព្រះអរហន្តជា ២ ប្រភេទតាមន័យនេះ គឺ

**១. ព្រះអរហន្ត** អ្នកមានបដិសម្ភិទាញាណ ។

**២. ព្រះអរហន្ត** អ្នកមិនមានបដិសម្ភិទាញាណ ។

**បដិសម្ភិទាញាណ** គឺ ដល់ព្រមដោយការដឹង ដែលបែកធ្លាយ ក្នុងពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ យល់ដឹងអត្ថ ដឹងធម៌ ផ្សេងៗ ។

## បដិសម្ភិទាញាណ មាន ៤ ប្រការ គឺ

១. **អត្ថប្បដិសម្ភិទាញាណ** គឺ បញ្ញាបែកធ្លាយក្នុងផលទាំងពួង ដែលកើតពីហេតុ **អត្ថ** សំដៅយក **ផល** បានដល់ ធម៌ ៥ ប្រការ គឺ

(១) **យំ កិញ្ចិ បច្ចយសម្ភូតំ** គឺ រូបធម៌ទាំងពួងដែលកើតឡើង មានបច្ច័យប្រជុំតាក់តែង ។

(២) **និព្វានំ** គឺ ព្រះនិព្វាន ។

(៣) **ភាសិតត្ថោ** គឺ អត្ថដែលពោលឲ្យដឹងវិបាកខន្ធ ៣២ ដួង ។

(៤) **ក្រិយចិត្តំ** គឺ កិរិយាចិត្ត ២០ ដួង ។

(៥) **ផលចិត្តំ** គឺ ផលចិត្ត ៤ ដួង ។

២. **ធម្មប្បដិសម្ភិទាញាណ** គឺ បញ្ញាបែកធ្លាយក្នុងហេតុ ដែលធ្វើឲ្យកើតផល **ធម្ម** សំដៅយក **ហេតុ** បានដល់ ធម៌ ៥ ប្រការ គឺ

(១) **យោ កោចិ ផលនិព្វត្តកោ ហេតុ** គឺ ហេតុទាំងពួងដែលញ៉ាំងផលឲ្យកើតឡើង ។

(២) **អរិយមគ្គោ** គឺ មគ្គចិត្ត ៤ ដួង ។

(៣) **ភាសិតំ** គឺ ព្រះធម៌ទាំង ៣ បិដក ។

(៤) **កុសលំ** គឺ លោកិយកុសលចិត្ត ១៧ ដួង ។

(៥) **អកុសលំ** គឺ អកុសលចិត្តទាំង ១២ ដួង ។

៣. **និរុត្តិប្បដិសម្ភិទាញាណ** គឺ បែកធ្លាយក្នុងភាសាជាបញ្ញត្តិ ដែលជាប់ដោយអត្ថប្បដិសម្ភិទា និងធម្មប្បដិសម្ភិទា បានសេចក្ដីថា ក្នុងការអធិប្បាយសេចក្ដីនៃអត្ថប្បដិសម្ភិទា និងធម្មប្បដិសម្ភិទា ឲ្យអ្នក

ស្តាប់ដឹងនិងយល់បានជាក់ច្បាស់ ដោយត្រឹមត្រូវល្អិតល្អន់ ត្រូវចេះប្រើពាក្យ ឬភាសាជាបញ្ញត្តិដែលហៅ ចេះប្រើវោហារដូច្នេះ ឈ្មោះថា **និរុត្តិប្បដិសម្ភិទា** ។

**៤. បដិភាណប្បដិសម្ភិទាញាណ** គឺ បញ្ញាបែកធ្លាយក្នុងបដិសម្ភិទាខាងដើមទាំង ៣ បានសេចក្តីថា មានបញ្ញាឈ្លាសវៃរហ័សរហួន ក្នុងការឆ្លើយតប **អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា** និង**និរុត្តិប្បដិសម្ភិទា** ទាំង ៣ នោះ បានយ៉ាងត្រឹមត្រូវនិងរហ័សរហួនជាក់ច្បាស់ ការបែកធ្លាយដូច្នេះ ហៅថា **បដិភាណប្បដិសម្ភិទាញាណ** ។

## ព្រះអរហន្តដែលចែកចេញជា ៣ ប្រភេទ បានដូច្នេះ គឺ

**១. ព្រះអរហន្ត** ដែលត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណដោយព្រះអង្គឯង និងអាចប្រោសវេនេយ្យសត្វឲ្យផុតទុក្ខបាន ដោយណែនាំឲ្យដល់អរិយមគ្គ អរិយផលបាន ព្រោះទ្រង់ជាអ្នកដល់ព្រមដោយញាណ ដែលជាគ្រឿងប្រោសសត្វ ៣ ប្រការ គឺ

**ក. អាសយានុសយញ្ញាណ** គឺ ញាណដែលអាចដឹងនូវអនុស័យកិលេសនិងអធ្យាស្រ័យរបស់វេនេយ្យសត្វទាំងឡាយ ។

**ខ. ឥន្ទ្រិយបរោបរិយត្តិញ្ញាណ** គឺ ញាណដែលអាចដឹងឥន្ទ្រិយរបស់សត្វទាំងឡាយថា ចាស់ក្លាឬក៏មិនទាន់ចាស់ក្លា ។

**គ. សព្វញ្ញុតញ្ញាណ** គឺ ញាណដែលអាចដឹងសង្ខតធម៌ និងអសង្ខតធម៌ រួមទាំងបញ្ញត្តិធម៌ទាំងពួង ព្រះអរហន្តប្រភេទនេះ ទើបបាន

ឈ្មោះថា ព្រះសព្វញ្ញូពុទ្ធ ឬព្រះអរហន្តសម្មាសម្ពុទ្ធ ។

**២. ព្រះអរហន្ត** ដែលត្រាស់ដឹងដោយព្រះអង្គឯងដូចគ្នា តែមិនអាចបញ្ញត្តព្រះធម៌ប្រោសវេនេយ្យសត្វទាំងឡាយ ឲ្យផុតទុក្ខបាន ព្រោះមិនដល់ព្រមដោយញាណជាគ្រឿងប្រោសសត្វ ៣ ប្រការ ដូចពោលហើយក្នុងចំណុចទី ១ ព្រះអរហន្តប្រភេទនេះ បានឈ្មោះថា ព្រះអរហន្តបច្ចេកពុទ្ធ ឬព្រះបច្ចេកពុទ្ធ ។

**៣. ព្រះអរហន្ត** ដែលត្រាស់ដឹងធម៌ សម្រេចព្រះអរហត្តផល តាមពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះ ក៏បានឈ្មោះថា ព្រះអរហន្ត បានដល់ ព្រះអរហន្តទូទៅ ដែលក្រៅពីព្រះអរហន្តសម្មាសម្ពុទ្ធនិងព្រះអរហន្តបច្ចេកពុទ្ធ ហៅថា ព្រះអរហន្តសាវ័កសុតពុទ្ធ និងអនុពុទ្ធ ។

## ព្រះអរហន្តសាវ័កមាន ៣ ប្រភេទ

**១. បកតិសាវក** បានដល់ សាវ័កដែលសម្រេចអរិយសច្ច អស់អាសវក្កិលេសហើយដោយទូទៅ ។

**២. មហាសាវក** បានដល់ ព្រះអរហន្តដែលជាសាវ័កធំជិតដិតជាមួយព្រះសាស្តា បានទទួលការលើកតម្កើងជាពិសេស (ឯតទគ្គ) ៤១ អង្គ និង ៣៩ អង្គទៀតមិនបានទទួលលើកតម្កើងជាពិសេស រួមជា ៨០ អង្គ ។

**៣. អគ្គសាវក** បានដល់ សាវ័កដែលជាកំពូលនៅខាងឆ្វេងនិងខាងស្តាំរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ បានដល់ ព្រះសារីបុត្តត្ថេរ (ខាងស្តាំ) និងព្រះមោគ្គល្លានត្ថេរ (ខាងឆ្វេង) ។

## លោកុត្តរចិត្តពិស្តារ ៤០ ដួង

ការរាប់លោកុត្តរចិត្តនោះ មាន ២ ន័យ

**១. លោកុត្តរចិត្ត** រាប់ដោយសង្ខេបមានចំនួន ៨ ដួង ។

**២. លោកុត្តរចិត្ត** រាប់ដោយពិស្តារមានចំនួន ៤០ ដួង ។

លោកុត្តរចិត្តដោយសង្ខេប ៨ ដួងនោះ បានសម្តែងទុកហើយ បានដល់ មគ្គចិត្ត ៤ ផលចិត្ត ៤ រួមជា ៨ ដួង ។

លោកុត្តរចិត្តដែលរាប់ដោយសង្ខេបនេះ បានដល់ លោកុត្តរចិត្តដែលប្រកបដោយលក្ខណូបនិជ្ឈាន ដោយអ្នកបដិបត្តិពិចារណាការកើតរលត់របស់សង្ខារធម៌ នាមរូបជាអារម្មណ៍រហូតដល់បានសម្រេចជាព្រះអរហន្តដែលហៅថា សុក្ខវិបស្សកព្រះអរហន្ត លោកុត្តរចិត្តដែលមិនមានអារម្មណូបនិជ្ឈានជាបាទនេះ អនុលោមរាប់ចូលនៅក្នុងបឋមជ្ឈានដោយហេតុថា មានចេតសិកដែលជាអង្គរបស់បឋមជ្ឈានប្រកបគ្រប់ ។

តែព្រះយោគាវចរដែលជាសុក្ខវិបស្សកៈ មិនអាចពិចារណាអង្គឈានឲ្យជា **អនិច្ចំ ទុក្ខំ អនត្តា** បាន និងមិនអាចលះអង្គឈានមានវិតក្កៈ និងវិចារៈជាដើមបាន មិនអាចចូលបឋមជ្ឈានបាន ឬព្រះយោគាវចរជាឈានលាភីបុគ្គល ដែលនិយមវិបស្សនា មិននិយមឈានដែលខ្លួនបាន

តែពិចារណាសង្ខារធម៌មាននាមរូបជាអារម្មណ៍ក៏ជាសុក្ខវិបស្សកៈដូចគ្នា ។ សេចក្តីផ្សេងគ្នារបស់លោកុត្តរចិត្តតាមប្រភេទរបស់ឈាន ទើបមិនមានក្នុងលោកុត្តរចិត្តដែលមិនបានប្រកបដោយអារម្មណូបនិជ្ឈាន ទើបមានត្រឹមតែ ៨ ដួង តាមចំនួនដែលរាប់ដោយសង្ខេបប៉ុណ្ណោះ ។

ចំណែកលោកុត្តរចិត្តដែលរាប់ដោយពិស្តារនោះ បានដល់លោកុត្តរចិត្តដោយសង្ខេប ៨ ដួងនោះកាលមានអារម្មណូបនិជ្ឈានជាបាទ និងមានសេចក្តីនឿយណាយក្នុងអង្គឈានណាមួយ ដែលមាន ៥ ថ្នាក់ គឺ បឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន និងបញ្ចមជ្ឈាន ទើបជាចំនួន ៤០ ដួង បានសេចក្តីថា ចិត្តរបស់ព្រះអរិយបុគ្គលដែលបានឈានផងនោះ កាលលោកុត្តរចិត្តកើតឡើង ដោយអាស្រ័យឈានចិត្តជាបាទ ចិត្តមួយដួងៗ នោះ ប្រកបដោយឈានមួយថ្នាក់ៗ នោះឯងទើបផ្សេងគ្នាដោយប្រភេទជាថ្នាក់ឈាន លោកុត្តរចិត្ត ៨ ដួង ប្រកបដោយឈាន ៥ ថ្នាក់ ទើបជាចំនួន ៨ × ៥ = ៤០ ដួង ។

**លោកុត្តរចិត្តពិស្តារ** មានចំនួន ៤០ ដួងនេះ ចែកបានជាមគ្គចិត្តពិស្តារ ២០ ដួង និងផលចិត្តពិស្តារ ២០ ដួងទៀត ដូចព្រះបាលីសម្តែងថា

**១០. ចតុមគ្គប្បភេទេន ចតុធា កុសលំ តថា**
**បាកំ តស្ស ផលត្តាតិ អដ្ឋធានុត្តរំ មតំ ។**
**។ល។ ។ល។**
**១៤. ឈានង្គយោគភេទេន កត្វេកេកន្តុ បញ្ចធា**

## វុច្ចតានុត្តរំ ចិត្តំ ចត្តាលីសវិធន្តិ ច ។

គប្បីជ្រាបថា លោកុត្តរចិត្តដោយសង្ខេប មាន ៨ ដួង គឺ កុសលចិត្តពោលដោយប្រភេទនៃមគ្គមាន ៤ វិបាកចិត្តក៏មាន ៤ ព្រោះជាផលរបស់មគ្គទាំង ៤ ។

**លោកុត្តរចិត្ត ៨** កាលសម្ដែងដោយពិស្តារមាន ៤០ ដួង ព្រោះពោលដោយប្រភេទនៃការប្រកបរបស់អង្គឈាន ហើយលោកុត្តរចិត្តមួយដួងៗ មានឈាន ៥ ដូច្នោះលោកុត្តរ ៨ ត្រូវជា ៤០ ដួង ។

**ចំណុចសម្គាល់ លោកុត្តរចិត្ត** មិនបានចែកទៅតាមអរូបជ្ឈាន ៤ ទៀត ព្រោះអរូបជ្ឈានទាំង ៤ នោះ រាប់ជាបញ្ចមជ្ឈាន ហើយការពោលដោយអង្គឈាន ក៏មានត្រឹមតែ ២ គឺ ឧបេក្ខា និងឯកគ្គតាប៉ុណ្ណោះ និងដូចគ្នាជាមួយរូបាវចរបញ្ចមជ្ឈាន ផ្សេងគ្នាតែអារម្មណ៍ប៉ុណ្ណោះ ចំណែកអង្គឈានគឺស្មើគ្នា ដូច្នោះទើបរាប់ថា ឈានទាំង ៩ មានអង្គឈានត្រឹមតែ ៥ ថ្នាក់ប៉ុណ្ណោះ លោកុត្តរចិត្ត ៨ ដួង ចែកតាមឈាន ៥ ថ្នាក់ ទើបមាន ៤០ ដួង ។

## ចិត្តភេទ

**ចិត្តភេទ** បានដល់ ការចែកចិត្តចេញជាប្រភេទផ្សេងៗ ចិត្តទាំងអស់ កាលរាប់ដោយសង្ខេបមានចំនួន ៨៩ ដួង និងរាប់ដោយពិស្តារមាន ១២១ ដួង កាលចែកជាប្រភេទផ្សេងៗ ហើយមាន ៩ ន័យ គឺ

**១. ជាតិភេទន័យ** គឺ ការចែកប្រភេទរបស់ចិត្តដោយជាតិមាន ៤ ជាតិ បានដល់ **អកុសលជាតិ កុសលជាតិ វិបាកជាតិ** និង**កិរិយាជាតិ** ។

**២. ភូមិភេទន័យ** គឺ ចែកប្រភេទរបស់ចិត្តដោយភូមិមាន ៤ បានដល់ **កាមភូមិ រូបភូមិ អរូបភូមិ** និង **លោកុត្តរភូមិ** ។

**៣. សោភណភេទន័យ** គឺ ការចែកប្រភេទរបស់ចិត្តដោយ **អសោភណ** និង **សោភណ** ។

**៤. លោកភេទន័យ** គឺ ការចែកប្រភេទរបស់ចិត្តដោយ **លោកិយ** និង **លោកុត្តរ** ។

**៥. ហេតុភេទន័យ** គឺ ការចែកប្រភេទរបស់ចិត្តដោយ **អហេតុក** និង **សហេតុក** ។

**៦. ឈានភេទន័យ** គឺ ការចែកប្រភេទរបស់ចិត្តដោយ **ឈាន** និង **អឈាន** ។

**៧. វេទនាភេទន័យ** គឺ ការចែកប្រភេទរបស់ចិត្តដោយវេទនា ៥ បានដល់ **សុខវេទនា ទុក្ខវេទនា សោមនស្សវេទនា ទោមនស្សវេទនា** និង **ឧបេក្ខាវេទនា** ។

**៨. សម្បយោគភេទន័យ** គឺ ការចែកប្រភេទរបស់ចិត្តដោយ **សម្បយុត្ត** និង **វិប្បយុត្ត** ។

**៩. សង្ខារភេទន័យ** គឺ ការចែកប្រភេទរបស់ចិត្តដោយ **អសង្ខារិក** និង **សសង្ខារិក** ។

## ១. ចែកចិត្ត ៨៩ ដោយជាតិភេទន័យ

**ចិត្ត ៨៩ ដួង** នោះ កាលចែកដោយជាតិ ឬត្រកូលនៃការកើតឡើងរបស់ចិត្តហើយមាន ៤ ជាតិ ដូច្នេះ គឺ

## គាថាសង្គហទី ១១

**១១. ទ្វាទសាកុសលានេវំ កុសលានេកវីសតិ**
**ឆត្តឹសេវ វិបាកានិ ក្រិយចិត្តានិ វីសតិ ។**

ប្រែថា ចិត្តទាំងអស់ កាលចែកដោយជាតិភេទន័យហើយ មាន ៤ ជាតិ គឺ អកុសលជាតិ ១២ ដួង កុសលជាតិ ២១ ដួង វិបាកជាតិ ៣៦ ដួង និងកិរិយាជាតិ ២០ ដួង ។

**អកុសលជាតិ ១២** ដួង បានដល់ ជាតិដែលជាដែនកើតនៃទោស និងឲ្យផលជាទុក្ខ បានដល់ អកុសលចិត្ត ១២ ដួង ។

**កុសលជាតិ ២១** ដួង បានដល់ ជាតិដែលជាដែនកើតប្រាសចាកទោស និងឲ្យផលជាសុខ បានដល់ កុសលចិត្ត ២១ ដួង គឺ

មហាកុសលចិត្ត ៨ ដួង
មហគ្គតកុសលចិត្ត ៩ ដួង } រួម ២១ ដួង ។
លោកុត្តរកុសលចិត្ត ៤ ដួង

**វិបាកជាតិ ៣៦** ដួង បានដល់ ជាតិដែលជាផលរបស់អកុសល និងកុសល គឺ

| | | |
|---|---|---|
| អកុសលវិបាកចិត្ត | ៧ ដួង | ៣៦ ដួង ។ |
| អហេតុកកុសលវិបាកចិត្ត | ៨ ដួង | |
| មហាវិបាកចិត្ត | ៨ ដួង | |
| មហគ្គតវិបាកចិត្ត | ៩ ដួង | |
| លោកុត្តរវិបាកចិត្ត | ៤ ដួង | |

**កិរិយាជាតិ ២០** ដួង បានដល់ ជាតិរបស់ចិត្តដែលមិនមែនជាកុសលអកុសលនិងទាំងមិនមែនជាផលរបស់កុសលឬអកុសលផង ជាចិត្តដែលគ្រាន់តែធ្វើកិច្ចតាមនាទីប៉ុណ្ណោះ

| | | |
|---|---|---|
| អហេតុកកិរិយាចិត្ត | ៣ ដួង | ២០ ដួង ។ |
| មហាកិរិយាចិត្ត | ៨ ដួង | |
| មហគ្គតកិរិយាចិត្ត | ៩ ដួង | |

វិបាកជាតិ និងកិរិយាជាតិនេះ ហៅថា អព្យាកតជាតិ បានដល់ជាតិរបស់ចិត្ត ដែលមិនមែនអកុសលជាតិនិងកុសលជាតិទាំង ២ ។

## ២. ចែកចិត្ត ៨៩ ដោយភូមិភេទន័យ

ចិត្តទាំង ៨៩ ដួង កាលចែកដោយភូមិ គឺ ស្ថានទីកើត ឬទីនៅអាស្រ័យរបស់ចិត្តហើយមាន ៤ ភូមិដូច្នេះ គឺ

## គាថាសង្គហទី ១២

**១២. ចតុបញ្ញាសធា កាមេ　　រូបេ បន្នរសីរយេ**

**ចិត្តានិ ទ្វាទសារុប្បេ　　អដ្ឋធានុត្តរេ តថា ។**

ប្រែថា ចិត្តទាំងអស់កាលចែកដោយភូមិហើយ បានកាមាវចរភូមិ ៥៤ ដួង រូបាវចរភូមិ ១៥ ដួង អរូបាវចរភូមិ ១២ ដួង និងលោកុត្តរភូមិ ៨ ដួង ។

**កាមាវចរភូមិ ៥៤** បានដល់ ភូមិដែលជាទីកើតរបស់កាមាវចរចិត្ត

| | | |
|---|---|---|
| អកុសលចិត្ត | ១២ ដួង | = ៥៤ ដួង ។ |
| អហេតុកចិត្ត | ១៨ ដួង | |
| មហាកុសលចិត្ត | ៨ ដួង | |
| មហាវិបាកចិត្ត | ៨ ដួង | |
| មហាកិរិយាចិត្ត | ៨ ដួង | |

**រូបាវចរភូមិ ១៥** បានដល់ ភូមិដែលជាទីកើតរបស់រូបាវចរចិត្ត

| | | |
|---|---|---|
| រូបាវចរកុសលចិត្ត | ៥ ដួង | = ១៥ ដួង ។ |
| រូបាវចរវិបាកចិត្ត | ៥ ដួង | |
| រូបាវចរកិរិយាចិត្ត | ៥ ដួង | |

**អរូបាវចរភូមិ ១២** បានដល់ ភូមិដែលជាទីកើតរបស់អរូបាវចរចិត្ត

| | | |
|---|---|---|
| អរូបាវចរកុសលចិត្ត | ៤ ដួង | = ១២ ដួង ។ |
| អរូបាវចរវិបាកចិត្ត | ៤ ដួង | |
| អរូបាវចរកិរិយាចិត្ត | ៤ ដួង | |

**លោកុត្តរភូមិ ៨** បានដល់ ទីកើតរបស់ចិត្តដែលផុតចាកភូមិទាំង ៣ ខាងដើម

លោកុត្តរកុសលចិត្ត ៤ ដួង
លោកុត្តរវិបាកចិត្ត ៤ ដួង } = ៨ ដួង ។

**ចំណុចសម្គាល់** អត្ថរបស់ **ភូមិ** ប្រែបានច្រើនន័យ គឺ ប្រែថា ផែនដី ទីនៅអាស្រ័យ ទីកើត ឬថ្នាក់ អត្ថរបស់ភូមិក្នុងទីនេះ បានដល់ ថ្នាក់ដែលជាទីអាស្រ័យរបស់ចិត្តផ្សេងៗ ដែលចែកដោយអំណាចរបស់ តណ្ហា ដែលហៅថា **អវត្ថាភូមិ** ។

## ចែកប្រភេទការរាប់ចំនួនចិត្ត

## គាថាសង្គហទី ១៣

**១៣. ឥត្ថមេកូននវុតិ- បភេទំ បន មានសំ**
**ឯកវីសសតំ វាថ វិភជន្តិ វិចក្ខណា ។**

ប្រែថា អ្នកប្រាជ្ញទាំងឡាយ បានចែកនូវចិត្តដែលមានប្រភេទ ៨៩ ដួង ន័យម្យ៉ាងទៀតចែកបានជា ១២១ ដួង ។

ចំនួនដែលផ្សេងគ្នារបស់ចិត្ត ២ ប្រភេទនោះ ដែលផ្សេងគ្នាតែ លោកុត្តរចិត្តមួយប៉ុណ្ណោះ ចំណែកកាមាវចរចិត្ត រូបាវចរចិត្ត ឬអរូបាវចរ ចិត្ត មានចំនួនដដែល មិនមានចំនួនប្រែប្រួលទេ ។

## ៣. ចែកចិត្ត ៨៩ ដោយសោភណភេទន័យ

ការចែកចិត្ត ជាប្រភេទចិត្តដែលល្អស្អាត ដែលហៅថា "**សោភណចិត្ត**" និងចិត្តប្រភេទដទៃ ដែលក្រៅអំពីសោភណចិត្ត ដែលហៅថា "**អសោភណចិត្ត**" នោះ ចែកចេញបាន ដូច្នេះ

**សោភណចិត្ត** មាន ៥៩ ដួង បានដល់

| | | |
|---|---|---|
| កាមាវចរសោភណចិត្ត | ២៤ ដួង | = សោភណចិត្ត ៥៩ ដួង |
| មហគ្គតចិត្ត | ២៧ ដួង | |
| លោកុត្តរចិត្ត | ៨ ដួង | |

**អសោភណចិត្ត** មាន ៣០ ដួង បានដល់

| | | |
|---|---|---|
| អកុសលចិត្ត | ១២ ដួង | = អសោភណចិត្ត ៣០ ដួង ។ |
| អហេតុកចិត្ត | ១៨ ដួង | |

## ៤. ចែកចិត្ត ៨៩ ដោយលោកភេទន័យ

ការចែកចិត្ត ជាប្រភេទចិត្តដែលត្រូវត្រាច់វិលវល់ទៅក្នុងលោកទាំង ៣ គឺ កាមលោក រូបលោក និងអរូបលោក ដែលហៅថា "**លោកិយចិត្ត**" និងចិត្តដែលផុតចាកការត្រាច់ទៅក្នុងលោក ហៅថា "**លោកុត្តរចិត្ត**" ចែកបានដូច្នេះ

**លោកិយចិត្ត** មាន ៨១ ដួង បានដល់

កាមាវចរចិត្ត ៥៤ ដួង
រូបាវចរចិត្ត ១៥ ដួង } = លោកិយចិត្ត ៨១ ដួង ។
អរូបាវចរចិត្ត ១២ ដួង

**លោកុត្តរចិត្ត** មាន ៨ ដួង បានដល់ = លោកុត្តរចិត្ត ៨ ដួង ។

## ៥. ចែកចិត្ត ៨៩ ដោយហេតុភេទន័យ

ការចែកចិត្តដោយហេតុភេទន័យ បានដល់ ការចែកចិត្ត ៨៩ ដួង ដោយប្រភេទដែលមិនមានសម្បយុត្តហេតុ ហៅថា “**អហេតុកចិត្ត**” ចំណែកប្រភេទដែលមានសម្បយុត្តហេតុ ហៅថា “**សហេតុកចិត្ត**” ។

**អហេតុកចិត្ត** បានដល់ ចិត្តដែលមិនមានទាំងអកុសលហេតុ និងកុសលហេតុប្រកប គឺ មិនមានលោភហេតុ ទោសហេតុ មោហហេតុ និងមិនមានអលោភហេតុ អទោសហេតុ អមោហហេតុប្រកបផងឡើយ បានដល់ **អហេតុកចិត្ត ១៨ ដួង** គឺ

អកុសលវិបាកចិត្ត ៧ ដួង
អហេតុកកុសលវិបាកចិត្ត ៨ ដួង } = អហេតុកចិត្ត ១៨ ដួង ។
អហេតុកកិរិយាចិត្ត ៣ ដួង

**សហេតុកចិត្ត** បានដល់ ចិត្តដែលប្រកបដោយហេតុ ទាំងអកុសលហេតុ និងកុសលហេតុតាមសមគួរ គឺ សហេតុកចិត្តដួងខ្លះមានហេតុប្រកបត្រឹមតែមួយ ហៅថា “**ឯកហេតុកចិត្ត**” ដួងខ្លះក៏មានហេតុ

ប្រកបបាន ២ ហៅថា "**ទ្វិហេតុកចិត្ត**" និងគ្រាខ្លះក៏មានហេតុប្រកបបានដល់ទៅ ៣ ហៅថា "**តិហេតុកចិត្ត**" ចិត្តប្រកបដោយហេតុយ៉ាងច្រើនបំផុត បានត្រឹម ៣ ហេតុប៉ុណ្ណោះ ។

ដូច្នោះ សហេតុកចិត្តទាំង ៣ ប្រភេទ ទើបចែកចេញបានដូច្នេះ គឺ

**១. ឯកហេតុកចិត្ត** មាន ២ ដួង បានដល់

**មោហមូលចិត្ត ២** មានហេតុត្រឹមតែមួយគឺមោហហេតុ ។

**២. ទ្វិហេតុកចិត្ត** មាន ២២ ដួង បានដល់

**លោភមូលចិត្ត ៨** មាន **លោភហេតុ** និង **មោហហេតុ ។**

**ទោសមូលចិត្ត ២** មាន **ទោសហេតុ** និង **មោហហេតុ ។**

មហាកុសលញាណវិប្បយុត្តចិត្ត ៤
មហាវិបាកញាណវិប្បយុត្តចិត្ត ៤
មហាកិរិយាញាណវិប្បយុត្តចិត្ត ៤
} មានអលោភហេតុ និងអទោសហេតុ។

**៣. តិហេតុកចិត្ត** មាន ៤៧ ដួង បានដល់

| | | |
|---|---|---|
| មហាកុសលញាណសម្បយុត្តចិត្ត | ៤ | មាន អលោភហេតុ អទោសហេតុ និងអមោហហេតុ ។ |
| មហាវិបាកញាណសម្បយុត្តចិត្ត | ៤ | |
| មហាកិរិយាញាណសម្បយុត្តចិត្ត | ៤ | |
| រូបាវចរកុសលចិត្ត | ៥ | |
| រូបាវចរវិបាកចិត្ត | ៥ | |
| រូបាវចរកិរិយាចិត្ត | ៥ | |
| អរូបាវចរកុសលចិត្ត | ៤ | |
| អរូបាវចរវិបាកចិត្ត | ៤ | |
| អរូបាវចរកិរិយាចិត្ត | ៤ | |
| លោកុត្តរចិត្ត | ៨ | |

រួមសេចក្ដីថា ចិត្ត ៨៩ ដួង កាលចែកដោយហេតុភេទន័យហើយ បានដល់ "**អហេតុកចិត្ត ១៨ ដួង** និង "**សហេតុកចិត្ត ៧១ ដួង**" ។

## ៦. ចែកចិត្ត ៨៩ ដោយឈានភេទន័យ

ការចែកចិត្តដោយប្រភេទនៃឈាននោះ បានដល់ ការចែកចិត្ត ដែលប្រកបដោយអារម្មណូបនិជ្ឈាន ឬប្រកបដោយអង្គឈាន ហៅថា "**ឈានចិត្ត**" និងចិត្តដែលមិនបានប្រកបដោយអារម្មណូបនិជ្ឈាន ឬមិនបាន ប្រកបដោយអង្គឈាន ដែលហៅថា "**អឈានចិត្ត**" ចែកបានដូច្នេះ

**ឈានចិត្ត** មាន ៣៥ ដួង បានដល់

| | | |
|---|---|---|
| រូបាវចរចិត្ត | ១៥ | = ឈានចិត្ត ៣៥ ដួង ។ |
| អរូបាវចរចិត្ត | ១២ | |
| លោកុត្តរចិត្ត | ៨ | |

**អឈានចិត្ត** មាន ៥៤ ដួង បានដល់

| | | |
|---|---|---|
| អកុសលចិត្ត | ១២ | = អឈានចិត្ត ៥៤ ដួង ។ |
| អហេតុកចិត្ត | ១៨ | |
| កាមាវចរសោភណចិត្ត | ២៤ | |

**ចំណុចសម្គាល់** សម្រាប់លោកុត្តរចិត្តដែលចាត់ជាឈានចិត្តនោះ សូម្បីលោកុត្តរចិត្តរបស់ព្រះយោគាវចរអ្នកចម្រើនវិបស្សនាសុទ្ធៗ កាលមគ្គចិត្តកើតជាអប្បនាចិត្ត ដែលមានអង្គរបស់បឋមជ្ឈានរួមផង ទើបសង្គ្រោះជាឈានចិត្តផង តែបើជាមគ្គ ផលរបស់ឈានលាភីបុគ្គលហើយ លោកុត្តរចិត្ត ទើបត្រូវរាប់ដោយពិស្តារ ៤០ ដួង លោកុត្តរចិត្តនេះត្រូវចាត់ជា "**ឈានចិត្ត**" ដោយពិតប្រាកដ ។

## ចែកលោកុត្តរចិត្តដោយអង្គឈាន

## អាចសានគាថា

១៤. ឈានង្គយោគភេទេន កត្វេកេកន្តុ បញ្ចធា
វុច្ចតានុត្តរំ ចិត្តំ ចត្តាលីសវិធន្តិ ច ។

ប្រែថា លោកុត្តរចិត្ត ៨ កាលសម្តែងដោយពិស្តារ ៤០ ដួង ព្រោះពោលដោយប្រភេទនៃការប្រកបរបស់អង្គឈានហើយ ដោយលោកុត្តរចិត្តមួយដួងៗ មានឈាន ៥ ដូច្នោះលោកុត្តរចិត្ត ៨ ទើបជា ៤០ ដួង ។

គាថានេះ រមែងសម្តែងឲ្យឃើញថា លោកុត្តរចិត្ត ៨ នោះ កាលសម្តែងដោយពិស្តារ រមែងចែកចេញទៅតាមចំនួនអង្គឈានដែលប្រកប ទើបចាត់ថា លោកុត្តរចិត្ត ដោយពិស្តារនោះជា "**ឈានចិត្ត**" ពិតប្រាកដ។

## សង្គ្រោះលោកុត្តរចិត្តជាមួយឈាន

## គាថាសង្គហទី ១៥

**១៥. យថា ច រូបាវចរំ គយ្ហតានុត្តរំ តថា**
**បឋមាទិឈានភេទេ អារុប្បញ្ចាបិ បញ្ចមេ ។**

ប្រែថា រូបាវចរចិត្តរាប់សង្គ្រោះចូលក្នុងឈានទាំង ៥ មានបឋមជ្ឈានជាដើម បានយ៉ាងណា លោកុត្តរចិត្តក៏រាប់សង្គ្រោះចូលក្នុងឈានទាំង ៥ មានបឋមជ្ឈានជាដើម ក៏បានយ៉ាងនោះដែរ ចំណែកអរូបាវចរចិត្ត ១២ នោះរាប់សង្គ្រោះចូលក្នុងបញ្ចមជ្ឈាន ។

អធិប្បាយថា លោកុត្តរចិត្តដែលព្រះអរិយបុគ្គលបានសម្រេចមគ្គផលនោះ រមែងមានអង្គឈានប្រកបទាំងអស់ មិនថាព្រះអរិយបុគ្គលនោះ ធ្លាប់បានសម្រេចឈានមកពីមុនឬមិនធ្លាប់ក្តី បើធ្លាប់សម្រេចឈានមកពីមុន អង្គឈានរមែងកើតព្រមគ្នាក្នុងខណៈមគ្គ ផលប្រាកដ តែបើមិនធ្លាប់បានធ្វើឈានមកពីមុន និងមិនមានបុញ្ញាធិការ

អប់រំឈានទុក អង្គឈានរមែងមិនមានឱកាសប្រាកដ តែយ៉ាងណាក្តី អង្គឈានទាំង ៥ គឺ **វិតក្ក វិចារ បីតិ សុខ** និង**ឯកគ្គតា** រមែងមានព្រមគ្នាក្នុងខណៈដែលមគ្គចិត្ត ឬផលចិត្តកើតឡើង ទើបរាប់បានថា លោកុត្តរចិត្តទើបមានបឋមជ្ឈានដូចគ្នាផង ។

## ៧. ចែកចិត្ត ៨៩ ដោយវេទនាភេទន័យ

ការចែកចិត្តដោយវេទនាភេទន័យ បានដល់ ការចែកចិត្ត ៨៩ ដួង ដែលកើតព្រមដោយវេទនាផ្សេងៗ បានដល់ វេទនា ៥ ប្រការ គឺ

**១. សុខវេទនា** ចិត្តដែលកើតព្រមដោយសុខវេទនា (សុខកាយ) បានដល់ **សុខសហគតកាយវិញ្ញាណចិត្ត ១ ដួង ។**

**២. ទុក្ខវេទនា** ចិត្តដែលកើតព្រមដោយទុក្ខវេទនា (ទុក្ខកាយ) បានដល់ **ទុក្ខសហគតកាយវិញ្ញាណចិត្ត ១ ដួង ។**

**៣. សោមនស្សវេទនា** ចិត្តដែលកើតព្រមដោយសោមនស្សវេទនា បានដល់

| | | | |
|---|---|---|---|
| សោមនស្សលោភមូលចិត្ត | ៤ | | |
| សោមនស្សសន្តីរណចិត្ត | ១ | | |
| សោមនស្សហសិតុប្បាទចិត្ត | ១ | = កាមសោមនស្ស ១៨ | |
| សោមនស្សមហាកុសលចិត្ត | ៤ | | |
| សោមនស្សមហាវិបាកចិត្ត | ៤ | | |
| សោមនស្សមហាកិរិយាចិត្ត | ៤ | | = ៣៨ ដួង |
| រូបាវចរបឋមជ្ឈាន | ៣ | | |
| រូបាវចរទុតិយជ្ឈាន | ៣ | | |
| រូបាវចរតតិយជ្ឈាន | ៣ | = ឈានសោមនស្ស ២០ | |
| រូបាវចរចតុត្ថជ្ឈាន | ៣ | | |
| លោកុត្តរចិត្ត | ៨ | | |

កាលពោលដោយទូទៅហើយ ការចែកចិត្ត ៨៩ ដោយវេទនានោះ លោកុត្តរចិត្ត ៨ ដួងនោះ រមែងកើតព្រមជាមួយសោមនស្សវេទនា តែបើចែកចិត្ត ១២១ ដួង ដោយប្រភេទនៃវេទនាហើយ ក៏ចាត់ជាសោមនស្ស-លោកុត្តរចិត្ត ៣២ ដួង គឺ លោកុត្តរចិត្តដែលប្រកបដោយអង្គឈាននៃបឋមជ្ឈាន ៨ ដួង ទុតិយជ្ឈាន ៨ ដួង តតិយជ្ឈាន ៨ ដួង និងចតុត្ថជ្ឈាន ៨ ដួង ជាសោមនស្សលោកុត្តរចិត្ត ចំណែកបញ្ចមជ្ឈាន រមែងកើតព្រមដោយឧបេក្ខាវេទនា ។

៤. **ទោមនស្សវេទនា** ចិត្តដែលកើតព្រមដោយទោមនស្សវេទនា បានដល់ ទោសមូលចិត្ត ២ ដួង ។

៥. **ឧបេក្ខាវេទនា** ចិត្តដែលកើតព្រមដោយឧបេក្ខាវេទនា មាន ៤៧ ដួង គឺ

| | | | |
|---|---|---|---|
| ឧបេក្ខាលោភមូលចិត្ត | ៤ | = កាមឧបេក្ខា ៣២ | = ៤៧ ដួង |
| ឧបេក្ខាមោហមូលចិត្ត | ២ | | |
| ឧបេក្ខាអហេតុកចិត្ត | ១៤ | | |
| ឧបេក្ខាមហាកុសលចិត្ត | ៤ | | |
| ឧបេក្ខាមហាវិបាកចិត្ត | ៤ | | |
| ឧបេក្ខាមហាកិរិយាចិត្ត | ៤ | | |
| រូបាវចរបញ្ចមជ្ឈានចិត្ត | ៣ | = មហគ្គតឧបេក្ខា ១៥ | |
| អរូបាវចរចិត្ត | ១២ | | |

## ៨. ចែកចិត្ត ៨៩ ដោយសម្បយោគភេទន័យ

ការចែកចិត្តដោយសម្បយោគភេទន័យ គឺ ការចែកចិត្តដែលមានសភាវធម៌ប្រកបខ្លះ ហៅថា **សម្បយុត្ត** និងមិនមានសភាវធម៌យ៉ាងនោះប្រកប ហៅថា **វិប្បយុត្ត** ។

កាលចែកចិត្ត ៨៩ ដោយ "**សម្បយុត្ត**" និង "**វិប្បយុត្ត**" ហើយ បានដូច្នេះ គឺ

**សម្បយុត្តចិត្ត** មាន ៥៥ ដួង ចែកជា ៥ ប្រភេទ គឺ

**១. ទិដ្ឋិគតសម្បយុត្តចិត្ត** មាន ៤ ដួង បានដល់ លោភមូលចិត្ត ដែលជា **ទិដ្ឋិគតសម្បយុត្ត ៤ ដួង ។**

**២.បដិឃសម្បយុត្តចិត្ត** មាន២ដួងបានដល់ **ទោសមូលចិត្ត** ២ដួង។

**៣. វិចិកិច្ឆាសម្បយុត្តចិត្ត** មាន ១ ដួង បានដល់ មោហមូលចិត្ត ដួងទី ១ ដែលជា **វិចិកិច្ឆាសម្បយុត្ត** ។

**៤. ឧទ្ធច្ចសម្បយុត្តចិត្ត** មាន ១ ដួង បានដល់ មោហមូលចិត្តដួងទី ២ ដែលជា **ឧទ្ធច្ចសម្បយុត្ត ។**

**៥. ញាណសម្បយុត្តចិត្ត** មាន ៤៧ ដួង បានដល់

| | | |
|---|---|---|
| កាមាវចរសោភណញាណសម្បយុត្ត | ១២ ដួង | |
| មហគ្គតចិត្ត | ២៧ ដួង | = ៤៧ ដួង ។ |
| លោកុត្តរចិត្ត | ៨ ដួង | |

**វិប្បយុត្តចិត្ត** មាន ៣៤ ដួង ចែកជា ៣ ប្រភេទ គឺ

**១. ទិដ្ឋិគតវិប្បយុត្តចិត្ត** មាន ៤ ដួង បានដល់ **លោភមូលចិត្ត** ដែលជា **ទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ដួង ។**

**២. ញាណវិប្បយុត្តចិត្ត** មាន ១២ ដួង បានដល់ **កាមាវចរសោភណញាណវិប្បយុត្តចិត្ត ១២ ដួង ។**

**៣. វិប្បយុត្តចិត្ត** មាន ១៨ ដួង បានដល់ **អហេតុកចិត្ត ១៨ ដួង ។**

សម្រាប់អហេតុកចិត្ត ១៨ ដួងនេះ មិនមានទិដ្ឋិ បដិឃ វិចិកិច្ឆា ឧទ្ធច្ចៈ ឬឈាន សូម្បីណាមួយប្រកបក្នុងអហេតុកចិត្តឡើយ ទើបចាត់

ជាវិប្បយុត្តចិត្ត ព្រោះមិនមានសម្បយុត្តធម៌ ៥ យ៉ាង ដូចពោលនោះឡើយ ។

## ៩. ចែកចិត្ត ៨៩ ដោយសង្ខារភេទន័យ

ការចែកចិត្តដោយសង្ខារភេទន័យ គឺ ការចែកចិត្តដែលកើតដោយឧស្សាហៈរបស់ខ្លួនឯង ឬចិត្តដែលកើតឡើងបានដោយត្រូវអាស្រ័យមានការដឹកនាំ ។

ចិត្តដែលកើតឡើងដោយឧស្សាហៈនៃខ្លួន មិនមានការដឹកនាំនោះ ឈ្មោះថា អសង្ខារិកចិត្ត និងចិត្តដែលកើតឡើងដោយអាស្រ័យមានការដឹកនាំនោះ ឈ្មោះថា **សសង្ខារិកចិត្ត** ។

កាលចែកដោយប្រភេទនៃសង្ខារហើយ បានដូច្នេះ

**អសង្ខារិកចិត្ត** មាន ៣៧ ដួង បានដល់

| | | |
|---|---|---|
| អកុសលអសង្ខារិកចិត្ត | ៧ | = ៣៧ ដួង |
| អហេតុកចិត្ត | ១៨ | |
| កាមាវចរសោភណអសង្ខារិកចិត្ត | ១២ | |

**សសង្ខារិកចិត្ត** មាន ៥២ ដួង បានដល់

| | | |
|---|---|---|
| អកុសលសសង្ខារិកចិត្ត | ៥ | = ៥២ ដួង ។ |
| កាមាវចរសោភណសសង្ខារិកចិត្ត | ១២ | |
| មហគ្គតចិត្ត | ២៧ | |
| លោកុត្តរចិត្ត | ៨ | |

សម្រាប់ព្រះអរិយបុគ្គលធ្លាប់បានឈានមកពីមុនហើយ ឈានណាមួយ តាំងពីបឋមជ្ឈានរហូតដល់បញ្ចមជ្ឈាន កាលសម្រេចមគ្គផល អង្គឈាននោះៗ ក៏កើតព្រមផង សូម្បីក្នុងអរូបជ្ឈានទាំងអស់ ក៏ប្រាកដដូចបញ្ចមជ្ឈាន ហើយឈានចិត្តទាំងអស់ សង្គ្រោះជា**សសង្ខារិកចិត្ត** ។

## ឈានចិត្ត ៦៧

## គាថាសង្គហទី ១៦

**១៦. ឯកាទសវិធំ តស្មា បឋមាទិកមីរិតំ**
**ឈានមេកេកមន្តេ តុ តេវីសតិវិធំ ភវេ ។**

ប្រែថា បឋមជ្ឈាន ជាដើម លោកពោលថា ឈាននីមួយៗ មាន ១១ ដួង ឈានចិត្តក្នុងទីបំផុត គឺ បញ្ចមជ្ឈាននោះមាន ២៣ ដួង ។

អធិប្បាយថា ក្នុងចំនួនចិត្តពិស្តារ ១២១ ដួងនោះ រាប់តាមចិត្តដែលចូលដល់ឈានហើយ មានដូច្នេះ គឺ

**បឋមជ្ឈានចិត្ត ១១ ដួង** គឺ ជាលោកិយចិត្ត ៣ លោកុត្តរចិត្ត ៨ ។
**ទុតិយជ្ឈានចិត្ត ១១ ដួង** គឺ ជាលោកិយចិត្ត ៣ លោកុត្តរចិត្ត ៨ ។
**តតិយជ្ឈានចិត្ត ១១ ដួង** គឺ ជាលោកិយចិត្ត ៣ លោកុត្តរចិត្ត ៨ ។
**ចតុត្ថជ្ឈានចិត្ត ១១ ដួង** គឺ ជាលោកិយចិត្ត ៣ លោកុត្តរចិត្ត ៨ ។
**បញ្ចមជ្ឈានចិត្ត ២៣ ដួង** គឺ ជាលោកិយចិត្ត ១៥ លោកុត្តរចិត្ត ៨ ។

រូមឈានចិត្តទាំងអស់ ៦៧ ដួង បានដល់

មហគ្គតចិត្ត ២៧ ⎫
លោកុត្តរចិត្ត ៤០ ⎭ = ឈានចិត្ត ៦៧ ដួង ។

## ចែកកុសលចិត្ត និង វិបាកចិត្តដោយពិស្តារ

## គាថាសង្គហទី ១៧

**១៧. សត្តតឹសវិធំ បុញ្ញំ ទ្វិបញ្ញាសវិធំ តថា**
**បាកមិច្ចាហុ ចិត្តានិ ឯកវីសសតំ ពុធា ។**

ប្រែថា កុសលចិត្ត ៣៧ និងវិបាកចិត្ត ៥២ ព្រោះហេតុនោះ អ្នកប្រាជ្ញទាំងឡាយពោលហើយដោយពិស្តារ ១២១ ដួង ។

អធិប្បាយថា តាមគាថាសង្គហៈទី ១១ បានសម្តែងហើយថា កុសលចិត្ត ២១ ដួង និងវិបាកចិត្ត ៣៦ ដួង នោះ ជាការសម្តែងជាតិរបស់ចិត្តដោយសង្ខេប ៨៩ ដួង ប៉ុណ្ណោះ តែកាលសម្តែងជាតិរបស់ចិត្តដោយពិស្តារ ១២១ ដួង ហើយបានដូច្នេះ

**កុសលចិត្ត ៣៧** ដួងនោះ បានដល់

កាមាវចរកុសលចិត្ត ៨ ⎫
មហគ្គតកុសលចិត្ត ៩ ⎬ = កុសលចិត្ត ៣៧ ដួង ។
លោកុត្តរកុសលចិត្ត ២០ ⎭

**វិបាកចិត្ត ៥២** ដួងនោះ បានដល់

| | | | | |
|---|---|---|---|---|
| អកុសលវិបាកចិត្ត | ៧ | = កាមាវចរវិបាក ២៣ | | = វិបាកចិត្ត ៥២ ដួង។ |
| អហេតុកកុសលវិបាកចិត្ត | ៨ | | | |
| មហាវិបាកចិត្ត | ៨ | | | |
| | | មហគ្គតវិបាក | ៩ | |
| | | លោកុត្តរវិបាក | ២០ | |

កាលពន្យល់សេចក្ដីតាមគាថាទី ១៧ ដែលជាគាថាចុងក្រោយនៃព្រះអភិធម្មត្ថសង្គហៈ ទើបត្រូវសម្ដែងការចែកចិត្ត ដោយពិស្ដារទុកដូច្នេះ គឺ

## ចែកចិត្ត ១២១ ដោយជាតិភេទន័យ

**អកុសលជាតិ** បានដល់ អកុសលចិត្ត ១២ ដួង ។

**កុសលជាតិ** បានដល់ កុសលចិត្ត ៣៧ ដួង ។

**វិបាកជាតិ** បានដល់ វិបាកចិត្ត ៥២ ដួង ។

**កិរិយាជាតិ** បានដល់ កិរិយាចិត្ត ២០ ដួង ។

## ចែកចិត្ត ១២១ ដោយភូមិភេទន័យ

**កាមភូមិ** បានដល់ កាមាវចរចិត្ត ៥៤ ដួង ។

**រូបភូមិ** បានដល់ រូបាវចរចិត្ត ១៥ ដួង ។

**អរូបភូមិ** បានដល់ អរូបាវចរចិត្ត ១២ ដួង ។

**លោកុត្តរភូមិ** បានដល់ លោកុត្តរចិត្ត ៤០ ដួង ។

## ចែកចិត្ត ១២១ ដោយសោភណភេទន័យ

**អសោភណ** បានដល់ អសោភណចិត្ត ៣០ ដួង ។

**សោភណ** បានដល់ សោភណចិត្ត ៩១ ដួង ។

## ចែកចិត្ត ១២១ ដោយលោកភេទន័យ

**លោកិយ** បានដល់ លោកិយចិត្ត ៨១ ដួង ។

**លោកុត្តរ** បានដល់ លោកុត្តរចិត្ត ៤០ ដួង ។

## ចែកចិត្ត ១២១ ដោយហេតុភេទន័យ

**អហេតុក** បានដល់ អហេតុកចិត្ត ១៨ ដួង ។

**សហេតុក** បានដល់ សហេតុកចិត្ត ១០៣ ដួង ។

## ចែកចិត្ត ១២១ ដោយឈានភេទន័យ

ចិត្តដែលមិនប្រកបដោយឈាន បានដល់ អឈានចិត្ត ៥៤ ដួង។

ចិត្តដែលប្រកបដោយឈាន បានដល់ ឈានចិត្ត ៦៧ ដួង ។

## ចែកចិត្ត ១២១ ដោយវេទនាភេទន័យ

**សុខវេទនា** បានដល់ សុខសហគតចិត្ត ១ ដួង ។

**ទុក្ខវេទនា** បានដល់ ទុក្ខសហគតចិត្ត ១ ដួង ។
**សោមនស្សវេទនា** បានដល់ សោមនស្សសហគតចិត្ត ៦២ ដួង ។
**ទោមនស្សវេទនា** បានដល់ ទោមនស្សសហគតចិត្ត ២ ដួង ។
**ឧបេក្ខាវេទនា** បានដល់ ឧបេក្ខាសហគតចិត្ត ៥៥ ដួង ។

## ចែកចិត្ត ១២១ ដោយសម្បយោគភេទន័យ

**សម្បយោគ** មាន ២ យ៉ាង គឺ "សម្បយុត្ត" និង "វិប្បយុត្ត" ។
**សម្បយុត្ត** បានដល់ សម្បយុត្តចិត្ត ៨៧ ដួង ។
**វិប្បយុត្ត** បានដល់ វិប្បយុត្តចិត្ត ៣៤ ដួង ។

## ចែកចិត្ត ១២១ ដោយសង្ខារភេទន័យ

**អសង្ខារ** បានដល់ អសង្ខារិកចិត្ត ៣៧ ដួង ។
**សសង្ខារ** បានដល់ សសង្ខារិកចិត្ត ៨៤ ដួង ។

## ចំណុចសម្គាល់ពិសេស

**អហេតុកចិត្ត ១៨** សង្គ្រោះចូលក្នុងវិប្បយុត្តចិត្ត ។
**ឈានចិត្ត ៦៧** សង្គ្រោះចូលក្នុងសម្បយុត្តចិត្ត ។
មោហមូលចិត្ត ២
អហេតុកចិត្ត ១៨ } សង្គ្រោះចូលក្នុងអសង្ខារិកចិត្ត ។
**ឈានចិត្ត ៦៧** សង្គ្រោះចូលក្នុងសសង្ខារិកចិត្ត ។

## អវសានគាថា

ឥច្ចានុរុទ្ធរចិតេ អភិធម្មត្ថសង្គហេ
បឋមោ បរិច្ឆេទោយំ សមាសេនេវ និដ្ឋិតោ ។

បរិច្ឆេទទី ១ "**ចិត្តសង្គហវិភាគ**" ក្នុងបករណ៍ដែលរួបរួមនូវអត្ថនៃព្រះអភិធម្មត្ថសង្គហៈ ដែលព្រះអនុរុទ្ធាចារ្យបានរចនាទុក ចប់ដោយសង្ខេបត្រឹមតែប៉ុណ្ណេះឯង ៕

# ចប់ បរិច្ឆេទទី ១

# អភិធម្មត្ថសង្គហបាលី-ប្រែ

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្ការចំពោះព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។

## គន្ថារម្ភកថា

កថាផ្ដើមបករណ៍

**(១) សម្មាសម្ពុទ្ធមតុលំ សសទ្ធម្មគណុត្តមំ**
**អភិវាទិយ ភាសិស្សំ អភិធម្មត្ថសង្គហំ ។**

ខ្ញុំព្រះអង្គ (អនុរុទ្ធាចារ្យ) សូមនមស្ការថ្វាយបង្គំចំពោះព្រះសម្មា-សម្ពុទ្ធជាម្ចាស់ដែលមិនមានបុគ្គលណាមួយស្មើបាន ព្រមទាំងព្រះសទ្ធម្ម និងគណៈនៃព្រះអរិយសង្ឃដ៏ឧត្តម ហើយនឹងសូមពោលនូវគម្ពីរ **អភិធម្មត្ថសង្គហ** ។

## ចតុបរមត្ថធម្មោ

បរមត្ថធម៌ ៤ ប្រការ

**(២) តត្ថ វុត្តាភិធម្មត្ថា ចតុធា បរមត្ថតោ**
**ចិត្តំ ចេតសិកំ រូបំ និព្វានមិតិ សព្វថា ។**

ប្រែថា អត្ថនៃព្រះអភិធម្ម ក្នុងអភិធម្មបិដកនោះ ពោលដោយបរមត្ថធម៌ហើយ មានត្រឹម ៤ ប្រការ គឺ **ចិត្ត ចេតសិក រូប និព្វាន** ដោយប្រការទាំងពួង ។

## គន្ថារម្ភកថា និដ្ឋិតា ។

កថាផ្តើមបករណ៍ចប់ ។

# បឋមោ បរិច្ឆេទោចិត្តសង្គហវិភាគោ

បរិច្ឆេទទី ១ ចិត្តសង្គហវិភាគ

## ភូមិភេទចិត្តំ

ចិត្តចែកដោយភូមិ

**(៣) តត្ថ ចិត្តំ តាវ, ចតុព្វិធំ ហោតិ កាមាវចរំ រូបាវចរំ អរូបាវចរំ លោកុត្តរញ្ចេតិ ។**

(បណ្តាអត្ថរបស់ព្រះអភិធម្មទាំង ៤ ប្រការ)នោះ ដំបូង ចិត្ត មាន ៤ ប្រការ បានដល់ កាមាវចរចិត្ត ១ រូបាវចរចិត្ត ១ អរូបាវចរចិត្ត ១ និងលោកុត្តរចិត្ត ១ ។

# **អកុសលចិត្តំ**

## អកុសលចិត្ត

## **លោភមូលចិត្ត ៨ ដួង**

**(៤) តត្ថ កតមំ កាមាវចរំ ? សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកំ, សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកំ, ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកំ, ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកន្តិ ឥមានិ អដ្ឋបិ លោភសហគតចិត្តានិ នាម ។**

(សួរថា) (បណ្តាចិត្តទាំងឡាយ ៤ ប្រការ)នោះ កាមាវចរចិត្តតើដូចម្តេច ?

(ឆ្លើយថា) អកុសលចិត្តទាំងឡាយ ៨ ដួងនេះ ឈ្មោះថា ចិត្តកើតរួមជាមួយលោភៈ (លោភមូលចិត្ត) បានដល់ ចិត្តដែលកើតរួមជាមួយសោមនស្សវេទនា ប្រកបដោយទិដ្ឋិ មិនមានសង្ខារ ១ ចិត្តដែលកើតរួមជាមួយសោមនស្សវេទនា ប្រកបដោយទិដ្ឋិ មានសង្ខារ ១ ចិត្តដែលកើតរួមជាមួយសោមនស្សវេទនា មិនប្រកបដោយទិដ្ឋិ មិនមានសង្ខារ ១ ចិត្តដែលកើតរួមជាមួយសោមនស្សវេទនា មិនប្រកបដោយទិដ្ឋិ មានសង្ខារ ១ ចិត្តដែលកើតរួមជាមួយឧបេក្ខាវេទនា ប្រកបដោយទិដ្ឋិ មិនមានសង្ខារ ១ ចិត្តដែលកើតរួមជាមួយឧបេក្ខាវេទនា ប្រកបដោយទិដ្ឋិ មានសង្ខារ ១ ចិត្តដែលកើតរួមជាមួយឧបេក្ខាវេទនា មិនប្រកបដោយ

ទិដ្ឋិ មិនមានសង្ខារ ១ ចិត្តដែលកើតរួមជាមួយឧបេក្ខាវេទនា មិនប្រកបដោយទិដ្ឋិ មានសង្ខារ ១ ។

## ទោសមូលចិត្ត ២ ដួង

**(៥) ទោមនស្សសហគតំ បដិឃសម្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកន្តិ ឥមានិ ទ្វេបិ បដិឃសម្បយុត្តចិត្តានិ នាម ។**

អកុសលចិត្តទាំងឡាយ ២ ដួងនេះ ឈ្មោះថា ចិត្តដែលប្រកបដោយសេចក្តីថ្នាំងថ្នាក់ (ទោសមូលចិត្ត) បានដល់ ចិត្តដែលកើតរួមជាមួយទោមនស្សវេទនា ប្រកបដោយបដិឃៈ មិនមានសង្ខារ ១ ចិត្តដែលកើតរួមជាមួយទោមនស្សវេទនា ប្រកបដោយបដិឃៈ មានសង្ខារ ១ ។

## មោហមូលចិត្ត ២ ដួង

**(៦) ឧបេក្ខាសហគតំ វិចិកិច្ឆាសម្បយុត្តមេកំ, ឧបេក្ខាសហគតំ ឧទ្ធច្ចសម្បយុត្តមេកន្តិ ឥមានិ ទ្វេបិ មោមូហចិត្តានិ នាម ។**

អកុសលចិត្តទាំងឡាយ ២ ដួងនេះ ឈ្មោះថា ចិត្តវង្វេងយ៉ាងក្រៃលែង (មោមូហចិត្ត ឬមោហមូលចិត្ត) បានដល់ ចិត្តដែលកើតរួមជាមួយឧបេក្ខាវេទនា ប្រកបជាមួយវិចិកិច្ឆា ១ ចិត្តដែលកើតរួមជាមួយឧបេក្ខាវេទនា ប្រកបជាមួយឧទ្ធច្ចៈ ១ ។

**(៧) ឥច្ចេវំ សព្វថាបិ ទ្វាទសាកុសលចិត្តានិ សមត្តានិ ។**

អកុសលចិត្តទាំងឡាយ ១២ ដួង ចប់ដោយប្រការទាំងពួង តាម-

ន័យដូចដែលបានពោលហើយយ៉ាងនេះ ។

## សង្គហគាថា

គាថាសរុបចំនួនអកុសលចិត្ត

**(៨) អដ្ឋធា លោភមូលានិ ទោសមូលានិ ច ទ្វិធា**
**មោហមូលានិ ច ទ្វេតិ ទ្វាទសាកុសា សិយុំ ។**

ប្រែថា លោភមូលចិត្ត ៨ ដួង ទោសមូលចិត្ត ២ ដួង មោហមូលចិត្ត ២ ដួង សរុប ១២ ដួងនេះជាអកុសលចិត្ត ។

## អហេតុកចិត្តំ

អហេតុកចិត្ត

### អកុសលវិបាកចិត្ត ៧ ដួង

**(៩) ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណំ, តថា សោតវិញ្ញាណំ, ឃានវិញ្ញាណំ, ជិវ្ហាវិញ្ញាណំ, ទុក្ខសហគតំ កាយវិញ្ញាណំ, ឧបេក្ខា-សហគតំ សម្បដិច្ឆនចិត្តំ, ឧបេក្ខាសហគតំ សន្តីរណចិត្តញ្ចេតិ ឥមានិ សត្តបិ អកុសលវិបាកចិត្តានិ នាម ។**

អហេតុកចិត្តទាំងឡាយ ៧ ដួងនេះ ឈ្មោះថា អកុសលវិបាកចិត្ត បានដល់ ចិត្តដែលអាស្រ័យចក្ខុបសាទ កើតរួមជាមួយឧបេក្ខាវេទនា ជាផលរបស់អកុសលកម្ម ១ ដោយប្រការដូចគ្នានេះ ចិត្តដែលអាស្រ័យសោតបសាទ កើតរួមជាមួយឧបេក្ខាវេទនា ជាផលរបស់អកុសលកម្ម ១

ចិត្តដែលអាស្រ័យឃានបសាទ កើតរួមជាមួយឧបេក្ខាវេទនា ជាផលរបស់អកុសលកម្ម ១ ចិត្តដែលអាស្រ័យជិវ្ហាបសាទ កើតរួមជាមួយឧបេក្ខា-វេទនា ជាផលរបស់អកុសលកម្ម ១ ចិត្តដែលអាស្រ័យកាយបសាទ កើតរួមជាមួយទុក្ខវេទនា ជាផលរបស់អកុសលកម្ម ១ សម្បដិច្ឆនចិត្ត ដែលកើតរួមជាមួយឧបេក្ខាវេទនា ជាផលរបស់អកុសលកម្ម ១ សន្តីរណ-ចិត្តដែលកើតរួមជាមួយឧបេក្ខាវេទនា ជាផលរបស់អកុសលកម្ម ១ ។

## អហេតុកកុសលវិបាកចិត្ត ៨ ដួង

**(១០) ឧបេក្ខាសហគតំ កុសលវិបាកំ ចក្ខុវិញ្ញាណំ, តថា សោតវិញ្ញាណំ, ឃានវិញ្ញាណំ, ជិវ្ហាវិញ្ញាណំ, សុខសហគតំ កាយ-វិញ្ញាណំ, ឧបេក្ខាសហគតំ សម្បដិច្ឆនចិត្តំ, សោមនស្សសហគតំ សន្តីរណចិត្តំ, ឧបេក្ខាសហគតំ សន្តីរណចិត្តញ្ចេតិ ឥមានិ អដ្ឋបិ កុសលវិបាកាហេតុកចិត្តានិ នាម ។**

អហេតុកចិត្តទាំងឡាយ ៨ ដួងនេះ ឈ្មោះថា កុសលវិបាក-អហេតុកចិត្ត បានដល់ ចិត្តដែលអាស្រ័យចក្ខុបសាទ កើតរួមជាមួយឧបេក្ខាវេទនា ជាផលរបស់កុសលកម្ម ១ ដោយប្រការដូចគ្នានេះ ចិត្តដែលអាស្រ័យសោតបសាទ កើតរួមជាមួយឧបេក្ខាវេទនា ជាផលរបស់កុសលកម្ម ១ ចិត្តដែលអាស្រ័យឃានបសាទ កើតរួមជាមួយឧបេក្ខាវេទនា ជាផលរបស់កុសលកម្ម ១ ចិត្តដែលអាស្រ័យជិវ្ហាបសាទ កើតរួមជាមួយឧបេក្ខាវេទនា ជាផលរបស់កុសលកម្ម ១ ចិត្តដែល

អាស្រ័យកាយបសាទ កើតរួមជាមួយសុខវេទនា ជាផលរបស់កុសលកម្ម ១ សម្បដិច្ឆនចិត្តដែលកើតរួមជាមួយឧបេក្ខាវេទនា ជាផលរបស់កុសលកម្ម ១ សន្តីរណចិត្តដែលកើតរួមជាមួយសោមនស្សវេទនា ជាផលរបស់កុសលកម្ម ១ សន្តីរណចិត្តដែលកើតរួមជាមួយឧបេក្ខាវេទនា ជាផលរបស់កុសលកម្ម ១ ។

## អហេតុកកិរិយាចិត្ត ៣ ដួង

**(១១) ឧបេក្ខាសហគតំ បញ្ចទ្វារាវជ្ជនចិត្តំ, តថា មនោទ្វារាវជ្ជនចិត្តំ, សោមនស្សសហគតំ ហសិតុប្បាទចិត្តញ្ចេតិ ឥមានិ តីណិបិ អហេតុកកិរិយចិត្តានិ នាម ។**

អហេតុកកិរិយាចិត្តទាំងឡាយ ៣ ដួងនេះ ឈ្មោះថា អហេតុកកិរិយាចិត្ត បានដល់ ចិត្តដែលរាវរកនូវអារម្មណ៍តាមបញ្ចទ្វារ កើតរួមជាមួយឧបេក្ខាវេទនា ១ ដោយប្រការដូចគ្នានេះ ចិត្តដែលរាវរកនូវអារម្មណ៍តាមមនោទ្វារ កើតរួមជាមួយឧបេក្ខាវេទនា ១ ចិត្តដែលញ៉ាំងការញញឹមឲ្យកើតឡើងរួមជាមួយសោមនស្សវេទនា ១ ។

**(១២) ឥច្ចេវំ សព្វថាបិ អដ្ឋារសាហេតុកចិត្តានិ សមត្តានិ ។**

អហេតុកចិត្តទាំងឡាយ ១៨ ដួង ចប់ដោយប្រការទាំងពួងតាមន័យដូចដែលបានពោលហើយយ៉ាងនេះ ។

## **សង្គហគាថា**

គាថាសរុបចំនួនអហេតុកចិត្ត

**(១៣) សត្តាកុសលបាកានិ បុញ្ញបាកានិ អដ្ឋធា**

**ក្រិយចិត្តានិ តីណីតិ អដ្ឋារស អហេតុកា ។**

ប្រែថា អកុសលវិបាកចិត្ត ៧ ដួង កុសលវិបាកចិត្ត ៨ ដួង កិរិយាចិត្ត ៣ ដួង រួមចិត្តទាំង ១៨ ដួងនេះជាអហេតុកចិត្ត ។

## **សោភណចិត្តំ**

សោភណចិត្ត

(១៤) **បាបាហេតុកមុត្តានិ សោភនានីតិ វុច្ចរេ**

**ឯកូនសដ្ឋិ ចិត្តានិ អថេកនវុតីបិ វា ។**

ប្រែថា ចិត្តទាំងឡាយ ៥៩ ឬ ៩១ ដួង ដែលផុតអំពីអកុសលចិត្ត និងអហេតុកចិត្តនោះ ហៅថា **សោភណចិត្ត** ។

## **កាមាវចរសោភណចិត្តំ**

កាមាវចរសោភណចិត្ត

**មហាកុសលចិត្ត ៨ ដួង**

**(១៥) សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកំ, សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកំ, ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកមេកំ,**

**សសង្ខារិកមេកំ ។ ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកន្តិ ឥមានិ អដ្ឋបិ កាមាវចរកុសលចិត្តានិ នាម ។**

សោភណចិត្តទាំងឡាយ ៨ ដួងនេះ ឈ្មោះថា សហេតុកកាមាវចរកុសលចិត្ត បានដល់ ចិត្តដែលកើតរួមជាមួយសោមនស្សវេទនា ប្រកបដោយបញ្ញា មិនមានសង្ខារ ១ ចិត្តដែលកើតរួមជាមួយសោមនស្សវេទនា ប្រកបដោយបញ្ញា មានសង្ខារ ១ ចិត្តដែលកើតរួមជាមួយសោមនស្សវេទនា មិនប្រកបដោយបញ្ញា មិនមានសង្ខារ ១ ចិត្តដែលកើតរួមជាមួយសោមនស្សវេទនា មិនប្រកបដោយបញ្ញា មានសង្ខារ ១ ចិត្តដែលកើតរួមជាមួយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មិនមានសង្ខារ ១ ចិត្តដែលកើតរួមជាមួយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានសង្ខារ ១ ចិត្តដែលកើតរួមជាមួយឧបេក្ខាវេទនា មិនប្រកបដោយបញ្ញា មិនមានសង្ខារ ១ ចិត្តដែលកើតរួមជាមួយឧបេក្ខាវេទនា មិនប្រកបដោយបញ្ញា មានសង្ខារ ១ ។

## មហាវិបាកចិត្ត ៨ ដួង

**(១៦) សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកំ, សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកំ, ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកំ, ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកន្តិ ឥមានិ អដ្ឋបិ សហេតុកកាមាវចរវិបាកចិត្តានិ នាម ។**

សោភណចិត្តទាំងឡាយ ៨ ដួងនេះ ឈ្មោះថា សហេតុក កាមាវចរវិបាកចិត្ត បានដល់ ចិត្តដែលកើតរួមជាមួយសោមនស្សវេទនា ប្រកបដោយបញ្ញា មិនមានសង្ខារ ១ ចិត្តដែលកើតរួមជាមួយសោមនស្ស-វេទនា ប្រកបដោយបញ្ញា មានសង្ខារ ១ ចិត្តដែលកើតរួមជាមួយ សោមនស្សវេទនា មិនប្រកបដោយបញ្ញា មិនមានសង្ខារ ១ ចិត្តដែល កើតរួមជាមួយសោមនស្សវេទនា មិនប្រកបដោយបញ្ញា មានសង្ខារ ១ ចិត្តដែលកើតរួមជាមួយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មិនមានសង្ខារ ១ ចិត្តដែលកើតរួមជាមួយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានសង្ខារ ១ ចិត្តដែលកើតរួមជាមួយឧបេក្ខាវេទនា មិនប្រកបដោយបញ្ញា មិន មានសង្ខារ ១ ចិត្តដែលកើតរួមជាមួយឧបេក្ខាវេទនា មិនប្រកបដោយ បញ្ញា មានសង្ខារ ១ ។

## មហាកិរិយាចិត្ត ៨ ដួង

**(១៧) សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកមេកំ, សសង្ខារកិមេកំ, សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកំ, ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកំ, ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកមេកំ, សសង្ខារិកមេកន្តិ ឥមានិ អដ្ឋបិ សហេតុកកាមាវចរកិរិយចិត្តានិ នាម ។**

សោភណចិត្តទាំងឡាយ ៨ ដួងនេះ ឈ្មោះថា សហេតុក កាមាវចរកិរិយាចិត្ត បានដល់ ចិត្តដែលកើតរួមជាមួយសោមនស្សវេទនា

ប្រកបដោយបញ្ញា មិនមានសង្ខារ ១ ចិត្តដែលកើតរួមជាមួយសោមនស្សវេទនា ប្រកបដោយបញ្ញា មានសង្ខារ ១ ចិត្តដែលកើតរួមជាមួយសោមនស្សវេទនា មិនប្រកបដោយបញ្ញា មិនមានសង្ខារ ១ ចិត្តដែលកើតរួមជាមួយសោមនស្សវេទនា មិនប្រកបដោយបញ្ញា មានសង្ខារ ១ ចិត្តដែលកើតរួមជាមួយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មិនមានសង្ខារ ១ ចិត្តដែលកើតរួមជាមួយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានសង្ខារ ១ ចិត្តដែលកើតរួមជាមួយឧបេក្ខាវេទនា មិនប្រកបដោយបញ្ញា មិនមានសង្ខារ ១ ចិត្តដែលកើតរួមជាមួយឧបេក្ខាវេទនា មិនប្រកបដោយបញ្ញា មានសង្ខារ ១ ។

**(១៨) ឥច្ចេវំ សព្វថាបិ ចតុវីសតិ សហេតុកកាមាវចរកុសលវិបាកកិរិយចិត្តានិ សមត្តានិ ។**

កាមាវចរកុសលចិត្ត កាមាវចរវិបាកចិត្ត និងកាមាវចរកិរិយាចិត្តទាំងឡាយ ដែលមានហេតុទាំង ២៤ ដួង ចប់ដោយប្រការទាំងពួងតាមន័យដូចដែលបានពោលហើយយ៉ាងនេះ ។

**(១៩) វេទនាញាណសង្ខារ- ភេទេន ចតុវីសតិ**
**សហេតុកាមាវចរ- បុញ្ញបាកក្រិយា មតា ។**

ប្រែថា ចិត្ត ២៤ ដួង កាលពោលដោយប្រភេទនៃវេទនា ញាណ និងសង្ខារ ហៅថា សហេតុកកាមាវចរកុសលចិត្ត សហេតុកកាមាវចរវិបាកចិត្ត និងសហេតុកកាមាវចរកិរិយាចិត្ត ។

## គាថាសរុបចំនួនចិត្តក្នុងកាមាវចរភូមិ

**(២០) កាមេ តេវីស បាកានិ បុញ្ញាបុញ្ញានិ វីសតិ**
**ឯកាទស ក្រិយា ចេតិ ចតុបញ្ញាស សព្វថា ។**

ប្រែថា កាមាវចរវិបាកចិត្តមាន ២៣ កាមាវចរកុសលចិត្ត និង អកុសលចិត្តមាន ២០ កាមាវចរកិរិយាចិត្តមាន ១១ រួមកាមាវចរចិត្តមាន ៥៤ ដោយប្រការទាំងពួង ។

## រូបាវចរចិត្តំ

រូបាវចរចិត្ត

### រូបាវចរកុសលចិត្ត ៥ ដួង

**(២១) វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានកុសលចិត្តំ, វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានកុសលចិត្តំ, បីតិសុខេកគ្គតា-សហិតំ តតិយជ្ឈានកុសលចិត្តំ, សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានកុសល-ចិត្តំ, ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានកុសលចិត្តញ្ចេតិ ឥមានិ បញ្ចបិ រូបាវចរកុសលចិត្តានិ នាម ។**

កុសលចិត្តទាំងឡាយ ៥ ដួងនេះ ឈ្មោះថា រូបាវចរកុសលចិត្ត បានដល់ កុសលចិត្តដែលប្រកបជាមួយបឋមជ្ឈាន កើតរួមជាមួយវិតក្ក វិចារ បីតិ សុខ និងឯកគ្គតា ១ កុសលចិត្តដែលប្រកបជាមួយទុតិយជ្ឈាន កើតរួមជាមួយវិចារ បីតិ សុខ និងឯកគ្គតា ១ កុសលចិត្តដែលប្រកបជា មួយតតិយជ្ឈាន កើតរួមជាមួយបីតិ សុខ និងឯកគ្គតា ១ កុសលចិត្តដែល

ប្រកបជាមួយចតុត្ថជ្ឈាន កើតរួមជាមួយសុខ និងឯកគ្គតា ១ កុសលចិត្ត ដែលប្រកបជាមួយបញ្ចមជ្ឈាន កើតរួមជាមួយឧបេក្ខា និងឯកគ្គតា ១ ។

## រូបាវចរវិបាកចិត្ត ៥ ដួង

**(២២) វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានវិបាកចិត្តំ, វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានវិបាកចិត្តំ, បីតិសុខេកគ្គតា-សហិតំ តតិយជ្ឈានវិបាកចិត្តំ, សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានវិបាកចិត្តំ, ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានវិបាកចិត្តញ្ចេតិ ឥមានិ បញ្ចបិ រូបាវចរវិបាកចិត្តានិ នាម ។**

វិបាកចិត្តទាំងឡាយ ៥ ដួងនេះ ឈ្មោះថា រូបាវចរវិបាកចិត្ត បានដល់ វិបាកចិត្តដែលប្រកបជាមួយបឋមជ្ឈាន កើតរួមជាមួយវិតក្ក វិចារ បីតិ សុខ និងឯកគ្គតា ១ វិបាកចិត្តដែលប្រកបជាមួយទុតិយជ្ឈាន កើតរួមជាមួយវិចារ បីតិ សុខ និងឯកគ្គតា ១ វិបាកចិត្តដែលប្រកបជាមួយតតិយជ្ឈាន កើតរួមជាមួយបីតិ សុខ និងឯកគ្គតា ១ វិបាកចិត្តដែលប្រកបជាមួយចតុត្ថជ្ឈាន កើតរួមជាមួយសុខ និងឯកគ្គតា ១ វិបាកចិត្តដែលប្រកបជាមួយបញ្ចមជ្ឈាន កើតរួមជាមួយឧបេក្ខា និងឯកគ្គតា ១ ។

## រូបាវចរកិរិយាចិត្ត ៥ ដួង

**(២៣) វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានកិរិយចិត្តំ, វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានកិរិយចិត្តំ, បីតិសុខេកគ្គតា-**

**សហិតំ តតិយជ្ឈានកិរិយចិត្តំ, សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានកិរិយចិត្តំ, ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានកិរិយចិត្តញ្ចេតិ ឥមានិ បញ្ចបិ រូបាវចរកិរិយចិត្តានិ នាម ។**

កិរិយាចិត្តទាំងឡាយ ៥ ដួងនេះ ឈ្មោះថា រូបាវចរកិរិយាចិត្ត បានដល់ កិរិយាចិត្តដែលប្រកបជាមួយបឋមជ្ឈាន កើតរួមជាមួយវិតក្ក វិចារ បីតិ សុខ និងឯកគ្គតា ១ កិរិយាចិត្តដែលប្រកបជាមួយទុតិយជ្ឈាន កើតរួមជាមួយវិចារ បីតិ សុខ និងឯកគ្គតា ១ កិរិយាចិត្តដែលប្រកបជាមួយតតិយជ្ឈាន កើតរួមជាមួយបីតិ សុខ និងឯកគ្គតា ១ កិរិយាចិត្តដែលប្រកបជាមួយចតុត្ថជ្ឈាន កើតរួមជាមួយសុខ និងឯកគ្គតា ១ កិរិយាចិត្តដែលប្រកបជាមួយបញ្ចមជ្ឈាន កើតរួមជាមួយឧបេក្ខា និងឯកគ្គតា ១ ។

**(២៤) ឥច្ចេវំ សព្វថាបិ បន្នរស រូបាវចរកុសលវិបាកកិរិយចិត្តានិ សមត្តានិ ។**

រូបាវចរកុសលចិត្ត រូបាវចរវិបាកចិត្ត និងរូបាវចរកិរិយាចិត្តទាំងឡាយ ១៥ ដួង ចប់ដោយប្រការទាំងពួង តាមន័យដូចដែលបានពោលហើយយ៉ាងនេះ ។

## សង្គហគាថា

គាថាសរុបចំនួនរូបាវចរចិត្ត

**(២៥) បញ្ចធា ឈានភេទេន រូបាវចរមានសំ**

**បុញ្ញបាកក្រិយាភេទា តំ បញ្ចទសធា ភវេ ។**

ប្រែថា រូបាវចរចិត្ត ពោលដោយប្រភេទនៃឈានមាន ៥ ដួង កាលចែកដោយកុសល វិបាក កិរិយា ហើយមាន ១៥ ដួង ។

## អរូបាវចរចិត្តំ

អរូបាវចរចិត្ត

### អរូបាវចរកុសលចិត្ត ៤ ដួង

**(២៦) អាកាសានញ្ចាយតនកុសលចិត្តំ, វិញ្ញាណញ្ចាយតន-កុសលចិត្តំ, អាកិញ្ចញ្ញាយតនកុសលចិត្តំ, នេវសញ្ញានាសញ្ញាយតន-កុសលចិត្តញ្ចេតិ ឥមានិ ចត្តារិបិ អរូបាវចរកុសលចិត្តានិ នាម ។**

កុសលចិត្តទាំងឡាយ ៤ ដួងនេះ ឈ្មោះថា អរូបាវចរកុសលចិត្ត បានដល់ កុសលចិត្តដែលប្រកបជាមួយអាកាសានញ្ចាយតនជ្ឈាន ១ កុសលចិត្តដែលប្រកបជាមួយវិញ្ញាណញ្ចាយតនជ្ឈាន ១ កុសលចិត្តដែលប្រកបជាមួយអាកិញ្ចញ្ញាយតនជ្ឈាន ១ កុសលចិត្តដែលប្រកបជាមួយនេវសញ្ញានាសញ្ញាយតនជ្ឈាន ១ ។

### អរូបាវចរវិបាកចិត្ត ៤ ដួង

**(២៧) អាកាសានញ្ចាយតនវិបាកចិត្តំ, វិញ្ញាណញ្ចាយតនវិបាកចិត្តំ, នេវសញ្ញានាសញ្ញាយតនវិបាកចិត្តំ, អាកិញ្ចញ្ញាយតនវិបាកចិត្តញ្ចេតិ ឥមានិ ចត្តារិបិ អរូបាវចរវិបាកចិត្តានិ នាម ។**

វិបាកចិត្តទាំងឡាយ ៤ ដួងនេះ ឈ្មោះថា អរូបាវចរវិបាកចិត្ត បានដល់ វិបាកចិត្តដែលប្រកបជាមួយអាកាសានញ្ចាយតនជ្ឈាន ១ វិបាកចិត្តដែលប្រកបជាមួយវិញ្ញាណញ្ចាយតនជ្ឈាន ១ វិបាកចិត្តដែលប្រកបជាមួយអាកិញ្ចញ្ញាយតនជ្ឈាន ១ វិបាកចិត្តដែលប្រកបជាមួយនេវសញ្ញានាសញ្ញាយតនជ្ឈាន ១ ។

## អរូបាវចរកិរិយាចិត្ត ៤ ដួង

**(២៨) អាកាសានញ្ចាយតនកិរិយចិត្តំ, វិញ្ញាណញ្ចាយតនកិរិយចិត្តំ, អាកិញ្ចញ្ញាយតនកិរិយចិត្តំ, នេវសញ្ញានាសញ្ញាយតនកិរិយចិត្តញ្ចេតិ ឥមានិ ចត្តារិបិ អរូបាវចរកិរិយចិត្តានិ នាម ។**

កិរិយាចិត្តទាំងឡាយ ៤ ដួងនេះ ឈ្មោះថា អរូបាវចរកិរិយាចិត្ត បានដល់ កិរិយាចិត្តដែលប្រកបជាមួយអាកាសានញ្ចាយតនជ្ឈាន ១ កិរិយាចិត្តដែលប្រកបជាមួយវិញ្ញាណញ្ចាយតនជ្ឈាន ១ កិរិយាចិត្តដែលប្រកបជាមួយអាកិញ្ចញ្ញាយតនជ្ឈាន ១ កិរិយាចិត្តដែលប្រកបជាមួយនេវសញ្ញានាសញ្ញាយតនជ្ឈាន ១ ។

**(២៩) ឥច្ចេវំ សព្វថាបិ ទ្វាទស អរូបាវចរកុសលវិបាកកិរិយចិត្តានិ សមត្តានិ ។**

អរូបាវចរកុសលចិត្ត អរូបាវចរវិបាកចិត្ត និងអរូបាវចរកិរិយាចិត្ត មាន ១២ ដួង ចប់ដោយប្រការទាំងពួង តាមន័យដូចដែលបានពោលហើយយ៉ាងនេះ ។

# **សង្គហគាថា**

គាថាសរុបចំនួនអរូបាវចរចិត្ត

**(៣០) អាលម្ពនប្បភេទេន ចតុធារុប្បមានសំ**
**បុញ្ញបាកក្រិយាភេទា បុន ទ្វាទសធា ឋិតំ ។**

ប្រែថា អរូបាវចរចិត្តនោះ ពោលដោយប្រភេទនៃអារម្មណ៍មាន ៤ ដួង កាលចែកដោយប្រភេទនៃជាតិ គឺ កុសល វិបាក កិរិយាហើយ មានចំនួន ១២ ដួង ។

# **លោកុត្តរចិត្តំ**

លោកុត្តរចិត្ត

## **លោកុត្តរកុសលចិត្ត ៤ ដួង**

**(៣១) សោតាបត្តិមគ្គចិត្តំ, សកទាគាមិមគ្គចិត្តំ, អនាគាមិមគ្គចិត្តំ, អរហត្តមគ្គចិត្តញ្ចេតិ ឥមានិ ចត្តារិបិ លោកុត្តរកុសលចិត្តានិ នាម ។**

ចិត្តទាំងឡាយ ៤ ដួងនេះ ឈ្មោះថា លោកុត្តរចិត្ត បានដល់ ចិត្តដែលប្រកបជាមួយសោតាបត្តិមគ្គ ១ ចិត្តដែលប្រកបជាមួយ សកទាគាមិមគ្គ ១ ចិត្តដែលប្រកបជាមួយអនាគាមិមគ្គ ១ និងចិត្តដែល ប្រកបជាមួយអរហត្តមគ្គ ១ ។

## លោកុត្តរវិបាកចិត្ត ៤ ដួង

**(៣២) សោតាបត្តិផលចិត្តំ, សកទាគាមិផលចិត្តំ, អនាគាមិផលចិត្តំ, អរហត្តផលចិត្តញ្ចេតិ ឥមានិ ចត្តារិបិ លោកុត្តរវិបាកចិត្តានិ នាម ។**

ចិត្តទាំងឡាយ ៤ ដួងនេះ ឈ្មោះថា លោកុត្តរវិបាកចិត្ត បានដល់ ចិត្តដែលប្រកបជាមួយសោតាបត្តិផល ១ ចិត្តដែលប្រកបជាមួយ សកទាគាមិផល ១ ចិត្តដែលប្រកបជាមួយអនាគាមិផល ១ និងចិត្តដែល ប្រកបជាមួយអរហត្តផល ១ ។

**(៣៣) ឥច្ចេវំ សព្វថាបិ អដ្ឋ លោកុត្តរកុសលវិបាកចិត្តានិ សមត្តានិ ។**

លោកុត្តរកុសលចិត្ត និងលោកុត្តរវិបាកចិត្តទាំងឡាយ ៨ ដួង ចប់ ដោយប្រការទាំងពួង តាមន័យដូចដែលបានពោលហើយយ៉ាងនេះ ។

## សង្គហគាថា

គាថាសរុបចំនួនលោកុត្តរចិត្ត

**(៣៤) ចតុមគ្គប្បភេទេន ចតុធា កុសលំ តថា**
**បាកំ តស្ស ផលត្តាតិ អដ្ឋធានុត្តរំ មតំ ។**

ប្រែថា អនុត្តរចិត្ត (លោកុត្តរចិត្ត) ដោយសង្ខេបមាន ៨ ដួង គឺ លោកុត្តរចិត្តពោលដោយប្រភេទនៃមគ្គមាន ៤ ដួង និងលោកុត្តរវិបាក ចិត្ត ដែលជាផលរបស់លោកុត្តរកុសលចិត្ត ក៏មាន ៤ ដួង ។

# ចិត្តគណនសង្គហោ

គាថាសរុបចំនួនចិត្ត

**(៣៥) ទ្វាទសាកុសលានេវំ កុសលានេកវីសតិ**

**ឆត្តឹសេវ វិបាកានិ ក្រិយចិត្តានិ វីសតិ ។**

ប្រែថា ចិត្តទាំងអស់ កាលចែកដោយជាតិភេទន័យហើយ មាន ៤ ជាតិ គឺ អកុសលជាតិ ១២ ដួង កុសលជាតិ ២១ ដួង វិបាកជាតិ ៣៦ ដួង និងកិរិយាជាតិ ២០ ដួង ។

**(៣៦) ចតុបញ្ញាសធា កាមេ រូបេ បន្នរសីរយេ**

**ចិត្តានិ ទ្វាទសារុប្បេ អដ្ឋធានុត្តរេ តថា ។**

ប្រែថា ចិត្តទាំងអស់កាលចែកដោយភូមិហើយ បានកាមាវចរភូមិ ៥៤ ដួង រូបាវចរភូមិ ១៥ ដួង អរូបាវចរភូមិ ១២ ដួង និងលោកុត្តរភូមិ ៨ ដួង ។

**(៣៧) ឥត្ថមេកូននវុតិ- បភេទំ បន មានសំ**

**ឯកវីសសតំ វាថ វិភជន្តិ វិចក្ខណា ។**

ប្រែថា អ្នកប្រាជ្ញទាំងឡាយ បានចែកនូវចិត្តដែលមានប្រភេទ ៨៩ ដួង ន័យម្យ៉ាងទៀតចែកបានជា ១២១ ដួង ។

## វិត្ថារគណនា

ចំនួនចិត្តដោយពិស្តារ

**(៣៨) កថមេកូននវុតិវិធំ ចិត្តំ ឯកវីសសតំ ហោតិ? វិតក្កវិចារ-បីតិសុខេកគ្គតាសហិតំ បឋមជ្ឈានសោតាបត្តិមគ្គចិត្តំ, វិចារបីតិសុខេ-កគ្គតាសហិតំ ទុតិយជ្ឈានសោតាបត្តិមគ្គចិត្តំ, បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានសោតាបត្តិមគ្គចិត្តំ, សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានសោតា-បត្តិមគ្គចិត្តំ, ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានសោតាបត្តិមគ្គចិត្តញ្ចេតិ ឥមានិ បញ្ចបិ សោតាបត្តិមគ្គចិត្តានិ នាម ។**

(សួរថា) ចិត្តមាន ៨៩ ដួង រមែងមាន ១២១ ដួង បានដោយប្រការដូចម្តេចទៅ ?

(ឆ្លើយថា) ចិត្តទាំង ៥ ដួងនេះ ឈ្មោះថា សោតាបត្តិមគ្គចិត្ត ជាចិត្តដែលប្រកបជាមួយបឋមជ្ឈាន កើតរួមជាមួយវិតក្ក វិចារ បីតិ សុខ និងឯកគ្គតា ១ សោតាបត្តិមគ្គចិត្តដែលប្រកបជាមួយទុតិយជ្ឈាន កើតរួមជាមួយវិចារ បីតិ សុខ និងឯកគ្គតា ១ សោតាបត្តិមគ្គចិត្តដែលប្រកបជាមួយតតិយជ្ឈាន កើតរួមជាមួយបីតិ សុខ និងឯកគ្គតា ១ សោតាបត្តិ-មគ្គចិត្តដែលប្រកបជាមួយចតុត្ថជ្ឈាន កើតរួមជាមួយសុខ និងឯកគ្គតា ១ សោតាបត្តិមគ្គចិត្តដែលប្រកបជាមួយបញ្ចមជ្ឈាន កើតរួមជាមួយឧបេក្ខា និងឯកគ្គតា ១ ។

**(៣៩) តថា សកទាគាមិមគ្គអនាគាមិមគ្គអរហត្តមគ្គចិត្តញ្ចេតិ សមវីសតិ មគ្គចិត្តានិ ។**

សកទាគាមិមគ្គចិត្ត អនាគាមិមគ្គចិត្ត និងអរហត្តមគ្គចិត្តក៏ដូចគ្នា ទើបមគ្គចិត្តមាន ២០ ដួងគត់ ។

**(៤០) តថា ផលចិត្តានិ ចេតិ សមចត្តាលីស លោកុត្តរចិត្តានិ ភវន្តីតិ ។**

ចំណែកផលចិត្តក៏ដូចគ្នាដែរ ដូច្នេះ លោកុត្តរចិត្តទាំងឡាយទើបមាន ៤០ ដួងគត់ដូច្នេះឯង ។

(៤១) **ឈានង្គយោគភេទេន កត្វេកេកន្តុ បញ្ចធា**
**វុច្ចតានុត្តរំ ចិត្តំ ចត្តាលីសវិធន្តិ ច ។**

ប្រែថា លោកុត្តរចិត្ត ៨ កាលសម្ដែងដោយពិស្ដារ ៤០ ដួង ព្រោះពោលដោយប្រភេទនៃការប្រកបរបស់អង្គឈានហើយ ដោយលោកុត្តរចិត្តមួយដួងៗ មានឈាន ៥ ដូច្នោះលោកុត្តរចិត្ត ៨ ទើបជា ៤០ ដួង ។

(៤២) **យថា ច រូបាវចរំ គយ្ហតានុត្តរំ តថា**
**បឋមាទិឈានភេទេ អារុប្បញ្ចាបិ បញ្ចមេ ។**
**ឯកាទសវិធំ តស្មា បឋមាទិកមីរិតំ**
**ឈានមេកេកមន្តេ តុ តេវីសតិវិធំ ភវេ ។**

លោកុត្តរចិត្តដែលលោកសម្ដែងតាមប្រភេទរបស់ឈានមាន ៥ មានបឋមជ្ឈានជាដើម ដូចរូបាវចរចិត្ត និងអរូបាវចរចិត្តដែលលោកសម្ដែងទុកក្នុងបញ្ចមជ្ឈាន ព្រោះហេតុនោះឈានចិត្តដែលប្រកបជាមួយបឋមជ្ឈានជាដើម ឈាននីមួយៗ មាន ១១ ដួង ចំណែកក្នុងឈានទី ៥ មាន ២៣ ដួង ។

(៨៣) **សត្តតឹសវិធំ បុញ្ញំ ទ្វិបញ្ញាសវិធំ តថា**
**បាកមិច្ចាហុ ចិត្តានិ ឯកវីសសតំ ពុធា ។**

ប្រែថា កុសលចិត្ត ៣៧ និងវិបាកចិត្ត ៥២ ព្រោះហេតុនោះ អ្នកប្រាជ្ញទាំងឡាយពោលហើយដោយពិស្ដារ ១២១ ដួង ។

**ឥតិ អភិធម្មត្ថសង្គហេ ចិត្តសង្គហវិភាគោ នាម**
**បឋមោ បរិច្ឆេទោ ។**

បរិច្ឆេទទី ១ ឈ្មោះថា ចិត្តសង្គហវិភាគក្នុងគម្ពីរអភិធម្មត្ថសង្គហៈ
ចប់ដោយប្រការដូច្នេះ ៕

# ចប់ អភិធម្មត្ថសង្គហបាលី-ប្រែ

# នាមពុទ្ធបរិស័ទចូលរួមបោះពុម្ព

១. លោកម្ចាស់ មេត្តាធនោ មឿន សឺន ២០០,០០០ រៀល
២. អ្នកមានអាយុ រតនវរោ សរ សារិទ្ធ ១០០,០០០ រៀល
៣. អ្នកមានអាយុ គីម ហ៊ាល ៥០,០០០ រៀល
៤. លោកម្ចាស់ ញាណសារោ យ៉ាវ សំអឿន ៤០,០០០ រៀល
៥. លោកម្ចាស់ ញាណនន្ទោ ងួន ភារុណ ៤០,០០០ រៀល
៦. ឧបាសិកា Kim sonanna ១០០ ដុល្លារ
៧. ឧបាសិកា ឡេា ហ៊្វ ២០ ដុល្លារ
៨. អ្នកមានអាយុ អ៊ិន សុភ័ក្រ្ត ១០ ដុល្លារ
៩. ឧបាសិកា ថោង ចងបៃ ១០ ដុល្លារ
១០. អ្នកមានអាយុ កែវ ភិរុណ ២០,០០០ រៀល
១១. ពុទ្ធបរិស័ទមណ្ឌលវិបស្សនាវត្តមុនីរង្សី ឃុំឈើតុំ ស្រុកក្រគរ ខេត្តពោធិ៍សាត់ តាមរយៈឧបាសិកា អឿ គីម ១,០០០,០០០ រៀល



# អចារុតា តេ អមតស្ស ទ្វារា
# យេ សោតវន្តោ បមុញ្ចន្តុ សទ្ធំ

ទ្វារនៃព្រះនិព្វានទាំងនោះបើកហើយ

សត្វទាំងឡាយណាមានសោតប្បសាទ

សត្វទាំងឡាយនោះចូរបញ្ចេញនូវសទ្ធាចុះ។